# ប្រវត្តិសាស្ត្រ
## កម្ពុជាប្រជាធិបតេយ្យ
## (១៩៧៥-១៩៧៩)

មជ្ឈមណ្ឌលឯកសារកម្ពុជា ២០២០



បោះពុម្ព
លើកទី ២

# ប្រវត្តិសាស្ត្រ

## កម្ពុជាប្រជាធិបតេយ្យ

## (១៩៧៥-១៩៧៩)

មជ្ឈមណ្ឌលឯកសារកម្ពុជា ២០២០



ច្រវាក់ ពូថៅនិងមេសោ មានស្លាក“ធ្វើនៅប្រទេសចិន” ត្រូវបានប្រទះឃើញនៅអតីតមន្ទីរសន្តិសុខ (គុក) របស់ខ្មែរក្រហម ដែលត្រូវបានស្គាល់ថាជា គុកក្រោល ស្ថិតនៅក្នុងឃុំស្រែសង្គម ស្រុកកោះញែក ខេត្តមណ្ឌលគិរី។(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បោះពុម្ពលើកទី២

**កម្ពុជាមិនអាចគេចវេះពីប្រវត្តិសាស្ត្ររបស់ខ្លួនបានទេ ប៉ុន្តែកម្ពុជាក៏មិនចាំបាច់ស្ថិតនៅជាទាសករនៃប្រវត្តិសាស្ត្ររបស់ខ្លួនឯងនោះដែរ។**

**យុត្តិធម៌ និង ការចងចាំ**


មជ្ឈមណ្ឌលឯកសារកម្ពុជា
ផ្ទះលេខ ៦៦ មហាវិថីព្រះសីហនុ
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ១២៣០១ ប្រអប់សំបុត្រលេខ១១១០
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥
សារអេឡិចត្រូនិច៖ dccam@online.com.kh
គេហទំព័រ៖ www.dccam.org



**ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)**

**បោះពុម្ពលើកទី២ ឆ្នាំ២០២០**

ផេង ពង្សរ៉ាស៊ី
ដេវីដ ឆេនដល័រ
គ្រីស្តូហ្វ័រ ឌៀរីង
សុភ័ក្រ្ត ភាណា

បោះពុម្ពលើកទី១ ឆ្នាំ២០០៧

ឌី ខាំបូលី
ដេវីដ ឆេនដល័រ
វេនី ខកហ្គៀល

ជំនួយទ្រទ្រង់ផ្នែកហិរញ្ញវត្ថុសម្រាប់គម្រោង ត្រូវបានផ្តល់ឱ្យដោយសប្បុរសពី Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH, Civil Peace Service, BMZ និង ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់ស៊ុយអែត។ ជំនួយទ្រទ្រង់ចំពោះប្រតិបត្តិការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានផ្តល់ឱ្យដោយទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍអន្តរជាតិ។

អំណះអំណាង៖ ទស្សនៈនៅក្នុងសៀវភៅនេះ គឺជារបស់អ្នកនិពន្ធផ្ទាល់តែប៉ុណ្ណោះ។



រក្សាសិទ្ធិគ្រប់យ៉ាង ឆ្នាំ២០២០ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។

រក្សាសិទ្ធិគ្រប់យ៉ាង។ មិនមានផ្នែកណាមួយនៃសៀវភៅនេះ ត្រូវបានយកទៅសរសេរឡើងវិញ ឬប្រើប្រាស់ក្នុងទម្រង់ ឬមធ្យោបាយបែបណាក៏ដោយ ដែលរួមមានទាំងការថតចម្លង ការកត់ត្រា ឬការថតទុកនៅក្នុងប្រព័ន្ធផ្ទុកព័ត៌មានផ្សេងៗទៀត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីមជ្ឈមណ្ឌលឯកសារកម្ពុជាឡើយ។



គំនិតរចនាក្របនិងតួសៀវភៅដោយ៖ ស្វេស៊ី ម៉ាធេឡូស រួមជាមួយនឹងក្រុមហ៊ុនរចនា ដាប់បល ហេភីនែស, លី សេនសូនីឡា និង ផាំង យុ

ចំណងជើងរូបថតដោយ៖ កែវ ដាស៊ីល, ផាំង យុ, សុភ័ក្រ្ត ភាណា និង ទ្រី សុជាតា

រូបថតក្របមុខ៖ ប្រជាជនកម្ពុជាកំពុងធ្វើការនៅទំនប់ “១ មករា” ស្ទឹងជីនិត ខេត្តកំពង់ធំ ឆ្នាំ១៩៧៦ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។

9 789924 907893 >

បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២០


# ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)



ប្រជាជនកម្ពុជា កំពុងធ្វើការនៅក្នុងការដ្ឋានមួយកន្លែង ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៨)។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មាតិកា


កថាមុខ viii

សេចក្តីថ្លែងអំណរគុណ ix

កំណត់ចំណាំលើការបោះពុម្ពសៀវភៅលើកទី២ xi

ជំពូកទី១ **សេចក្តីសង្ខេប** ១

ជំពូកទី២ **តើខ្មែរក្រហមជានរណា? តើខ្មែរក្រហមឡើងកាន់អំណាចដោយរបៀបណា?** ៥

- ១. ចលនាកុម្មុយនីស្តដំបូងបំផុត ៥
- ២. ការបង្កើតបក្សប្រជាជនបដិវត្តន៍ខ្មែរ ៦
- ៣. បក្សពលករកម្ពុជា ៨
- ៤. បក្សកុម្មុយនីស្តកម្ពុជា ៩

ជំពូកទី៣ **ការឡើងកាន់អំណាចរបស់ខ្មែរក្រហម៖ ការជម្លៀសប្រជាជនចេញពីទីក្រុង, ការជម្លៀសដោយបង្ខំ និង ការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ** ១៣

- ១. ការចូលកាន់កាប់ទីក្រុងភ្នំពេញ ១៣
- ២. ការជម្លៀសប្រជាជនចេញពីទីក្រុងនិងទីប្រជុំជន ១៤
- ៣. ការជម្លៀសដោយបង្ខំ ១៧
- ៤. ទួលពោធិ៍ជ្រៃ ១៩

ជំពូកទី៤ **ការឡើងកាន់អំណាចរបស់ខ្មែរក្រហម៖ ការលើកឡើងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម** ២០

- ១. ការលើកឡើងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងអ្នករស់រានមានជីវិតដទៃទៀត ស្តីអំពីការជម្លៀសប្រជាជនដោយបង្ខំ ២០
- ២. ការលើកឡើងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលជាគ្រូពេទ្យ ២៣
- ៣. សាក្សីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ស្តីពីការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ ២៥

ជំពូកទី ៥ **ការបង្កើតរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ** ២៧

- ១. អង្គការ ២៧
- ២. ការយាងនិវត្តន៍មកកម្ពុជារបស់សម្តេចព្រះ នរោត្តម សីហនុ ២៨
- ៣. រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ២៩
- ៤. សម្តេចព្រះ នរោត្តម សីហនុ លាលែងពីតំណែងប្រមុខរដ្ឋ ៣០
- ៥. រចនាសម្ព័ន្ធចាត់តាំងរបស់កម្ពុជាប្រជាធិបតេយ្យ ៣២
- ៦. ការផ្លាស់ប្តូរថ្ងៃកំណើតបក្ស ៣២

ជំពូកទី៦ **ភូមិសាស្ត្ររដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ** ៣៣

ជំពូកទី៧ **គម្រោងផែនការបួនឆ្នាំ (១៩៧៧-១៩៨០)** ៣៦

ជំពូកទី៨ **ជីវិតរស់នៅប្រចាំថ្ងៃក្នុងរបបកម្ពុជាប្រជាធិបតេយ្យ** ៣៩

- ១. ការបង្កើតសហករណ៍ ៣៩
- ២. វណ្ណៈសង្គមថ្មីពីរ ៤០
- ៣. ពិធីរៀបមង្គលការ ៤២
- ៤. ការរំលោភលើសិទ្ធិនិងពលកម្មរបស់កុមារ ៤៤
- ៥. ការបង្ខំឱ្យធ្វើការជាទម្ងន់ ៤៧
- ៦. បន្សុទ្ធកម្ម និងការសម្លាប់រង្គាល ៤៨

ជំពូកទី៩ **ប្រព័ន្ធសន្តិសុខ** ៥២

- ១. មន្ទីរសន្តិសុខ ៥២
- ២. ខ្មាំងរបស់អង្គការ ៥៣
- ៣. ការចាប់ខ្លួននិងការឃុំខ្លួន ៥៦
- ៤. ការសួរចម្លើយ និងការធ្វើទារុណកម្ម ៥៦
- ៥. ការសម្លាប់ ៥៧

ជំពូកទី១០ **មន្ទីរស-២១** ៥៨

- ១. អគារនៅក្នុងមន្ទីរស-២១ ៥៩
- ២. អ្នកទោស ៥៩
- ៣. បទបញ្ញត្តិសម្រាប់អ្នកទោស ៦០
- ៤. ស្ថានភាពនៅក្នុងមន្ទីរស-២១ ៦៣
- ៥. ការសួរចម្លើយ ៦៣
- ៦. រចនាសម្ព័ន្ធចាត់តាំងនៅក្នុងមន្ទីរ ស-២១ ៦៥
- ៧. ថ្នាក់ដឹកនាំមន្ទីរស-២១ ៦៦
- ៨. ការសម្លាប់នៅមន្ទីរស-២១ ៦៦

ជំពូកទី១១ **ទំនាក់ទំនងការបរទេស** ៦៧

ជំពូកទី១២ **ការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ** ៦៩

- ១. មូលហេតុបីយ៉ាងនៃការដួលរលំរបស់កម្ពុជាប្រជាធិបតេយ្យ ៦៩
- ២. កម្ពុជាប្រជាធិបតេយ្យក្រោយឆ្នាំ១៩៧៩ ៧២

ជំពូកទី១៣ **ការបង្កើត ការរៀបចំ និងយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** ៧៥

- ១. គោលការណ៍ច្បាប់ បញ្ញត្តិ និងច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ៧៩

ជំពូកទី១៤ **សំណុំរឿងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា៖ សំណុំរឿង ០០១, ០០២, ០០៣ និង ០០៤** ៨១

- ១. សំណុំរឿង ០០១ ៨២
- ២. សំណុំរឿង ០០២ ៨៣
- ៣. សំណុំរឿង ០០៣ ៨៨
- ៤. សំណុំរឿង ០០៤ ៨៩

ជំពូកទី១៥ **ពាក្យថ្លែងសូមអភ័យទោសរបស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច** ៩២

- ១. ពាក្យសូមអភ័យទោសលើកទី១ ៩៣
- ២. ពាក្យសូមអភ័យទោសលើកទី២ ៩៥
- ៣. ពាក្យសូមអភ័យទោសលើកទី៣ ៩៥

ជំពូកទី១៦ **ផលប៉ះពាល់ពីការសម្លាប់រង្គាល, អំពើប្រល័យពូជសាសន៍ និងការបំពានសិទ្ធិមនុស្សមកលើបុគ្គលម្នាក់ៗ** ៩៦

- ១. សំណុំរឿង ០០១ ៩៧
- ២. សំណុំរឿង ០០២ ៩៩

ជំពូកទី១៧ **សេចក្តីបញ្ចប់** ១០៣

**វិន័យសម្រាប់អ្នកយាមនៅមន្ទីរស-២១** ១០៥

**ឯកសារយោង** ១០៧

# កថាមុខ

អង្គទូតចិន ជីវ តាក្វាន់ បានរៀបរាប់ឱ្យពិភពលោកបានដឹងអំពីរឿងរ៉ាវជីវិតរបស់គាត់ នៅប្រាសាទអង្គរវត្ត កាលពី៨០០ឆ្នាំមុន។ ចាប់តាំងពីពេលនោះមក អ្នកស្រាវជ្រាវជាច្រើនផ្សេងទៀតបានសរសេរប្រវត្តិសាស្ត្រប្រទេសរបស់យើងសម្រាប់ឱ្យយើងសិក្សា។ អ្នកស្រាវជ្រាវជាន់ខ្ពស់ជាច្រើនបានសិក្សាស្រាវជ្រាវពីសម្បត្តិវប្បធម៌ដ៏មានតម្លៃរបស់យើង ហើយក្នុងពេលថ្មីៗនេះបានសិក្សាពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាក្នុងចន្លោះឆ្នាំ១៩៧៥ និង ឆ្នាំ១៩៧៩។ ប៉ុន្តែសៀវភៅ "ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ" បានបង្ហាញឱ្យឃើញថា នៅទីបំផុតប្រជាជនកម្ពុជាបានចាប់ផ្តើមការងារស្រាវជ្រាវ និងកត់ត្រារឿងរ៉ាវពីអតីតកាលនៃប្រទេសជាតិរបស់ខ្លួន។ សៀវភៅប្រវត្តិសាស្ត្រដែលបានបោះពុម្ពលើកទី២នេះ បានបង្ហាញអំពីការសិក្សាស្រាវជ្រាវ ដែលមានរយៈពេលជាច្រើនឆ្នាំ ក៏ដូចជាត្រូវបានកែសម្រួលបន្ថែមលើខ្លឹមសារបោះពុម្ពដើមដំបូង និងបង្ហាញអំពីអត្ថបទប្រវត្តិសាស្ត្រដែលសរសេរដោយជនជាតិខ្មែរជាលើកដំបូង។

ការសរសេរទំព័រប្រវត្តិសាស្ត្រក្នុងអំឡុងពេលនេះ សម្រាប់ក្មេងជំនាន់ក្រោយ អាចជាការប្រថុយប្រថានទៅនឹងការរើឡើងវិញនូវស្នាមរបួសចាស់របស់អ្នករស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ។ ប្រជាជនកម្ពុជាភាគច្រើន បានព្យាយាមដាក់ចុះការចងចាំរបស់ខ្លួនចំពោះរបបនេះ និងបន្តដំណើរទៅមុខទៀត។ ក៏ប៉ុន្តែ យើងមិនអាចបន្តដំណើរទៅមុខបានទេ យ៉ាងហោចណាស់ក៏ត្រូវផ្សះផ្សាជាមួយខ្លួនឯង និងអ្នកដទៃ លុះត្រាតែយើងបានតទល់ទៅនឹងអតីតកាល និងបានយល់ដឹងពីអ្វីដែលបានកើតឡើង និងមូលហេតុអ្វីបានជាព្រឹត្តិការណ៍នោះកើតមាន។ មានតែការយល់ដឹងនេះទេ ដែលអាចឱ្យយើងជាសះស្បើយពិតប្រាកដ។

សៀវភៅនេះត្រូវបានបង្កើតឡើងសម្រាប់សិស្សានុសិស្សថ្នាក់វិទ្យាល័យ។ ទោះបីជាយ៉ាងណាក្តី សៀវភៅនេះក៏អាចឱ្យមនុស្សពេញវ័យសិក្សាស្វែងយល់បានដែរ។ យើងទាំងអស់គ្នាអាចទទួលបានមេរៀនពីប្រវត្តិសាស្ត្ររបស់យើង។ តាមរយៈការប្រឈមមុខនឹងអតីតកាលដ៏ខ្មៅងងឹតនៃរបបនេះ យើងអាចសិក្សាអំពីព្រឹត្តិការណ៍អតីតកាលទាំងនេះ និងប្រែក្លាយប្រទេសយើងឱ្យទៅជាប្រជាជាតិមួយ ដែលប្រជាជនបានចូលរួមក្នុងការទប់ស្កាត់ការកើតមានឡើងនូវអំពើប្រល័យពូជសាសន៍នាពេលអនាគត ទាំងនៅក្នុងប្រទេសរបស់យើង ទាំងនៅក្នុងប្រទេសផ្សេងៗជាច្រើនទៀត ដែលកំពុងតែប្រឈមមុខទៅនឹងការរំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ។ តាមរយៈការទទួលខុសត្រូវក្នុងការបង្ហាត់បង្រៀនកូនចៅរបស់យើង តាមរយៈអត្ថបទប្រវត្តិសាស្ត្រដូចជាសៀវភៅនេះ កម្ពុជាអាចបោះជំហានទៅមុខ និងបណ្តុះបណ្តាលកូនខ្មែរជំនាន់ក្រោយ ដែលជាអ្នកធានាថាគ្រាប់ពូជនៃអំពើប្រល័យពូជសាសន៍នឹងមិនអាចចាក់ឫសនៅក្នុងប្រទេសរបស់យើងសាជាថ្មីម្តងទៀតបានទេ។

**ឆាំង យុ**

នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

# សេចក្តីថ្លែងអំណរគុណ


មជ្ឈមណ្ឌលឯកសារកម្ពុជា មានកិត្តិយស ធ្វើសេចក្តីប្រកាសអំពីការបោះពុម្ពលើកទីពីរនៃសៀវភៅសិក្សា «***ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ***»។ ការបោះពុម្ពលើកទីពីរនេះ រួមបញ្ចូលនូវជំពូកថ្មីៗ ដែលពិភាក្សាអំពីយុត្តិធម៌ក្រោយអំពើប្រល័យពូជសាសន៍ដែលបានកើតឡើង ក៏ដូចជា ព័ត៌មាននិងឯកសារផ្សេងៗ មកពីការជំនុំជម្រះក្តី និងសេចក្តីសម្រេចនានារបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ការបោះពុម្ពលើកទីពីរនេះ មិនត្រឹមតែផ្តល់ជូនអ្នកអាននូវចំណេះដឹងប្រវត្តិសាស្ត្រស្តីពីរបបខ្មែរក្រហមតែប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងផ្តល់អង្គហេតុជាមូលដ្ឋាននិងគោលគំនិតស្តីពីការបង្កើត ការរៀបចំ និងការងាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាថែមទៀតផង។

ដូចដែលក្រុមអ្នកនិពន្ធ ( ផេង ពង្សរ៉ាស៊ី, សុភ័ក្រ្ត ភាណា, និង គ្រីស្តូហ្វ័រ ឌៀរីង ) បានលើកឡើងនៅក្នុងសៀវភៅរបស់ខ្លួនថា "សាលក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានជួយដល់ប្រជាជនកម្ពុជា ក៏ដូចជា ពិភពលោកទាំងមូលឲ្យស្វែងយល់កាន់តែច្បាស់ថែមទៀតអំពីអ្វីដែលជាកត្តាជំរុញ និងការកើតមានឡើងនៅក្នុងរបបខ្មែរក្រហម។" មានការសង្ឃឹមទុកថា តាមរយៈសៀវភៅនេះ ព័ត៌មានមួយចំនួនដែលបានលើកឡើង នឹងបញ្ចូលទៅក្នុងថ្នាក់រៀនព្រមទាំងមេរៀនថ្មីៗ សម្រាប់សិស្សានុសិស្សកម្ពុជានិងសាធារណជនទូទៅ។

ការបោះពុម្ពលើកទីពីរនេះ នឹងមិនអាចប្រព្រឹត្តទៅបាននោះទេ ប្រសិនបើគ្មានការគាំទ្រដ៏ថ្លៃថ្លាពីសំណាក់ភាគីពាក់ព័ន្ធសំខាន់ៗនានា។ មជ្ឈមណ្ឌលឯកសារកម្ពុជា សូមថ្លែងអំណរគុណ ដល់រាជរដ្ឋាភិបាលកម្ពុជា ដែលបានផ្តួចផ្តើមនិងគាំទ្រការបង្រៀនពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៨០មកម្ល៉េះ។ ការគាំទ្រជាបន្តបន្ទាប់ របស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះការអប់រំមនុស្សជំនាន់ក្រោយអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះ គឺជាកត្តាចាំបាច់សម្រាប់អនាគតប្រទេសជាតិ។

ខ្ញុំសូមថ្លែងអំណរគុណដល់ក្រសួងអប់រំ យុវជន និងកីឡា ដែលគឺជាដៃគូរយូរអង្វែងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ខ្ញុំសង្ឃឹមថាសៀវភៅនេះនឹងអាចជួយដល់លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សជាច្រើន ក្នុងការសិក្សាអំពីអតីតកាល ដ៏ខ្មៅងងឹតរបស់ប្រទេសកម្ពុជា។

ខ្ញុំសូមអរគុណដល់ម្ចាស់ជំនួយ ទាំងម្ចាស់ជំនួយដែលបានផ្តល់ហិរញ្ញប្បទានជា ពិសេសចំពោះការបោះពុម្ពសៀវភៅនេះ ក៏ដូចជាម្ចាស់ជំនួយដទៃទៀត ដែលបានផ្តល់ការគាំទ្រ ទូទៅដល់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ជំនួយទ្រទ្រង់ផ្នែកហិរញ្ញវត្ថុ សម្រាប់ការបោះពុម្ពសៀវភៅនេះ ត្រូវបានផ្តល់ឲ្យដោយសប្បុរសពី កម្មវិធីសន្តិភាពនៃសង្គមស៊ីវិលអាល្លឺម៉ង់សម្រាប់សហប្រតិបត្តិការអន្តរជាតិ ក្រសួងអភិវឌ្ឍសេដ្ឋកិច្ចនិងសហប្រតិបត្តិការ ព្រមទាំងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត។ មជ្ឈមណ្ឌលឯកសារកម្ពុជា សូមអរគុណដល់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ ដែលបានបន្តគាំទ្រយ៉ាងសប្បុរសដល់កិច្ចការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំង ៥លាននាក់។ កិច្ចខិតខំប្រឹងប្រែងរបស់អ្នករស់រានមានជីវិតទាំងអស់នេះ ក្នុងការនិយាយរៀបរាប់សាច់រឿងរបស់ខ្លួន បានធានាថាទំព័រប្រវត្តិសាស្ត្រមួយនេះ នឹងមិនត្រូវបានបំភ្លេចចោល។ សៀវភៅនេះ គឺជាការឧទ្ទិសស្នាដៃចំពោះអ្នករស់រានមានជីវិតពីសម័យខ្មែរក្រហមទាំងអស់។


ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺជាកម្មសិទ្ធរបស់ប្រជាជនកម្ពុជាគ្រប់រូប មិនមែនត្រឹមតែ សិទ្ធិជាម្ចាស់ប៉ុណ្ណោះទេ ក៏ប៉ុន្តែគឺជាកាតព្វកិច្ចរបស់ប្រជាជនគ្រប់រូបក្នុងការ យល់ដឹងអំពីប្រវត្តិសាស្ត្រនេះ។ លទ្ធិប្រជាធិបតេយ្យដ៏រស់រវើក ពឹងផ្អែកលើសិទ្ធិស្មើៗគ្នារបស់ប្រជាជនទាំងអស់ ក្នុងការចូលរួមយ៉ាងពេញលេញក្នុងកិច្ចការរបស់ប្រទេសជាតិខ្លួន។ ទោះបីជាយ៉ាងណាក៏ដោយ ប្រជាជនត្រូវទទួលខុសត្រូវចំពោះការផ្តល់ព័ត៌មានទៅកាន់អ្នកដទៃទៀត។ ប្រជាជនដែលមិនអើពើ ប្រានចោល ឬមិនផ្តល់តម្លៃចំពោះអតីតកាលរបស់ខ្លួន នឹងជំរុញឲ្យស្ថានភាពលំបាកនិងអំពើអមនុស្សធម៌ដែលបានបំផ្លិចបំផ្លាញមនុស្សជំនាន់មុនៗ អាចនឹងកើតមានម្តងទៀត។ អនាគតរបស់ប្រទេសកម្ពុជាពឹងផ្អែកលើការអប់រំ ដែលជាសិទ្ធិចូលរួមរបស់ប្រជាជននិងកាតព្វកិច្ចសីលធម៌របស់បុគ្គលម្នាក់ៗ។ សៀវភៅនេះនឹងផ្តល់ឲ្យសិស្សានុសិស្សនិងសាធារណជន នូវសម្ភារថ្មីមួយបន្ថែមទៀត ដើម្បីយល់ដឹងអំពីចំណុចគោលនៃភាពពេញលេញរបស់បុគ្គលនិងសមូហភាព។

**ឆាំង យុ**

នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

# កំណត់ចំណាំលើការបោះពុម្ព

# សៀវភៅលើកទី២

គ្រីស្តូហ្វ័រ ឌៀរីង,ផេង ពង្សរ៉ាស៊ី, សុភ័ក្ត្រ ភាណា



រូបថតនេះជារបស់ សាន្ត សុខ ដែលចូលរួមចលនាតស៊ូបដិវត្តន៍ ក្នុងឆ្នាំ១៩៧២។ ពីឆ្វេងទៅស្តាំ៖ អុល, អ៊ឹម, ផេង, អោ, ញ៉េប (សុខ), សាន្ត សុខ និងផ្លូច។ រូបថតនេះ ជាអំណោយរបស់លោក សាន្ត សុខ។ គាត់បានសរសេរនៅលើខ្នងរូបថតថា «សាន្ត សុខ រួមចលនាតស៊ូបដិវត្តន៍។ ថតរួមជាមួយប្អូនៗ បុគ្គលិកអង្គភាព គណៈកម្មាធិការទទួលប្រជាជនជម្លៀស ស្រុកព្រៃកប្បាស (ហៅស្រុក៥៥)។ ថតឆ្នាំ១៩៧២។
ប្រភព៖ សាន្ត សុខ/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

សៀវភៅថ្មីនេះ មានរួមបញ្ចូលការរៀបរៀងនូវជំពូកចាំបាច់មួយចំនួនឡើងវិញ ដើម្បីពន្យល់អំពីអង្គហេតុពិតនៃប្រវត្តិសាស្ត្រ និងរឿងរ៉ាវជាច្រើនរបស់អ្នករស់រានមានជីវិត ក៏ដូចជាការលើកឡើងអំពីជំពូកថ្មីៗទាក់ទងនឹងដំណើរការយុត្តិធម៌ក្រោយពេលដែលអំពើប្រល័យពូជសាសន៍បានកើតឡើង។ ក្រុមអ្នកនិពន្ធបានរៀបរៀងជំពូកទី៣និងទី៤ឡើងវិញ ដែលពិភាក្សាអំពីការចាប់ផ្តើមនៃរបបខ្មែរក្រហម។ ជំពូកទាំងពីរនេះរួមបញ្ចូលនូវព័ត៌មានថ្មីៗអំពីការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងប្រទេសកម្ពុជា ព្រមទាំងការស្រង់សម្តីរបស់សាក្សីដែលឆ្លងកាត់ប្រវត្តិសាស្ត្រនេះ អមជាមួយនឹងការផ្តោតជាពិសេសទៅលើទុក្ខវេទនារបស់ប្រជាជនកម្ពុជា។ ដោយប្រើប្រាស់ព័ត៌មានមកពីដំណើរការសាលក្រមក្នុងសំណុំរឿង០០២ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក៏ដូចជាសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជំពូកទាំងពីរនឹងផ្តល់ជាព័ត៌មានពិស្តារអំពីអ្វីដែលបានកើតមានឡើងនៅដំណាក់កាលដំបូងនៃរបបខ្មែរក្រហម។

ក្រុមអ្នកនិពន្ធក៏បានបន្ថែមជំពូកថ្មីមួយចំនួនទៀត ដែលបង្ហាញអំពីការបង្កើត និងការប្រតិបត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ជំពូកទី១៣ អធិប្បាយអំពីការបង្កើត ការរៀបចំ និងយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយផ្តោតលើកាលៈទេសៈដែលជំរុញឱ្យមានការបង្កើតអង្គជំនុំជម្រះនេះ ក៏ដូចជាបញ្ញត្តិនិងគោលការណ៍ច្បាប់សំខាន់ៗ ដែលបង្កើតបានជាអាណត្តិ និងបទដ្ឋានច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ជំពូកនេះ ក៏បានបកស្រាយពីទិដ្ឋភាពទូទៅ នៃសមាសធាតុសំខាន់ៗ មន្ត្រីតុលាការ និងបុគ្គលពាក់ព័ន្ធនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ជំពូកទី១៤ អធិប្បាយពីទិដ្ឋភាពទូទៅនៃសំណុំរឿងទាំង៤របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយមានការពិពណ៌នាដោយសង្ខេបអំពីបទឧក្រិដ្ឋកម្មដែលត្រូវបានចោទ ស្ថានភាពរបស់ជនជាប់ចោទ និងការវិនិច្ឆ័យ និង/ឬ ទោសទណ្ឌសំខាន់ៗ ដែលបានដាក់ចេញ គិតត្រឹមកាលបរិច្ឆេទនៃការបោះពុម្ពសៀវភៅនេះ។ ជំពូកទី១៥ បង្ហាញពីការដកស្រង់ពាក្យសម្តីសុំទោសរបស់ជនជាប់ចោទម្នាក់ និយាយទៅកាន់ជនរងគ្រោះ អង្គសវនាការ និងសាធារណៈ។ ចំណែកជំពូកទី១៦ បង្ហាញពីការដកស្រង់សក្ខីកម្មខ្លីៗរបស់ជនរងគ្រោះ អ្នករស់រានមានជីវិត និងសាក្សីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ជំពូកថ្មីៗទាំងនេះ ដែលលើកឡើងអំពីការបង្កើត កិច្ចការងារ និងសក្ខីកម្មនានាដែលធ្វើឡើងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាផ្នែកដ៏មានសារសំខាន់មួយនៃរឿងរ៉ាវស្តីពីការតស៊ូរបស់ប្រជាជនកម្ពុជា ក្នុងការប្រឈមមុខនឹងអតីតកាលនៃប្រទេសជាតិរបស់ខ្លួន។ កិច្ចការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អាចផ្តោតជាសំខាន់ត្រឹមតែទៅលើដំណើរការកាត់ទោសព្រហ្មទណ្ឌចំពោះមេដឹកនាំជាន់ខ្ពស់ និងអ្នកទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងពេលនៃរបបខ្មែរក្រហម។ ប៉ុន្តែកិច្ចការរបស់តុលាការ ពិតជាមានសារប្រយោជន៍ជាច្រើនយ៉ាងទៀត ដែលមានឥទ្ធិពលលើការតស៊ូរបស់ប្រជាជនកម្ពុជា ក្នុងការប្រឈមមុខនឹងប្រវត្តិសាស្ត្រនេះ។ សាលក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានជួយដល់ប្រជាជនកម្ពុជា ក៏ដូចជាពិភពលោកទាំងមូលឱ្យស្វែងយល់កាន់តែច្បាស់ថែមទៀតអំពីអ្វីដែលជាកត្តាជំរុញ និង ការកើតមានឡើងនៅក្នុងរបបខ្មែរក្រហម ហើយវិធានការច្បាប់ យុត្តាធិការ និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាចំណុចយោងសម្រាប់បង្កើនប្រសិទ្ធិភាពក្នុងការអនុវត្តនិងការយល់ដឹងអំពីភាពស្មើគ្នាចំពោះមុខច្បាប់នៅក្នុងប្រទេសកម្ពុជា។

ជាចុងក្រោយ តុលាការបានផ្តល់នូវភាពពេញលេញមួយ។ ភាពពេញលេញក្នុងន័យនេះ មិនសំដៅដល់សំណង ការប៉ះប៉ូវ ឬការផ្សះផ្សានោះទេ។ ភាពពេញលេញ គឺជាដំណើរការមួយដែលមាននិយមន័យផ្សេងៗពីគ្នា អាស្រ័យលើការកំណត់របស់អ្នករស់រានមានជីវិតម្នាក់ៗ ឬស្ថានភាពនៃបុគ្គលជាទីស្រឡាញ់ម្នាក់ៗ និងជារួម។ ភាពពេញលេញនេះ អាចនឹងត្រូវចំណាយពេលវេលាជាច្រើនជំនាន់ទៀត។ ក្នុងមធ្យោបាយណាក៏ដោយ កិច្ចការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនអាចសម្រេចបានភាពពេញលេញថ្នាក់ជាតិ ឬជារួមបានទេ ក៏ប៉ុន្តែកិច្ចការនេះបានជួយសម្រួលដល់ដំណើរការដើម្បីសម្រេចបាននូវភាពពេញលេញមួយ។ សៀវភៅនេះ ត្រូវបានឧទ្ទិសដល់ការគាំទ្រចំពោះភាពពេញលេញ តាមរយៈការចងចាំ និងការអប់រំអំពីប្រវត្តិសាស្ត្រនេះ សម្រាប់យុវជន-យុវនារី និងមនុស្សជំនាន់ក្រោយៗទៀត។



**កម្មាភិបាលជំទង់ខ្មែរក្រហម រុំក្រមាមានវេចផ្លែឈើ។ ក្រមាគឺជាសំពត់ប្រពៃណីខ្មែរដែល អាចយកមកប្រើប្រាស់បានច្រើនយ៉ាង។ ថតនៅវាំងឆ្នាំ១៩៧៥-១៩៧៨។**

(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



**ទាហានខ្មែរក្រហមពីរនាក់ នៅក្នុងលេណដ្ឋានខាងមុខប្រាសាទអង្គរវត្ត។ ថតក្នុងឆ្នាំ១៩៧៣។**
ប្រភព៖ ហូលីយ៉ូ ដែលជ្រេស/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

ជំពូកទី១

# សេចក្តីសង្ខេប

“ខ្មែរក្រហម” គឺជាឈ្មោះដែលសម្តេចព្រះនរោត្តម សីហនុ មានព្រះរាជបន្ទូលសំដៅទៅលើក្រុមកុម្មុយនីស្តដែលប្រឆាំងនឹងព្រះអង្គនៅទសវត្សរ៍ទី៦០។

[១]ឈ្មោះផ្លូវការរបស់ក្រុមនេះគឺ បក្សកុម្មុយនីស្តកម្ពុជា ដែលបានចូលកាន់កាប់ប្រទេសកម្ពុជា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ បក្សកុម្មុយនីស្តកម្ពុជា បានបង្កើតរដ្ឋកម្ពុជាប្រជាធិបតេយ្យនៅឆ្នាំ១៩៧៦ និងគ្រប់គ្រងប្រទេសរហូតដល់ខែមករាឆ្នាំ១៩៧៩។ វត្តមានរបស់បក្សត្រូវបានរក្សាជាការសម្ងាត់រហូតដល់ឆ្នាំ១៩៧៧ ហើយពុំមាននរណាម្នាក់នៅក្រៅបក្សកុម្មុយនីស្តកម្ពុជាដឹងថា មេដឹកនាំរបស់បក្សនេះគឺជានរណាទេ (ព្រោះមេដឹកនាំទាំងនោះបានហៅខ្លួនឯងថា អង្គការបដិវត្តន៍)។

ពីរបីថ្ងៃបន្ទាប់ពីការឡើងកាន់កាប់អំណាចនៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានបង្ខំប្រជាជនប្រហែលពីរលាននាក់ដែលកំពុងរស់នៅក្នុងទីក្រុងភ្នំពេញ និងនៅតាមទីប្រជុំជនដទៃទៀត ឱ្យចាកចេញទៅកាន់ទីជនបទដើម្បីធ្វើការងារកសិកម្ម។ ប្រជាជនរាប់ពាន់នាក់ បានស្លាប់នៅក្នុងអំឡុងពេលជម្លៀសនេះ។

ក្នុងពេលជាមួយគ្នានេះ ខ្មែរក្រហមបានចាប់ផ្តើមអនុវត្តកម្មវិធីកែទម្រង់តាមលទ្ធិម៉ៅ និងលទ្ធិម៉ាក្សលេនីនដ៏ជ្រុលហួសហេតុ។ ខ្មែរក្រហមចង់ប្រែក្លាយប្រទេសកម្ពុជា ឱ្យទៅជាប្រទេសដែលមិនមានវណ្ណៈសង្គម ពោលគឺពុំមានអ្នកមាន ពុំមានអ្នកក្រ និងគ្មានការកេងប្រវ័ញ្ចគ្នា។ ដើម្បីសម្រេចឱ្យបានគោលបំណងនេះ ខ្មែរក្រហមបានលុបបំបាត់រូបិយវត្ថុ ផ្សារផ្សេង ការអប់រំ ទ្រព្យសម្បត្តិឯកជន ម៉ូតសម្លៀកបំពាក់ស៊ីវិល័យបរទេស ការគោរពជំនឿសាសនា និងប្រពៃណីវប្បធម៌ខ្មែរ។ សាលារៀន វត្តអារាម វិហារសាសនាអ៊ីស្លាម វិហារសាសនាគ្រិស្ត សាកលវិទ្យាល័យ ហាងលក់ទំនិញ និងអគាររដ្ឋាភិបាលត្រូវបិទទ្វារ ឬក៏ប្រែក្លាយទៅជា(មន្ទីរសន្តិសុខ) គុក ក្រោលគោ ជំរំអប់រំកែប្រែ និង ជង្រុកស្រូវ។ ក្នុងសង្គមនេះគ្មានមធ្យោបាយដឹកជញ្ជូនឯកជនឬសាធារណៈ គ្មានទ្រព្យសម្បត្តិឯកជន និងគ្មានសិល្បៈកម្សាន្តណាដែលមិនមានលក្ខណៈបដិវត្តន៍ទេ ហើយការលម្ហែកម្សាន្តត្រូវអង្គការហាមឃាត់យ៉ាងតឹងរ៉ឹងបំផុត។ ប្រជាជននៅទូទាំងប្រទេសរួមទាំងថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាផង ត្រូវបានតម្រូវឱ្យស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ ដែលជាសម្លៀកបំពាក់ប្រពៃណីបដិវត្តន៍របស់ខ្លួន។

ស្ថិតនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ មនុស្សគ្រប់រូបត្រូវបានដកហូតសិទ្ធិជាមូលដ្ឋានរបស់ខ្លួន និងមិនអនុញ្ញាតឱ្យទៅណាមកណាដោយសេរី ឬដើរចេញក្រៅសហករណ៍របស់ខ្លួនឡើយ។ របបនេះក៏មិនអនុញ្ញាតឱ្យប្រជាជនប្រមូលផ្តុំ ឬពិភាក្សាគ្នាអ្វីទាំងអស់។ ប្រសិនបើមនុស្សបីនាក់ផ្តុំគ្នាហើយនិយាយគ្នាលេង អ្នកទាំងនោះអាចត្រូវបានចោទប្រកាន់ថាជាខ្មាំង ព្រមទាំងអាចត្រូវចាប់ខ្លួន ឬយកទៅសម្លាប់ចោលទៀតផង។

ទំនាក់ទំនងក្នុងគ្រួសារក៏ត្រូវទទួលរងការរិះគន់យ៉ាងខ្លាំងក្លាដែរ។ ប្រជាជនគ្រប់រូបត្រូវបានហាមឃាត់ មិនឱ្យសម្តែងចេញនូវសេចក្តីស្រឡាញ់ សេចក្តីសប្បាយរីករាយ ឬ សេចក្តីអាណិតអាសូរសូម្បីតែបន្តិចបន្តួចក៏ដោយ។ ខ្មែរក្រហមបាន បង្គាប់បញ្ជាឱ្យប្រជាជនគ្រប់រូបជឿ ធ្វើតាម និងគោរពអង្គការបដិវត្តន៍តែមួយគត់ដែលជា «ឪពុកម្តាយ» របស់ប្រជាជនគ្រប់រូប។

ខ្មែរក្រហមបានអះអាងថា មានតែមនុស្សស្អាតស្អំប៉ុណ្ណោះ ទើបមានគុណសម្បត្តិគ្រប់គ្រាន់ក្នុងការកសាងបដិវត្តន៍។ បន្ទាប់ពីដណ្តើមបានអំណាចភ្លាម កម្មាភិបាលខ្មែរក្រហមបានធ្វើការចាប់ខ្លួននិងសម្លាប់ពលទាហាន នាយទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដែលដឹកនាំដោយ សេនាប្រមុខ លន់ នល់ ដែលខ្លួនចាត់ទុកថាមិន«ស្អាតស្អំ» អស់រាប់ពាន់នាក់។ ក្នុងរយៈកាលជាងបីឆ្នាំបន្ទាប់មកទៀត ខ្មែរក្រហមបានធ្វើការបោសសម្អាត (សម្លាប់) បញ្ញវន្ត អ្នកទីក្រុង ជនជាតិភាគតិចចាម វៀតណាម និងចិន អស់រាប់សែននាក់។ ខ្មែរក្រហមក៏បានសម្លាប់យោធានិងសមាជិកបក្សរបស់ខ្លួនអស់ជាច្រើននាក់ ដោយចោទថាជាជនក្បត់ជាតិនិងក្បត់បដិវត្តន៍។

> ការសម្លាត់
> គឺជាគោលការណ៍គ្រឹះនៃដំណើរការរបស់កម្ពុជាប្រជាធិបតេយ្យ។
> ខ្មែរក្រហមមានពាក្យស្លោកមួយថា៖
> «លាក់ការណ៍ជាកត្តាជ័យជម្នះ។
> លាក់ការណ៍ខ្ពស់ រស់បានយូរ»។

នៅក្នុងគម្រោងឆ្នាំ១៩៧៦នៃផែនការបួនឆ្នាំរបស់បក្សកុម្មុយនីស្តកម្ពុជា ប្រជាជនកម្ពុជានៅទូទាំងប្រទេសត្រូវបានដាក់កម្រិតឱ្យធ្វើការបង្កបង្កើនផលឱ្យបានបីតោនក្នុងមួយហិកតា(ជួនកាលទិន្នផលស្រូវដែលកំណត់មានបរិមាណលើសពីនេះទៀត)។ នេះមានន័យថា ប្រជាជនត្រូវតែដាំដុះនិងច្រូតកាត់ស្រូវរៀងរាល់ខែ គឺពេញដប់ពីរខែក្នុងមួយឆ្នាំ។ នៅក្នុងតំបន់ភាគច្រើន ខ្មែរក្រហមបានបង្ខំប្រជាជនឱ្យធ្វើការលើសពីដប់ពីរម៉ោងក្នុងមួយថ្ងៃ ដោយមិនបានសម្រាកនិងគ្មានអាហារហូបចុកគ្រប់គ្រាន់។

រហូតមកដល់ចុងឆ្នាំ១៩៧៧ ការប៉ះទង្គិចជាមួយវៀតណាមបានផ្ទុះឡើង។ ប្រជាជនរាប់ម៉ឺននាក់ ត្រូវបានអង្គការបញ្ជូនទៅកាន់សមរភូមិ ហើយត្រូវស្លាប់រាប់ពាន់នាក់។

នៅខែធ្នូ ឆ្នាំ១៩៧៨ កងកម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដោយមានជំនួយពីកងទ័ពវៀតណាម បានធ្វើការវាយសម្រុកចូលប្រទេសកម្ពុជា និងរំដោះទីក្រុងភ្នំពេញនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។

នៅពេលនោះ មេដឹកនាំខ្មែរក្រហមបានភៀសខ្លួនទៅកាន់ភាគខាងលិចនៃប្រទេសកម្ពុជា ព្រមទាំងបានរៀបចំបង្កើតកងកម្លាំងរបស់ខ្លួនឡើងវិញ នៅក្នុងដែនដីនៃប្រទេសថៃ ដោយមានជំនួយពីប្រទេសចិននិងថៃ។ អង្គការសហប្រជាជាតិបានបោះឆ្នោតផ្តល់អាសនៈនៅមហាសន្និបាតអង្គការសហប្រជាជាតិ ឱ្យទៅក្រុមអ្នកតស៊ូប្រឆាំងនឹងកុម្មុយនីស្ត ដែលមានខ្មែរក្រហមនៅក្នុងនោះដែរ។ ចាប់តាំងពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៩០ អង្គការសហប្រជាជាតិបានទទួលស្គាល់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ថាជាតំណាងស្របច្បាប់តែមួយគត់របស់កម្ពុជា។

នៅឆ្នាំ១៩៨២ ខ្មែរក្រហមបានចងសម្ព័ន្ធភាពជាមួយសម្ដេចព្រះនរោត្តម សីហនុ និងមេដឹកនាំមិនមែនកុម្មុយនីស្ត សឺន សាន ដើម្បីបង្កើតរដ្ឋាភិបាលចម្រុះត្រីភាគី។ នៅភ្នំពេញឯណោះវិញ វៀតណាមបានជួយបង្កើតរដ្ឋាភិបាលសម្រាប់គ្រប់គ្រងរដ្ឋថ្មីមួយឈ្មោះ "សាធារណរដ្ឋប្រជាមានិតកម្ពុជា"។

ខ្មែរក្រហមបានបន្តនិរន្តរភាពរបស់ខ្លួនរហូតដល់ឆ្នាំ១៩៩៩ គឺនៅពេលដែលមេដឹកនាំខ្មែរក្រហម ទាំងអស់ចុះចូលជាមួយរដ្ឋាភិបាលកម្ពុជា ឬត្រូវចាប់ខ្លួន ឬទទួលមរណភាព។ ក៏ប៉ុន្តែ ខ្មែរក្រហមបានបន្សល់ទុកនូវភាពប្រេះស្រាំក្នុងសង្គមជាតិរហូតដល់សព្វថ្ងៃនេះ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនកម្ពុជាប្រមាណជាងពីរលាននាក់បានស្លាប់ដោយសារជំងឺ ដែលបណ្ដាលមកពីការខ្វះខាតថ្នាំសង្កូវ និងសេវាសុខាភិបាល ការអត់អាហារ ការសម្លាប់ ឬការធ្វើពលកម្មហួសកម្លាំង[២]។ ប្រជាជនដែលនៅរស់រានមានជីវិតក្រោយរបបខ្មែរក្រហម បានទទួលរងនូវការប៉ះទង្គិចផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ដោយសារតែបទពិសោធន៍ដែលខ្លួនបានជួបប្រទះ។



ខៀវ សំផន និងកងការពារខ្មែរក្រហម នៅក្នុងតំបន់រំដោះដែលគ្រប់គ្រងដោយខ្មែរក្រហមនៅឆ្នាំ១៩៧៣។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




វាលពិឃាតនៅកម្ពុជា៖ មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលប្រើប្រាស់ឧបករណ៍កំណត់ទីតាំងភូមិសាស្ត្រក្នុងការស្វែងរក និងគូរផែនទីរណ្ដៅសាកសពរួមជាមួយនឹងការចុះទៅស្រាវជ្រាវដល់ទីកន្លែង បានធ្វើការកំណត់រណ្ដៅសាកសពនៅទូទាំងប្រទេស។ រហូតមកដល់ពេលនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញវាលពិឃាតចំនួន៣៩០កន្លែង ដែលរួមមាន១៩០០០រណ្ដៅ (មជ្ឈមណ្ឌលឯកសារកម្ពុជា ឱ្យនិយមន័យទៅលើពាក្យ វាលពិឃាត ថាជារណ្ដៅដែលផ្ទុកសាកសពចាប់ពី៤នាក់រហូតដល់ទៅជាង១ពាន់នាក់)។ ជាងនេះទៅទៀត មជ្ឈមណ្ឌលឯកសារកម្ពុជា បានរកឃើញទីតាំងគុកចំនួន១៩៧កន្លែង និងទីតាំងបូជនីយដ្ឋានដែលសាងសង់ឡើងក្រោយរបបកម្ពុជាប្រជាធិបតេយ្យចំនួន៨១កន្លែង។ (ទិន្នន័យ៖ ផេង ពង្សរ៉ាស៊ី។ គូសផែនទី៖ លី កុកឆាយ។)



កងកម្លាំងខ្មែរឥស្សរៈ និងកងកម្លាំងស្ម័គ្រចិត្តវៀតណាម ពួតដៃគ្នា ក្នុងរវាងឆ្នាំ១៩៤៥-១៩៥៣។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជំពូកទី២

# តើខ្មែរក្រហមជានរណា? តើខ្មែរក្រហមឡើងកាន់អំណាចដោយរបៀបណា?

## ១. ចលនាកុម្មុយនីស្តដំបូងបំផុត

ចលនាកុម្មុយនីស្តនៅកម្ពុជា កើតចេញពីចលនាតស៊ូប្រឆាំងនឹងអាណានិគមបារាំងក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៤០។ នៅខែមេសា ឆ្នាំ១៩៥០ គឺក្នុងអំឡុងពេលនៃសង្គ្រាមឥណ្ឌូចិនលើកទី១[៣] គណៈប្រតិភូចំនួន២០០នាក់បានមកជួបជុំគ្នានៅខេត្តកំពត ហើយបានបង្កើតរណសិរ្សឯកភាពឥស្សរៈ (ខ្មែរឥស្សរៈ) ដែលដឹកនាំដោយក្រុមកុម្មុយនីស្ត។ ក្រុមនេះបានសហការជាមួយវៀតណាម ដើម្បីធ្វើការតស៊ូប្រឆាំងនឹងអាណានិគមបារាំង។

រណសិរ្សនេះដឹកនាំដោយ សឺង ង៉ុកមិញ (មានឈ្មោះពិតថា អាចារ្យ មៀន) ដែលជាអាចារ្យនៅវត្តឧណ្ណាលោម។ ចាន់ សាម៉យ ជាអនុប្រធាន និង ស៊ីវ ហេង ជាលេខាធិការ។ សមាជិករណសិរ្សស្ទើរតែទាំងអស់គឺជាជនជាតិខ្មែរដែលចេះនិយាយភាសាវៀតណាម។ សមាជិកមួយចំនួនបានចូលជាសមាជិកបក្សកុម្មុយនីស្តឥណ្ឌូចិន ដែលបង្កើតឡើងនៅប្រទេសវៀតណាម[៤]។ សមាជិកថ្មីៗរបស់រណសិរ្សភាគច្រើនជាកសិករដែលត្រូវបានអូសទាញដើម្បីបុព្វហេតុបដិវត្តន៍។ រីឯសមាជិកផ្សេងៗទៀតជាក្រុមនិស្សិតជាតិនិយមដែលបានក្លាយទៅជាជនកុម្មុយនីស្តក្នុងពេលស្នាក់អាស្រ័យរៀនសូត្រនៅបរទេស។

និស្សិតមួយចំនួនក្នុងចំណោមនិស្សិតទាំងនេះរួមមាន សាឡុត ស (ប៉ុល ពត) សុន សេន ខៀវ សំផន និង អៀង សារី ក្រោយមកបានក្លាយជាមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា។ ជនទាំងនេះយល់ឃើញថា កសិករនិងប្រជាជនក្រីក្រនៅទូទាំងពិភពលោក ត្រូវបានប្រែក្លាយទៅជាទាសករ និងត្រូវបានជិះជាន់សង្កត់សង្កិនដោយពួកមូលធននិយមនិងពួកសក្តិភូមិនិយម ហើយបានគិតថាបដិវត្តន៍តាមបែបម៉ាក្សលេនីន គឺជាផ្លូវតែមួយគត់ដែលកម្ពុជាអាចទទួលបាននូវឯករាជ្យភាពនិងភាពស្មើគ្នានៅក្នុងសង្គម។

## ២. ការបង្កើតបក្សប្រជាជនបដិវត្តន៍ខ្មែរ

ក្នុងឆ្នាំ១៩៥១ នៅពេលដែលការប្រយុទ្ធប្រឆាំងនឹងបារាំងកាន់តែមានសភាពខ្លាំងក្លាទៅៗ នៅក្នុងឧបទ្វីបឥណ្ឌូចិន ជនកុម្មុយនីស្តវៀតណាមបានផ្តួចផ្តើមឱ្យមានការបង្កើតបក្សប្រជាជនបដិវត្តន៍ខ្មែរ[៥]។ សមាជិករបស់គណៈកម្មាធិការមជ្ឈិមបក្សសម្ងាត់នេះរួមមាន៖

- សឺង ង៉ុកមិញ កាន់តំណែងកំពូល
- ស៊ីវ ហេង ទទួលបន្ទុកកិច្ចការយោធា
- ទូ សាមុត (ហៅ អាចារ្យ សុខ ជាអតីតព្រះសង្ឃមកពីកម្ពុជាក្រោម) ទទួលបន្ទុកកិច្ចការអប់រំមនោគមវិជ្ជា
- ចាន់ សាម៉យ ទទួលបន្ទុកផ្នែកសេដ្ឋកិច្ច

នៅពេលដែលសង្គ្រាមឥណ្ឌូចិនលើកទីមួយ បញ្ចប់ទៅនៅក្នុងឆ្នាំ១៩៥៤ កងទ័ពបារាំងបានដកចេញពីឥណ្ឌូចិន ហើយកងកម្លាំងរបស់វៀតមិញក៏បានដកចេញពីកម្ពុជា[៦]។ ទោះជាយ៉ាងដូច្នេះក៏ដោយ ក៏យោធាវៀតណាមមួយចំនួននៅតែបន្តស្នាក់នៅក្នុងប្រទេសកម្ពុជាដដែល។ ដោយមានការព្រួយបារម្ភពីសុវត្ថិភាពបដិវត្តន៍ក្នុងអំឡុងពេលនយោបាយក្នុងប្រទេសកម្ពុជាមានការផ្លាស់ប្តូរ ស៊ីវ ហេង ចាន់ សាម៉យ, កម្មាភិបាល និងសកម្មជនរបស់បក្សប្រជាជនបដិវត្តន៍ខ្មែរជាងមួយពាន់នាក់ទៀត បានភៀសខ្លួនទៅកាន់ប្រទេសវៀតណាម ដើម្បីចូលរួមជាមួយ សឺង ង៉ុកមិញ និងសកម្មជនដទៃទៀតដែលបានភៀសខ្លួនទៅកាន់ទីនោះមុន។

មិនយូរប៉ុន្មាន ស៊ីវ ហេង បានវិលត្រឡប់មកប្រទេសកម្ពុជាវិញ អមដំណើរដោយ នួន ជា (ជាសមាជិកបក្សកុម្មុយនីស្តឥណ្ឌូចិន ដែលបានទៅហ្វឹកហ្វឺននៅប្រទេសថៃនិងវៀតណាម) ព្រមទាំងកម្មាភិបាលជាន់ខ្ពស់ដទៃទៀត។ ដោយសារមេបក្ស សឺង ង៉ុកមិញ នៅបន្តស្នាក់នៅនិរទេសខ្លួនក្នុងទីក្រុងហាណូយតទៅទៀត បក្សប្រជាជនបដិវត្តន៍ខ្មែរត្រូវបានដឹកនាំដោយគណៈកម្មាធិការមជ្ឈិមបក្សបណ្តោះអាសន្នមួយ ដែលមាន ស៊ីវ ហេង ជាលេខាបក្ស ទូ សាមុត ជាអនុលេខាបក្ស។

**ប៉ុល ពត** (ឈ្មោះដើម សាឡុត ស)

ប៉ុល ពត កើតនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩២៥ ត្រូវនឹងឆ្នាំឆ្លូវ នៅស្រុកស្ទោង ខេត្តកំពង់ធំ និងជាកូនរបស់ម្ចាស់ដីដ៏ស្តុកស្តម្ភម្នាក់។ នៅពេល មានអាយុ៦ឆ្នាំ ប៉ុល ពត បានទៅរស់នៅជាមួយបងប្រុសដែលជាមន្ត្រីធ្វើការនៅក្នុងព្រះបរមរាជវាំង ជាកន្លែងដែលគាត់បានសិក្សារៀនសូត្រនៅតាមសាលាបារាំងជាច្រើនហើយបានបួសជាលោកនេន។

នៅឆ្នាំ១៩៤៩ ប៉ុល ពត បានទទួលអាហារូបករណ៍ទៅសិក្សានៅប្រទេសបារាំង ប៉ុន្តែមិនបានទទួលសញ្ញាប័ត្រទេ។ ក្នុងអំឡុងពេលស្នាក់នៅរៀនសូត្រនៅក្រុងប៉ារីស ប៉ុល ពត បានក្លាយទៅជាសមាជិកបក្សកុម្មុយនីស្តបារាំង ហើយបានចំណាយពេលយ៉ាងច្រើនទៅលើសកម្មភាពនយោបាយ។ នៅឆ្នាំ១៩៥៣ ប៉ុល ពត បានត្រឡប់មកប្រទេសកម្ពុជាវិញ និងបានធ្វើជាគ្រូបង្រៀនប្រវត្តិវិទ្យានិងភូមិវិទ្យានៅសាលាឯកជន ព្រមទាំងបានចូលរួមជាមួយចលនាកុម្មុយនីស្តខុសច្បាប់មួយ។

ប៉ុល ពត បានរៀបការជាមួយ ខៀវ ប៉ុណ្ណារី នៅឆ្នាំ១៩៥៦។ នៅឆ្នាំ១៩៦០ ប៉ុល ពត មានឋានៈទីបីនៅក្នុងបក្សពលករកម្ពុជា ហើយត្រូវបានតែងតាំងជាអនុលេខាបក្សទីពីរក្នុងឆ្នាំ១៩៦១ និងជាលេខាបក្សក្នុងឆ្នាំ១៩៦៣។ ក្រោយមក ប៉ុល ពត បានដឹកនាំកងទ័ពខ្មែរក្រហមធ្វើសង្គ្រាមប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែររបស់លោកសេនាប្រមុខ លន់ នល់។

ប៉ុល ពត បានក្លាយជានាយករដ្ឋមន្ត្រីរបស់កម្ពុជាប្រជាធិបតេយ្យនៅឆ្នាំ១៩៧៦ ហើយបានលាលែងពីតំណែងនៅឆ្នាំ១៩៧៩។ ទោះជាយ៉ាងដូច្នេះក៏ដោយ ក៏ប៉ុល ពត នៅតែជាមេដឹកនាំដ៏មានឥទ្ធិពលរបស់ខ្មែរក្រហមដដែល។ ប៉ុល ពត រស់នៅនិរទេសខ្លួនភាគច្រើននៅក្នុងទឹកដីថៃរហូតដល់ថ្ងៃទទួលមរណភាពនៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨ ។ សាកសព ប៉ុល ពត ត្រូវបានបូជានៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៨។

នួន ជា ស្ថិតនៅក្នុងលំដាប់ទីបីក្នុងបក្ស ហើយ សោ ភឹម (ដែលជាលេខាភូមិភាគបូព៌ាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ) ស្ថិតក្នុងលំដាប់ទីបួន។ ទោះជាយ៉ាងដូច្នេះក៏ដោយ ក៏ការគ្រប់គ្រងទូទៅនៅក្នុងបក្សប្រជាជនបដិវត្តន៍ខ្មែរ នៅតែស្ថិតក្រោមការគ្រប់គ្រងរបស់ ផាំ វ៉ាន់បា សមាជិកបក្សកុម្មុយនីស្តវៀតណាមដែលធ្លាប់រស់នៅក្នុងប្រទេសកម្ពុជា និងបានអះអាងថា វៀតណាមគួរបន្តគ្រប់គ្រងលើចលនាកុម្មុយនីស្ត នៅកម្ពុជាតទៅទៀត។

ទូ សាមុត ទទួលខុសត្រូវលើសកម្មភាពការងាររបស់បក្សនៅក្នុងតំបន់ទីក្រុងនានា ដោយមានជំនួយពី នួន ជា និង សាឡុត ស (ក្រោយមកត្រូវបានស្គាល់ថា ប៉ុល ពត) ដែលទើបតែត្រឡប់មកពីសិក្សានៅប្រទេសបារាំងវិញ។ ប៉ុល ពត ត្រូវបានចាត់តាំងឱ្យធ្វើជាខ្សែរយៈទាក់ទងដើម្បីបង្កើតគណបក្សស្របច្បាប់មួយឈ្មោះ "គណបក្សប្រជាជន" ដើម្បីចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជាតិឆ្នាំ១៩៥៥ ស្របតាមសេចក្ដីសម្រេចរបស់កិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ[៧]។ គណបក្សនេះដឹកនាំដោយ កែវ មាស ដែលជាមនុស្សស្ថិតនៅក្រោមការបង្គាប់បញ្ជារបស់ ទូ សាមុត។

ប៉ុល ពត បានជួយបង្កើតលក្ខន្តិកៈនិងកម្មវិធីនយោបាយរបស់បក្ស។ ក្នុងពេលជាមួយគ្នានេះ ប៉ុល ពត ក៏បានធ្វើទំនាក់ទំនងជាមួយគណបក្សប្រជាធិបតេយ្យ ដែលនឹងចូលរួមប្រកួតប្រជែងជាមួយគណបក្សសង្គមរាស្ត្រនិយម របស់សម្ដេចព្រះ នរោត្តម សីហនុ ក្នុងការបោះឆ្នោតឆ្នាំ១៩៥៥ដែរ ពីព្រោះ ប៉ុល ពត ជឿជាក់ថា គណបក្សប្រជាធិបតេយ្យ ដែលមាននិន្នាការប្រឆាំងនឹងពួកសក្ដិភូមិនិងពួកមូលធននិយមនោះ នឹងឈ្នះនៅក្នុងការបោះឆ្នោតនេះ ហើយនឹងផ្ដល់ឥទ្ធិពលនយោបាយខ្លះៗមកឱ្យក្រុមកុម្មុយនីស្ត។



**កងកម្លាំងរណសិរ្សរួបរួមជាតិកម្ពុជា ប្រមូលផ្ដុំគ្នានៅក្នុងព្រៃនៅខេត្តសៀមរាបនាឆ្នាំ១៩៧៣។ រណសិរ្សរួបរួមជាតិកម្ពុជា គឺជាក្រុមចម្រុះដែលមានទាំងអ្នកគាំទ្រសម្ដេចព្រះ នរោត្តម សីហនុ និងខ្មែរក្រហម។ ក្រុមនេះ រួបរួមគ្នាតស៊ូប្រឆាំងនឹងកងកម្លាំង លន់ នល់។ រូបភាពខាងលើបង្ហាញអំពីកាំភ្លើងយន្ត ដែលដណ្ដើមបានពីទាហាន លន់ នល់។**
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**នួន ជា** (ឈ្មោះដើម ឡុង ប៊ុនរួត, ឡៅ គឹមលន, រុងឡឺត ឡាវឌី,ឈ្មោះហៅក្រៅ ខួច)

នួន ជា កើតនៅក្នុងឆ្នាំ១៩២៦ នៅខេត្តបាត់ដំបង។ នៅឆ្នាំ ១៩៤២ នួន ជា បានទៅស្នាក់អាស្រ័យនៅក្នុងវត្តបិណ្ឌចាម៉ាបូពិត ដើម្បីបន្តការសិក្សាថ្នាក់មធ្យមសិក្សាកម្រិត២ក្នុងទីក្រុងបាងកក។ នៅឆ្នាំ១៩៤៤ នួន ជា បានបន្តការសិក្សាផ្នែកច្បាប់នៅសាកលវិទ្យាល័យធម្មាសាត ដែលនៅទីនោះ នួន ជា បានចូលជាសមាជិកបក្សកុម្មុយនីស្តថៃ។

នួន ជា បានវិលត្រឡប់មកប្រទេសកម្ពុជានៅឆ្នាំ១៩៥០ ហើយបានប្ដូរសមាជិកភាពរបស់ខ្លួន មកជាសមាជិកបក្សកុម្មុយនីស្តឥណ្ឌូចិនវិញ។ នួន ជា បានចូលរួមវគ្គហ្វឹកហ្វឺននៅទីក្រុងហាណូយក្នុងឆ្នាំ១៩៥៤ ហើយបានវិលត្រឡប់មកកម្ពុជាវិញនៅឆ្នាំ១៩៥៥។ នៅឆ្នាំ១៩៦០ នួន ជា ត្រូវបានជ្រើសរើសជាអនុលេខាបក្សពលករកម្ពុជា។

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា ត្រូវបានជ្រើសតាំងជាប្រធានសភាតំណាងប្រជាជនកម្ពុជា និងមានតួនាទីសំខាន់មួយទៀតក្នុងបក្សគឺ អនុលេខាគណៈកម្មាធិការមជ្ឈិមបក្ស និងគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស។ នួន ជា ដើរតួនាទីសំខាន់ក្នុងបញ្ហាសន្តិសុខ ហើយក្នុងនាមជាកម្មាភិបាលជាន់ខ្ពស់លំដាប់ទីពីរ នួន ជា ទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយឃោរឃៅជាច្រើន ដែលបានអនុម័តឱ្យអនុវត្តដោយគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស។

នួន ជា បាននិរទេសខ្លួនទៅព្រំដែនខ្មែរ-ថៃនៅ ឆ្នាំ១៩៧៩។ នួន ជា ជាមួយ ខៀវ សំផន បានចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៨ បន្ទាប់ពីមរណភាពរបស់ ប៉ុល ពត។ នួន ជា ត្រូវបានចាប់ខ្លួន និងឃុំខ្លួនបណ្ដោះអាសន្ននៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

អស់រយៈពេលជាងមួយទសវត្សរ៍ក្រោយមក នួន ជា ត្រូវបានកាត់ទោសដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងត្រូវបានជាប់ទោសពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានសម្រេចដោយតុលាការកំពូលក្នុងសំណុំរឿង០០២/០១ បន្ទាប់ពីការបដិសេធលើបណ្ដឹងឧទ្ធរណ៍។ នួន ជា ត្រូវបានផ្ដន្ទាទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិត។ នួន ជា ក៏ត្រូវបានកាត់ទោសដោយអង្គជំនុំជម្រះសាលាដំបូងពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងអំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាមនិងចាម។ នួន ជា បានរៀបចំបណ្ដឹងឧទ្ធរណ៍ទៅកាន់តុលាការកំពូល ក៏ប៉ុន្តែបណ្ដឹងពុំត្រូវបានវិនិច្ឆ័យ និងសម្រេចឱ្យបញ្ចប់ ដោយសារតែមរណភាពរបស់ នួន ជា នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៩។

ទោះជាយ៉ាងនេះក្ដី ប៉ុល ពត បានធ្វើការព្យាករណ៍ខុសទាំងស្រុង។ គណបក្សសង្គមរាស្ត្រនិយម បានឈ្នះកៅអីទាំងអស់នៅក្នុងរដ្ឋសភាជាតិ ខណៈដែលបក្សប្រជាជនឈ្នះត្រឹម៣ភាគរយនៃកៅអីសរុបតែប៉ុណ្ណោះ។ ភ្លាមៗនោះ ស៊ីវ ហេង ជឿជាក់ថា បុព្វហេតុរបស់ក្រុមកុម្មុយនីស្តនៅកម្ពុជាស្ថិតក្នុងភាពអស់សង្ឃឹម ព្រោះថាប្រជាជនស្ទើរតែទាំងអស់បានគាំទ្រកម្មវិធីនយោបាយរបស់សម្ដេចព្រះ នរោត្តម សីហនុ ជាងគំនិតធ្វើបដិវត្តន៍។ ជាងនេះទៅទៀត ចលនាខ្មែរឥស្សរៈមួយចំនួនបានបោះបង់ចោលការតស៊ូរបស់ខ្លួន ហើយចុះចូលជាមួយរាជរដ្ឋាភិបាលរបស់សម្ដេចព្រះ នរោត្តម សីហនុ។

ក្នុងឆ្នាំ១៩៥៦ ស៊ីវ ហេង បាន ទាក់ទងជាសម្ងាត់ជាមួយឧត្តមសេនីយ៍ លន់ នល់ ដែលជាអគ្គមេបញ្ជាការកងទ័ពរបស់សម្ដេចព្រះ នរោត្តម សីហនុ ដើម្បីសុំឱ្យរាជរដ្ឋាភិបាលរបស់សម្ដេចព្រះ នរោត្តម សីហនុ ផ្ដល់នូវការធានាសន្តិសុខសុវត្ថិភាពដល់ខ្លួន។ ក្នុងឆ្នាំ១៩៥៩ ស៊ីវ ហេង បានចុះចូលជាមួយរាជរដ្ឋាភិបាលរបស់សម្ដេចព្រះ នរោត្តម សីហនុ ដែលជាហេតុធ្វើឱ្យអាជ្ញាធររដ្ឋាភិបាលមានលទ្ធភាពចង្អុល និងចាប់ខ្លួនកម្មាភិបាលបក្សលួចលាក់ខុសច្បាប់ជាច្រើននាក់។ យោងតាមសម្ដី របស់ ប៉ុល ពត ពីឆ្នាំ១៩៥៥ដល់ឆ្នាំ១៩៥៩ សមាជិកបក្សប្រជាជនបដិវត្តន៍ខ្មែរប្រហែល៩០ភាគរយ ត្រូវបានចាប់ខ្លួននិងសម្លាប់។ រហូតមកដល់ដើមឆ្នាំ១៩៦០ មានតែកម្មាភិបាលបក្សប្រហែល៨០០នាក់ និងសាខាបក្សចំនួនពីរនៅជនបទប៉ុណ្ណោះ ដែលនៅមានសកម្មភាពនិងដំណើរការពេញលេញ។ សាខាទាំងពីរនោះរួមមាន៖

- ភូមិភាគបូព៌ាមានមូលដ្ឋាននៅខេត្តកំពង់ចាម (ដឹកនាំដោយ សោ ភឹម) និង
- ភូមិភាគនិរតីមានមូលដ្ឋាននៅខេត្តតាកែវ (ដឹកនាំដោយ ឈិត ជឿន ហៅ តាម៉ុក)។

ទូ សាមុត, ប៉ុល ពត, និង នួន ជា បានបន្តដឹកនាំសកម្មភាពបក្សនៅក្នុងទីក្រុងភ្នំពេញ ដោយមានជំនួយពី អៀង សារី និង សុន សេន ជាបញ្ញវន្តដែលបានទៅសិក្សានៅប្រទេសបារាំង។

## ៣. បក្សពលករកម្ពុជា

មហាសន្និបាតបក្សប្រជាជនបដិវត្តន៍ខ្មែរ បានប្រារព្ធធ្វើឡើងជាសម្ងាត់នៅនៅក្នុងស្ថានីយរថភ្លើងក្រុងភ្នំពេញ ពីថ្ងៃទី២៨ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ ដែលក្នុងនោះមាន៧រូបមកពីសាខាបក្សក្នុងក្រុងភ្នំពេញ និង១៤រូបមកពីសាខាបក្សនៅតាមជនបទ។ មហាសន្និបាតបានសម្រេចរៀបចំបក្សឡើងវិញ បង្កើតគោលនយោបាយថ្មី និងប្ដូរឈ្មោះបក្សទៅជា "បក្សពលករកម្ពុជា"។ ទូ សាមុត ត្រូវបានតែងតាំងជាលេខាបក្ស, នួន ជា ជាអនុលេខាបក្ស និង ប៉ុល ពត មានឋានៈលំដាប់ទី៣ក្នុងបក្ស។ នៅឆ្នាំ១៩៦១ ប៉ុល ពត បានទទួលតំណែងជាអនុលេខាបក្សទី២។

បន្ទាប់ពី ទូ សាមុត បានបាត់ខ្លួន[៩] នៅឆ្នាំ១៩៦២ មហាសន្និបាតបក្សត្រូវបានប្រារព្ធធ្វើឡើងជាបន្ទាន់នៅខែកុម្ភៈឆ្នាំ១៩៦៣។ មហាសន្និបាតបានសម្រេចជ្រើសតាំង ប៉ុល ពត ជាលេខាបក្ស។ នួន ជា ដែលមានតំណែងខ្ពស់ជាង ប៉ុល ពត នៅក្នុងបក្ស មិនត្រូវបានជ្រើសរើសទេ ដោយហេតុថា នួន ជា ជាប់ជាសាច់ញាតិថ្លៃជាមួយជនក្បត់បក្ស ស៊ីវ ហេង។ ទោះបីជាយ៉ាងណាក៏ដោយ នួន ជា គឺជាជន

កុម្មុយនីស្តដ៏ស្មោះត្រង់ម្នាក់ ដែលចង់ឱ្យបក្សពលករកម្ពុជាកាន់តែរឹងមាំឡើង ហេតុដូច្នេះហើយទើប នួន ជា មិនធ្វើការប្រកួតប្រជែងជាមួយ ប៉ុល ពត សម្រាប់តំណែងនេះទេ។ នួន ជា បានបន្តស្ថិតនៅជាអនុលេខាបក្ស និងជាជនដ៏មានឥទ្ធិពលម្នាក់នៅក្នុងចលនាកុម្មុយនីស្តអស់រយៈពេលជាង៣០ឆ្នាំ។

បន្ទាប់ពីទទួលតំណែងជាលេខាបក្សភ្លាម ប៉ុល ពត បានទៅជ្រកកោននៅឯមូលដ្ឋានទ័ពរបស់វៀតណាមឈ្មោះថា“មន្ទីរ១០០” ស្ថិតនៅភាគឦសានប្រទេសកម្ពុជា។ នៅឆ្នាំ១៩៦៥ ប៉ុល ពត បានធ្វើដំណើរតាមផ្លូវលំហូជីមិញទៅទីក្រុងហាណូយ ដើម្បីធ្វើការពិភាក្សាជាមួយវៀតណាមខាងជើង។ ប៉ុល ពត ក៏បានធ្វើទស្សនកិច្ចទៅកាន់ប្រទេសចិន និងប្រទេសកូរ៉េខាងជើងដែរ។ ប៉ុល ពត ទទួលបានការស្វាគមន៍យ៉ាងរាក់ទាក់ពីភាគីចិន ជាងភាគីវៀតណាម។ ប៉ុល ពត មានការមិនពេញចិត្តចំពោះគំនិតថា បក្សកុម្មុយនីស្តកម្ពុជាត្រូវតែបន្តស្ថិតនៅក្រោមការមើលខុសត្រូវរបស់វៀតណាមបន្តទៅទៀត។

## ៤. បក្សកុម្មុយនីស្តកម្ពុជា

នៅខែកញ្ញា ឆ្នាំ១៩៦៦ ប៉ុល ពត បានប្តូរឈ្មោះបក្សទៅជាបក្សកុម្មុយនីស្តកម្ពុជា ដោយហេតុថា ប៉ុល ពត ចង់កាត់បន្ថយឥទ្ធិពលរបស់វៀតណាម និងងាកមករឹតចំណងមិត្តភាពជាមួយចិនវិញ។ គណៈកម្មាធិការមជ្ឈិមបក្សនៅពេលនោះរួមមាន៖ ប៉ុល ពត, នួន ជា, អៀង សារី, វន វ៉េត (អតីតគ្រូបង្រៀននៅវិទ្យាល័យចម្រើនវិជ្ជាក្នុងទីក្រុងភ្នំពេញ) និងសុន សេន។

ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៦០ សមាជិកថ្មីៗរបស់បក្សកុម្មុយនីស្តកម្ពុជា (ដែលសម្តេចព្រះ នរោត្តម សីហនុ ហៅថាខ្មែរក្រហម) បានកើនឡើងថែមទៀត។ ភាគច្រើននៃក្រុមនេះ រស់នៅតាមបណ្តោយព្រំដែនវៀតណាម ដែលជាតំបន់ដាច់ស្រយាលឆ្ងាយពីកងកម្លាំងរបស់សម្តេចព្រះ នរោត្តម សីហនុ។ មូលដ្ឋានធំរបស់បក្សពីឆ្នាំ១៩៦៦ ដល់ឆ្នាំ១៩៧០ ស្ថិតនៅខេត្តរតនគិរី។



មហាសន្និបាតបក្សកុម្មុយនីស្តកម្ពុជា ប្រារព្ធធ្វើនៅក្នុងទីក្រុងភ្នំពេញ។ បដាព្យួរនៅខាងលើ សរសេរថា៖ “ជយោ ពិធីចាត់តាំង កងទ័ព បដិវត្ត របស់បក្ស!”។ ចំណែកឯបដានៅក្រោមបន្ទាប់ សរសេរថា៖ “ជយោ បក្ស កុម្មុយនីស្ត កម្ពុជា ដ៏ ត្រឹមត្រូវ និង ភ្លឺស្វាង មហាអស្ចារ្យ! (១៩៧៥-១៩៧៨)។

ប្រភព៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

**តំបន់រំដោះរបស់ខ្មែរក្រហមខែឧសភា ឆ្នាំ១៩៧១**




**តំបន់រំដោះរបស់ខ្មែរក្រហម ក្នុងខែឧសភា ឆ្នាំ១៩៧១** (តំបន់ដែលមានផ្ទៃពណ៌ផ្កាឈូកចាស់ បង្ហាញពីតំបន់ដែលកាន់កាប់ដោយខ្មែរក្រហម ហើយតំបន់ដែលមានផ្ទៃពណ៌ផ្កាឈូកស្រាល បង្ហាញពីតំបន់គ្រប់គ្រងដោយរដ្ឋាភិបាលនៃរបបសាធារណរដ្ឋខ្មែរ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**តំបន់រំដោះរបស់ខ្មែរក្រហមខែឧសភា ឆ្នាំ១៩៧២**




**តំបន់រំដោះរបស់ខ្មែរក្រហម ក្នុងខែឧសភា ឆ្នាំ១៩៧២** (តំបន់ដែលមានផ្ទៃពណ៌ផ្កាឈូកចាស់ បង្ហាញពីតំបន់ដែលកាន់កាប់ដោយខ្មែរក្រហម ហើយតំបន់ដែលមានផ្ទៃពណ៌ផ្កាឈូកស្រាល បង្ហាញពីតំបន់គ្រប់គ្រងដោយរដ្ឋាភិបាលនៃរបបសាធារណរដ្ឋខ្មែរ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**តំបន់រំដោះរបស់ខ្មែរក្រហមខែឧសភា ឆ្នាំ១៩៧៣**




**តំបន់រំដោះរបស់ខ្មែរក្រហម ក្នុងខែឧសភា ឆ្នាំ១៩៧៣** (តំបន់ដែលមានផ្ទៃពណ៌ផ្កាឈូកចាស់បង្ហាញពីតំបន់ដែលកាន់កាប់ដោយខ្មែរក្រហម ហើយ តំបន់ដែលមានផ្ទៃពណ៌ផ្កាឈូកស្រាល បង្ហាញពីតំបន់គ្រប់គ្រងដោយរដ្ឋាភិបាលនៃរបបសាធារណរដ្ឋខ្មែរ។

(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅខែមីនា ឆ្នាំ១៩៧០ ឧត្តមសេនីយ៍ លន់ នល់ និងសហការីរបស់ខ្លួនដែលនិយមអាមេរិក បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ពីព្រះប្រមុខរដ្ឋ ដោយជោគជ័យ។ មិនយូរប៉ុន្មានបន្ទាប់ពីនោះ កងកម្លាំងវៀតមិញ និងខ្មែរក្រហម បានកាន់កាប់តំបន់ជាច្រើននៅក្នុងប្រទេសកម្ពុជា។ ប្រជាជនរាប់ម៉ឺននាក់បានបដិសេធមិនគាំទ្ររដ្ឋាភិបាលសាធារណរដ្ឋខ្មែរដែលមានអាមេរិកជាខ្នងបង្អែករបស់លោកសេនាប្រមុខ លន់ នល់ ហើយបែរមកចូលរួមជាមួយខ្មែរក្រហម ដើម្បីនាំយកសម្តេចព្រះ នរោត្តម សីហនុ មកគ្រប់គ្រងអំណាចវិញ។ ក្នុងពេលនោះដែរ សម្តេចព្រះ នរោត្តម សីហនុ បាននិរទេសព្រះកាយទៅប្រទេសចិន។ ដោយមានការលើកទឹកចិត្ត និងជួយជ្រោមជ្រែងពីសំណាក់រដ្ឋាភិបាលចិន រដ្ឋាភិបាលវៀតណាមខាងជើង និងបក្សកុម្មុយនីស្តកម្ពុជាផង ព្រះអង្គបានបង្កើតរដ្ឋាភិបាលនិរទេសមួយមានឈ្មោះថា "រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា"[៩]។ សមាជិករបស់បក្សកុម្មុយនីស្តកម្ពុជា គឺជាសមាជិកនៃរដ្ឋាភិបាលនេះ។

សភាពការណ៍វិវដ្តទាំងនេះ បានផ្តល់ឱកាសយ៉ាងច្រើនដល់ក្រុមខ្មែរក្រហម។ វៀតណាមខាងជើង និងចិនគាំទ្រក្រុមខ្មែរក្រហម ហើយសម្តេចព្រះ នរោត្តម សីហនុ បានអំពាវនាវឱ្យប្រជាជនរត់ចូលព្រៃម៉ាគី (ព្រៃដែលអ្នកតស៊ូធ្វើបដិវត្តលាក់ខ្លួន) ជួយផ្តួលរំលំរដ្ឋាភិបាលរបស់សេនាប្រមុខ លន់ នល់។ ជាងនេះទៅទៀត ការទម្លាក់គ្រាប់បែកដ៏សន្ធឹកសន្ធាប់ទៅលើផ្លូវផ្គត់ផ្គង់សម្ភារនិងមូលដ្ឋាននានារបស់ក្រុមកុម្មុយនីស្ត ប្រព្រឹត្តឡើងដោយរបបសាធារណរដ្ឋខ្មែរ ក្រោមការជួយជ្រោមជ្រែងរបស់សហរដ្ឋអាមេរិក បានធ្វើឱ្យការគាំទ្រខ្មែរក្រហមពីសំណាក់ប្រជាជន មានសន្ទុះកាន់តែច្រើនឡើងៗ ហើយកម្លាំងទ័ពរបស់ខ្មែរក្រហមមានចំនួនកាន់តែកើនឡើងជាលំដាប់។

កងកម្លាំងកុម្មុយនីស្តវៀតណាម បានចូលកាន់តែជ្រៅទៅក្នុងប្រទេសកម្ពុជានៅឆ្នាំ១៩៧០ ហើយបានធ្វើការជាមួយខ្មែរក្រហមដើម្បីរើស និងហ្វឹកហ្វឺនទ័ពសម្រាប់កងកម្លាំងតស៊ូ ដែលបានកើនឡើងពីចំនួនប្រហែល៣ពាន់នាក់ក្នុងឆ្នាំ១៩៧០ ទៅចំនួន៤ម៉ឺននាក់ក្នុងឆ្នាំ១៩៧៣។ នៅលើសមរភូមិ ដោយមានជំនួយពីវៀតណាម ខ្មែរក្រហមបានទទួលជ័យជម្នះលើកងទ័ពរបស់សេនាប្រមុខ លន់ នល់ ជាបន្តបន្ទាប់។ នៅចុងឆ្នាំ១៩៧២ កងទ័ពវៀតណាមបានដកចេញពីកម្ពុជា ហើយបានប្រគល់បន្ទុកសំខាន់ៗនៃសង្គ្រាមនេះទៅឱ្យបក្សកុម្មុយនីស្តកម្ពុជាគ្រប់គ្រងវិញ។ ទោះជាយ៉ាងនេះក៏ដោយ ក៏ទីប្រឹក្សាវៀតណាមប្រហែលពីរឬបីពាន់នាក់ បានបន្តស្នាក់នៅធ្វើជាទីប្រឹក្សាផ្នែកបច្ចេកទេសតទៅទៀត។



ការសម្តែងសិល្បៈក្នុងតំបន់រំដោះរបស់ខ្មែរក្រហម ក្នុងថ្ងៃចូលឆ្នាំថ្មីនៅខេត្តក្រចេះ នៅឆ្នាំ១៩៧៥។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**ទាហាននៃកងវរសេនាតូចឆ័ត្រយោងខ្មែរទី១ នៃរបបសាធារណរដ្ឋខ្មែរ កំពុងជីកដីដាំបង្គោលស្លាកសញ្ញាលេខ «២៦» ដែលបញ្ជាក់ពីលេខកងពលរបស់ខ្លួន នៅរវាងឆ្នាំ១៩៧៥-១៩៧៩។** ប្រភព៖ ឡេះ កាសេម/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

ចាប់ពីខែមករាដល់ខែសីហាឆ្នាំ១៩៧៣ របបសាធារណរដ្ឋខ្មែរដែលមានអាមេរិកជាអ្នកផ្គត់ផ្គង់គ្រឿងសព្វាវុធ បានទម្លាក់គ្រាប់បែកប្រមាណកន្លះលានតោនមកលើប្រទេសកម្ពុជា ហើយធ្វើឱ្យប្រជាជនកម្ពុជាប្រមាណជាង៣សែននាក់ស្លាប់បាត់បង់ជីវិត។ ការទម្លាក់គ្រាប់បែកនេះ បានបង្អាក់ដំណើរឆ្ពោះទៅរកជ័យជម្នះរបស់ខ្មែរក្រហម ហើយក្នុងពេលនោះដែរ មនុស្សជាច្រើននាក់ដែលមានការខឹងសម្បានឹងការទម្លាក់គ្រាប់បែក ឬដែលបានបាត់បង់សមាជិកគ្រួសាររបស់ខ្លួននោះ បានចូលរួមជាមួយបដិវត្តន៍ខ្មែរក្រហម។

កងទ័ពខ្មែរក្រហមមានភាពស្វាហាប់ និងគោរពវិន័យជាងកងទ័ពរបស់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ហើយក្រុមនេះអាចទ្រាំទ្រនឹងការខ្វះខាតម្ហូបអាហារ និងថ្នាំសង្កូវបាន។ ជាងនេះទៅទៀត "ខ្មែរហាណូយ"[១០] មួយចំនួនបានត្រឡប់ចូលមកក្នុងប្រទេសវិញ ដើម្បីជួយចលនាបដិវត្តន៍របស់ខ្មែរក្រហម។ យុវជននិងយុវនារីទាំងនេះត្រូវបានដាក់ឱ្យកាន់តំណែងថ្នាក់ទាបនៅទូទាំងប្រទេស និងក្រោយមកបន្ទាប់ពីទីប្រឹក្សាវៀតណាមភាគច្រើនបានវិលត្រឡប់ទៅកាន់ប្រទេសរបស់ខ្លួនវិញនៅចុងឆ្នាំ១៩៧២ អ្នកទាំងនេះត្រូវបានធ្វើឃាតជាសម្ងាត់ក្រោមបញ្ជាពីថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដែលចង់ឱ្យបក្សចេញផុតពីឥទ្ធិពលរបស់វៀតណាម។

នៅដើមឆ្នាំ១៩៧៣ ទឹកដីនៃប្រទេសកម្ពុជាប្រមាណ៨៥ភាគរយ ត្រូវធ្លាក់ក្រោមការត្រួតត្រារបស់ខ្មែរក្រហម ហើយកងទ័ពលោកសេនាប្រមុខ លន់ នល់ ស្ទើរតែគ្មានលទ្ធភាពធ្វើការប្រយុទ្ធបន្តទៅទៀត។ ទោះជាយ៉ាងនេះក៏ដោយ ក្រោមការជួយឧបត្ថម្ភពីអាមេរិក កងទ័ពលោកសេនាប្រមុខ លន់ នល់ នៅតែអាចមានលទ្ធភាពបន្តការប្រយុទ្ធជាមួយខ្មែរក្រហមអស់ រយៈពេលជាងពីរឆ្នាំបន្តមកទៀត។



**ប្រជាជនប្រមូលផ្តុំគ្នានៅខាងមុខវត្តកោះ ស្ថិតនៅកណ្តាលទីក្រុងភ្នំពេញ ដើម្បីអបអរសាទរ ការមកដល់ និងជ័យជម្នះរបស់ខ្មែរក្រហម នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ អ្នកថតរូបស្ថិតនៅលើរថយន្តទល់មុខនឹងក្រុមមនុស្ស។** ប្រភព៖ រ៉ូឡង់ នូវ៉ូ/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

ជំពូកទី៣

# ការឡើងកាន់អំណាចរបស់ខ្មែរក្រហម៖ ការជម្លៀសប្រជាជនចេញពីទីក្រុង, ការជម្លៀសដោយបង្ខំ និង ការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ

## ១. ការចូលកាន់កាប់ទីក្រុងភ្នំពេញ

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បានបញ្ចប់រាល់ការជៀតជ្រែកពីសំណាក់បរទេស ការទម្លាក់គ្រាប់បែក និងការប្រយុទ្ធមអាវុធដាក់គ្នានៃសង្គ្រាមស៊ីវិលរវាងខ្មែរនិងខ្មែរ ដែលអូសបន្លាយពេលប្រាំឆ្នាំនៅកម្ពុជា។ ប៉ុន្តែនៅថ្ងៃដដែលនេះ ទីក្រុងភ្នំពេញបានធ្លាក់ក្រោមការគ្រប់គ្រងរបស់កងកម្លាំងកុម្មុយនីស្តទាំងស្រុង។



**ទិដ្ឋភាពមនុស្សនៅលើដងវិថីក្នុងទីក្រុងភ្នំពេញ នាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ជនបរទេសស្នើទៅកាន់កាកបាទក្រហម ដើម្បីសុំភៀសខ្លួនចេញពីទីក្រុង និងប្រជាជនស្តាយរបស់របរផ្ទាល់ខ្លួន ចាកចេញពីទីក្រុងភ្នំពេញ តាមបញ្ជារបស់ខ្មែរក្រហម។ អ្នកខ្លះធ្វើដំណើរដោយថ្មើរជើង កង់, ម៉ូតូ, រទេះ និងរថយន្ត។**

ប្រភព៖ រ៉ូឡង់ នូវ៉ូ/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

កងកម្លាំងឧទ្ទាមដែលប្រកបដោយឯកសណ្ឋានពណ៌ខ្មៅនិងពណ៌អាចម៍សេះ បានធ្វើដំណើរចូលទីក្រុងពីគ្រប់ទិសទី។ ប្រជាជនភាគច្រើនដែលរស់នៅក្នុងទីក្រុងបាននាំគ្នាឈរតម្រៀបត្រាតាមដងផ្លូវ ហើយបានស្រែកអបអរសាទរនិងគ្រវីទង់ក្រណាត់ស។ ទោះបីជាយ៉ាងនេះក្តី ក៏មានមនុស្សជាច្រើននាក់ទៀត បានសម្ងំលាក់ខ្លួននៅក្នុងផ្ទះ ដោយព្រួយបារម្ភថាខ្លួនអាចនឹងត្រូវចាប់ខ្លួនឬបាញ់សម្លាប់ ព្រោះភ្លាមៗនោះ ខ្មែរក្រហមបានប្រកាសតាមវិទ្យុជាតិថា ខ្លួនមិនមែនមកដើម្បីចរចាជាមួយនរណាទាំងអស់ ហើយនឹងធ្វើការប្រហារជីវិតមន្ត្រីជាន់ខ្ពស់ និងមេញ្ញាការកងទ័ពរបស់រដ្ឋាភិបាលចាស់។[១១]

ជនបរទេសរាប់រយនាក់ និងជនជាតិខ្មែរមួយចំនួនបានរត់ទៅជ្រកកោននៅសណ្ឋាគារឡឺភ្នំ (បច្ចុប្បន្នជាសណ្ឋាគាររ៉ូយ៉ាល់) ដែលកាកបាទក្រហមអន្តរជាតិបានប្រកាសថាជាតំបន់អព្យាក្រឹត។ ក៏ប៉ុន្តែ នៅពេលដែលខ្មែរក្រហមចូលពិនិត្យបោសសម្អាតសណ្ឋាគារនេះ ជនបរទេស អ្នកកាសែត និងជនជាតិខ្មែរប្រហែល១០០នាក់ផ្សេងទៀត បានរត់ទៅជ្រកកោនក្នុងបរិវេណស្ថានទូតបារាំងវិញ។ ខ្មែរក្រហម បានបញ្ជាឱ្យជនជាតិខ្មែរទាំងអស់ដែលកំពុងស្ថិតនៅក្នុងស្ថានទូត ធ្វើដំណើរទៅកាន់ទីជនបទដើម្បីធ្វើការងារកសិកម្ម។ ជនបរទេសប្រមាណ ៦១០នាក់បានបន្តស្នាក់នៅក្នុងស្ថានទូតចំនួន២សប្តាហ៍ទៀត មុនពេលត្រូវបានដឹកជញ្ជូនតាមរថយន្តទៅកាន់ព្រំដែនថៃ។

ភ្លាមៗបន្ទាប់ពីរំដោះបានទីក្រុងភ្នំពេញ ខ្មែរក្រហមបានប្រហារជីវិតមេដឹកនាំជាន់ខ្ពស់បីរូប មន្ត្រីរាជការ និងនាយទាហានរាប់រយនាក់របស់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ។ មេដឹកនាំជាន់ខ្ពស់ទាំងបីរូបខាងលើ រួមមាននាយករដ្ឋមន្ត្រី ឡុង បូរ៉េត, ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ និង លន់ ណុន ដែលជាប្អូនប្រុសរបស់លោកសេនាប្រមុខ លន់ នល់។ លន់ នល់ បានចាកចេញពីប្រទេសកម្ពុជា នៅមុនព្រឹត្តិការណ៍នេះបន្តិចជាមួយនឹងប្រាក់សោធននិវត្តន៍ចំនួនមួយលានដុល្លារសហរដ្ឋអាមេរិក។ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានយល់ព្រមចំពោះការជម្លៀសអ្នកទាំងបីទៅកាន់សហរដ្ឋអាមេរិក ប៉ុន្តែអ្នកទាំងនេះបានបដិសេធមិនព្រមចាកចេញ។ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ បានសរសេរសំបុត្រ១ច្បាប់ ផ្ញើទៅកាន់ស្ថានទូតអាមេរិក ដែលមានសេចក្តីថា ៖

*ខ្ញុំសូមសម្តែងនូវការដឹងគុណយ៉ាងស្មោះស្ម័គ្រចំពោះសំបុត្រ និងការផ្តល់ជូនរបស់លោក ដើម្បីនាំខ្ញុំទៅកាន់សេរីភាព។ ប៉ុន្តែពុទ្ធោអើយ ខ្ញុំមិនអាចចាកចេញក្នុងសភាពដ៏កំសាកបែបនេះបានទេ។ ចំពោះលោក ហើយជាពិសេសចំពោះប្រទេសដ៏អស្ចារ្យរបស់លោក ខ្ញុំមិនដែលជឿមួយវិនាទីណាឡើយថា លោកដាច់ចិត្តបោះបង់ចោលមនុស្សដែលបានជ្រើសរើសយកសេរីភាព។ លោកបានបដិសេធមិនផ្តល់ការការពារដល់យើងខ្ញុំ ហើយយើងខ្ញុំមិនអាចធ្វើអ្វីបានទាំងអស់។ លោកបានចាកចេញ ហើយវាគឺជាសេចក្តីប្រាថ្នារបស់ខ្ញុំ ដែលថាលោកនិងប្រទេសរបស់លោក នឹងរកឃើញសុភមង្គលនៅក្រោមមេឃ។ ប៉ុន្តែសូមកត់ចំណាំឱ្យបានល្អថា ប្រសិនបើខ្ញុំត្រូវស្លាប់នៅទីនេះ នៅនឹងកន្លែង គឺនៅក្នុងប្រទេសរបស់ខ្ញុំដែលខ្ញុំស្រឡាញ់ ខ្ញុំក៏មិនដឹងធ្វើម៉េចដែរ ពីព្រោះមនុស្សយើងគ្រប់រូបកើតមកហើយ ត្រូវតែស្លាប់ទៅវិញនៅថ្ងៃណាមួយមិនខាន។ ខ្ញុំបានប្រព្រឹត្តកំហុសតែមួយគត់ គឺការជឿជាក់ទៅលើសហរដ្ឋអាមេរិក។ សូមទទួលនូវមនោសញ្ចេតនារាប់អានអំពីខ្ញុំ ឯកឧត្តមមិត្តជាទីស្រឡាញ់ មិត្តដ៏ស្មោះត្រង់និងរួសរាយរាក់ទាក់របស់ខ្ញុំ។ សិរិមតៈ*

## ២. ការជម្លៀសប្រជាជនចេញពីទីក្រុងនិងទីប្រជុំជន

ប្រជាជននៅតាមទីក្រុងនិងទីប្រជុំជនភាគច្រើនជឿជាក់ថា ខ្លួននឹងរស់នៅប្រកបដោយសុខសន្តិភាព ក្រោមការគ្រប់គ្រងរបស់មេដឹកនាំថ្មីរបស់ខ្លួន ហើយថាប្រជាជនគ្រប់រូបនឹងពួតដៃគ្នាធ្វើការដើម្បីបង្រួបបង្រួមជាតិ។ ផ្ទុយទៅវិញពីរឬបីម៉ោងបន្ទាប់ពីកាន់កាប់បានទីក្រុងភ្នំពេញ កងទ័ពខ្មែរក្រហមបានចាប់ផ្តើមបាញ់រះទៅលើអាកាសជាសញ្ញាបង្ខំប្រជាជនឱ្យចាកចេញពីទីក្រុង។ ប្រជាជនត្រូវបាន



**ប្រជាជនឈរនៅសងខាងផងវិថីក្នុងទីក្រុងភ្នំពេញ មើលក្បួនដង្ហែរ និងទទួលអបអរសាទរជ័យជម្នះរបស់ខ្មែរក្រហម នាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ទង់សបង្ហាញពីការចុះចាញ់របស់ទីក្រុងភ្នំពេញ។ លោក រ៉ូឡង់ នវ៉ូ ដែលជាអ្នកថតរូបនេះ បានឱ្យដឹងថា លោកស្ថិតនៅលើរថយន្តមួយផ្សេងទៀតដែលមិនសូវមានមនុស្ស។** ប្រភព៖ រ៉ូឡង់ នវ៉ូ/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

ជូនដំណឹង ជាទូទៅតាមរយៈស្នូរកាំភ្លើង ថាខ្លួនត្រូវតែចាកចេញពីផ្ទះសម្បែងរបស់ខ្លួនភ្លាមៗ។ ប្រជាជនភាគច្រើនដែលមានរថយន្តមានបំណងបើកបរចេញពីទីក្រុង ក៏ប៉ុន្តែដោយសារតែមិនមានកន្លែងចាក់ប្រេងឥន្ធនៈ យានជំនិះផ្សេងៗត្រូវបានទុកចោលនៅកណ្តាលហ្វូងមនុស្សយ៉ាងកកកុញ ឬត្រូវបានដកហូតដោយទាហានខ្មែរក្រហម។

ចលនាផ្លាស់ទីចេញពីទីក្រុងភ្នំពេញ នាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រព្រឹត្តទៅក្នុងស្ថានភាពចលាចល គួរឱ្យភ័យខ្លាច និងដោយបង្ខំ។ ប្រជាជនត្រូវបានប្រាប់ឱ្យធ្វើដំណើរចេញពីផ្ទះសម្បែងរបស់ខ្លួនដោយគ្មានការលើកលែង។ ការប្រយុទ្ធតតាំងគ្នារវាងកងកម្លាំង លន់ នល់ និងខ្មែរក្រហម កើតឡើងគ្រប់ទិសទី ព្រមទាំងបានរីករាលដាលកាន់តែគំហុក ដែលជាហេតុបណ្តាលឱ្យមានការកាត់ផ្តាច់ផ្លូវចេញពីទីក្រុង ជំរុញឱ្យសមាជិកនៃគ្រួសារនីមួយៗមិនអាចចាកចេញពីទីក្រុងជាមួយគ្នាបាន។ នៅគ្រប់ទីតាំងដែលប្រជាជនបានធ្វើដំណើរទៅដល់ គេតែងឃើញសាកសពនិងទ្រព្យសម្បត្តិផ្សេងៗដែលត្រូវបានបោះបង់ចោល។ ទីតាំងត្រួតពិនិត្យត្រូវបានបង្កើតឡើងយ៉ាងប្រទាក់ក្រឡាគ្នា ដើម្បីកំណត់អត្តសញ្ញាណនៃអតីតទាហាននិងមន្ត្រីរដ្ឋការ លន់ នល់។ ប្រជាជនជាច្រើនត្រូវលាក់បាំងអត្តសញ្ញាណរបស់ខ្លួន ដោយសារតែខ្លាចថានឹងត្រូវឃាត់ខ្លួន។

កងយោធា លន់ នល់ បានសម្លាប់អ្នកទោសដែលខ្លួនបានឃាត់ខ្លួនអស់ជាច្រើននាក់ ចំណែកឯខ្មែរក្រហមក៏បានឆ្លើយតបទៅវិញក្នុងទង្វើដូចគ្នា។ នរណាម្នាក់ដែលត្រូវកំណត់ថាជាសមាជិកនៃរបបមុន ត្រូវបានចាប់ខ្លួននិងសម្លាប់ភ្លាមៗ។ បញ្ញវន្ត អ្នកមានទ្រព្យស្តុកស្តម្ភ និងប្រជាជនជាច្រើនដទៃទៀតដែលគួរឱ្យសង្ស័យ ត្រូវបាននាំចេញមកម្ខាងនិងសម្លាប់ចោល។

ខ្មែរក្រហម បានបង្ខំអ្នករស់នៅទីក្រុងភ្នំពេញប្រហែលពីរលាននាក់ ដែលក្នុងនោះរួមបញ្ចូលទាំងអ្នកភៀសខ្លួនចូលទីក្រុងក្នុងអំឡុងពេលសង្គ្រាមចំនួនជាងមួយលាននាក់ផង ឱ្យចាកចេញទៅកាន់ទីជនបទ។ ត្រឹមតែក្នុងរយៈពេលមួយសប្តាហ៍ប៉ុណ្ណោះ ប្រជាជនក្នុងទីក្រុងភ្នំពេញ និងទីប្រជុំជនផ្សេងៗទៀត ត្រូវបានបណ្តេញចេញឱ្យទៅធ្វើការងារកសិកម្មនៅតាមតំបន់ជនបទ។

មិនមានការលើកលែងណាមួយទេនៅក្នុងការជម្លៀសនេះ។ អ្នកជំងឺត្រូវបានបណ្តេញចេញពីមន្ទីរពេទ្យ។ ជនភៀសខ្លួនរាប់ពាន់នាក់ ជាពិសេសកុមារ មនុស្សចាស់ជរា និងអ្នកជំងឺបានស្លាប់នៅតាមផ្លូវ។ ស្ត្រីមានផ្ទៃពោះជាច្រើនបានស្លាប់នៅពេលសម្រាលកូន ដោយសារតែគ្មានថ្នាំសង្កូវឬសេវាសុខាភិបាល។ ក្មេងៗបានវង្វេងបាត់ពីឪពុកម្តាយ។ ប្រជាជនភាគច្រើនមិនដឹងថា តើមានអ្វីកំពុងតែកើតឡើងនោះទេ។



**កងទ័ពខ្មែរក្រហមបានបង្ខំប្រជាជនដែលរស់នៅក្នុងទីក្រុងភ្នំពេញប្រមាណជិត ២លាននាក់ ឱ្យចាកចេញពីផ្ទះសម្បែងដោយអះអាងមិនពិតថា នឹងមានការទម្លាក់គ្រាប់បែកមកលើទីក្រុង។ ការជម្លៀសធ្វើឡើងដោយមិនមានការលើកលែងអ្វីឡើយ សូម្បីតែមនុស្សចាស់ អ្នកជម្ងឺ និងស្ត្រីមានផ្ទៃពោះ ក៏ត្រូវចាកចេញដែរ។ ខ្មែរក្រហម បានបំបែកក្មេងៗចេញពីឪពុកម្តាយ ហើយប្រជាជនរាប់ពាន់នាក់ បានស្លាប់ក្នុងអំឡុងពេលជម្លៀស ដោយសារតែមិនមានការព្យាបាលតាមលក្ខណៈវេជ្ជសាស្ត្រ និងមិនមានអាហារគ្រប់គ្រាន់។** (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

*ដូចដែលអ្វីដែលម្នាក់ៗបានរំពឹងទុក មនុស្សតែងចោទជាសំណួរថា៖ "តើយើងគួរទៅទីណា? តើយើងគួរយកអ្វីទៅខ្លះ? និង តើពេលណាយើងនឹងត្រឡប់មកវិញ?"*

ថ្វីត្បិតតែខ្មែរក្រហមផ្តល់ចម្លើយផ្សេងៗគ្នា មូលហេតុចម្បងដែលផ្តល់ឱ្យដោយទាហានភាគច្រើនគឺថា អាមេរិកនឹងទម្លាក់គ្រាប់បែកលើទីក្រុងភ្នំពេញ ហេតុនេះហើយ ប្រជាជនត្រូវតែចាកចេញ។ មូលហេតុមួយផ្សេងទៀតដែលបានលើកឡើងគឺ ខ្មែរក្រហមត្រូវបោសសម្អាតកងកម្លាំងសត្រូវឱ្យអស់ពីទីក្រុង។ ប្រជាជនភាគច្រើនត្រូវបានប្រាប់ឱ្យវេចខ្ចប់របស់ស្រាលៗ ពីព្រោះអ្នកទាំងនេះនឹងអាចត្រឡប់មកវិញនៅរយៈពេលបីថ្ងៃក្រោយ។ ប្រជាជនភាគច្រើនជឿជាក់លើការលើកឡើងខាងលើ និងចាកចេញទៅជាមួយនឹងអាហារ ទឹក ឬថ្នាំសង្កូវបន្តិចបន្តួចតែប៉ុណ្ណោះ។

ប្រជាជនភាគច្រើនបានបោះបង់ទ្រព្យសម្បត្តិដែលខ្លួនបានចំណាយពេលមួយជីវិតដើម្បីរកមក ចោលនៅឯទីក្រុងភ្នំពេញ ដោយគ្រាន់តែយកគ្រឿងអលង្ការ ប្រាក់កាស ឬរបស់មានតម្លៃមួយចំនួនមកជាប់ខ្លួន ដើម្បីប្រើប្រាស់ក្នុងពេលដែលមានតម្រូវការ។ គ្មាននរណាម្នាក់ដឹងទេថា ខ្លួននឹងត្រូវចាកចេញពីផ្ទះសម្បែងរយៈពេលប៉ុន្មាន ហើយអ្នកដែលមានមន្ទិលសង្ស័យថា ការចាកចេញនេះនឹងមានថេរវេលាលើសពីបីថ្ងៃ ក៏មិនបានដឹងដែរថា នោះគឺជាពេលវេលាដែលខ្លួនអាចមើលឃើញទិដ្ឋភាពទីក្រុងភ្នំពេញ (ទីក្រុង ឬស្រុកកំណើតរបស់ខ្លួន) ជាលើកចុងក្រោយ នៅមុនពេលបានវិលត្រឡប់មកវិញនៅរយៈពេលជាងបីឆ្នាំបន្ទាប់។

ប្រជាជនភាគច្រើនដែលបានចាកចេញពីទីក្រុង ត្រូវបានបញ្ជូនទៅកាន់ភូមិស្រុកនៅខាងក្រៅទីក្រុង ជាទីតាំងដែលអ្នកទាំងនោះត្រូវរស់នៅនិងធ្វើការអស់ជាច្រើនខែ។ ក្នុងករណីជាច្រើន ប្រជាជនទាំងនោះបានផ្លាស់ទីទៅកាន់ទីតាំងផ្សេងដែលសាច់ញាតិឬអ្នកមានទំនាក់ទំនងជាមួយខ្លួនរស់នៅ។ បន្ទាប់ពីប៉ុន្មានខែក្រោយមក ខ្មែរក្រហមបានផ្លាស់ប្រជាជនដោយបង្ខំ ជាទូទៅតាមរយៈរថយន្តនិងរថភ្លើង ទៅកាន់សហករណ៍ដែលត្រូវបានបង្កើតឡើងនៅពាសពេញផ្ទៃប្រទេស។

ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យ អៀង សារី ក្រោយមកបានពន្យល់ហេតុផលនៃការជម្លៀសថា បណ្តាលមកពីកង្វះខាតសម្ភារនិងមធ្យោបាយដឹកជញ្ជូនដើម្បីដឹកស្បៀងអាហារមកកាន់ទីក្រុង។ ប៉ុល ពត ពេលបំពេញទស្សនកិច្ចនៅប្រទេសចិន នៅខែតុលា ឆ្នាំ១៩៧៧ បាននិយាយថា មូលហេតុនៃការជម្លៀសប្រជាជន គឺដើម្បីបំបែក «ក្រុមចារកិច្ចរបស់ខ្មាំង»។

បន្ទាប់ពីការជម្លៀសបានបញ្ចប់ ទីក្រុងភ្នំពេញបានក្លាយទៅជា "ទីក្រុងខ្មោច" ដែលមានមនុស្សរស់នៅប្រហែល៤ម៉ឺននាក់ប៉ុណ្ណោះ។ អ្នកដែលបន្តស្ថិតនៅក្នុងទីក្រុង គឺសុទ្ធតែជាកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហម កងទ័ព និងកម្មកររោងចក្រ។ មានហាងលក់ទំនិញ (ផ្សារធំថ្មី) តែមួយគត់នៅក្នុងទីក្រុងដែលបើកលក់សម្រាប់តែអ្នកការទូត។ ខ្មែរក្រហម បានធ្វើឱ្យប្រទេសកម្ពុជាស្ថិតនៅឯកោពីពិភពលោកខាងក្រៅ។ ខ្មែរក្រហមមិនបើកទូលាយឱ្យជនបរទេសចូលមកក្នុងប្រទេស ហើយក៏មិនអនុញ្ញាតឱ្យប្រជាជនខ្មែរចាកចេញពីប្រទេសរបស់ខ្លួនដែរ។

ពីរ-បីថ្ងៃបន្ទាប់ពី ប៉ុល ពត និងកម្មាភិបាលជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា បានធ្វើដំណើរចូលមកកាន់ទីក្រុងដ៏ស្ងាត់ជ្រងំនេះ ក្រុមខ្មែរក្រហមបានរៀបចំពិធីបុណ្យរំឭកវិញ្ញាណក្ខន្ធចំពោះអ្នកដែលបានពលីជីវិតក្នុងអំឡុងពេលសង្គ្រាម។ នៅទីក្រុងប៉េកាំងឯណោះវិញ មានមនុស្សជាង១ម៉ឺននាក់ ព្រមទាំងមន្ត្រីជាន់ខ្ពស់ចិនជាច្រើនរូបទៀត បានប្រារព្ធពិធីជ័យជម្នះរបស់កងកម្លាំងកុម្មុយនីស្ត លើរដ្ឋាភិបាលដែលគាំទ្រដោយសហរដ្ឋអាមេរិក។ ទោះបីជាយ៉ាងណាក៏ដោយ ក៏សម្តេចព្រះនរោត្តម សីហនុ មេដឹកនាំមានតែឈ្មោះ របស់កងកម្លាំងបដិវត្តន៍មិនបានចូលរួមក្នុងពិធីនេះទេ។ ព្រះអង្គគង់នៅក្បែរព្រះមាតារបស់ព្រះអង្គ គឺព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ នារីរ័ត្នសិរីវឌ្ឍនា ដែលកំពុងតែប្រឈួនជាទម្ងន់នៅទីក្រុងប៉េកាំង។ ក្នុងអំឡុងពេលគង់នៅនិរទេសខ្លួននៅទីក្រុងប៉េកាំងតាំងពីឆ្នាំ១៩៧០ រដ្ឋាភិបាលកុម្មុយនីស្តចិន បានថ្វាយព្រះអង្គនូវការគាំទ្រទាំងផ្លូវនយោបាយនិងផ្លូវចិត្ត ព្រមទាំងភូមិគ្រឹះប្រកបដោយផាសុកភាពមួយខ្នងទៀតផង។ ក្រោយមក ព្រះអង្គបានធ្វើសេចក្តីថ្លែងការណ៍មួយកោតសរសើរអំពីជ័យជម្នះរបស់ខ្មែរក្រហម។

## ៣. ការជម្លៀសដោយបង្ខំ

គោលបំណងរួមរបស់បក្សកុម្មុយនីស្តកម្ពុជា គឺដើម្បីអនុវត្តបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សនៅក្នុងប្រទេសកម្ពុជាតាមរយៈគោលនយោបាយ "មហាលោតផ្លោះ" និងការពារបក្សកុម្មុយនីស្តប្រឆាំងនឹង "សត្រូវផ្ទៃក្នុងនិងសត្រូវខាងក្រៅ"។ វិធីសាស្រ្តដ៏ចម្បងមួយក្នុងការសម្រេចបានគោលបំណងនេះ គឺការផ្លាស់ទីប្រជាជនពីទីក្រុងនិងទីប្រជុំជនទៅកាន់ទីជនបទ ក៏ដូចជាពីទីជនបទមួយកន្លែងទៅកាន់មួយកន្លែងទៀត ម្តងហើយម្តងទៀត។



**ទីមួយពីខាងឆ្វេង៖ អៀង ធីរិទ្ធ រដ្ឋមន្ត្រីសង្គមកិច្ចនៃកម្ពុជាប្រជាធិបតេយ្យ។ ទីបួនពីខាងឆ្វេងដែលកំពុងនិយាយទៅកាន់មនុស្សក្នុងក្រុម៖ អៀង សារី ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ។ ខាងស្តាំបំផុត៖ វ៉ាង តុងស៊ីង អនុលេខាគណៈកម្មាធិការកណ្តាលបក្សកុម្មុយនីស្តចិន។ អ្នកដទៃទៀតមិនស្គាល់អត្តសញ្ញាណ។ ថតក្នុងអំឡុងពេលទស្សនកិច្ចរបស់ប្រតិភូចិន នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ១៩៧៨។** (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



**កម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហម និងគណៈប្រតិភូនៃសាធារណរដ្ឋប្រជាមានិតចិន នៅលើផ្លូវរថភ្លើងក្នុងអំឡុងចុងឆ្នាំ១៩៧៥។ ពីឆ្វេងទៅស្តាំ៖ វន វ៉េត ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីពាណិជ្ជកម្ម, ម៉ី ប្រាង (ចង្អុលមកមុខ) ប្រធានគណៈកម្មាធិការទំនាក់ទំនង, អៀង សារី ឧបនាយករដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីការបរទេស, ឧត្តមសេនីយ៍ តឹង យុនសាន (ពាក់អាវព័ណ៌សខាងក្រោយ អៀង សារី) ប្រធានអ្នកជំនាញការចិនប្រចាំកម្ពុជាប្រជាធិបតេយ្យ និង សមមិត្ត ស៊ូ (ពាក់វ៉ែនតាឈរខាងក្រោយឧត្តមសេនីយ៍ តឹង យុនសាន) អ្នកបកប្រែភាសា។** (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ស្ថិតនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនមួយភាគធំតែងតែត្រូវបានផ្លាស់ទីដោយបង្ខំពីផ្ទះសម្បែងរបស់ខ្លួនទៅកាន់ទីតាំងឆ្ងាយៗនៅតាមទីជនបទ។ ជួនកាល ខ្មែរក្រហមបានសំដៅដល់ទីតាំងទាំងនោះថាគឺជា "ទីតាំងដកពិសោធន៍ប្រជាជនថ្មី"។

គោលនយោបាយផ្លាស់ទីប្រជាជនដោយបង្ខំពីទីកន្លែងមួយទៅកាន់ទីកន្លែងដទៃទៀត (គឺជាការជម្លៀសដោយបង្ខំ) ដោយពុំមានជូនដំណឹងជាមុន សំណង ឬសិទ្ធិបដិសេធតាមផ្លូវច្បាប់ណាមួយនេះ បានបង្កជាទុក្ខវេទនានិងភាពលំបាកលំបិនដល់ប្រជាជននិងសហគមន៍យ៉ាងខ្លាំងក្លា។

ក្នុងរយៈពេលប្រមាណជាង៤៥ខែ របបខ្មែរក្រហមបានអនុវត្តការជម្លៀសដោយបង្ខំជាច្រើនលើកច្រើនសាលើប្រជាជន ពីតំបន់មួយទៅតំបន់មួយទៀត។ ក្រុមគ្រួសារត្រូវបែកបាក់។ ប្តីត្រូវបំបែកចេញពីប្រពន្ធ កូនៗត្រូវបំបែកចេញពីឪពុកម្តាយ ហើយមនុស្សជាទីស្រឡាញ់ជាច្រើនទៀតបានបាត់ខ្លួនសូន្យសុងដោយគ្មានដំណឹងអ្វីសោះ។ សមាជិកនៃរបប លន់ នល់ ជាច្រើន ក៏ដូចជាប្រជាជនជាច្រើនផ្សេងទៀតដែលត្រូវបានសង្ស័យថាមានការគាំទ្រ ឬមានទំនាក់ទំនងជាមួយនឹង "សត្រូវ" ត្រូវបានចាប់ខ្លួននិងសម្លាប់។

គោលនយោបាយជម្លៀសដោយបង្ខំរបស់បក្សកុម្មុយនីស្តកម្ពុជា ប៉ុនប៉ងបំបែកសម្ព័ន្ធភាពរបស់មនុស្សនិងអង្គភាពនានា ដែលបានគ្រប់គ្រងលើជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាភាគច្រើន នៅមុនពេលបដិវត្តន៍កើតមានឡើង។ បន្ថែមពីលើរដ្ឋាភិបាល លន់ នល់ ចំណុចដែលបានលើកឡើងខាងលើរួមបញ្ចូលនូវ សម្ព័ន្ធភាពគ្រួសារបែបប្រពៃណី អង្គភាពសាសនា សហគមន៍ជនជាតិភាគតិច និងខ្សែរយៈនៃបញ្ញវន្ត និងអ្នកជំនួញជាអាទិ៍។ ប្រសិនបើគ្មានសម្ព័ន្ធភាពឬអង្គភាពទាំងនេះទេ ក្រុមប្រឆាំងនឹងរបបខ្មែរក្រហមអាចនឹងមានភាពលំបាកក្នុងការប្រមូលផ្តុំគ្នាបះបោរ។ វាអាចនឹងមានភាពងាយស្រួលជាងក្នុងការបញ្ចុះបញ្ចូលប្រជាជនកម្ពុជា ជាពិសេសកុមារ ឱ្យមានភាពស្មោះត្រង់ចំពោះអង្គការ ប្រសិនបើការជម្លៀសដោយបង្ខំរារាំងមនុស្សទាំងនោះពីការស្មោះត្រង់ចំពោះឪពុកម្តាយ ពូជសាសន៍ សាសនា ឬអ្នកដឹកនាំសហគមន៍បែបប្រពៃណីផ្សេងៗ។

ជារួម របបខ្មែរក្រហមបង្កើតឱ្យមានការផ្លាស់ទីប្រជាជនក្នុងដំណាក់កាលទូទៅបី រួមមាន៖

- ការផ្លាស់ទីប្រជាជនចេញពីទីក្រុងនានា ដូចជាទីក្រុងភ្នំពេញ ក្រុងបាត់ដំបង ក្រុងសៀមរាប និងក្រុងពីរ-បីផ្សេងទៀត ចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ (រួមបញ្ចូលទាំងការផ្លាស់ទីតាមរយៈរថភ្លើង ដែលកើតមានឡើងនៅរយៈពេល៦ខែក្រោយមកទៀត)
- ការផ្លាស់ទីប្រជាជននៅតាមទីជនបទ ក្នុងភូមិភាគកណ្តាល ភូមិភាគនិរតី ភូមិភាគបស្ចិម ភូមិភាគបូព៌ា ចាប់តាំងពីចុងឆ្នាំ១៩៧៥ ទៅកាន់ផ្នែកដទៃទៀតនៃប្រទេសកម្ពុជា និង
- ការផ្លាស់ទីប្រជាជនចេញពីភូមិភាគបូព៌ានៅក្នុងឆ្នាំ១៩៧៧។

ការជម្លៀសដោយបង្ខំប្រព្រឹត្តឡើងលើប្រជាជនជាច្រើន អាចចាត់ទុកបានថាជាវិនាសកម្មចំពោះមនុស្សភាគច្រើន និងជាការចាប់ផ្តើមនៃរបបផ្តាច់ការថ្មីមួយសម្រាប់ប្រជាជនកម្ពុជាទាំងអស់។ ជាលទ្ធផលនៃការធំធាត់ឡើងនៅតាមទីជនបទ និងការផ្សារភ្ជាប់ខ្លួនទៅនឹងទីជនបទ ប្រជាជនខ្លះអាចសុំស្នាក់អាស្រ័យជាមួយសាច់ញាតិឬមិត្តភក្តិរបស់ខ្លួន។ ចំពោះប្រជាជនកម្ពុជាភាគច្រើន ជាពិសេសអ្នកដែលមានសាវតារជាអ្នកទីក្រុង ឬអ្នកមានជីវភាពមធ្យម/ធូរធារ ការជម្លៀសដោយបង្ខំអាចបង្កជាទុក្ខវេទនាយ៉ាងធ្ងន់ធ្ងរ ហើយប្រជាជនរាប់ពាន់នាក់បានបាត់បង់ជីវិត។



**គណៈប្រតិភូនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដឹកនាំដោយលេខាបក្សកុម្មុយនីស្តវៀតណាម ឡេ យន់ (កំពុងឱប សុន សេន) មកទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យ ក្នុងខែសីហា ឆ្នាំ១៩៧៥។ សុន សេន ទៅទទួលស្វាគមន៍ដំណើរទស្សនកិច្ចនេះនៅអាកាសយានដ្ឋាន ពោធិ៍ចិនតុង (បច្ចុប្បន្នគឺអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ)។ គណៈប្រតិភូវៀតណាមដទៃទៀតមិនស្គាល់អត្តសញ្ញាណ។** (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

តាមរយៈប្រវត្តិសាស្រ្ត រដ្ឋាភិបាលដែលគាបសង្កត់ បានប្រើប្រាស់ការជម្លៀសដោយបង្ខំ ដើម្បីនិរទេសប្រជាជនដែលខ្លួនមិនត្រូវការ ឬដើម្បីបន្ទន់ ដាក់ពិន័យ ឬគ្រប់គ្រងលើក្រុមមនុស្សណាមួយដែលរស់នៅក្នុងដែនដីរបស់ខ្លួន។ ទោះបីជាយ៉ាងណាក្តី ការជម្លៀសដោយបង្ខំត្រូវបានហាមឃាត់ដោយច្បាប់អន្តរជាតិបែបទំនើប ពីព្រោះតែ

ទង្វើនេះបំពានលើសិទ្ធិមនុស្សមូលដ្ឋាន ដែលរួមមានសិទ្ធិក្នុងការរស់រាននៅក្នុងផ្ទះសម្បែងរបស់បុគ្គលប្រកបដោយសុវត្ថិភាព និងកិត្តិយស។ រដ្ឋាភិបាលអាចជម្លៀសប្រជាជនចេញពីផ្ទះសម្បែងបាន លុះត្រាតែប្រជាជនយល់ស្របក្នុងការផ្លាស់ទីលំនៅដោយពុំមានការគាបសង្កត់ណាមួយ ឬក្នុងករណីមួយចំនួនផ្សេងទៀត នៅពេលដែលរដ្ឋាភិបាលផ្តល់ជាសំណងហិរញ្ញវត្ថុជូនប្រជាជនបានសមស្រប ក៏ដូចជាឱកាសទទួលការតវ៉ាតាមដំណើរការច្បាប់ដ៏ត្រឹមត្រូវចំពោះការជម្លៀសរបស់ខ្លួន។ ការជម្លៀសប្រជាជនដោយបង្ខំទ្រង់ទ្រាយធំ ប្រព្រឹត្តឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យ ពុំបានផ្តល់ជាសំណង ឬឱកាសទទួលបានយុត្តិធម៌អ្វីទាំងអស់ដល់ជនរងគ្រោះ។ គ្មានអ្វីជាមន្ទិលសង្ស័យឡើយចំពោះអ្នកជំនាញផ្នែកច្បាប់ដែលថា ការជម្លៀសដោយបង្ខំនេះគឺជាទង្វើខុសច្បាប់។

## ៤. ទួលពោធិ៍ជ្រៃ

នៅក្នុងឆ្នាំ១៩៧៥ ទួលពោធិ៍ជ្រៃគឺជាទីវាលធំមួយ ស្ថិតនៅកៀកទៅនឹងបឹងទន្លេសាប និងជាប់នឹងតំបន់ព្រៃនាម។ ទោះបីជាយ៉ាងណាក៏ដោយ នៅខែមេសា ឆ្នាំ១៩៧៥ ទីវាលនេះត្រូវបានគេស្គាល់ថាជាទីតាំងសម្លាប់យ៉ាងអសោច លើទាហាន លន់ នល់ និងប្រជាជនស៊ីវិលរាប់ពាន់នាក់។ ទីនេះជាទីតាំងនៃការសម្លាប់រង្គាលដ៏សោកសង្រេងមួយនៅក្នុងអំឡុងពេលនៃការជម្លៀសដោយបង្ខំទ្រង់ទ្រាយធំលើកដំបូងបំផុតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅពេលដែលខ្មែរក្រហមបានបណ្តេញប្រជាជនចេញពីទីក្រុង និងបាន "ចាត់ថ្នាក់" អតីតមន្ត្រី និងអ្នកគាំទ្ររបប លន់ នល់។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងយោធា លន់ នល់ នៅក្នុងខេត្តពោធិ៍សាត់ ទទួលបានការបង្គាប់តាមរយៈវិទ្យុពីរាជធានីភ្នំពេញឱ្យធ្វើការដាក់អាវុធចុះ។ នៅត្រឹមថ្ងៃទី១៩ ខែមេសា ខ្មែរក្រហមបានគ្រប់គ្រងលើខេត្តពោធិ៍សាត់ទាំងស្រុង។ ភ្លាមៗបន្ទាប់ពីនោះ ខ្មែរក្រហមបាននាំខ្លួនទាហាន លន់ នល់ តាមរថយន្តទៅកាន់ទីស្នាក់ការខេត្ត ដើម្បីជួបជាមួយនឹងមេដឹកនាំខ្មែរក្រហម។ ការប្រជុំនេះមានរយៈពេលបីឬបួនម៉ោង និងមានកងទាហាន និងមន្ត្រីបម្រើរដ្ឋការ ប្រមាណជាង៥០០នាក់ចូលរួម។

នៅក្នុងកិច្ចប្រជុំនេះ ទាហាន លន់ នល់ ទទួលបានវគ្គបំពាក់បំប៉ននយោបាយ ដើម្បីរៀបចំខ្លួនជួបជាមួយនឹងអង្គការនៅថ្ងៃបន្ទាប់។ ខ្មែរក្រហមក៏បានជំរុញឱ្យប្រជាជននៅក្នុងទីរួមខេត្តពោធិ៍សាត់ចាកចេញដែរ។ ទាហាន លន់ នល់ បានទទួលដំណឹងថា ខ្លួននឹងត្រូវបញ្ជូនទៅចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ ព្រមទាំងចូលគាល់សម្តេចព្រះ នរោត្តម សីហនុ។ ទាហានទាំងនោះក៏ត្រូវបានប្រាប់ទៀតថា ខ្លួនអាចទៅកាន់តំណែងចាស់វិញបន្ទាប់ពីវគ្គបណ្តុះបណ្តាល។ សមាសភាពដែលចូលរួមការប្រជុំ រួមមាន មន្ត្រីយោធា លន់ នល់ ដែលមានតំណែងជាអនុសេនីយ៍ទោ អនុសេនីយ៍ឯក និងឧត្តមសេនីយ៍។ បន្ទាប់ពីកិច្ចប្រជុំ ទាហាន លន់ នល់ ហាក់ដូចជាមានភាពរីករាយ ជជែកលេងជាមួយសាច់ញាតិខណៈពេលដែលកំពុងរង់ចាំ និងប្រាប់សាច់ញាតិថាខ្លួននឹងទៅសិក្សាព្រមទាំងជួបជាមួយព្រះមហាក្សត្រ។

តាមរយៈសក្ខីកម្មរបស់លោក សាត លឹម បន្ទាប់ពីការប្រជុំជាមួយខ្មែរក្រហម ទាហាន លន់ នល់ បានវិលត្រឡប់ទៅកាន់រថយន្តដែលដឹកខ្លួនទៅចូលរួមប្រជុំ។ រថយន្តទាំងនេះបានបើកសំដៅទៅកាន់ទួលពោធិ៍ជ្រៃ។ បើតាមសម្តីបុគ្គលមួយរូបទៀត គឺលោក អ៊ុង ឆាត ទាហាន លន់ នល់ បានស្ម័គ្រចិត្តឡើងជិះលើរថយន្តដោយខ្លួនឯង។ នៅឯបន្ទាយក្នុងភូមិពោធិ៍ ខ្មែរក្រហមបានបង្កើតជាទីតាំងត្រួតពិនិត្យនានា ដើម្បីរារាំងប្រជាជនក្នុងការធ្វើដំណើរទៅកាន់ទីកន្លែងនោះ។ ខ្មែរក្រហមអនុញ្ញាតឱ្យរថយន្តបរចូលម្តងតែមួយប៉ុណ្ណោះទៅក្នុងបន្ទាយ។

រថយន្តផ្ទុកពេញទៅដោយទាហាន លន់ នល់ បានចាកចេញពីបន្ទាយភូមិពោធិ៍ មួយម្តងៗ រៀងរាល់រយៈពេល២០នាទី។ ការលើកឡើងខ្លះបានអះអាងថា រថយន្តមានផ្ទុកទាំងទាហាន លន់ នល់ និងមន្ត្រីរដ្ឋការនានា។ ខ្មែរក្រហមមិនអនុញ្ញាតឱ្យរថយន្តបន្ទាប់ចាកចេញទៅកាន់ទួលពោធិ៍ជ្រៃទេ គឺត្រូវចាំរហូតទាល់តែឃើញរថយន្តដែលបានបរចេញទៅមុនត្រឡប់មកវិញ។ អ្នកភូមិបានកត់សម្គាល់ថា ទាហាន លន់ នល់ ហាក់ដូចជាគ្មានភាពខ្វាយខ្វល់អ្វីទេនៅក្នុងរថយន្តពេលដែលធ្វើដំណើរទៅកាន់ទួលពោធិ៍ជ្រៃ ពីព្រោះអ្នកទាំងនេះបានទទួលដំណឹងថាខ្លួននឹងបានជួបជាមួយនឹងអង្គការនិងព្រះមហាក្សត្រ។ យ៉ាងណាមិញ រថយន្តបានត្រឡប់មកវិញដោយទទេស្អាត។ អ្នកភូមិលើកឡើងថាបានឮស្នូររំសេវ និងស្នូរបំផ្ទុះកាំភ្លើងនៅក្បែរភូមិស្រុក។ ទាហាន លន់ នល់ ដែលត្រូវបានបញ្ជូនទៅកាន់ទួលពោធិ៍ជ្រៃ ត្រូវបានសម្លាប់។ គ្មានតួលេខច្បាស់លាស់ថាតើមានទាហាន លន់ នល់ ប៉ុន្មាននាក់ត្រូវបានសម្លាប់នៅទួលពោធិ៍ជ្រៃទេ មានតែតួលេខប៉ាន់ស្មានប៉ុណ្ណោះ គឺមានទាហានចំនួនចន្លោះពី ២ ០០០នាក់ រហូតដល់៨ ០០០នាក់។

ការសម្លាប់នៅទួលពោធិ៍ជ្រៃ បានប្រព្រឹត្តឡើងជាបន្តបន្ទាប់ ចាប់តាំងពីចុងឆ្នាំ១៩៧៥ រហូតដល់រវាងឆ្នាំ១៩៧៧ នៅស្របនឹងអំឡុងពេលដែលការសម្លាប់ទ្រង់ទ្រាយធំលើអតីតយោធា និងប្រជាជនស៊ីវិល ត្រូវបានប្រព្រឹត្តឡើង។



**ទាហាននិងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ឬរបប លន់ នល់ ថតក្នុងអំឡុងឆ្នាំ១៩៦០។ ទាហាននិងមន្ត្រីរដ្ឋការនៃរបប លន់ នល់ គឺជាមុខសញ្ញារបស់ខ្មែរក្រហម។ ប្រសិនបើខ្មែរក្រហមស៊ើបដឹងពីអត្តសញ្ញាណថា នរណាម្នាក់ជាទាហាន ឬមន្ត្រីរដ្ឋការរបស់ លន់ នល់ អ្នកនោះនឹងត្រូវយកទៅសម្លាប់ ហើយការសម្លាប់រង្គាលលើក្រុមនេះ បានកើតឡើងនៅទួលពោធិ៍ជ្រៃ ក្នុងខេត្តពោធិ៍សាត់។** ប្រភព៖ ឡេះ កាសេម/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

ជំពូកទី៤

# ការឡើងកាន់អំណាចរបស់ខ្មែរក្រហម៖ ការលើកឡើងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នករស់រានមានជីវិត

## ១. ការលើកឡើងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងអ្នករស់រានមានជីវិតដទៃទៀត ស្តីអំពីការជម្លៀសប្រជាជនដោយបង្ខំ

លោកស្រី យឹម សុវណ្ណ ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការស្តាប់ក្តីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងសំណុំរឿង ០០២ បានពិពណ៌នាអំពីការជម្លៀសប្រជាជនដោយបង្ខំ ចេញពីទីក្រុងភ្នំពេញ ថា៖

> *នៅម៉ោងប្រហែល ៣រសៀល ដំបូងឡើយ ឪពុករបស់លោកស្រីបានបដិសេធក្នុងការចាកចេញ។ "ខ្មែរក្រហមកាន់កាំភ្លើងវែងមកជាមួយ ព្រមទាំងអង្ករមួយចំនួន រួចប្រាប់ឪពុកខ្ញុំថា៖ "មិត្តត្រូវតែចាកចេញ អាមេរិកាំងនឹងទម្លាក់គ្រាប់បែកលើទីក្រុងភ្នំពេញ។" ឪពុករបស់ខ្ញុំប្រញាប់ប្រញាល់រៀបចំកាបូបនិងប្រមែប្រមូលស្រូវខ្លះនៅមុនពេលចាកចេញពីទីលំនៅរបស់យើង។ ពេលនោះ ជាការចាកចេញដ៏សោកសង្រេងមួយ។"*

លោកស្រី សុវណ្ណ ក៏បានបន្តទៀតថា “អ្នកទាំងនោះសុទ្ធតែមានប្រដាប់អាវុធ ទាំងស្រី ទាំងប្រុស។ គេស្លៀកពាក់ព័ណ៌ខ្មៅនិងបង់ក្រមាព័ណ៌ក្រហម។ អ្នកទាំងនោះបានប្រាប់ក្រុមគ្រួសាររបស់លោកស្រីថា “អង្គការថ្នាក់លើ” បានស្នើឱ្យគ្រួសារលោកស្រីចាកចេញ និងត្រូវធ្វើដំណើរទៅកាន់ភូមិកំណើតរបស់ខ្លួនរយៈពេលបីថ្ងៃ បើមិនអ៊ីចឹងទេអាមេរិកាំងនឹងទម្លាក់គ្រាប់បែកនិងសម្លាប់គ្រួសាររបស់លោកស្រី។ ទាហានទុកពេលឱ្យយើងត្រឹមតែ១៥នាទីប៉ុណ្ណោះ ដើម្បីចាកចេញ ហើយបើយើងបដិសេធ វិធានការណ៍ផ្សេងៗនឹងត្រូវធ្វើឡើង។”

លោកស្រីបានពិពណ៌នាថាខ្លួនបានឃើញទាហានបាញ់បំបែកមេសោជាប់នឹងទ្វារផ្ទះមួយខ្នងក្នុងផ្សារអូរឬស្សី។ បន្ទាប់មកទាហានបានបាញ់មនុស្សម្នាទាំងឡាយដែលបានរត់ចេញពីក្នុងផ្ទះនោះ។ លោកស្រីក៏បានឃើញទាហាន លន់ នល់ រងរបួសនៅឯមន្ទីរពេទ្យយោធាក្នុងបុរីកីឡា ដែលជាកម្មសិទ្ធិរបស់យោធា លន់ នល់។ ទាហានខ្មែរក្រហមបានរុញទម្លាក់ទាហានទាំងនោះពីលើគ្រែ។ អ្នករងរបួសខ្លះ ត្រូវបានបញ្ជូនទៅឱ្យសាច់ញាតិ ចំណែកអ្នកឯទៀតត្រូវបានទុកចោលដល់ស្លាប់។ អ្នកដែលបានស្លាប់ក្នុងអំឡុងពេលជម្លៀស ពុំទទួលបានការរៀបចំបុណ្យសពទេ។ សាកសពត្រូវបានទម្លាក់ទៅក្នុងប្រឡាយ ឬទុកចោលនៅតាមផ្លូវ។

លោក ជុំ សុខា ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងសំណុំរឿង០០២ បានផ្តល់សក្ខីកម្មអំពីដំណើរចាកចេញពីទីក្រុងរបស់ក្រុមគ្រួសារលោក៖

សុខា រៀបរាប់ថា បានឃើញសាកសពនៅតាមបណ្តោយផ្លូវ អមជាមួយនឹងភ្លើងហ្វារបស់យានយន្ត ក៏ដូចជាផ្ទះដែលឆេះហុយផ្សែង ព្រមទាំងសាកសពដែលត្រូវបានដុតនៅជុំវិញអាកាសយានដ្ឋានពោធិ៍ចិនតុង និងនៅខាងមុខនាយកដ្ឋានដឹកជញ្ជូន។

លោក សុខា បានបកស្រាយថា រូបលោក ម្តាយរបស់លោក ប្អូនស្រី ឪពុកមា និងជីដូនជីតា បានធ្វើដំណើរដោយថ្មើរជើងទៅមុន ចំណែកឯឪពុកនិងឪពុកមាលោកម្នាក់ទៀត មកតាមក្រោយបន្ទាប់ពីក្រុមលោកធ្វើដំណើរបានប្រមាណ២គីឡូម៉ែត្រ។ ឪពុករបស់លោកបានប្រាប់លោកថា ខ្លួនគាត់ស្ទើរតែនឹងត្រូវឃុំខ្លួន តែគាត់សម្គាល់ឃើញថាមនុស្សម្នាត្រូវបានចងភ្ជាប់គ្នាជាខ្សែ គាត់ក៏បានគេចខ្លួន និងប្រាប់ក្រុមគ្រួសារឱ្យប្រញាប់ចេញទៅ។ នេះបើតាមសក្ខីកម្មរបស់លោក សុខា។ លោកបានពិពណ៌នាអំពីស្ថានភាពស្នាក់នៅរបស់ក្រុមគ្រួសារលោកនៅឯវត្តអង្គក្រូចរយៈពេលប៉ុន្មានថ្ងៃ ដោយសារតែប្អូនស្រីរបស់លោកហើមជើងនិងមិនអាចដើរបាន។ ក្រោយមក អង្គការបានប្រាប់ក្រុមគ្រួសាររបស់លោកថា គាត់ទាំងអស់ត្រូវបានអនុញ្ញាតឱ្យត្រឡប់ទៅកាន់ភូមិកំណើតដើមរបស់ខ្លួន គឺនៅភូមិត្បូងក្តី ខេត្តព្រៃវែងវិញ។

ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ បានបកស្រាយទៀតថា ប្អូនស្រីរបស់លោកនៅតែមានបញ្ហាជើង ដូច្នេះម្តាយរបស់លោកបានដោះដូរគ្រឿងអលង្ការនិងសម្លៀកបំពាក់ល្អៗមួយចំនួន ដើម្បីអាចឱ្យប្អូនស្រីលោកធ្វើដំណើរតាមរទេះ។ បន្ទាប់មកក្រុមគ្រួសារនេះបានមកដល់ភូមិមួយនៅក្បែរទន្លេបាទី រួចក៏បានសម្រាកនៅទីនេះមួយយប់ នៅមុនពេលបន្តដំណើរទៅកាន់ភូមិបឹងខ្វក។

លោក សុខា បានបន្តទៀតថា បន្ទាប់ពីចំណាយពេលជាងមួយខែធ្វើដំណើរចេញពីទីក្រុងភ្នំពេញ ក្រុមគ្រួសារលោកបានមកដល់ភូមិត្បូងក្តី ខេត្តព្រៃវែង ដែលជាភូមិកំណើតរបស់ក្រុមគ្រួសារលោក។

ស៊ឹម សុត ហៅ កុយ គឺជាអ្នករស់រានមានជីវិតម្នាក់ពីរបបខ្មែរក្រហម ព្រមទាំងធ្លាប់ជាអ្នករត់ស៊ីក្លូនៅក្នុងទីក្រុងភ្នំពេញ បានរំឭកឡើងវិញពីហេតុការណ៍ដែលគាត់បានឃើញក្នុងអំឡុងពេលជម្លៀស៖

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបានចេញដំណើរទៅប្រកបរបរដូចធម្មតា។ ពីរ-បីម៉ោងក្រោយមក ខ្ញុំឃើញកងទ័ពខ្មែរក្រហមធ្វើដំណើរមកភ្នំពេញ។ ប្រជាជនបានចេញមកក្រៅហើយគ្រវីក្រណាត់សនិងអាវសស្វាគមន៍ខ្មែរក្រហម។ ភ្លាមៗនោះ ពួកគេបានបាញ់កាំភ្លើងទៅលើអាកាស បញ្ជាប្រជាជនឱ្យចាកចេញពីទីក្រុងដោយអះអាងថាអាមេរិកាំងនឹងមកទម្លាក់គ្រាប់បែក។ ដូចអ្នកឯទៀតដែរ ខ្ញុំបានប្រញាប់ប្រញាល់ធ្វើដំណើរចាកចេញនៅម៉ោងដប់



ពីឆ្វេងទៅស្តាំ៖ ប្អូនជីដូនមួយរបស់ ម៉ុក ស៊ិនហៀង, ម៉ុក ស៊ិនហុង, ម៉ុក ស៊ិនអ៊ូ និងបងប្អូនជីដូនមួយម្នាក់ទៀត។ ថតនៅសួនផ្កាក្នុងផ្ទះរបស់ ម៉ុក ស៊ិនហៀង ក្នុងខណ្ឌទួលគោក ក្រុងភ្នំពេញ ក្នុងឆ្នាំ១៩៧១។ ម៉ុក ស៊ិនហុង និង ម៉ុក ស៊ិនអ៊ូ បានស្លាប់ដោយភាពអត់ឃ្លាននៅឆ្នាំ១៩៧៦ ក្នុងខេត្តពោធិ៍សាត់។ ម៉ុក ស៊ិនហៀង បានរស់រានមានជីវិតពីរបបខ្មែរក្រហម។ ក្នុងឆ្នាំ២០០៦ ម៉ុក ស៊ិនហៀង បានដាក់ពាក្យបណ្តឹងទៅសាលាក្តីខ្មែរក្រហម ហើយលោកស្រី ក៏បានសរសេរអត្ថបទមួយ មានចំណងជើងថា «ខ្ញុំត្រូវការយុត្តិធម៌» ចេញផ្សាយនៅក្នុងកាសែតភ្នំពេញប៉ុស្តិ៍ នាថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤។

ប្រភព៖ ម៉ុក ស៊ិនហៀង/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

ជាមួយបងប្រុសខ្ញុំ មិត្តភក្តិនៅវត្តជាមួយខ្ញុំនិងលោកសង្ឃ។ នៅលើផ្លូវដ៏ណែនណាន់តាន់តាប់ ខ្ញុំឮសូរសំឡេងមនុស្សម្នាស្រែកហៅរកឪពុកម្តាយបងប្អូន និងសម្រែកក្មេងៗយំទាររកបាយ។ ខ្មែរក្រហមបានរឹបអូសយករបស់របរប្រជាជន។ អ្នកដែលជំទាស់មិនព្រមឱ្យនឹងត្រូវសម្លាប់ឬក៏ចាប់ខ្លួនយកទៅបាត់។ នៅពេលដែលខ្ញុំកំពុងតែដើរ ទ័ពខ្មែរក្រហមស្រីម្នាក់បានទាញកអាវខ្ញុំហើយសួរខ្ញុំថាជាអតីតទាហានឬ? គាត់រុញខ្ញុំថយក្រោយវិញ នៅពេលដែលខ្ញុំប្រាប់គាត់ថាខ្ញុំជាកូនសិស្ស។ ខ្ញុំក៏បានបន្តដំណើររបស់ខ្ញុំទៅក្រុងតាខ្មៅ។ នៅតាមផ្លូវ ខ្ញុំបានឃើញសាកសពដែលទើបតែហើមថ្មីៗជាច្រើន។ បន្ទាប់ពីបានធ្វើដំណើរអស់រយៈពេលបីថ្ងៃ ខ្ញុំបានមកដល់ខេត្តតាកែវ។

សូ រី អ្នកភូមិរស់នៅខេត្តតាកែវ ក៏បានរំឭកពីព្រឹត្តិការណ៍ជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែរ។ ប្តីរបស់ សូ រី គឺជាទាហានរបស់របបសាធារណរដ្ឋខ្មែរ ដែលត្រូវរបួសភ្លៅក្នុងពេលប្រយុទ្ធជាមួយកងទ័ពខ្មែរក្រហម ហើយត្រូវបានបញ្ជូនមកកាន់មន្ទីរពេទ្យនៅភ្នំពេញ។ សូ រី បានរៀបរាប់ ថា ៖

កងទ័ពខ្មែរក្រហម បានបញ្ជាឱ្យពួកយើងចេញពីទីក្រុង។ ខ្ញុំនិយាយថា “ខ្ញុំមិនអាចទៅបានទេ ព្រោះខ្ញុំកំពុងមានផ្ទៃពោះ ហើយប្តីខ្ញុំមានរបួសធ្ងន់”។ ពួកគេនៅតែបង្ខំឱ្យយើងចាកចេញ។ ពួកយើងយំអើយយំ ព្រោះប្តីខ្ញុំដើរមិនរួច។ បន្ទាប់មកយើងរកបានរទេះមួយ។ ខ្ញុំគ្រាហ៍ប្តីខ្ញុំដាក់លើ រទេះ ហើយបានដាក់ក្រមាទាក់អូសប្តីខ្ញុំបន្តទៀត។ យើងចង់ទៅតាកែវ តែខ្មែរក្រហមបានបង្ខំឱ្យយើងធ្វើដំណើរទៅមុខបន្តទៀតតាមផ្លូវជាតិលេខ៥។ យើងឆ្លងកាត់ព្រែកក្តាម ហើយក៏ឈប់ដើម្បីដាំបាយហូប។ ពេលហូបបាយហើយគេប្រាប់យើងឱ្យទៅមុខទៀត។ ខ្ញុំអូសរទេះឡើងរលោកក្រលៀនអស់ហើយ។ នៅតាមផ្លូវ ប្តីខ្ញុំត្រូវគេចាប់យកទៅសម្លាប់ចោល។ ខ្ញុំយំខ្លាំងណាស់ ប៉ុន្តែមិនដឹងធ្វើយ៉ាងម៉េច។ ខ្ញុំបានទៅដល់ស្រុកចម្ការលើ ខេត្តកំពង់ចាម។ មួយខែក្រោយមក ខ្ញុំឆ្លងទន្លេបានកូនស្រីមួយ។

លោកស្រី ឡាយ ប៊ុននី ដើមបណ្តឹងរដ្ឋប្បវេណីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងសំណុំរឿង០០២ ក៏បានផ្តល់សក្ខីកម្មស្តីពីការជម្លៀសដោយបង្ខំចេញពីទីក្រុងភ្នំពេញដែរ៖

*ទាហានខ្មែរក្រហមបានប្រាប់ប្រជាជនឱ្យចាកចេញតាមវិធីសាស្ត្រដែលគេអាចធ្វើទៅបាន នេះបើតាមសក្ខីកម្មរបស់លោកស្រី ប៊ុននី។ ខ្មែរក្រហមមិនបានប្រាប់ប្រជាជនថារបស់របរអ្វីដែលគេគួរយកទៅតាមខ្លួនទេ។ ក្រុមគ្រួសាររបស់លោកស្រី មិនបានយកអង្ករទៅតាមទេ លោកស្រីលើកឡើង។ ក្រុមគ្រួសារលោកស្រី យកទៅតែប្រាក់កាស ដែលខ្លួនគិតថាអាចប្រើប្រាស់បាននៅតាមផ្លូវ។ លោកស្រីបន្ថែមទៀតថា ទាហានខ្មែរក្រហម មិនបានប្រាប់លោកស្រីទេថាប្រាក់កាសគ្មានប្រយោជន៍ទេ។ លោកស្រី "ប្រែជាអស់សង្ឃឹម" នៅពេលលោកស្រីបានដឹងរឿងនេះនៅតាមផ្លូវ។*

*មនុស្សម្នាដែលមិនអាចធ្វើដំណើរដោយខ្លួនឯងបាន ដូចជា អ្នកជំងឺដែលសម្រាកនៅមន្ទីរពេទ្យ "ត្រូវបានរុញដោយប្រើប្រាស់គ្រែអ្នកជំងឺរបស់មន្ទីរពេទ្យ ឬសែងដោយស្នែងសែង ឬអង្រឹង។ អ្នកខ្លះឈឺធ្ងន់ ត្រូវជិះលើខ្នងម្នាក់ទៀតដែលអាចដើរបាន។" លោកស្រីបានបន្តទៀតថា ប្រជាជនដែលត្រូវជម្លៀសអាចឮសម្រែកថ្ងូររបស់អ្នកសម្រាលកូននៅតាមដងផ្លូវ ហើយនៅទីបំផុតអ្នកដែលត្រូវជម្លៀសទាំងនោះក៏រកបានឆ្មបម្នាក់មកជួយសម្រាលកូនរបស់ស្ត្រីជាម្តាយ។*

លោកស្រី ប៊ុននី ត្រូវបានជម្លៀសដោយបង្ខំ ជាមួយនឹងកូនស្រីអាយុ៥ឆ្នាំម្នាក់របស់លោកស្រី។ លោកស្រីបានលើកឡើងអំពីជោគវាសនារបស់កូនស្រីអាយុ៥ឆ្នាំរូបនោះថា៖

*នៅពេលដែលយើងបានទៅដល់ស្រុកខ្សាច់កណ្តាល កូនស្រីរបស់ខ្ញុំបានធ្លាក់ខ្លួនឈឺអស់រយៈពេលប៉ុន្មានថ្ងៃមកហើយ។ នាងរាករូសយ៉ាងខ្លាំង... ខ្ញុំត្រូវបានគេបង្គាប់ឱ្យរកស្លឹករុក្ខជាតិមកព្យាបាលជំងឺរបស់នាង។ សមាជិកគ្រួសាររបស់ខ្ញុំម្នាក់ៗសុទ្ធតែក្តៅខ្លួន... នៅពេលដែលម្តាយមីងរបស់ខ្ញុំមកលេង ហើយឃើញស្ថានភាពនេះ គាត់ចង់យកកូនខ្ញុំទៅនៅជាមួយគាត់ដើម្បីព្យាបាលនាង... ខ្ញុំយល់ព្រមឱ្យគាត់យកនាងទៅ... ខ្ញុំជឿជាក់ថាកូនស្រីរបស់ខ្ញុំនឹងត្រូវព្យាបាល ឬមើលថែទាំបានត្រឹមត្រូវ ក្រោយមកខ្ញុំដឹងថានាងបានស្លាប់បាត់ទៅហើយ។*

លោកស្រី ប៊ុននី ក៏ត្រូវបានបង្ខំឱ្យផ្លាស់ទីម្តងទៀតពីស្រុកខ្សាច់កណ្តាលទៅខេត្តពោធិ៍សាត់ ដែលលោកស្រីបានពិពណ៌នាថា របបអាហារនៅទីនេះមានសភាពយ៉ាប់យ៉ឺន។ អ្នកដែលត្រូវជម្លៀសនានា "ហូបអាហារនៅតាមផ្លូវ ហើយអាហារទាំងនោះមិនល្អចំពោះយើងទេ វាបណ្តាលឱ្យពោះយើងមានបញ្ហា។"

## ២. ការលើកឡើងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលជាគ្រូពេទ្យ

លោក មាស សារ៉ាន់ គឺជាគ្រូពេទ្យមួយរូប ធ្វើការនៅក្នុងទីក្រុងភ្នំពេញ នាប៉ុន្មានថ្ងៃមុនពេលខ្មែរក្រហមទទួលបានជ័យជម្នះលើកងកម្លាំង លន់ នល់។ លោកបានបកស្រាយអំពីស្ថានភាពភ្លាមៗបន្ទាប់ពីការជម្លៀស។

*នៅបុរីកីឡានាពេលនោះ ខ្ញុំ (លោក មាស សារ៉ាន់) កំពុងធ្វើការនៅមន្ទីរវះកាត់មួយកន្លែង។ នៅទីនោះមានផ្នែកវះកាត់ចំនួនប្រាំ ដែលត្រៀមដើម្បីទទួលអ្នករងរបួស។ ផ្នែករបស់ខ្ញុំជាទីតាំងដំបូងបំផុតដែលទទួលអ្នករងរបួស។*

*នៅថ្ងៃទី១៦ ខែមេសា មានការទម្លាក់គ្រាប់បែកនៅផ្សារឱឡាំពិច។ ប្រជាជនរងរបួស និងត្រូវបានបញ្ជូនមកកាន់មន្ទីរព្យាបាលនោះ។ ខ្ញុំមិនអាចចាំបានអំពីចំនួនអ្នកជំងឺទេ ក៏ប៉ុន្តែផ្នែកមន្ទីរព្យាបាលនីមួយៗនៅតែបន្តទទួលអ្នករបួស ហើយគ្មានគ្រែគ្រប់គ្រាន់សម្រាប់ដាក់អ្នករបួសទេ។ ហេតុនេះ យើងត្រូវដាក់អ្នករបួសដែលត្រូវបញ្ជូនមកជាបន្តបន្ទាប់នៅផ្ទាល់នឹងដី។*

*នៅព្រឹកថ្ងៃទី១៧ ខែមេសា នៅពេលដែលយើងត្រូវបានប្រាប់ឱ្យចាកចេញ មនុស្សម្នានៅក្នុងមន្ទីរពេទ្យទាំងអស់ត្រូវបានប្រាប់ឱ្យដើរចេញពីទីនោះ។ អ្នកជំងឺដែលសម្រាកនៅលើគ្រែត្រូវបានរុញចេញ។*

លោក សារ៉ាន់ បានរៀបរាប់អំពីអារម្មណ៍របស់លោកចំពោះព្រឹត្តិការណ៍ទាំងនេះ ក្នុងនាមជាអ្នកជំនាញផ្នែកសុខាភិបាលមួយរូប៖

*ម្តាយខ្ញុំបានប្រាប់ខ្ញុំឱ្យធ្វើជាគ្រូពេទ្យម្នាក់ កុំធ្វើជាទាហាន។ ខ្ញុំបូជាជីវិតរបស់ខ្ញុំដើម្បីជួយអ្នកជំងឺ ដែលរួមទាំងទាហានខ្មែរក្រហមរងរបួសដែរ។ ខ្ញុំបានព្យាបាលទាហានខ្មែរក្រហមពីរនាក់។ នៅខណៈពេលដែលខ្ញុំត្រូវបានប្រាប់ឱ្យចាកចេញពីមន្ទីរពេទ្យ ខ្ញុំមានអារម្មណ៍ពិបាកពន់ពេក ពីព្រោះនៅពេលនោះ ខ្ញុំគិតថាអ្នកជំងឺនិងអ្នករបួស នឹងត្រូវបានជួយទំនុកបម្រុងនិងព្យាបាលយ៉ាងសមស្របនៅក្នុងអំឡុងពេលជម្លៀស ស្របពេលគ្នានោះ ខ្ញុំក៏មិនច្បាស់ថាអ្នកទាំងអស់នេះនឹងត្រូវបានព្យាបាលឱ្យសមស្របឬយ៉ាងណាទេ។ ខ្ញុំចាំបានថា មានក្មេងស្រីរងរបួសធ្ងន់ម្នាក់បានអង្វរខ្ញុំ សុំឱ្យខ្ញុំជួយនាង។ ខ្ញុំមិនអាចជួយអ្វីបានទាំងអស់។ ក្នុងនាមជាគ្រូពេទ្យ ខ្ញុំមានកាតព្វកិច្ចជួយដល់នាង ក៏ប៉ុន្តែខ្ញុំមិនអាចជួយអ្វីបានទាល់តែសោះនៅពេលនោះ។*

លោក សារ៉ាន់ បានបន្តថា៖

*"នៅពេលនោះ គ្មានបុគ្គលិកសុខាភិបាលឬទាហានខ្មែរក្រហម មកគ្រប់គ្រងមន្ទីរពេទ្យទេ។ ខ្ញុំមិនបានដឹងថាមានអ្វីកើតឡើងបន្ទាប់មកទៀតទេ ក៏ប៉ុន្តែនៅក្នុងអំឡុងពេលនោះ ខ្ញុំប្រាកដណាស់ថាគ្មាននរណាម្នាក់នៅទីនោះដើម្បីជួយដល់បុគ្គលិកសុខាភិបាលទេ នៅក្នុងពេលជម្លៀស។"*

លោក សារ៉ាន់ បានបន្តពិពណ៌នាអំពីអារម្មណ៍របស់លោក នៅពេលដែលត្រូវបង្ខំឱ្យចាកចេញពីអ្នកជំងឺរបស់ខ្លួន៖

*ក្នុងដែនសមត្ថកិច្ចខ្ញុំជាបុគ្គលិកសុខាភិបាលម្នាក់ វាជាកាតព្វកិច្ចរបស់ខ្ញុំ។ និយាយដោយស្មោះ ខ្ញុំមានអារម្មណ៍មិនស្រួលសោះក្នុងការទុកអ្នកជំងឺចោល។ នៅក្នុងចិត្តខ្ញុំ ប្រសិនបើខ្ញុំទុកអ្នកទាំងនេះចោល ទីមួយ អ្នកទាំងនេះអាចស្លាប់ ហើយទីពីរ ប្រសិនបើខ្មែរក្រហមចូលមកជួយ អ្នកទាំងនេះអាចនឹងបន្តរស់រាន។ ក៏ប៉ុន្តែ ថាតើខ្ញុំអាចជួយអ្នកទាំងនេះបានតាមសមត្ថភាពខ្ញុំយ៉ាងណា? ខ្ញុំមិនអាចជួយអ្នកទាំងនេះជាដុំកំភួនអ្វីទេ។ នៅពេលដែលខ្ញុំចាកចេញ ខ្ញុំមានអារម្មណ៍មិនស្រួលទាល់តែសោះ... ហើយខ្ញុំនៅតែគិតដល់ប្រពន្ធរបស់ខ្ញុំ។ ខ្ញុំមានអារម្មណ៍មិនស្រួលទេនៅពេលចាកចេញពីព្រោះខ្ញុំបានទុកអ្នកជំងឺចោល ជាពិសេសក្មេងស្រីម្នាក់នោះ ហើយរូបភាពរបស់ក្មេងស្រីនោះនៅតែបន្តលងបន្លាចខ្ញុំ។*

*ដំបូងឡើយ យើងត្រូវបានប្រាប់ឱ្យចាកចេញពីទីក្រុងភ្នំពេញចំនួនបីថ្ងៃ ហើយនៅក្នុងអំឡុងពេលបីថ្ងៃនេះ នៅតាមផ្លូវយើងជួបភាពលំបាកជាច្រើន។ បន្ទាប់មក យើងឆ្លងស្ពានមុនីវង្ស។ បន្ទាប់ពីរយៈពេលបីថ្ងៃបានកន្លងផុតទៅ ប្រជាជនក្នុងចំនួនច្រើននៅម្ខាងទៀតនៃស្ពាននៅឡើយ។ ខ្ញុំនៅបន្តរង់ចាំប្រពន្ធខ្ញុំ ហើយខ្ញុំនៅតែសង្ឃឹមថាខ្ញុំអាចត្រឡប់ទៅវិញបន្ទាប់ពីរយៈពេលបីថ្ងៃ។ ខ្ញុំព្រួយបារម្ភអំពីប្រពន្ធខ្ញុំយ៉ាងខ្លាំង ព្រោះគាត់មានផ្ទៃពោះ ហើយគាត់មិនស្គាល់ទីក្រុងភ្នំពេញច្បាស់ទេ។ បន្ទាប់ពីបីថ្ងៃកន្លងផុតទៅ ខ្ញុំបានស្វះស្វែងរកប្រពន្ធខ្ញុំ នៅក្នុងចំណោមហ្វូងមនុស្សដែលនៅពុំទាន់បានឆ្លងស្ពាន។ នៅទីបំផុត ខ្ញុំក៏អស់សង្ឃឹម ហើយខ្ញុំត្រូវស្វែងរកមធ្យោបាយនានាដើម្បីរកប្រពន្ធខ្ញុំនៅស្រុកកំណើតរបស់គាត់។ បន្ទាប់ពីបីថ្ងៃកន្លងផុត មានសេចក្តីប្រកាសតាមឧគ្ឃោសនសព្ទពីទីក្រុងភ្នំពេញ កោះហៅមន្ត្រីរដ្ឋការឱ្យត្រឡប់ទៅបំពេញការងារនៅទីក្រុងភ្នំពេញវិញ។ ខ្ញុំបានឃើញអ្នកខ្លះវិលត្រឡប់ទៅកាន់ទីក្រុងភ្នំពេញវិញ។ ក៏ប៉ុន្តែ អ្នកទាំងនោះទៅវិញតែឯកឯងដោយមិនបានយកសមាជិកក្រុមគ្រួសារទៅជាមួយទេ ហើយខ្ញុំក៏មិនដែលឃើញអ្នកទាំងនោះត្រឡប់មកវិញទេ។ ហេតុនេះ ខ្ញុំគិតថាច្បាស់ជាមានអ្វីកើតឡើង ហើយខ្ញុំមានការបារម្ភអំពីបញ្ហានោះ។*

គ្រូពេទ្យរូបនេះ បានបន្តបកស្រាយការដែលលោកបានឆ្លងផុតទីតាំងត្រួតពិនិត្យជាច្រើន នៅតាមផ្លូវទៅកាន់ស្រុករបស់ប្រពន្ធលោក។ លោកត្រូវបានសួរសំណួរនៅឯទីតាំងត្រួតពិនិត្យនីមួយៗ ហើយលោកបានដឹងនិងកុហកខ្មែរក្រហម ពីព្រោះលោកមិនជឿជាក់លើអ្នកទាំងនោះទេ។

*និយាយការពិតទៅ ខ្ញុំមិនជឿអ្នកទាំងនោះទេ។ ខ្ញុំមិនជឿ ពីព្រោះខ្ញុំបានឃើញប្រជាជនដែលត្រូវបានហៅទៅកាន់ទីក្រុងភ្នំពេញ មិនដែលត្រឡប់មកវិញទេ។ ខ្ញុំមិនជឿអ្នកទាំងនោះ ពីព្រោះអ្នកទាំងនោះបានលើកឡើងអំពីការទម្លាក់គ្រាប់បែកដែលជិតនឹងកើតមាន ហើយយើងត្រូវតែជម្លៀសចេញរយៈពេលត្រឹម៣ថ្ងៃប៉ុណ្ណោះ ក៏ប៉ុន្តែអ្នកទាំងនោះកុហក។ អ្វីៗទាំងនេះមិនបានកើតឡើងទេ។ ប្រាកដណាស់ ប្រសិនបើប្រជាជនត្រូវបានអនុញ្ញាតឱ្យត្រឡប់ទៅវិញ អ្នកទាំងនោះអាចនឹងរស់រានមានជីវិត។ ក៏ប៉ុន្តែវាមិនបានកើតឡើង... អ៊ីចឹង... ខ្ញុំសម្រេចចិត្តកុហកខ្មែរក្រហមទាំងនោះ។*

បន្តទៅកាន់ព្រឹត្តិការណ៍ដែលកើតមានឡើង បន្ទាប់ពីលោកបានទៅដល់ស្រុកកំណើតប្រពន្ធរបស់លោក លោក សារ៉ាន់ បាននិយាយថា៖

*នៅពេលដែលខ្ញុំទៅដល់ភូមិនោះ ម្ដាយក្មេកខ្ញុំយំ ពីព្រោះគាត់មិនបានឃើញប្រពន្ធរបស់ខ្ញុំ។ ខ្ញុំខ្លួនឯងក៏ខកចិត្តដែរ ព្រោះខ្ញុំមិនឃើញប្រពន្ធខ្ញុំ។*

## ៣. សាក្សីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ស្ដីពីការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ

លោក សាត លឹម អតីតទាហានខ្មែរក្រហម និងជាសាក្សីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងសំណុំរឿង០០២ បានផ្ដល់សក្ខីកម្មអំពីអ្វីដែលខ្លួនបានឃើញនិងឮ នៅពេលដែលលោកស្ថិតនៅក្នុងតំបន់ទួលពោធិ៍ជ្រៃ ក្នុងខែមេសា ឆ្នាំ១៩៧៥។

លោក សាត បានលើកឡើងថា ទាហាន លន់ នល់ ប្រមាណ៣ ០០០នាក់ត្រូវបានសម្លាប់ក្នុងអំឡុងពេលខ្មែរក្រហមវាយប្រហារលើទួលពោធិ៍ជ្រៃនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ លោក សាត បាននិយាយថា ទាហាន លន់ នល់ ដែលចុះចាញ់ បានលើកទង់សនៅឯបន្ទាយទួលពោធិ៍ជ្រៃ។ លោកជឿជាក់ថា មានទាហានប្រមាណ១០០នាក់បានស្លៀកសម្លៀកបំពាក់យោធា ហើយកម្ម៉ង់ដូប៉ុន្មាននាក់ផ្សេងទៀតបានស្លៀកសម្លៀកបំពាក់ស៊ីវិល។ បន្ទាប់ពីការចុះចាញ់ អាវុធទាំងអស់ត្រូវបានដកហូត ហើយអ្នកទាំងនោះត្រូវបានប្រមូលផ្ដុំជាក្រុម។ នៅទីបំផុត ទាហាន លន់ នល់ ត្រូវបានផ្ទេរពីសាលាខេត្តទៅកាន់ទួលពោធិ៍ជ្រៃដែលជាទីតាំងសម្លាប់។

លោកស្រី យឹម សុវណ្ណ ដើមបណ្ដឹងរដ្ឋប្បវេណីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងសំណុំរឿង០០២ បានផ្ដល់សក្ខីកម្មអំពីអ្វីដែលលោកស្រីបានឃើញនិងឮ ខណៈពេលលោកស្រីរស់នៅតំបន់ទួលពោធិ៍ជ្រៃនៅចុងឆ្នាំ១៩៧៦។ លោកស្រី យឹម តែងតែឆ្លងកាត់តំបន់ទួលពោធិ៍ជ្រៃនៅចុងឆ្នាំ១៩៧៦និងដើមឆ្នាំ១៩៧៧ ដើម្បីប្រមែប្រមូលស្បូវ។ ប្រជាជនក្នុងខេត្តពោធិ៍សាត់បានប្រាប់លោកស្រីថា ទាហាន លន់ នល់ ត្រូវបានសម្លាប់នៅទួលពោធិ៍ជ្រៃ។ លោកស្រី យឹម បានឮពីទាហានខ្មែរក្រហមថា ក្រោមបញ្ជារបស់ទាហានខ្មែរក្រហម ទាហាន លន់ នល់ ត្រូវបានផ្ទុកនៅក្នុងរថយន្តនិងបញ្ជូនទៅកាន់ទួលពោធិ៍ជ្រៃដើម្បីសម្លាប់នៅក្នុងខែមេសា ឆ្នាំ១៩៧៥។ អ្នកភូមិបានប្រាប់លោកស្រី សុវណ្ណ ថាការសម្លាប់បានកើតឡើងរយៈពេលប្រមាណ "កន្លះខែ"។ លោកស្រីបានឃើញពំនូកដីនៅទួលពោធិ៍ជ្រៃ ដែលលោកស្រីសន្និដ្ឋានថាជា "ការបិតបាំង"មួយ ហើយលោកស្រីក៏បានជួបជាមួយនឹងប្រជាជនមកពីសហករណ៍ក្បាលឈើពុក ដែលមានសាច់ញាតិត្រូវបានគេសម្លាប់នៅទីនោះ។ លោកស្រី រៀបរាប់ថាទីតាំងនោះជាទីវាលធំមួយកៀកទៅនឹងបឹងទន្លេសាបនិងស្ថិតនៅក្បែរព្រៃរនាម។ លោកស្រី យឹម បាននិយាយថា លោកស្រីមិនបានដឹងពីចំនួនជាក់ស្ដែងនៃទាហាន លន់ នល់ ដែលបានស្លាប់នៅទួលពោធិ៍ជ្រៃទេ ក៏ប៉ុន្តែអ្នកភូមិបានប្រាប់លោកស្រីថា គេបានឃើញរថយន្តមួយផ្ទុកមនុស្សពេញបរទៅកាន់ទួលពោធិ៍ជ្រៃ។ លោកស្រី បញ្ជាក់ថា អ្នកភូមិប្រាប់ថា មិនមែនមានតែទាហាន លន់ នល់ ទេ មន្ត្រីរដ្ឋការក្នុងរបបមុន ក៏ត្រូវបានប្រមូលផ្ដុំ និងបញ្ជូនទៅកាន់ទួលពោធិ៍ជ្រៃដើម្បីសម្លាប់ដែរ។

លោក អ៊ុង ឆាត អតីតទាហានខ្មែរក្រហម និងជាសាក្សីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងសំណុំរឿង០០២ បានផ្ដល់សក្ខីកម្មអំពីអ្វីដែលលោកបានឃើញនិងឮខណៈពេលលោករស់នៅតំបន់ទួលពោធិ៍ជ្រៃក្នុងអំឡុងខែមេសា ឆ្នាំ១៩៧៥។

លោក អ៊ុង បានពិពណ៌នាថាបានជួបជាមួយនឹងទាហាន លន់ នល់ នៅឯបន្ទាយភូមិពោធិ៍៖ "អង្គការ (របបខ្មែរក្រហម) អនុញ្ញាតឱ្យរថយន្តបរទៅកាន់ទីនោះម្ដងមួយប៉ុណ្ណោះ។ ខ្ញុំបានឃើញទ័ពខ្មែរក្រហមរាប់រយនាក់ឡោមព័ទ្ធទាហាន លន់ នល់ ទាំងនោះ។ ទ័ពខ្មែរក្រហមបានតាំងទីត្រួតពិនិត្យនៅចំទីតាំងនោះ និងហាមឃាត់ប្រជាជនពីការធ្វើដំណើរទៅកាន់តំបន់នោះ។ ខ្ញុំត្រូវបានបង្អាក់ និងសាកសួរដោយទាហានខ្មែរក្រហម ក៏ប៉ុន្តែដោយសារតែខ្ញុំមានលិខិតអនុញ្ញាត គេអនុញ្ញាតឱ្យខ្ញុំចូលទៅ។ នៅពេលខ្ញុំនៅទីនោះ ខ្ញុំបានឃើញខ្មែរក្រហម បើកផ្លូវឱ្យរថយន្តបរចេញពីទីនោះម្ដងមួយៗ រៀងរាល់រយៈពេល២០នាទី។ ខ្មែរក្រហមមិនអនុញ្ញាតឱ្យរថយន្តបន្ទាប់ដែលផ្ទុកដោយទាហាន លន់ នល់ ចេញទៅកាន់ទួលពោធិ៍ជ្រៃទេ លុះត្រាណាតែគេឃើញរថយន្តដែលបរចេញទៅមុន ត្រឡប់មកវិញដោយទទេ។"

ក្រោយមក លោក អ៊ុង បានទៅទីនោះជាមួយអ្នកភូមិពីរនាក់ ដើម្បីទៅមើលសាកសពនៅក្នុងបន្ទាយទួលពោធិ៍ជ្រៃ។

លោក បានរាយការណ៍ថា សាកសពរបស់ទាហានទាំងអស់ គ្រៀបគ្រានៅលើដី ដោយក្បាលនៃសាកសពនោះដាក់សំដៅទៅកាន់ទិសខាងជើង និងស្លៀកពាក់ស៊ីវិល ជាជាងឯកសណ្ឋានយោធា។ សាកសពទាំងនោះត្រូវបានចងភ្ជាប់គ្នាដោយខ្សែជាក្រុមពី ១៥ទៅ២០សាកសពក្នុងមួយក្រុម ហើយដៃទាំងពីរត្រូវបានចងទៅក្រោយ។

លោក ស៊ុំ អាឡាត់ អតីតទាហាន លន់ នល់ និងជាសាក្សីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងសំណុំរឿង០០២ បានផ្ដល់សក្ខីកម្មអំពីអ្វីដែលលោកបានឃើញនិងឮ នៅពេលលោកស្ថិតនៅក្នុងតំបន់ទួលពោធិ៍ជ្រៃ ក្នុងអំឡុងខែមេសា ឆ្នាំ១៩៧៥។ "នៅក្នុងកិច្ចប្រជុំនៅឯទីស្នាក់ការខេត្ត ខ្មែរក្រហមបានអប់រំយើងអំពីគោលនយោបាយផ្សះផ្សា និងការកសាងប្រទេសជាតិ និងជាចុងក្រោយ ខ្មែរក្រហមបាននិយាយឱ្យយើងជឿទុកចិត្ត ដោយលើកឡើងពីជំនួបស្វាគមន៍ (ជាមួយអង្គការ)។ នេះគឺជាវិធីសាស្ត្ររបស់ខ្មែរក្រហម ដើម្បីឱ្យយើងជឿជាក់។ ជាទូទៅ យើងមិនបានដឹងទេថាអ្វីនឹងកើតមានឡើងនៅពេលអនាគត ក៏ប៉ុន្តែយើងទាំងអស់គ្នាយល់ស្របទៅចូលរួមក្នុងជំនួបស្វាគមន៍នោះ។"



**វរសេនីយ៍ឯក ចេង ស៊ីយ៉ម៉ប៊ិន បម្រើការនៅក្នុងរបបសាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥)។ ខ្មែរក្រហមបានចាប់ខ្លួន និងសម្លាប់គាត់នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៦។**
ប្រភព៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

ទួលពោធិ៍ជ្រៃស្ថិតនៅរយៈចម្ងាយប្រមាណ២០គីឡូម៉ែត្រ។ នៅពេលដែលយើងប្រមូលផ្ដុំដើម្បីទៅកាន់ទួលពោធិ៍ជ្រៃ ជាទីតាំងជំនួបស្វាគមន៍របស់អង្គការប្រព្រឹត្តទៅ រូបខ្ញុំផ្ទាល់បានយល់ស្របទៅកាន់ទីនោះ ក៏ប៉ុន្តែរថយន្តដែលដឹកជញ្ជូនខ្ញុំទៅបានឈប់នៅពាក់កណ្ដាលទី។ ហេតុនេះ ការពិតទៅ ខ្ញុំចង់ឡើងជិះរថយន្តនោះ ក៏ប៉ុន្តែរថយន្តនោះពេញទៅហើយ។ ខ្ញុំត្រូវបានប្រាប់ឱ្យចាំជិះយានជំនិះបន្ទាប់។ ដូច្នេះ រូបខ្ញុំផ្ទាល់មិនបានទៅដល់ទួលពោធិ៍ជ្រៃទេ។ យ៉ាងណាមិញ បីថ្ងៃក្រោយមក ខ្ញុំបានឮថាអ្នកទាំងអស់នោះត្រូវបានសម្លាប់។

រំពឹងអំពីពាក្យថា អង្គការ យើងពុំធ្លាប់ឮអំពីអង្គការទេ នៅពេលដែលយើងឮអំពីទីតាំងរដ្ឋបាល ហេតុនេះហើយ យើងត្រូវបានគេប្រាប់ថា យើងនឹងបានទៅជួបរាក់ទាក់ជាមួយអង្គការ។ យើងចង់ជួបជាមួយអង្គការ ពីព្រោះយើងសង្ឃឹមថាយើងអាចផ្សះផ្សាជាមួយគ្នា។ បន្ទាប់មក យើងនឹងអាចប្រមូលផ្ដុំកម្លាំងដើម្បីកសាងប្រទេសជាតិ ក៏ប៉ុន្តែខ្ញុំមិនដឹងថានរណាជាអង្គការទេ។



មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងសមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។ ពីឆ្វេងទៅស្តាំ៖ ប៉ុល ពត (លេខាបក្សកុម្មុយនីស្តកម្ពុជា និងជានាយករដ្ឋមន្ត្រីកម្ពុជាប្រជាធិបតេយ្យ, នួន ជា (អនុលេខាបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានសភាតំណាងប្រជាជនកម្ពុជា), អៀង សារី (ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស), សុន សេន (ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកការពារជាតិ) និង វន វ៉េត (ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកសេដ្ឋកិច្ច)។ ទីពីរខាងស្តាំ នៅជួរមុខ៖ កុយ ធួន រដ្ឋមន្ត្រីពាណិជ្ជកម្ម។ អ្នកដទៃទៀតនៅក្នុងរូបថត គឺជាកងការពារខ្មែរក្រហម ដែលមិនស្គាល់អត្តសញ្ញាណ។

(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជំពូកទី៥

# ការបង្កើតរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ

## ១. អង្គការ[១២]

ទោះបីជាខ្មែរក្រហមបានធ្វើសង្គ្រាមប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែររបស់ឧត្តមសេនីយ៍ លន់ នល់ អស់រយៈពេលប្រាំឆ្នាំក៏ដោយ ក៏ចលនានិងមេដឹកនាំសំខាន់ៗរបស់ខ្មែរក្រហមមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈទេ។ បក្សកុម្មុយនីស្តកម្ពុជាបានរក្សាការសម្ងាត់នេះស្ទើរតែពេញរយៈពេលដែលខ្លួនគ្រប់គ្រងប្រទេសកម្ពុជា។

"អង្គការបដិវត្តន៍" ត្រូវបានបង្កើតឡើងដោយស្ត្រីនិងបុរស ដែលជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា។ អ្នកទាំងនេះត្រូវបានដឹកនាំដោយសម្ងាត់ពីសំណាក់ "បងធំទី១" ឬ ប៉ុល ពត។

នៅខែកញ្ញា ឆ្នាំ១៩៧៥ គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជារួមមាន៖ ប៉ុល ពត, នួន ជា, សោ ភឹម, អៀង សារី, សុន សេន, តាម៉ុក, និង វន វ៉េត។ នៅឆ្នាំ១៩៧៧ សមាជិកបីនាក់ទៀតគឺ (រស់ ញឹម, ខៀវ សំផន និង កែ ពក) ត្រូវបានដាក់បញ្ចូលទៅក្នុងគណៈកម្មាធិការនេះ។ ប៉ុល ពត, អៀង សារី, សុន សេន និង ខៀវ សំផន បានទទួលការអប់រំនៅប្រទេសបារាំង ចំណែក នួន ជា ធ្លាប់បានសិក្សារៀនសូត្រនៅប្រទេសថៃ និងវៀតណាម។ សមាជិកផ្សេងទៀតនៃគណៈកម្មាធិការមជ្ឈិម មានចំណេះដឹងបន្តិចបន្តួចប៉ុណ្ណោះ។

### សមាជិកគណៈកម្មាធិការមជ្ឈិមបក្សពីឆ្នាំ១៩៧៦-១៩៧៨

- ប៉ុល ពត — លេខាបក្ស (បងធំទី១)
  - នួន ជា* — អនុលេខាបក្ស (បងធំទី២)
    - សោ ភឹម*
    - អៀង សារី
    - សុន សេន*
    - តាម៉ុក*
    - វន វ៉េត*
    - កែ ពក*
    - ខៀវ សំផន
    - រស់ ញឹម*

* វន វ៉េត, សោ ភឹម និង រស់ ញឹម (ហៅ មូល សម្បត្តិ និង មូល អ៊ុន) ត្រូវបានសម្លាប់នៅ ឆ្នាំ១៩៧៨។ សុន សេន ត្រូវបានសម្លាប់ក្នុងឆ្នាំ១៩៩៧។ កែ ពក ស្លាប់ដោយសារជំងឺនៅ ឆ្នាំ២០០២។ តាម៉ុក ស្លាប់ដោយសារជំងឺក្នុងឆ្នាំ២០០៦។
* នួន ជា ស្លាប់ដោយសារជំងឺ នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៩ នៅមន្ទីរពេទ្យខ្មែរ-សូវៀត។

## ២. ការយាងនិវត្តន៍មកកម្ពុជារបស់សម្តេចព្រះ នរោត្តម សីហនុ

រហូតដល់ចុងឆ្នាំ១៩៧៥ ខ្មែរក្រហមនៅតែហៅខ្លួនឯងថាជា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា (រដ្ឋាភិបាលដែលត្រូវបានបង្កើតឡើងនៅទីក្រុងប៉េកាំងនៅឆ្នាំ១៩៧០ ដែលមានសម្តេចព្រះ នរោត្តម សីហនុ ជាព្រះប្រមុខរដ្ឋ)។ មកដល់ឆ្នាំ១៩៧២ ខ្មែរក្រហមបានត្រួតត្រាលើចលនាតស៊ូស្ទើរតែទាំងស្រុងទៅហើយ ប៉ុន្តែដើម្បីបានការទទួលស្គាល់ពីអន្តរជាតិ និងការគាំទ្រពីប្រជាជននៅក្នុងប្រទេស ចលនានេះនៅបន្តស្ថិតក្រោមអធិបតីភាពរបស់សម្តេចព្រះនរោត្តម សីហនុ និងរាជរដ្ឋាភិបាលនិរទេសរបស់ព្រះអង្គ។

នៅខែកក្កដា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានសុំយាងសម្តេចព្រះ នរោត្តម សីហនុ ដែលកំពុងគង់និរទេសនៅទីក្រុងព្យុងយ៉ាង ប្រទេសកូរ៉េខាងជើង មកកម្ពុជាវិញ។ នៅមុនពេលយាងត្រឡប់ ព្រះអង្គបានយាងទៅកាន់ទីក្រុងប៉េកាំង ដើម្បីសុំលាលេខាបក្សកុម្មុយនីស្តចិន ម៉ៅ សេទុង និងនាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ ដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ។ ក្រោយមកព្រះអង្គបានមានព្រះបន្ទូលថា៖ "ការសម្រេចព្រះទ័យរបស់ខ្ញុំក្នុងការវិលត្រឡប់មកកម្ពុជាវិញ មិនមានន័យថាខ្ញុំយល់ព្រមទទួលស្គាល់ខ្មែរក្រហមទាំងនោះទេ ប៉ុន្តែខ្ញុំត្រូវតែធ្វើពលិកម្មដើម្បីជាកិត្តិយសដល់ប្រទេសចិនហើយជាពិសេសដល់លោកនាយករដ្ឋមន្ត្រី ជូ អេនឡាយ ដែលបានជួយប្រទេសកម្ពុជា និងខ្លួនខ្ញុំយ៉ាងច្រើនលើសលប់"[១៣]។ ព្រះអង្គបានយាងត្រឡប់មកជាមួយអគ្គមហេសីនៅដើមខែកញ្ញា ឆ្នាំ១៩៧៥ ដោយមានសម្តេច ប៉ែន នុត (នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា), ខៀវ សំផន, អៀង ធីរិទ្ធ និងរាជវង្សានុវង្សមួយចំនួនអមព្រះរាជដំណើរទៀតផង។




**គម្របទស្សនាវដ្តី «ទង់បដិវត្ត» លេខ៤ បោះពុម្ពនៅខែមេសា ឆ្នាំ១៩៧៧។ ទស្សនាវដ្តី «ទង់បដិវត្ត» គឺជាសម្ភារឃោសនា ប្រើប្រាស់នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។** ប្រភព៖ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



**ទិដ្ឋភាពនៃការរៀបចំប្រារព្ធ "ខួបទី៣ នៃមហាជ័យជម្នះ១៧ មេសា ដ៏មហាអស្ចារ្យ និងកំណើតកម្ពុជាប្រជាធិបតេយ្យ ដ៏រុងរឿង!" នៅក្នុងពហុកីឡដ្ឋានជាតិអូឡាំពិកក្នុងខែមេសា ឆ្នាំ១៩៧៨។ ពហុកីឡដ្ឋានជាតិ តែងតែត្រូវបានប្រើប្រាស់ជាទីតាំងប្រជុំរបស់បក្សកុម្មុយនីស្តកម្ពុជា។ បដាខាងលើ សរសេរថា "ជយោ បក្សកុម្មុយនីស្តកម្ពុជា ដ៏ត្រឹមត្រូវ និងភ្លឺស្វាង មហាអស្ចារ្យ!"។ ឯបដាខាងក្រោមបន្ទាប់ សរសេរថា "ជយោ បដិវត្តកម្ពុជា ដ៏ខ្លាំងក្លា មហាអស្ចារ្យ! ជយោ ប្រជាជនកម្ពុជា ដ៏មហិមា មហាអស្ចារ្យ!"** (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់ពីយាងនិវត្តន៍មកដល់កម្ពុជាភ្លាម ព្រះអង្គបានធ្វើជាអធិបតីនៅក្នុងសម័យប្រជុំគណៈរដ្ឋមន្ត្រី ប៉ុន្តែព្រះអង្គមិនត្រូវបានអនុញ្ញាតឱ្យមានព្រះបន្ទូលអ្វីទាំងអស់។ តំណែងជាព្រះប្រមុខរដ្ឋ ដែលក្រុមមេដឹកនាំកុម្មុយនីស្តថ្វាយព្រះអង្គនោះមិនមានអំណាចទេ។ បីសប្តាហ៍ក្រោយការយាងត្រឡប់មកដល់កម្ពុជា ព្រះអង្គត្រូវបានបញ្ជូនទៅអង្គការសហប្រជាជាតិ ដើម្បីទាមទារយកអាសនៈរបស់កម្ពុជានៅមហាសន្និបាតអង្គការសហប្រជាជាតិ។ នៅក្នុងប្រទេសឯណោះវិញ ក្រុមអ្នកគាំទ្ររបស់ព្រះអង្គជាច្រើននាក់បានបាត់ខ្លួនដោយគ្មានដំណឹង។ សមាជិករាជវង្សានុវង្សរបស់ព្រះអង្គប្រហែល២០អង្គបានចូលទិវង្គតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយយ៉ាងតិចមានព្រះរាជវង្សានុវង្ស៧អង្គផ្សេងទៀត ត្រូវបានសម្លាប់នៅគុកទួលស្លែង។

## ៣. រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ

មហាសន្និបាតជាតិលើកទី៣ដែលត្រូវបានប្រារព្ធធ្វើឡើងនៅថ្ងៃទី១៥ដល់១៩ ខែធ្នូ ឆ្នាំ១៩៧៥ បានអនុម័តដោយសភាជាតិដែលមានសមាជិកចំនួន១ ០០០ នាក់ នៅទីក្រុងភ្នំពេញ សម្រេចឱ្យមានការបង្កើតរដ្ឋធម្មនុញ្ញថ្មីមួយ ដែលត្រូវបានប្រកាសជាផ្លូវការនៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦។ ប្រទេសកម្ពុជាត្រូវបានប្តូរឈ្មោះជាផ្លូវការថា "កម្ពុជាប្រជាធិបតេយ្យ"។



ទង់ជាតិកម្ពុជាប្រជាធិបតេយ្យ

**មាត្រា១៦ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ បានចែងអំពីរូបភាព និងខ្លឹមសារនៃទង់ជាតិនេះមានដូចតទៅ៖ «ផ្ទៃក្រហមមានរូបប្រាសាទកំពូលបីពណ៌លឿងនៅចំកណ្តាល។ ផ្ទៃក្រហម ជានិមិត្តរូបនៃចលនាបដិវត្តន៍ ការប្រយុទ្ធមោះមុត អង់អាចក្លាហានក្នុងការរំដោះជាតិ ការពារជាតិ និងកសាងជាតិកម្ពុជារបស់ប្រជាជនកម្ពុជា។ ប្រាសាទពណ៌លឿងជានិមិត្តរូបនៃប្រពៃណីជាតិ និងប្រជាជនកម្ពុជា ដែលជាអ្នកការពារប្រទេស ជាអ្នកស្ថាបនាប្រទេសឱ្យបានថ្កុំថ្កើងរុងរឿង»។** (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

### ចម្រៀងជាតិកម្ពុជាប្រជាធិបតេយ្យ ១៧មេសា មហាជោគជ័យ

ឈាមក្រហមច្រាល ស្រោចស្រពក្រុងវាលកម្ពុជាមាតុភូមិ
ឈាមកម្មករកសិករដ៏ឧត្តម ឈាមយុទ្ធជន យុទ្ធនារីបដិវត្តន៍។

ឈាមប្រែក្លាយជាកំហឹងខ្លាំងក្លា តស៊ូមោះមុត ១៧មេសា
ក្រោមទង់បដិវត្តន៍ ឈាមរំដោះផុតពីភាពខ្ញុំគេ។

ជយោ! ជយោ ១៧មេសា ជោគជ័យមហាអស្ចារ្យ មានន័យធំធេង
លើសសម័យអង្គរ។ យើងរួបរួមគ្នាកសាងកម្ពុជានិងសង្គមថ្មីបវរ
ប្រជាធិបតេយ្យ សមភាព និងយុត្តិធម៌តាមមាគ៌ាម្ចាស់ការឯករាជ្យ
រឹងមាំ ប្តេជ្ញាដាច់ខាត ការពារមាតុភូមិ ទឹកដីឧត្តមដ៏រុងរឿង។

ជយោ! ជយោ! ជយោ កម្ពុជាថ្មី ប្រជាធិបតេយ្យ សម្បូរថ្កុំថ្កើង
ប្តេជ្ញាជ្រោងគ្រវីទង់បដិវត្តន៍ក្រហមខ្ពស់ឡើង សាងមាតុភូមិយើង
ឱ្យចម្រើនលោតផ្លោះ មហារុងរឿង មហាអស្ចារ្យ។




**សញ្ញាជាតិ មាត្រា១៧នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យចែងថា «សញ្ញាជាតិ គឺមានប្រព័ន្ធស្រែ និងប្រឡាយទឹកជានិមិត្តរូបនៃកសិកម្មជឿនលឿន មានរោងចក្រជានិមិត្តរូបនៃឧស្សាហកម្ម មានកម្រងកួរស្រូវជាស្នែងក្របីព័ទ្ធពីក្រៅ ហើយមានអក្សរ «កម្ពុជាប្រជាធិបតេយ្យ» នៅពីក្រោម»។** (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រដ្ឋធម្មនុញ្ញបានបង្កើតសភាតំណាងប្រជាជន ចំនួន២៥០អាសនៈ ដែលក្នុងនោះ១៥០អាសនៈតំណាងឱ្យវណ្ណៈកសិករ ៥០អាសនៈតំណាងឱ្យវណ្ណៈកម្មករ និងពលករ និង៥០អាសនៈទៀតតំណាងឱ្យកងទ័ពបដិវត្តន៍កម្ពុជា។ រដ្ឋធម្មនុញ្ញមិនមានចែងអ្វីទាំងអស់ទាក់ទងនឹងបក្សកុម្មុយនីស្តកម្ពុជា ហើយរដ្ឋសភាបានបើកសម័យប្រជុំតែម្តងគត់នៅខែមេសា ឆ្នាំ១៩៧៦។

ចម្រៀងជាតិថ្មីមានឈ្មោះថា "១៧ មេសា មហាជោគជ័យ"។ បទចម្រៀងនេះនិពន្ធដោយ ប៉ុល ពត។ ទង់ជាតិថ្មីមានផ្ទៃពណ៌ក្រហមហើយមានរូបប្រាសាទអង្គរវត្តកំពូលបីពណ៌លឿងនៅចំកណ្តាល។



**បន្ទាប់ពីការយាងនិវត្តមកកាន់ប្រទេសកម្ពុជាវិញ នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៥ សម្តេចព្រះ នរោត្តម សីហនុ អមព្រះរាជដំណើរដោយសម្តេចព្រះមហាក្សត្រិយ៍ នរោត្តម មុនីនាថ សីហនុ, ព្រះអង្គម្ចាស់ នរិន្ទ្រះពង្ស និងព្រះអង្គម្ចាស់ សីហមុនី បាននាំយកព្រះអង្ជិធាតុរបស់អតីតព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈ ទៅតម្កល់នៅព្រះចេតិយមួយក្នុងព្រះបរមរាជវាំង។** ប្រភព៖ ហូលីយ៉ូ ដែលជ្រេស/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

## ៤. សម្តេចព្រះ នរោត្តម សីហនុ លាលែងពីតំណែងប្រមុខរដ្ឋ

នៅថ្ងៃ១១ ខែមីនា ឆ្នាំ១៩៧៦ គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា បានជួបពិភាក្សាគ្នាអំពីបញ្ហាសុំលាលែងពីតំណែងរបស់សម្តេចព្រះ នរោត្តម សីហនុ។ គណៈអចិន្ត្រៃយ៍បានព្រមព្រៀងទទួលយកសំណើសុំលាលែងរបស់ព្រះអង្គ ប៉ុន្តែនឹងមិនអនុញ្ញាតឱ្យព្រះអង្គចាកចេញពីប្រទេស ឬធ្វើសេចក្តីថ្លែងការណ៍ ឬជួបពិភាក្សាជាមួយអង្គទូតបរទេសណាមួយឡើយ។ របបរាជានិយមនៅកម្ពុជាដែលកើតមានឡើងអស់រយៈពេលជិត២ពាន់ឆ្នាំមកហើយនោះ ត្រូវបានបញ្ចប់។

ក្នុងខែមេសា ឆ្នាំ១៩៧៦ សភាតំណាងប្រជាជនកម្ពុជាបានបើកសម័យប្រជុំលើកទីមួយនិងតែម្តងគត់របស់ខ្លួន។ អង្គប្រជុំបានព្រមព្រៀងគ្នាជាឯកច្ឆន្ទទៅលើសំណើសុំយាងចូលនិវត្តន៍របស់សម្តេចព្រះ នរោត្តម សីហនុ ដោយផ្តល់ថ្វាយព្រះអង្គនូវប្រាក់សោធននិវត្តន៍ចំនួន៨ពាន់ដុល្លារក្នុងមួយឆ្នាំ ដែលមិនដែលបើកថ្វាយព្រះអង្គទាល់តែសោះ។ ព្រះអង្គ និងព្រះរាជវង្សានុវង្ស ត្រូវបានឃុំឃាំងនៅក្នុងវីឡាតូចមួយស្ថិតក្នុងបរិវេណនៃព្រះបរមរាជវាំង។ ព្រះអង្គបានជាប់ឃុំនៅទីនោះរហូតដល់ខែមករាឆ្នាំ១៩៧៩ គឺរហូតដល់ថ្ងៃដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ[១៤]។

### រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ






គណៈប្រតិភូកម្ពុជាប្រជាធិបតេយ្យ នៅខាងមុខវិហារថានចឺ ក្នុងទីក្រុងប៉េកាំង អំឡុងពេលទស្សនកិច្ចទៅកាន់ប្រទេសចិនក្នុងឆ្នាំ១៩៧៧។ រូបទីបីពីឆ្វេង៖ អៀង សារី ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេស។ រូបទីបួនពីឆ្វេង៖ ចាន់ យូ៉ាន់ អគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យប្រចាំប្រទេសចិន និង រូបទីប្រាំពីឆ្វេង៖ ប៉ុល ពត នាយករដ្ឋមន្ត្រី និងជាលេខាបក្សកម្មុយនីស្តកម្ពុជា។ គណៈប្រតិភូដទៃទៀតមិនស្គាល់អត្តសញ្ញាណ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## ៥. រចនាសម្ព័ន្ធចាត់តាំងរបស់កម្ពុជាប្រជាធិបតេយ្យ

បក្សកុម្មុយនីស្តកម្ពុជាលាក់មុខ គឺជាអង្គការតែមួយគត់ដែលមានអំណាចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ក្រសួងដែលមានសកម្មភាពការងារច្រើន ត្រូវបានបង្កើតឡើងនៅទីក្រុងភ្នំពេញ រួមមានក្រសួងការបរទេស ដឹកនាំដោយ អៀង សារី, ក្រសួងការពារជាតិ ដឹកនាំដោយ សុន សេន, ក្រសួងឧស្សាហកម្ម ដឹកនាំដោយ ចេង អន, និងក្រសួងសេដ្ឋកិច្ច ដឹកនាំដោយ វន វ៉េត។ គណៈកម្មាធិការតែមួយគត់ ដែលមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងអនុម័តគោលនយោបាយរដ្ឋាភិបាល និងលក្ខន្តិកៈផ្សេងៗ គឺគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ដែលមាន ប៉ុល ពត ជាលេខា និង នួន ជា ជាអនុលេខា។ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា មិនដែលយកចិត្តទុកដាក់គោរពរដ្ឋធម្មនុញ្ញ និងបទបញ្ញត្តិនានាដែលខ្លួនបានបង្កើតឡើងឡើយ។ សមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្ស ក៏មានតំណែងនៅក្នុងរដ្ឋាភិបាលដែរ[១៥]។

## ៦. ការផ្លាស់ប្តូរថ្ងៃកំណើតបក្ស

នៅខែមីនា ឆ្នាំ១៩៧៦ គណៈកម្មាធិការមជ្ឈិមបក្សបានសម្រេចយកឆ្នាំ១៩៦០ (មិនយកឆ្នាំ ១៩៥១) ជាឆ្នាំកំណើតបក្សកុម្មុយនីស្តកម្ពុជា។ មេដឹកនាំទាំងនោះបានសម្រេចថាអ្នកទាំងឡាយណាដែលចូលជាសមាជិកមុនឆ្នាំ១៩៦០នឹងមិនត្រូវបានចាត់ទុកថាជាសមាជិកបក្សទៀតទេ។ មជ្ឈិមបក្ស មិនចង់ទទួលស្គាល់សារសំខាន់នៃការជួយជ្រោមជ្រែងរបស់វៀតណាមមុនឆ្នាំ១៩៦០ឡើយ ហើយចង់បដិសេធចោលឥទ្ធិពលរបស់វៀតណាមមកលើបក្សកុម្មុយនីស្តកម្ពុជា និងចង់កាត់ផ្តាច់ទំនាក់ទំនងទាំងឡាយដែលធ្លាប់មានជាមួយវៀតណាម។

### ខៀវ សំផន (ហៅសមមិត្ត ហែម)

ខៀវ សំផន កើតឆ្នាំ១៩៣១ នៅខេត្តកំពង់ចាម។ បន្ទាប់ពីទទួលបានអាហារូបករណ៍ទៅសិក្សានៅប្រទេសបារាំង ខៀវ សំផន បានបញ្ចប់សញ្ញាប័ត្រថ្នាក់បណ្ឌិតវិទ្យាសាស្ត្រសេដ្ឋកិច្ច ហើយបានវិលត្រឡប់មកកម្ពុជាវិញក្នុងឆ្នាំ១៩៥៩។ បន្ទាប់មក សម្តេចព្រះ នរោត្តម សីហនុ បានតែងតាំង ខៀវ សំផន ជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម។ នៅឆ្នាំ១៩៦៤ ខៀវ សំផន បានលាលែងពីមុខតំណែង ក៏ប៉ុន្តែបន្តស្ថិតនៅជាសមាជិកសភារយៈពេលបួនឆ្នាំទៀត។

ឆ្នាំ១៩៦៧ ដោយត្រូវចោទប្រកាន់ថាជាភ្នាក់ងាររបស់ក្រុមកុម្មុយនីស្ត ខៀវ សំផន បានរត់ទៅលាក់ខ្លួននៅក្នុងព្រៃ។ ឆ្នាំ១៩៧៦ បន្ទាប់ពីការសុំលាលែងតំណែងរបស់សម្តេចព្រះ នរោត្តម សីហនុ ខៀវ សំផន ត្រូវបានតែងតាំងជាប្រធានគណៈប្រធានរដ្ឋរបស់កម្ពុជាប្រជាធិបតេយ្យ។ ខៀវ សំផន បានចូលរួមជាមួយរដ្ឋាភិបាលនិរទេសរបស់ ប៉ុល ពត ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៨ ហើយបន្ទាប់មក ខៀវ សំផន បានចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា។ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៧ ខៀវ សំផន ត្រូវបានឃាត់ខ្លួន។

អស់រយៈពេលជាងមួយទសវត្សរ៍ក្រោយមក ខៀវ សំផន ត្រូវបានកាត់ទោសដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងត្រូវជាប់ទោសពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានសម្រេចដោយតុលាការកំពូលក្នុងសំណុំរឿង០០២/០១ បន្ទាប់ពីការបដិសេធលើបណ្តឹងឧទ្ធរណ៍។ ខៀវ សំផន ត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិត។ ខៀវ សំផន ក៏ត្រូវបានកាត់ទោសដោយអង្គជំនុំជម្រះសាលាដំបូងពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងអំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម។ ខៀវ សំផនបានដាក់ពាក្យបណ្តឹងទៅកាន់តុលាការកំពូល ដែលការវិនិច្ឆ័យទោសនៅមិនទាន់ប្រព្រឹត្តទៅនៅឡើយ បើគិតត្រឹមកាលបរិច្ឆេទនៃការបោះពុម្ពសៀវភៅនេះ។

បក្សកុម្មុយនីស្តកម្ពុជាបានបន្តដឹកនាំប្រទេសជាសម្ងាត់នៅក្រោមឈ្មោះថា“អង្គការ”។ ទោះជាយ៉ាងនេះក្តី នៅខែកញ្ញា ឆ្នាំ១៩៧៧ គឺមុនដំណើរទស្សនកិច្ចទៅប្រទេសចិនបន្តិច ប៉ុល ពត បានប្រកាសជាសាធារណៈនូវវត្តមានរបស់បក្សកុម្មុយនីស្តកម្ពុជា និងតួនាទីរបស់ខ្លួនជានាយករដ្ឋមន្ត្រីនៃកម្ពុជាប្រជាធិបតេយ្យ។



**ប៉ុល ពត នាយករដ្ឋមន្ត្រីកម្ពុជាប្រជាធិបតេយ្យ និងជាលេខាបក្សកុម្មុយនីស្តកម្ពុជា ចាប់ដៃជាមួយកងការពារ។ នៅខាងក្រោយ ប៉ុល ពត គឺ សិន ជាន អនុប្រធាននាយកដ្ឋានការបរទេសនៃបក្សកុម្មុយនីស្តចិន ក្នុងអំឡុងទស្សនកិច្ចរបស់គណៈប្រតិភូចិន មកកាន់ទីក្រុងភ្នំពេញ នៅរវាងឆ្នាំ១៩៧៥ ដល់ ១៩៧៨។ រូបថតនេះថតនៅអាកាសយានដ្ឋានពោធិ៍ចិនតុង (បច្ចុប្បន្ន អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ)។** (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជំពូកទី៦

# ភូមិសាស្ត្ររដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ

នៅឆ្នាំ១៩៧៦ បក្សកុម្មុយនីស្តកម្ពុជាបានបែងចែកកម្ពុជាប្រជាធិបតេយ្យទៅជា៦ភូមិភាគ ដែលរួមមាន៣២តំបន់។ ភូមិភាគនីមួយៗ គឺយកខេត្តពីរឬច្រើនមកបញ្ចូលគ្នា ឬកាត់ស្រុក១ ឬច្រើន ចេញពីខេត្តនេះខ្លះ ឬខេត្តនោះខ្លះមកបញ្ចូលគ្នា។ ភូមិភាគនិងតំបន់ទាំងអស់ សុទ្ធតែត្រូវបានដាក់កំណត់សម្គាល់ជាលេខ។ ភូមិភាគនីមួយៗ ចែកចេញជាច្រើនតំបន់ ហើយតំបន់នីមួយៗចែកចេញជាស្រុក ឃុំ និងសហករណ៍។

ភូមិភាគបូព៌ា (ភូមិភាគ២០៣) ដឹកនាំដោយ សោ ភឹម ដែលបានធ្វើអត្តឃាត នៅខែឧសភា ឆ្នាំ១៩៧៨។ ភូមិភាគនេះរួមមានខេត្តព្រៃវែង និងខេត្តស្វាយរៀងទាំងមូល, ផ្នែកខ្លះនៃខេត្តកំពង់ចាមដែលស្ថិតនៅត្រើយខាងឆ្វេងទន្លេមេគង្គទាំងអស់, ស្រុកឆ្លូងក្នុងខេត្តក្រចេះ និងស្រុកចំនួន៣ក្នុងខេត្តកណ្តាល រួមមានស្រុកខ្សាច់កណ្តាល ស្រុកល្វាឯម និងស្រុកមុខកំពូល។ ភូមិភាគនេះចែកចេញជា៥តំបន់ រួមមាន៖ តំបន់២០ តំបន់២១ តំបន់២២ តំបន់២៣ និង តំបន់ ២៤។

ភូមិភាគនិរតី (ភូមិភាគ៤០៥) ដឹកនាំដោយ ឈិត ជឿន ហៅ តាម៉ុក។ ភូមិភាគនេះរួមមានខេត្តកំពត និងខេត្តតាកែវទាំងមូល, ស្រុក២ក្នុងខេត្តកំពង់ស្ពឺ គឺស្រុកសំរោងទង និងស្រុកគងពិសី, និងស្រុក៥ក្នុងខេត្តកណ្តាល គឺស្រុកកណ្តាលស្ទឹង ស្រុកស្អាង ស្រុកកោះធំ ស្រុកកៀនស្វាយ និងស្រុកលើកដែក។ ភូមិភាគនេះ ចែកចេញជា៤តំបន់គឺ ៖ តំបន់១៣ តំបន់៣៣ តំបន់៣៥ និង តំបន់២៥។

ភូមិភាគឧត្តរ (ភូមិភាគ៣០៣) ដឹកនាំដោយ កុយ ធួន ហៅ ធុច ពីឆ្នាំ១៩៧០ ដល់ដើមឆ្នាំ១៩៧៦។ បន្ទាប់ពី កុយ ធួន ត្រូវបានចាប់ខ្លួន និងសម្លាប់នៅគុកទួលស្លែងក្នុងឆ្នាំ១៩៧៦ កែ ពក ត្រូវបានចាត់តាំងជាលេខាភូមិភាគជំនួសវិញរហូតដល់ឆ្នាំ១៩៧៧ទើប កែ ពក ត្រូវបានចាត់តាំងឱ្យធ្វើជាលេខាភូមិភាគកណ្តាល ដែលទើបបង្កើតថ្មី ហើយលេខាថ្មីរបស់ភូមិភាគឧត្តរគឺ កង ចាប។ ភូមិភាគនេះរួមមានខេត្តកំពង់ធំទាំងមូល, ផ្នែកខាងស្តាំទន្លេមេគង្គទាំងអស់នៃខេត្តកំពង់ចាម និងស្រុកមួយក្នុងខេត្តក្រចេះ (ស្រុកព្រែកប្រសប់) ហើយចែកចេញជាបីតំបន់គឺ៖ តំបន់៤១ តំបន់៤២ និង តំបន់៤៣។

ភូមិភាគពាយ័ព្យ (ភូមិភាគ៥៦០) ដឹកនាំដោយ រស់ ញឹម។ ភូមិភាគនេះរួមមានខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបងទាំងមូល ដែលចែកចេញជា៧តំបន់គឺ៖ តំបន់១ តំបន់២ តំបន់៣ តំបន់៤ តំបន់៥ តំបន់៦ និង តំបន់៧។

ភូមិភាគបស្ចិម (ភូមិភាគ៤០១) ដឹកនាំដោយ ជូ ជេត។ ភូមិភាគនេះរួមមានខេត្តកោះកុង និងខេត្តកំពង់ឆ្នាំងទាំងមូល និងផ្នែកខ្លះនៃខេត្តកំពង់ស្ពឺ ហើយចែកចេញជា៥តំបន់គឺ៖ តំបន់៣១ តំបន់៣២ តំបន់៣៧ តំបន់១៥ និង តំបន់១១។



**ទឹកាម (រូបទីពីររាប់ពីស្តាំ) ជាជំនាញការវៀតណាម និងជាអតីតអនុប្រធានគណៈកម្មាធិការការបរទេសប្រជាជនវៀតណាមនិងកម្ពុជា ឈរថតជាមួយកម្មាភិបាលវៀតណាម (រូបទីមួយរាប់ពីស្តាំ) និង វ៉ាន់ រិទ្ធ (រូបទីបីរាប់ពីស្តាំ) ប្រធានគណៈកម្មាធិការពាណិជ្ជកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងកម្មាភិបាលខ្មែរក្រហមដទៃទៀត ក្នុងឆ្នាំ១៩៧៦។**
ប្រភព៖ ទឹកាម/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា



**អៀង សារី (ពាក់មួក និងចាប់រលាក់ដៃជាមួយទាហាន) ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ជួបជាមួយទាហានខ្មែរក្រហមនៅមូលដ្ឋាន រវាងឆ្នាំ១៩៧៥-១៩៧៨។** (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ភូមិភាគឦសាន (ភូមិភាគ១០៨) ដឹកនាំដោយ ណៃ សារ៉ាន់ ហៅ យ៉ា (សម្លាប់នៅឆ្នាំ១៩៧៦)។ ភូមិភាគនេះរួមមាន ខេត្តរតនគិរីនិងខេត្តមណ្ឌលគិរីទាំងមូល, ផ្នែកខ្លះនៃខេត្តក្រចេះ និងផ្នែកខ្លះនៃខេត្តស្ទឹងត្រែងដែលស្ថិតនៅត្រើយខាងលិចទន្លេមេគង្គ។ ភូមិភាគនេះចែកចេញជា៦តំបន់គឺ តំបន់១០១ តំបន់១០២ តំបន់១០៤ តំបន់១០៥ តំបន់១០៧ និង តំបន់៥០៥។

នៅឆ្នាំ១៩៧៦ កម្ពុជាប្រជាធិបតេយ្យ បានបង្កើតតំបន់ស្វយ័តចំនួន២ផ្សេងទៀតដែលមិនជាចំណុះឱ្យភូមិភាគណាមួយឡើយ ហើយធ្វើទំនាក់ទំនងផ្ទាល់ជាមួយគណៈកម្មាធិការមជ្ឈិមបក្ស។ តំបន់ស្វយ័តទាំង២ រួមមាន តំបន់សៀមរាប-ឧត្តរមានជ័យ (តំបន់១០៦) និងតំបន់ព្រះវិហារ(តំបន់១០៣)។ ចំណែកក្រុងកំពង់សោម(បច្ចុប្បន្នខេត្តព្រះសីហនុ) ក៏ត្រូវបានចាត់តាំងដោយឡែកពីភូមិភាគដែរ។

នៅឆ្នាំ១៩៧៧ ភូមិភាគថ្មីមួយទៀត គឺភូមិភាគកណ្តាល ត្រូវបានបង្កើតឡើង។ ភូមិភាគនេះមានទីតាំងស្ថិតនៅត្រង់អតីតភូមិភាគឧត្តរ។ ចំណែកភូមិភាគឧត្តរថ្មី ត្រូវបានប្តូរទីតាំងទៅតំបន់សៀមរាប-ឧត្តរមានជ័យ និងតំបន់ព្រះវិហារ។ តំបន់ក្រចេះ(ឬតំបន់៥០៥) និងតំបន់មណ្ឌលគិរី (ឬតំបន់១០៥) ត្រូវបានបំបែកចេញពីភូមិភាគឦសាន្ត និងចាត់តាំងជាតំបន់ស្វយ័ត។




**ផែនទីកម្ពុជាប្រជាធិបតេយ្យ បោះពុម្ពផ្សាយដោយក្រសួងសិក្សាធិការកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៦ បង្ហាញអំពីភូមិភាគនិងតំបន់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។** (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



**ការដ្ឋានសាងសង់ទំនប់ នៅតាមផ្លូវឆ្ពោះទៅទិសខាងជើងនាឆ្នាំ១៩៧៨។ ហ្គូណា បើគស្ត្រម បានថតរូបនេះ ក្នុងអំឡុងពេលដែលគាត់ និងសមាជិកដទៃទៀតនៃសមាគមមិត្តភាពស៊ុយអែត-កម្ពុជា កំពុងធ្វើ «ទស្សនកិច្ចការទូត» រៀបចំឡើងដោយខ្មែរក្រហម រយៈពេល១៤ថ្ងៃក្នុងឆ្នាំ១៩៧៨។ ខ្មែរក្រហម មានបំណងប្រើប្រាស់ជនជាតិស៊ុយអែតទាំងនេះ ដើម្បីបង្កើនការគាំទ្រពីបរទេស ជាពិសេសប្រទេសកុម្មុយនីស្ត ចំពោះរដ្ឋាភិបាលខ្លួន។ រូបថតនេះ ត្រូវបានដកស្រង់ចេញពីបណ្តុំរូបថតជាច្រើនទៀតនៅក្នុងសៀវភៅ «ឋាននរកកម្ពុជាប្រជាធិបតេយ្យ» ដែលហ្គូណា បើគស្ត្រម បានថតក្នុងអំឡុងទស្សនកិច្ច។**

ប្រភព ៖ ហ្គូណា បើគស្ត្រម/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

ជំពូកទី៧

# គម្រោងផែនការបួនឆ្នាំ (១៩៧៧-១៩៨០)

ខ្មែរក្រហមបានធ្វើការបោសសម្អាតទីក្រុងនិងទីប្រជុំជននានា ដើម្បីលុបបំបាត់ចោលការរស់នៅតាមទីក្រុង និងកសាងកម្ពុជាមួយថ្មីដោយពឹងផ្អែកលើការពង្រីកផលិតកម្មស្រូវ។ នៅដើមឆ្នាំ១៩៧៦ បក្សកុម្មុយនីស្តកម្ពុជាបានប្រញាប់ប្រញាល់រៀបរៀងផែនការបួនឆ្នាំលើកទី១ (១៩៧៧-១៩៨០) ដែលតម្រូវឱ្យធ្វើការប្រមូលផ្តុំទ្រព្យសម្បត្តិឯកជនទាំងអស់ និងដាក់ការដាំដុះស្រូវជាអាទិភាពចម្បងរបស់ជាតិ។ បន្ទាប់ពីបញ្ហាសន្តិសុខជាតិ សមូហភាវូបនីយកម្ម គឺជាគោលនយោបាយដ៏សំខាន់បំផុតរបស់កម្ពុជាប្រជាធិបតេយ្យ។

ប្រជាជនកម្ពុជា មិនដែលជួបប្រទះការប្រមូលផ្តុំបែបនេះតាំងពីមុនមកទេ។ ក្នុងឆ្នាំ១៩៧៦ ទ្រព្យសម្បត្តិឯកជនទាំងអស់របស់ប្រជាជន (រួមទាំងសម្ភារផ្ទះបាយផង) ត្រូវបានប្រមូលផ្តុំដើម្បីបម្រើផលប្រយោជន៍រួម។ ជាមួយគ្នានេះដែរ សមាជិកគ្រួសារទាំងអស់ត្រូវបានបំបែកចេញពីគ្នា និងតម្រូវឱ្យធ្វើការតាមក្រុមរៀងៗខ្លួន។ ប្តី ប្រពន្ធត្រូវបានបំបែកឱ្យរស់នៅផ្សេងពីគ្នា ហើយកូនៗត្រូវបានបំបែកចេញពីឪពុកម្តាយ។

ផែនការបួនឆ្នាំ មានគោលបំណងសម្រេចឱ្យបានទិន្នផលជាតិជាមធ្យម ៣តោនក្នុង១ហិកតានៃដំណាំស្រូវ។ គោលបំណងនេះគឺជាការងារមួយដែលមិនអាចសម្រេចបាន ពីព្រោះប្រជាជនកម្ពុជាពុំធ្លាប់ត្រូវបានបង្ខំឱ្យផលិតស្រូវក្នុងចំនួនច្រើនបែបនេះនៅទូទាំងផ្ទៃប្រទេសពីមុនមកទេ។ លើសពីនេះទៅទៀត ប្រទេសកម្ពុជាត្រូវបានបំផ្លិចបំផ្លាញយ៉ាងដំណំដោយសង្គ្រាម ព្រមទាំងកង្វះខាតឧបករណ៍ សត្វពាហនៈ និងកម្លាំងពលកម្មមាំទាំទៀតផង។

ផែនការបួនឆ្នាំ មានរួមបញ្ចូលទាំងគម្រោងដាំបន្លែបង្ការ ហើយសង្ឃឹមថានឹងអាចទាញយកប្រាក់ចំណូលពីអនុផលព្រៃឈើ ការនេសាទ ការចិញ្ចឹមសត្វ និងការដាំដើមឈើ។ មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ សង្ឃឹមថានឹងធ្វើឱ្យកម្ពុជាមានឯករាជ្យភាពពេញបរិបូរណ៍ ទាំងវិស័យសេដ្ឋកិច្ច ក៏ដូចជាវិស័យនយោបាយ និងមានបំណងប្រែក្លាយកម្ពុជាពីប្រទេសកសិកម្មឱនថយ ឱ្យទៅជាប្រទេសកសិកម្មជឿនលឿន។

ទោះជាយ៉ាងនេះក៏ដោយ ក៏មេដឹកនាំខ្មែរក្រហមមិនបានគិតគូរដល់ផលវិបាកនៃការអនុវត្តផែនការនេះ និងទុក្ខវេទនារបស់ប្រជាជនដែលបណ្ដាលមកពីការធ្វើការហួសកម្លាំង លក្ខខណ្ឌរស់នៅមិនល្អ ការទទួលទានអាហារមិនគ្រប់គ្រាន់ ការខ្វះខាតសេរីភាពនិងសិទ្ធិជាមូលដ្ឋាន និងជំងឺដែលគ្មានការព្យាបាល។ ក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ លក្ខខណ្ឌរស់នៅរបស់ប្រជាជន មានសភាពយ៉ាប់យ៉ឺនយ៉ាងខ្លាំង។ របបនេះបានបំផ្លាញសុភមង្គលនិងសេចក្ដីថ្លៃថ្នូររបស់មនុស្សស្ទើរគ្មានសល់ចន្លោះ។ ប្រជាជនភាគច្រើនដឹងថា ប្រទេសមួយត្រូវការអ្នកចេះដឹងដើម្បីអភិវឌ្ឍ។ ផ្ទុយទៅវិញ ខ្មែរក្រហមបានសម្លាប់បញ្ញវន្តនិងអ្នកបច្ចេកទេសអស់ជាច្រើន ហើយបានបិទសាកលវិទ្យាល័យ សាលារៀន និងស្ថាប័នអប់រំដទៃទៀតទូទាំងប្រទេស។ ទន្ទឹមនឹងនេះ ខ្មែរក្រហមបានបញ្ជូនកសិករដែលពុំមានបទពិសោធន៍ ពីជនបទឱ្យមកធ្វើការនៅតាមរោងចក្រមួយចំនួននៅក្នុងទីក្រុងភ្នំពេញ។


កងចល័តនារីខ្មែរក្រហមកំពុងប្រមូលទិន្នផលស្រូវ។ បដិវត្តន៍ខ្មែរក្រហមផ្អែកលើការអះអាងថា ប្រទេសកម្ពុជាអាចអភិវឌ្ឍទៅមុខយ៉ាងឆាប់រហ័សតាមរយៈការបង្កើនទិន្នផលស្រូវឱ្យបានខ្លាំងក្លា ដូចដែលបានបញ្ជាក់នៅក្នុងពាក្យស្លោករបស់កម្ពុជាប្រជាធិបតេយ្យថា៖ "អ្នកមានស្រូវគឺមានអ្វីៗទាំងអស់!" និង "ស្រូវបីតោនក្នុងមួយហិកតា!"។ ផ្ទុយទៅវិញ ទិន្នផលស្រូវដែលជាតម្រូវការរបស់បក្សក្នុងការលក់ទៅឱ្យបរទេស ជាទូទៅគឺមិនគ្រប់ផែនការឡើយ ហើយកម្មាភិបាលថ្នាក់ក្រោម តែងភូតកុហកនិងលាក់បាំងពីកង្វះខាតនេះ ដោយដាក់បង្រ្គប់នូវចំណែកទិន្នផលស្រូវដែលត្រៀមសម្រាប់ទុកធ្វើពូជ ស្បៀងប្រចាំថ្ងៃ និងបម្រុង រួចប្រគល់ទៅឱ្យបក្ស។ ជាលទ្ធផល ប្រជាជនទទួលរងភាពអត់ឃ្លាន។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ បានចែកដីស្រែទៅជាដីស្រែប្រភេទលេខមួយ និងដីស្រែធម្មតា។ ទិន្នផលស្រូវសម្រាប់ដីស្រែធម្មតាគឺ៣តោនក្នុង១ហិកតា ហើយសម្រាប់ដីស្រែប្រភេទលេខមួយវិញគឺពី៦ទៅ៧តោនក្នុង១ហិកតា។ ជាងនេះទៅទៀត ទិន្នផលស្រូវនឹងត្រូវបង្កើនជារៀងរាល់ឆ្នាំ។

នៅក្នុងទ្រឹស្ដីដែលបានចែងក្នុងផែនការបួនឆ្នាំនេះ ទិន្នផលស្រូវដែលទទួលបានត្រូវបានបែងចែកជាបួនចំណែកគឺ៖ ស្បៀងប្រចាំថ្ងៃរបស់ប្រជាជន ដែលម្នាក់ៗទទួលបានស្រូវចំនួន៣១២គីឡូក្រាម ក្នុងមួយឆ្នាំ ឬស្មើនឹង០,៨៥គីឡូក្រាមស្រូវ ក្នុងមួយថ្ងៃ។ ស្រូវសម្រាប់ធ្វើពូជ។ ស្រូវដែលរក្សាទុកជាស្បៀងបម្រុង ហើយជាចុងក្រោយគឺស្រូវសម្រាប់លក់នៅឯបរទេសដើម្បីប្ដូរយករូបិយប័ណ្ណបរទេស ដែលអាចប្រើប្រាស់ក្នុងការទិញម៉ាស៊ីនសម្រាប់ធ្វើស្រែចម្ការ ទំនិញផ្សេងៗ និងគ្រឿងសព្វាវុធ។ ចំណែកនេះ ជាចំណែកធំជាងគេ ក្នុងចំណោមចំណែកទាំងបួន។

ជាអកុសល ដោយសារតែទិន្នផលស្ទើរតែមិនគ្រប់តាមផែនការដែលបានកំណត់នោះ មានស្រូវតិចតួចណាស់ដែលរក្សាទុកសម្រាប់ចិញ្ចឹមប្រជាជននិងសម្រាប់ធ្វើជាគ្រាប់ពូជ។ ផ្ទុយទៅវិញ ទិន្នផលស្រូវភាគច្រើន ត្រូវបានយកទៅផ្គត់ផ្គង់កងទ័ពនិងកម្មកររោងចក្រ និងនាំចេញទៅប្រទេសចិននិងប្រទេសសង្គមនិយមដទៃទៀត។

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ស្ទើរតែគ្មាននរណាម្នាក់អាចទទួលបានរបបអាហារគ្រប់គ្រាន់ឡើយ។ ប្រជាជនភាគច្រើនហូបតែបបរលាយពោត លាយដើមចេក និងលាយគល់ល្ហុង ហើយទទួលបានរបបអង្ករតិចជាងកន្លះកំប៉ុងទឹកដោះគោក្នុងមួយថ្ងៃ។ មានតែកម្មាភិបាល និងកងទ័ពខ្មែរក្រហមប៉ុណ្ណោះ ដែលមានបាយហូបគ្រប់គ្រាន់។ អ្នកដែលនៅរស់រានមានជីវិតពីរបបនេះ បានយល់ស្របថា អ្វីដែលគាត់ចងចាំបំផុតក្រៅពីការបង្ខំឱ្យធ្វើការហួសកម្លាំង និងការកាប់សម្លាប់នោះគឺការខ្វះខាតអាហារយ៉ាងខ្លាំង។

អ៊ុំ សារ៉េត ស្ត្រីវ័យ៥៧ឆ្នាំមួយរូបរស់នៅក្នុងទីក្រុងភ្នំពេញ បានរៀបរាប់ពីជីវិតឈឺចាប់របស់គ្រួសារគាត់ ដែលបង្កមកពីការហូបមិនគ្រប់គ្រាន់ថា៖

*នៅឆ្នាំ១៩៧៦ ដោយទ្រាំមិនបាននឹងការស្រេកឃ្លាន ឪពុកខ្ញុំបានដួសកូនក្អុកមកស្ងោរហូបដោយគាត់គិតថានោះគឺជាកូនត្រី។ ថ្ងៃមួយ កម្មាភិបាលខ្មែរក្រហមម្នាក់បានសម្លាប់ពស់មានពិសមួយ ហើយយកមកទុកចោលនៅលើរបង។ គាត់ដឹងដែរថា ពស់នោះមានពិស ប៉ុន្តែគាត់នៅតែពិសាទៀតរហូតធ្វើឱ្យគាត់ស្លាប់។ ប្អូនស្រីខ្ញុំនិងកូនៗ បានស្លាប់ដោយសារតែការអត់ឃ្លាន។ គ្រួសាររបស់ខ្ញុំក៏ស្ថិតនៅក្នុងស្ថានភាពដូចគ្នាដែរ។ យើងបានខិតខំធ្វើស្រែចម្ការយ៉ាងច្រើន ប៉ុន្តែយើងមិនដែលបានហូបគ្រប់គ្រាន់ទេ។ ដោយឃ្លានខ្លាំងពេក ពេលខ្លះខ្ញុំកាត់ដើមត្រាវព្រៃមកស្ងោរហូប។ ពេលហូបហើយរមាស់ពេញខ្លួន។ កូនៗខ្ញុំយំទ្រហឹងពេញផ្ទះ។ ថ្ងៃមួយខ្ញុំទៅស្ទូចត្រី។ ប្រធានកងគំរាមខ្ញុំថា ៖ "ធ្វើឫកថោកទាបទៅអង្គុយស្ទូចត្រី ប្រយ័ត្នអង្គការយកទៅសម្លាប់ចោល"។ ដោយសារកង្វះអាហារកូនរបស់ខ្ញុំម្នាក់ធ្លាក់ខ្លួនឈឺជាទម្ងន់។ ខ្ញុំបានយកខ្សែកចុងក្រោយ ទៅដូរយកអង្ករមកដាំបាយឱ្យកូនខ្ញុំហូប។ កូនខ្ញុំហូបបាយច្រើនណាស់ តែជំងឺរបស់វាធ្ងន់ធ្ងរឡើងជាលំដាប់ ហើយក៏ស្លាប់បាត់ទៅ។ កូនខ្ញុំពីរនាក់ទៀតនិងប្ដីរបស់ខ្ញុំក៏ធ្លាក់ខ្លួនឈឺដែរ ដោយសារតែហូបមិនគ្រប់គ្រាន់។ ទោះជាយ៉ាងនេះក្ដី យើងបានប្រឹងប្រែងរស់យ៉ាងវេទនាជាទីបំផុត។*


**កងកុមារកំពុងរែកដីលើកទំនប់ ក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៨)។ ខ្មែរក្រហម បានបំបែកកុមារចេញពីឪពុកម្ដាយ និងបញ្ជូនអ្នកទាំងនោះទៅកាន់កងកុមារដើម្បីធ្វើការងារកសិកម្ម។ កុមារ មិនទទួលបានការរៀនសូត្រ ការយកចិត្តទុកដាក់ផ្នែកសុខភាព និងហូបចុកគ្រប់គ្រាន់ឡើយ។ កុមារ រាប់ម៉ឺននាក់បានស្លាប់ក្នុងរបបខ្មែរក្រហម និងរាប់ម៉ឺននាក់ទៀត ក្លាយជាក្មេងកំព្រាបន្ទាប់ពីរបបខ្មែរក្រហម។** (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


**កងយុវជន កំពុងជីកប្រឡាយលើកទំនប់ ក្នុងការដ្ឋានការងារមួយកន្លែងក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៨)។** (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



កុមារ និងយុវជន កំពុងហូបអាហារនៅក្នុងរោងបាយរួមមួយកន្លែងនៃសហករណ៍ក្នុងខែសីហា ឆ្នាំ១៩៧៨ ក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចរបស់គណៈប្រតិភូប្រទេសស៊ុយអែត។ អាហារទាំងនេះ ត្រូវបានរៀបចំទុកជាមុន ដើម្បីបន្លំភ្នែកគណប្រតិភូបរទេស។ ហ្គូណា បើគស្ត្រម បានថតរូបនេះ ក្នុងអំឡុងពេលដែលគាត់ និងគណៈប្រតិភូដទៃទៀតកំពុងធ្វើ «ទស្សនកិច្ចការទូត» រៀបចំឡើងដោយខ្មែរក្រហម រយៈពេល១៤ថ្ងៃក្នុងឆ្នាំ១៩៧៨។ រូបថតនេះ ត្រូវបានដកស្រង់ចេញពីបណ្តុំរូបថតជាច្រើនទៀតនៅក្នុងសៀវភៅ «ឋាននរកកម្ពុជាប្រជាធិបតេយ្យ» ដែលហ្គូណា បើគស្ត្រម បានថតក្នុងអំឡុងទស្សនកិច្ច។

ប្រភព៖ហ្គូណា បើគស្ត្រម/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

ជំពូកទី៨

# ជីវិតរស់នៅប្រចាំថ្ងៃក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

## ១. ការបង្កើតសហករណ៍

ក្នុងអំឡុងពេលមានសង្គ្រាមស៊ីវិល ពីឆ្នាំ១៩៧០-១៩៧៥ ប្រជាជនភាគច្រើនដែលរស់នៅតាមតំបន់រំដោះរបស់ខ្មែរក្រហម ត្រូវបានរៀបចំឱ្យទៅជា "ក្រុមប្រវាស់ដៃ" ដែលមានសមាជិកពី១០ទៅ៣០គ្រួសារក្នុងមួយក្រុម។ ទោះជាយ៉ាងនេះក៏ដោយ ចាប់ពីឆ្នាំ១៩៧៣ និងជាពិសេសបន្ទាប់ពីជ័យជម្នះឆ្នាំ១៩៧៥ ក៏ក្រុមប្រវាស់ដៃត្រូវបានរៀបចំឱ្យទៅជា "សហករណ៍កម្រិតទាប" ដែលមានសមាជិកពី៣០០ទៅ៤០០នាក់ ឬក៏ភូមិមួយទាំងមូល។ រហូតដល់ឆ្នាំ១៩៧៧ សហករណ៍កម្រិតទាប ត្រូវបានរៀបចំឡើងវិញឱ្យក្លាយទៅជា "សហករណ៍កម្រិតខ្ពស់" ដែលរួមមាន១ពាន់គ្រួសារក្នុងសហករណ៍នីមួយៗ ឬក៏ឃុំមួយទាំងមូល។

មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានបង្កើតសហករណ៍ទាំងនេះឡើង ដែលជាផ្នែកមួយនៃដំណើររបស់ខ្លួនឆ្ពោះទៅលុបបំបាត់ចោលកម្មសិទ្ធិឯកជន និងរបបមូលធននិយម និងដើម្បីពង្រឹងវណ្ណៈកម្មករនិងកសិករ។ សម្រាប់ខ្មែរក្រហម សហករណ៍មានន័យថា ប្រជាជនរស់នៅជាមួយគ្នា ធ្វើការជាមួយគ្នា ហូបចុកជាមួយគ្នា និងចែករំលែកការកម្សាន្តជាសមូហភាព។ គោលការណ៍នេះ ធ្វើឱ្យមានការដាក់កំហិតយ៉ាងតឹងរ៉ឹងទៅលើជីវិតជាគ្រួសារ។ គ្រួសារខ្មែរធ្លាប់រស់នៅហូបចុកជាមួយគ្នាអស់រយៈពេលរាប់ពាន់ឆ្នាំមកហើយ ដូច្នេះការបង្ខំប្រជាជនឱ្យហូបរួមគ្នានៅក្នុងសហករណ៍ ជាពិសេសនៅពេលដែលមានការខ្វះខាតស្បៀងអាហារយ៉ាងខ្លាំងបែបនេះ គឺជាទង្វើមួយឃោរឃៅខ្លាំងណាស់។ ជាងនេះទៅទៀត ប្រជាជនត្រូវប្រគល់ទ្រព្យសម្បត្តិរបស់ខ្លួនទាំងអស់ ដែលជាមធ្យោបាយផលិតកម្មសំខាន់ៗដាក់ជាសម្បត្តិរួមរបស់សហករណ៍ ដែលមានដូចជា ៖ ឧបករណ៍ប្រើប្រាស់ គោក្របី នង្គ័ល រនាស់ គ្រាប់ពូជ និងដីស្រែជាដើម។

សហករណ៍ត្រូវបានរៀបចំឡើង ដើម្បីឱ្យមនុស្សចេះជួយខ្លួនឯងដោយមិនពឹងផ្អែកអ្នកដទៃ។ មេដឹកនាំខ្មែរក្រហម បានពណ៌នាសហករណ៍ថាជា "កម្លាំងដ៏អស្ចារ្យ" ក្នុងការកសាងប្រទេស និងជា "កំផែងដែកថែបយ៉ាងរឹងមាំបំផុត" សម្រាប់ការពារកម្ពុជាប្រជាធិបតេយ្យទប់ទល់នឹងសត្រូវ។

## ២. វណ្ណៈសង្គមថ្មីពីរ

ទោះបីជាខ្មែរក្រហមបានអះអាងថា ខ្លួនកំពុងតែកសាងប្រទេសមួយប្រកបដោយភាពស្មើគ្នានិងលុបបំបាត់ចោលវណ្ណៈសង្គមយ៉ាងណាក៏ដោយ ប៉ុន្តែជាតុពិតខ្មែរក្រហមបានបង្កើតឡើងនូវការបែងចែកវណ្ណៈថ្មីពីរនៅក្នុងប្រទេសគឺ "ប្រជាជនមូលដ្ឋាន" និង "ប្រជាជនថ្មី"។

ប្រជាជនមូលដ្ឋាន ឬប្រជាជនចាស់ គឺជាអ្នកទាំងឡាយណាដែលរស់នៅតាមតំបន់ជនបទ គ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជានៅមុនថ្ងៃ១៧ មេសា ១៩៧៥។ ខ្មែរក្រហមបានបែងចែកអ្នកទាំងនេះ ជាប្រជាជនពេញសិទ្ធិឬប្រជាជនត្រៀម។ ប្រជាជនពេញសិទ្ធិ គឺអ្នកទាំងឡាយណាដែលមិនមានបងប្អូនធ្លាប់ធ្វើការក្នុងរបបសាធារណរដ្ឋខ្មែរ ហើយជាសមាជិកនៃគ្រួសារក្រីក្រ ឬគ្រួសារកម្រិតកណ្តាលថ្នាក់ក្រោម (កសិករនិងកម្មករ)។ ប្រជាជនប្រភេទនេះត្រូវបានអនុញ្ញាតឱ្យទៅបោះឆ្នោត ឬឈរឈ្មោះឱ្យគេបោះឆ្នោត ទោះបីជាការបោះឆ្នោតមានតែម្តងគត់នៅថ្ងៃទី២០ មីនា ឆ្នាំ១៩៧៦ ក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យក៏ដោយ។ (ការបោះឆ្នោតនេះ មិនអនុលោមតាមបទដ្ឋានអន្តរជាតិទេ ហើយឈ្មោះសមាជិកសភាតំណាងប្រជាជនមិនត្រូវបានប្រកាសឱ្យប្រជាជនដឹងទេ)។ ប្រជាជនពេញសិទ្ធិអាចក្លាយជាប្រធានសហករណ៍ និងប្រធានកងផ្សេងៗ។ ប្រជាជនត្រៀម គឺអ្នកទាំងឡាយដែលមានបងប្អូនធ្លាប់ធ្វើការជាមួយរបបសាធារណរដ្ឋខ្មែរ។ ប្រជាជនប្រភេទនេះ នឹងទទួលបានការសន្តោសប្រណីដរាបណាអ្នកទាំងនោះខិតខំធ្វើការងារបានខ្ជាប់ខ្ជួន។




**ក្រុមគ្រួសាររបស់កម្មាភិបាលខ្មែរក្រហម ឈរនៅខាងមុខនាវាចិនមួយ ឈ្មោះថា តាឈឹង (មានន័យថា "ទីក្រុងធំ") នៅកំពង់ផែកំពង់សោម (បច្ចុប្បន្ន កំពង់ផែក្រុងព្រះសីហនុ) នៅរវាងឆ្នាំ១៩៧៥-១៩៧៨។** (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រជាជនថ្មី ឬប្រជាជន១៧មេសា គឺជាអ្នកទាំងឡាយណាដែលត្រូវបានជម្លៀសចេញពីទីក្រុង ឬទីប្រជុំជននានា នៅខែមេសា ឆ្នាំ១៩៧៥។ ទោះជាយ៉ាងដូច្នេះក៏ដោយ ប្រជាជនថ្មីភាគច្រើន គឺជាអ្នកដែលធ្លាប់រស់នៅជនបទហើយបានរត់កៀសខ្លួនមកកាន់ទីក្រុងដើម្បីគេចពីសង្គ្រាម។ ប្រជាជនថ្មី ត្រូវបានចាត់ទុកថាជាមនុស្សដែលមិនអាចជឿទុកចិត្តបាន ហើយទទួលការស្អប់ខ្ពើម និងការសង្ស័យពីសំណាក់អង្គការខ្មែរក្រហម។ អ្នកទាំងនេះ ត្រូវបានអង្គការចាត់ទុកថាជា "ជនបញ្ញើក្អែក" ដែលគ្មានសិទ្ធិអ្វីទាំងអស់ ដូចដែលពាក្យស្លោកខ្មែរក្រហមមួយឃ្លាបានអះអាងថា "ពួក១៧មេសាជាជនបញ្ញើក្អែក។ ពួកវាជាអ្នកចាញ់សង្គ្រាម និងជាឈ្លើយសឹក"។ ពាក្យស្លោកមួយទៀតដែលអ្នករស់រានមានជីវិតភាគច្រើននៅចងចាំនោះគឺ "ទុកក៏មិនចំណេញ ដកចេញក៏មិនខាត"។ ប្រជាជនថ្មី ទទួលរងការធ្វើទុក្ខបុកម្នេញខ្លាំងជាងប្រជាជនចាស់។ ប៉ុន្តែទំហំនៃអំពើឃោរឃៅ មានកម្រិតខុសៗគ្នាពីតំបន់មួយទៅតំបន់មួយទៀត។



សិស្សនារី ឈរជាជួរជាមួយអ្នកគ្រូខ្មែរក្រហមរបស់ខ្លួន នៅខាងមុខអគារសិក្សាមួយកន្លែង (នៅរវាងឆ្នាំ១៩៧៥-១៩៧៨)។ ខ្មែរក្រហមអនុញ្ញាតឱ្យកុមារទទួលបានការអប់រំកម្រិតបឋមប៉ុណ្ណោះ គឺរៀនពីរបៀបអាន និងសរសេរលេខនិងព្យញ្ជនៈសាមញ្ញ។ ពេលវេលាភាគច្រើនត្រូវបានប្រើប្រាស់ដើម្បីបង្រៀនពីគំនិត មនោគមន៍វិជ្ជា និងការឃោសនាបដិវត្តន៍។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ប្រជាជនទីក្រុងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហ្គូណា បើគស្ត្រម បានថតរូបនេះ ក្នុងអំឡុងពេលដែលគាត់ និងគណៈប្រតិភូដទៃទៀតកំពុងធ្វើ «ទស្សនកិច្ចការទូត» រៀបចំឡើងដោយខ្មែរក្រហម រយៈពេល១៤ថ្ងៃ ក្នុងឆ្នាំ១៩៧៨។ រូបថតនេះ ត្រូវបានដកស្រង់ចេញពីបណ្តុំរូបថតជាច្រើនទៀតនៅក្នុងសៀវភៅ «ឋាននរកកម្ពុជាប្រជាធិបតេយ្យ» ដែល ហ្គូណា បើគស្ត្រម បានថតក្នុងអំឡុងទស្សនកិច្ច។ ប្រភព៖ហ្គូណា បើគស្ត្រម/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

ឧទាហរណ៍ ប្រជាជននៅខេត្តស្វាយរៀងនិងព្រៃវែងក្នុងភូមិភាគបូព៌ា បានទទួលការគាំពារប្រសើរជាងអ្នកដែលត្រូវបានជម្លៀសទៅខេត្តពោធិ៍សាត់ និងបាត់ដំបងនៃភូមិភាគពាយ័ព្យ។

ចាប ស៊ីថា អាយុ៦៥ឆ្នាំ ជាប្រជាជន១៧មេសា បច្ចុប្បន្នរស់នៅក្នុងទីក្រុងភ្នំពេញ បានរៀបរាប់ពីជីវិតរបស់គាត់ថា៖

*នៅពេលជម្លៀសឆ្នាំ១៩៧៥ ក្រុមគ្រួសារខ្ញុំដែលមានសមាជិកទាំងអស់១៤នាក់ត្រូវបានជម្លៀសទៅរស់នៅស្រុកកោះធំ ខេត្តកណ្តាល។ នៅទីនោះ អង្គការចាត់តាំងឱ្យយើងដាំបន្លែបង្ការនិងធ្វើស្រែ។ ថ្ងៃមួយ វេលាម៉ោង៩យប់ ប្តីរបស់ខ្ញុំត្រូវអង្គការស្នើឱ្យទៅរៀនសូត្រមួយរយៈ។ ខ្ញុំរង់ចាំប្តីខ្ញុំ ប៉ុន្តែមិនឃើញគាត់ត្រឡប់មកវិញសោះ។ ស្ត្រីម្នាក់នៅក្នុងភូមិបានប្រាប់កូនរបស់ខ្ញុំម្នាក់ថា "មិនចាំបាច់មើលផ្លូវឪពុកឯងទេ ហើយប្រយ័ត្នប្រយែងមាត់ផង។ កុំនិយាយអ្វីផ្តេសផ្តាសឱ្យសោះ ប្រយ័ត្នគេយកទៅមួយពូជ ព្រោះឪពុកឯងមានប្រវត្តិធំណាស់"។ ខ្ញុំដឹងថាអង្គការបានយកប្តីខ្ញុំទៅសម្លាប់ចោល ព្រោះគាត់ជាអតីតចៅហ្វាយខេត្តកណ្តាល។ ២ខែក្រោយមក អង្គការបានប្រាប់ខ្ញុំឱ្យផ្លាស់ទៅរស់នៅទីក្រុងភ្នំពេញ។ តាមពិតគេនាំពួកយើងទៅខេត្តបាត់ដំបង។ អង្គការបានចែកកូនខ្ទមបាក់បែកមួយឱ្យក្រុមគ្រួសារខ្ញុំរស់នៅ។ ពួកយើងត្រូវបានបំបែកឱ្យទៅរស់នៅក្នុងកងផ្សេងៗគ្នា។ មានតែកូនស្រីពៅរបស់ខ្ញុំម្នាក់ អាយុ៦ឆ្នាំប៉ុណ្ណោះ ដែលរស់នៅជាមួយខ្ញុំ។ ជីវិតនៅបាត់ដំបងគឺជារឿងរ៉ាវមួយដែលមិនអាចបំភ្លេចបានទេសម្រាប់ខ្ញុំ។ ក្នុងរយៈពេលតែ១០ថ្ងៃប៉ុណ្ណោះ កូនប្រុសខ្ញុំ៤នាក់ និងកូនស្រីម្នាក់ បានស្លាប់បន្តបន្ទាប់គ្នា។ ខ្លះស្លាប់ដោយសារអត់អាហារនិងជំងឺ ខ្លះទៀតត្រូវបានសម្លាប់ ដោយអង្គការចោទប្រកាន់ថាមានជាប់ពាក់ព័ន្ធជាមួយខ្មាំង។ មួយរយៈក្រោយមក ម្តាយក្មេករបស់ខ្ញុំអាយុ៧០ឆ្នាំ បានស្លាប់ដោយជំងឺខ្វះអាហារបរិភោគ។ ជារៀងរាល់យប់ ខ្ញុំមិនដែលដេកបានស្រួលទេ។ ប្រជាជន នៅក្នុងភូមិរបស់ខ្ញុំជាច្រើនត្រូវអង្គការហៅទៅ ហើយបាត់ខ្លួនរហូត។*

## ៣. ពិធីរៀបមង្គលការ

មង្គលការ (ឬពិធីបើកវគ្គ) ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខុសគ្នាទាំងស្រុងពីមង្គលការតាមទំនៀមទម្លាប់ប្រពៃណីខ្មែរ។ កូនកំលោះក្រមុំទាំងអស់ ត្រូវបានរៀបចំក្នុងពិធីរួមតែមួយ ដែលមានចំនួនពី៣ទៅ១០គូ ក្នុងពិធីតូចហើយពី៣០ទៅ៥០គូ ឬរហូតដល់ជាង១០០គូ ក្នុងពិធីធំនីមួយៗ។ បុរសនារីភាគច្រើនមិនត្រូវបានអនុញ្ញាតឱ្យជ្រើសរើសគូស្រករបស់ខ្លួនទេ។ គូនីមួយៗ ត្រូវបានចាត់តាំងឡើងដោយអង្គការ ដែលអះអាងថាជាឪពុកម្តាយរបស់មនុស្សគ្រប់រូប។ អ្នកខ្លះមិនទាំងស្គាល់ឈ្មោះនិងមុខមាត់អនាគតគូស្រកររបស់ខ្លួនផង រហូតដល់ពេលប្រារព្ធពិធីតែម្តង។ បងប្អូនសាច់ញាតិ មិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងពិធីមង្គលការ ឬចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តណាមួយឡើយ។ សម្លៀកបំពាក់ប្រពៃណី ពិធីរាំវង់ ចម្រៀងប្រពៃណី និងពិធីតាមបែបសាសនា ត្រូវបានហាមឃាត់។

នារីមួយចំនួន ត្រូវបានបង្ខំឱ្យរៀបការជាមួយយុទ្ធជនពិការដាច់ដៃ ឬដាច់ជើងម្ខាង ដែលរងរបួសក្នុងពេលសង្គ្រាម។ នារីដែលជំទាស់មិនទទួលយកបុរសពិការទាំងនេះ អាចត្រូវបានចាប់ឃុំឃាំង ឬទទួលរងទណ្ឌកម្មជាទម្ងន់ ឬត្រូវបញ្ជូនឱ្យទៅធ្វើការនៅតំបន់ដាច់ស្រយាលឆ្ងាយៗពីផ្ទះសម្បែង។ នារីខ្លះដែលជួបប្រទះហេតុការណ៍បង្ខំបែបនេះបានធ្វើអត្តឃាត។



ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានរកឃើញរូបភាពនេះនៅក្នុងឆ្នាំ១៩៩៦។ រយៈពេលម្ភៃឆ្នាំក្រោយមក គឺក្នុងខែសីហា ឆ្នាំ២០១៦ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង បានរាយការណ៍ថាខ្លួនមានហ្វីលនៃរូបថតនេះ។ ក្នុងខែកញ្ញា ឆ្នាំ២០១៦ ប្រធានកងថតរូបនៃមន្ទីរស-២១ ញឹម គឹមស្រៀង បានផ្តល់សក្ខីកម្មនៅសាលាក្តីខ្មែរក្រហម និងបញ្ជាក់ថាខ្លួនជាអ្នកថតរូបមួយនេះនៅក្នុងគុកមួយរបស់ខ្មែរក្រហម គឺមន្ទីរស-២៤។ រូបថតនេះបង្ហាញអំពីការរៀបការរបស់ នុន ហ៊ុយ ហៅ ហ៊ុយ ស្រែ (ខាងឆ្វេង) និង ប្រុក ឃឿន ហៅ ប្រាក់ សាមុត (ខាងស្តាំ)។ ហ៊ុយកើតនៅឆ្នាំ១៩៥១ និងមាននាទីជាប្រធានមន្ទីរអប់រំរបស់ខ្មែរក្រហមនៅព្រៃស ដែលត្រូវបានស្គាល់ថាជាមន្ទីរស-២៤។ ព្រៃស គឺជាផ្នែកមួយនៃបណ្តុំមន្ទីរសន្តិសុខកណ្តាលផ្ទៃក្នុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយបណ្តុំនោះក៏រួមបញ្ចូលនូវមន្ទីរស-២១ និងវាលពិឃាតជើងឯកដែរ។ ឯកសាររបស់គុកមួយ ចុះថ្ងៃទី២៣ កក្កដា ឆ្នាំ១៩៧៧ បានរាយការណ៍អំពីការសម្លាប់អ្នកទោសចំនួន១៨នាក់នៅមន្ទីរស-២៤ និងភ្ជាប់មកជាមួយនឹងកំណត់ត្រាមួយចែងថា "បានសម្លាប់កុមារ១៦០នាក់ក្នុងចំណោមសត្រូវចំនួន១៧៨នាក់ដែលបានសម្លាប់"។ ឌុច អ្នកគ្រប់គ្រងមន្ទីរស-២១និងស-២៤ បានផ្តល់សក្ខីកម្មក្នុងសប្តាហ៍នោះថា ហ៊ុយត្រូវបានសម្លាប់បន្ទាប់ពីអ្នកធ្វើការផ្សាយវិទ្យុនៅព្រៃសម្នាក់បានគេចខ្លួន។ ប្រពន្ធរបស់ហ៊ុយ គឺ ប្រុក ឃឿន (កើតនៅឆ្នាំ១៩៥៣)គឺជាកម្មាភិបាលម្នាក់នៃមន្ទីរស-២៤រហូតដល់ខែមិថុនា ឆ្នាំ១៩៧៧ គឺនៃពេលដែលគាត់ត្រូវបានចាត់តាំងជាអនុប្រធានកងស្នួរចម្លើយ ដែលស្គាល់ថាជា «កងក្តៅ» នៅទួលស្លែង។ ប្រភព៖ មជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារលេខ D១១៧៥ និងK០៨២៧៣។ រូបថតពីមន្ទីរស-២៤ ដោយ ញឹម គឹមស្រៀង ប្រធានកងថតរូបមន្ទីរស-២១ (សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង)។ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។ ចំណងជើងរូបថតដោយ បណ្ឌិតផ្នែកច្បាប់ ចន ឌី. ឆចឈីអារី ទីប្រឹក្សាជាន់ខ្ពស់ផ្នែកច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ប្រភព៖ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងបណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

មូសា សុខា ជនជាតិចាមរស់នៅខេត្តក្រចេះ ជាអតីតប្រធានសមាគមស្ត្រីឃុំ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានរំឭកពីការរៀបការរបស់គាត់កាលពីសម័យខ្មែរក្រហម ដូច្នេះថា៖

*នៅឆ្នាំ១៩៧៤ ពេលខ្ញុំមានអាយុ១៥ឆ្នាំ។ ខ្ញុំបានរៀបការជាមួយអ្នកលីសែងគ្រឿងសព្វាវុធម្នាក់ឈ្មោះ ណុះ លាស់។ ពួកយើងសំណាងល្អណាស់ដែលបានរៀបការមួយខែមុនការអនុម័តច្បាប់ថ្មី ដែលហាមប្រាមប្រជាជនមិនឱ្យតុបតែងខ្លួននឹងគ្រឿងអលង្ការចក្រពត្តិ។ អ្វីក៏ដោយដែលប្រើសម្រាប់តុបតែងកាយ ត្រូវបានចាត់ទុកជារបស់ចក្រពត្តិទាំងអស់ សូម្បីតែគ្រឿងអលង្ការក្លែងក្លាយក៏ដោយ។ មកត្រឹមពេលនោះ មានបុរសស្ត្រីពី៥ទៅ១០គូ ត្រូវបានបង្ខំឱ្យរៀបការជារួមរួចស្រេចទៅហើយ។ ប្រសិនបើគូណាមួយជំទាស់មិនព្រមការជាមួយគ្នា ពួកគេនឹងត្រូវហៅឱ្យទៅរៀនសូត្រ។ ប្ដីប្រពន្ធដែលទើបការហើយថ្មីថ្មោង ត្រូវបំបែកចេញពីគ្នា។ ក្នុងពិធីមង្គលការរបស់ខ្ញុំ ខ្ញុំមានអ្នកកំដរនិងមានពាក់គ្រឿងអលង្ការ ប៉ុន្តែខ្ញុំស្លៀកពាក់ខ្មៅនិងពាក់ស្បែកជើងកង់ឡាន។ បន្ទាប់ពីការហើយបានបីថ្ងៃ អង្គការបានហៅប្ដីខ្ញុំឱ្យទៅសមរភូមិ ព្រោះអង្គការត្រូវការកម្លាំងបន្ថែមដើម្បីវាយរំលំរដ្ឋាភិបាលក្រុងភ្នំពេញ។ ខ្ញុំបានអង្វរប្រធានភូមិឱ្យប្ដីខ្ញុំស្នាក់នៅក្នុងភូមិ ប៉ុន្តែគាត់បានបដិសេធ។ នៅឆ្នាំ១៩៧៦ ខ្ញុំសម្រាលបានកូនប្រុសម្នាក់ ប៉ុន្តែបានស្លាប់ទៅវិញបន្ទាប់ពីមួយសប្តាហ៍ក្រោយមកដោយសារជំងឺ។*

អាពាហ៍ពិពាហ៍ដោយបង្ខំកាន់តែមានសភាពតឹងរ៉ឹងឡើង បន្ទាប់ពីជ័យជម្នះរបស់ខ្មែរក្រហមឆ្នាំ១៩៧៥។ បុរសស្ត្រីកាន់តែច្រើនគូត្រូវបានបង្ខំឱ្យរៀបការក្នុងពេលតែមួយ។ ផេង ហាង្ស ប្រជាជនមកពីខេត្តកំពង់ចាម បានរៀបរាប់ពីមង្គលការរបស់គាត់ដូច្នេះថា៖

*នៅឆ្នាំ១៩៧៨ គឺមួយខែមុនការដួលរលំនៃរបបនេះ អង្គការចាត់តាំងឱ្យខ្ញុំរៀបការ។ ស្អែកឡើង ខ្ញុំអង្គុយលើកៅអីនៅក្នុងពិធីរៀបការដោយតាំងចិត្តថា នឹងធ្វើតាមអ្វីដែលអង្គការបញ្ជា។ ពិធីនោះមានយុវជនយុវនារី ដែលត្រូវរៀបការសរុប១៦០គូ។ ខ្ញុំ និងប្រពន្ធខ្ញុំ បានសច្ចាថានឹងរួមរស់ជាមួយគ្នា និងមានកូនមួយក្នុងពេលមួយឆ្នាំ។ ខ្មែរក្រហមបានចែកខោអាវខ្មៅមួយកំប្លេនិងក្រមាមួយ ហើយមានរៀបចំម្ហូបអាហារឱ្យហូប។ ក្រោយបដិវត្តន៍ ខ្ញុំនិងប្រពន្ធខ្ញុំវិលមកផ្ទះវិញ។ ឥឡូវនេះ យើងមានកូនប្រាំនាក់។*



**នារីសិល្បៈជនជាតិអ៊ីស្លាមពីររូបគឺ មូសា សុខា (ស្តាំ) និងមិត្តរបស់គាត់ ថតនៅក្នុងស្ទូឌីយ៉ូថតរូបមួយកន្លែង នៅក្នុងតំបន់រំដោះខ្មែរក្រហម នៅខេត្តក្រចេះ ក្នុងឆ្នាំ១៩៧២។**
ប្រភព៖ មូសា សុខា/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា



**កងកម្លាំងស្ត្រី ស្លៀកពាក់ឯកសណ្ឋានទំពប្រដាប់ដោយអាវុធ កំពុងដើរដង្ហែគ្នានៅលើផ្លូវមួយ ក្នុងរបបខ្មែរក្រហម រវាងឆ្នាំ១៩៧៥-១៩៧៨។**
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃរៀបការ បុរសនារីទាំងអស់ឈរជាពីរជួរ។ បន្ទាប់មក ប្រធានភូមិបញ្ជាឱ្យអ្នកទាំងនេះចាប់ដៃគ្នាហើយធ្វើការប្ដេជ្ញាថា នឹងរួមរស់ជាមួយគ្នាអស់មួយជីវិត។ នេះបញ្ជាក់ថាបុរសនារីទាំងអស់នោះបានរៀបការរួចហើយ។ ពិធីដ៏ខ្លីនេះត្រូវបញ្ចប់បន្ទាប់ពីការហូបអាហារបន្តិចបន្តួចរួច។

បន្ទាប់ពីរៀបការហើយ ប្ដីប្រពន្ធបានទទួលការអនុញ្ញាតឱ្យរស់នៅជាមួយគ្នាតែពីរ-បីថ្ងៃប៉ុណ្ណោះ ហើយបន្ទាប់មកត្រូវទៅធ្វើការតាមក្រុមរៀងៗខ្លួនវិញ។ ប្ដីប្រពន្ធមួយចំនួន ទទួលបានការអនុញ្ញាតឱ្យមកជួបមុខគ្នាក្នុងរវាងពីប្រាំពីរទៅដប់ថ្ងៃម្តង។

ខ្មែរក្រហមចាត់ទុកពិធីរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ ដូចគ្នាទៅនឹងការគោរពប្រណិប័តន៍ជំនឿសាសនា និងការសិក្សានៅតាមសាលារៀនឬមហាវិទ្យាល័យដែរ គឺសកម្មភាពទាំងអស់នេះជាការចំណាយពេលវេលាឥតប្រយោជន៍និងគ្មានបានជួយអ្វីទាល់តែសោះក្នុងការបង្កបង្កើនផលស្រូវ។ មង្គលការរួមត្រូវបង្កើតឡើង ដោយសារតែវាចំណាយពេលវេលាតិច ហើយពេលវេលាដែលនៅសល់នឹងត្រូវចំណាយទៅលើការងារសហករណ៍និងអ្វីដែលខ្មែរក្រហមហៅថា “បដិវត្តន៍មហាលោតផ្លោះមហាអស្ចារ្យ” ដែលជាពាក្យស្លោកចម្លងចេញមកពីកុម្មុយនីស្តចិន។ មេដឹកនាំកម្ពុជាប្រជាធិបតេយ្យចង់បញ្ជាក់ឱ្យច្បាស់ថា ពិធីរៀបការនេះគឺដើម្បីបង្កើតកូនដែលអាចបន្តបដិវត្តន៍របស់ខ្លួនបាន។ សម្រាប់ខ្មែរក្រហម គោលបំណងចម្បងនៃការរៀបការមិនមែនដើម្បីបង្កើតក្រុមគ្រួសារនោះទេ ប៉ុន្តែដើម្បីបង្កើតមនុស្សដែលអាចបម្រើដល់បដិវត្តន៍បាន។

## ៤. ការរំលោភលើសិទ្ធិនិងពលកម្មរបស់កុមារ

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនមានសាលារៀនជាផ្លូវការទេ។ កុមារត្រូវបានបញ្ជូនឱ្យទៅរៀននៅក្រោមដើមឈើ ឬនៅក្រោមផ្ទះប្រជាជន។ គ្រូភាគច្រើន គឺជាកសិករក្រដែលអាចអាននិងសរសេរបានតែបន្តិចបន្តួចប៉ុណ្ណោះ។ ទោះបីជាការអប់រំនៅតាមតំបន់មួយចំនួន មានការរីកចម្រើនក្នុងឆ្នាំ១៩៧៨ (កុមារទទួលបានការសិក្សាថ្នាក់បឋម ពី២ទៅ៣ម៉ោងក្នុងមួយថ្ងៃ) ក៏ដោយ នៅតែមិនទាន់មានសាលារៀនដែលមានដំណើរការពេញលេញសម្រាប់សិក្សាដែរ។ ខ្មែរក្រហមនិយាយថា “អង្គការគ្មានទេសញ្ញាប័ត្រ មានតែសញ្ញាឃើញ។ បើចង់បានបាក់អង បាក់ឌុប ត្រូវទៅយកនៅទំនប់ប្រឡាយ” ហើយថា “ការរៀនអក្សរ រៀនលេខ មិនសំខាន់ទេ ការសំខាន់គឺការងារនិងចលនាបដិវត្តន៍”។

ស្របពេលដែលកុមារត្រូវបានបង្ហាត់បង្រៀនឱ្យចេះអាននិងសរសេរអក្សរបន្តិចបន្តួចនោះ ភាគច្រើននៃការអប់រំកុមារទាំងនោះ គឺផ្តោតទៅលើការអប់រំនយោបាយ។ ក្មេងៗត្រូវបានជ្រើសរើសឱ្យទៅចូលរួមវគ្គហ្វឹកហ្វឺនមនោគមន៍វិជ្ជា ដើម្បីអាចបម្រើក្នុងជួរកងទ័ព កងការពារ ឬនីរសារបាន។

ក្មេងៗក៏ត្រូវបានចាត់តាំងឱ្យធ្វើការងារដែរ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ការងាររបស់កុមារ គឺដើររើសអាចម៍គោ កាត់ទន្រ្ទានខែត្រ ប្រមូលលាមកមនុស្សដើម្បីធ្វើជី និងជញ្ជូនអាវុធទៅសមរភូមិ ដែលនៅទីនោះកុមារជួនកាលទទួលរងរបួសឬក៏ត្រូវគ្រាប់កាំភ្លើងស្លាប់ក៏មាន។ ជាងនេះទៅទៀត កុមារកុមារីទាំងនេះត្រូវបំបែកចេញពីឪពុកម្តាយ ហើយមិនដែលស្គាល់ភាពកក់ក្តៅក្នុងគ្រួសារឡើយ។

ភិន រដ្ឋា ប្រជាពលរដ្ឋរស់នៅរាជធានីភ្នំពេញ បានរំឭកពីរឿងរ៉ាវរបស់គាត់ ដែលជាក្មេងអាយុ១០ឆ្នាំ ក្នុងឆ្នាំ១៩៧៥ ថា៖

*ពួកយើងត្រូវបានជម្លៀសទៅស្រុកគិរីវង្ស ខេត្តតាកែវ។ នៅទីនោះ អង្គការចែកផ្ទះឱ្យមួយខ្នងដល់គ្រួសារនីមួយៗ។ ក្រុមគ្រួសារខ្ញុំរស់នៅដោយពឹងលើការដើររកក្តាម-ខ្យង ធ្វើជាម្ហូប។ បន្ទាប់ពីប្រជុំនយោបាយជាមួយប្រធានភូមិហើយ ពួកយើងត្រូវបានចាត់តាំងឱ្យហូបរួម ហើយខ្ញុំមិនអាចរកក្តាម-ខ្យងបានទៀតទេ។ ដោយសារតែឃ្លានខ្លាំងពេក ខ្ញុំឧស្សាហ៍លួចបេះបន្លែដែលយើងបានដាំនៅជុំវិញផ្ទះហូបណាស់។ ខ្ញុំត្រូវបានចាត់តាំងឱ្យទៅធ្វើការនៅកងចល័តកុមារដែលស្ថិតនៅឆ្ងាយពីផ្ទះ។ រយៈពេលបី-បួនខែទើបអង្គការអនុញ្ញាតឱ្យខ្ញុំមកលេងផ្ទះម្តង។ ការងាររបស់ខ្ញុំគឺ សែងកណ្តាប់ក្នុងស្រែ។ ពេលខ្លះខ្ញុំមិនចង់ចុះធ្វើការងារក្នុងស្រែទេ ពីព្រោះខ្ញុំខ្លាចឈ្លើងទាម។ ប្រធានកងនៅទីនោះតែងតែវាយធ្វើបាបខ្ញុំ។ ខ្ញុំបានរត់ទៅផ្ទះជាច្រើនដងដើម្បីឱ្យឪពុកម្តាយខ្ញុំជួយ ប៉ុន្តែគ្មានអ្នកណាអាចជួយខ្ញុំបានឡើយ។ បន្ទាប់មក ខ្ញុំបានទៅពួនក្នុងព្រៃអស់មួយរយៈ។ ខ្ញុំរស់នៅដោយបេះស្លឹកឈើព្រៃ និងផ្លែឈើព្រៃហូបនិងលួចម្ហូបអ្នកភូមិ។ ដោយមិនអាចទ្រាំបាននឹងស្ថានភាពរស់នៅដ៏លំបាកលំបិនបែបនោះ ខ្ញុំរត់មកនៅផ្ទះខ្ញុំវិញ។ ដោយខ្លាចអង្គការ ឪពុកម្តាយខ្ញុំបានបញ្ជូនខ្ញុំឱ្យទៅកងចល័តវិញ។ ពេលទៅដល់កងវិញ ប្រធានកងបានធ្វើទារុណកម្មខ្ញុំ និងព្រមានខ្ញុំមិនឱ្យរត់ទៀត។ ខ្ញុំត្រូវបានចាត់តាំងឱ្យដឹកស្លែទឹក និងក្រោយមកទៀត ប្រមូលអាចម៍ជ្រូក។ ថ្ងៃមួយ ដោយសារខ្ញុំ*



កងកុមារ កំពុងរែកដីនៅការដ្ឋានមួយកន្លែងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (នៅរវាងឆ្នាំ១៩៧៥-១៩៧៨)។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



**សុន សេន ឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីការពារជាតិ កំពុងត្រួតពិនិត្យកងកម្លាំងនៅពហុកីឡដ្ឋានជាតិ ក្នុងឆ្នាំ១៩៧៦។**
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

*មានការអស់កម្លាំងនិងទន់ជង្គង់ផង ខ្ញុំដួលហើយកំពប់អាចម៍ជ្រូកពីអម្រែក។ ប្រធានកងយករំពាត់ខ្សែគោមកវាយខ្ញុំ ហើយរំពាត់នោះខ្ទាតត្រូវភ្នែករបស់ខ្ញុំ។ ចាប់ពីពេលនោះមក ពីមួយថ្ងៃទៅមួយថ្ងៃ ភ្នែកខ្ញុំឈឺចាប់យ៉ាងខ្លាំង។ ទីបំផុតខ្ញុំត្រូវវង្វឹតមើលអ្វីលែងឃើញ។*

រស់ សំពៅ ប្រជាពលរដ្ឋរស់នៅទីក្រុងភ្នំពេញ បានបាត់បង់សមាជិកគ្រួសារទាំងអស់របស់គាត់ក្នុងសម័យខ្មែរក្រហម។ គាត់បានរៀបរាប់ថា៖

*គ្រួសាររបស់ខ្ញុំដែលមានសមាជិកប្រាំនាក់ ត្រូវបានដឹកទៅភ្នំត្រឡោកដែលស្ថិតក្នុងស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង (បច្ចុប្បន្ន ខេត្តបន្ទាយមានជ័យ)។ ខ្ញុំនិងកុមារផ្សេងទៀតត្រូវបានចាត់តាំងឱ្យទៅដឹកដី លើកទំនប់ ឃ្វាលគោ និងដើរកាប់ដើមទន្រ្ទានខែត្រ។ យើងត្រូវតែធ្វើឱ្យហើយតាមការកំណត់។ ប្រសិនបើមិនហើយ យើងនឹងត្រូវកាត់របបអាហារនិងទទួលទារុណកម្ម។ ឪពុករបស់ខ្ញុំស្លាប់ដោយជំងឺគ្រុនចាញ់ ចំណែកបងស្រីខ្ញុំស្លាប់ដោយសារជំងឺហើមពោះ។ គ្រាមួយបន្ទាប់ពីបំពេញការងារ យើងបានមកជួបជុំគ្នា ហើយប្រាប់គ្នាទៅវិញទៅមកអំពីប្រវត្តិគ្រួសាររបស់យើង។ បន្តិចក្រោយមក បងប្រុសម្នាក់បានដើរចូលមក ហើយប្រាប់ខ្ញុំថាម្តាយរបស់ខ្ញុំត្រូវអង្គការយកទៅសម្លាប់ចោលបាត់ទៅហើយ។ ក្រោយពីទទួលបានដំណឹងនេះភ្លាម ទឹកភ្នែកខ្ញុំហូរធ្លាក់មកដោយមិនដឹងខ្លួន។ ខ្ញុំមានអារម្មណ៍ថាខ្ញុំគ្មាននៅសេសសល់អ្វីទៀតទេ។ សូម្បីតែរូបខ្លួនឯងក៏ពុំដឹងថាអាចមានជីវិតរស់បានយូរប៉ុណ្ណាដែរ។ សមាជិកចុងក្រោយតែម្នាក់គត់របស់គ្រួសារខ្ញុំ គឺបងប្រុសរបស់ខ្ញុំដែលបាត់ខ្លួនដោយគ្មានដំណឹងអ្វីបន្តិចបន្តួចសោះ។*

ខ្មែរក្រហមបានបង្កើតពាក្យស្លោកទាក់ទងនឹងការអប់រំថា

"អង្គការយកម្លប់ឈើធ្វើជាសាលារៀននិងកន្លែងធ្វើមិទ្ទិង។ ធ្វើបណ្តើរ រៀនបណ្តើរ ធ្វើកាន់តែច្រើន ចេះកាន់តែច្រើន"។

កុមារទាំងឡាយត្រូវបានបង្ហាត់បង្រៀនថា "អង្គការជាមាតាបិតារបស់កុមារាកុមារីនិងយុវជនយុវនារី។ បើម៉ែឪវាយកូន មានន័យថា មើលងាយអង្គការ ដូច្នេះអង្គការមិនប្រណីឡើយ"។ កម្មាភិបាលខ្មែរក្រហម បានឱ្យកុមារស៊ើបការណ៍ពីឪពុកម្តាយរបស់ខ្លួន ហើយជួនកាល កុមារទាំងនេះហ៊ានសម្លាប់ឪពុកម្តាយបង្កើតរបស់ខ្លួនទៀតផង ប្រសិនបើទទួលបានបញ្ជាពីអង្គការ។ ក្នុងរយៈកាលកន្លងផុតទៅនេះ កុមាររាប់ម៉ឺននាក់បានជឿទៅលើអ្វីដែលអង្គការបានប្រាប់ ហើយគោរពតាមតែបញ្ជារបស់អង្គការប៉ុណ្ណោះ។

ក្នុងអំឡុងពេលសង្គ្រាមជាមួយវៀតណាមក្នុងឆ្នាំ១៩៧៧-១៩៧៨ កងទ័ពខ្មែរក្រហមជាច្រើនបានស្លាប់ឬរងរបួសជាទម្ងន់។ ខ្មែរក្រហម បានបញ្ជូនកុមារឱ្យទៅសមរភូមិមុខ ដែលនៅទីនោះ កុមាររាប់ពាន់នាក់ត្រូវរងរបួសនិងស្លាប់។

## ៥. ការបង្ខំឱ្យធ្វើការជាទម្ងន់

ប្រជាជនគ្រប់រូបក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានចាត់តាំងឱ្យធ្វើការងារទាំងអស់។ កុមារត្រូវបានប្រើឱ្យធ្វើការងារស្រាលៗ។ ចំណែកមនុស្សចាស់ៗ ត្រូវទទួលតួនាទីមើលថែទាំកុមារតូចៗនិងសត្វពាហនៈ ព្រមទាំងត្បាញកញ្ច្រែងល្អី។ មនុស្សដែលមានអាយុចាប់ពី ១៤ឆ្នាំឡើងទៅ (កុមារវ័យជំទង់) ត្រូវទទួលការងារធ្ងន់ៗនិងលំបាក។ កុមារជំទង់ៗទាំងនេះ ត្រូវទទួលបញ្ជាឱ្យជីកប្រឡាយឬអាងស្តុកទឹក លើកទំនប់ កាប់ឈើធ្វើផ្ទះ រានដីដើម្បីធ្វើស្រែចម្ការ ក៏ដូចជាដាំនិងច្រូតកាត់ស្រូវ។ បុរសស្ត្រីដែលបក្សទុកចិត្តប្រហែលពីពីរ-បីពាន់នាក់ ត្រូវបាន បញ្ជូនឱ្យទៅធ្វើការនៅរោងចក្រឯទីក្រុងភ្នំពេញ។

ប្រជាជនស្ទើរគ្រប់រូបធ្វើការច្រើនជាង១២ម៉ោងក្នុងមួយថ្ងៃ និង៧ថ្ងៃក្នុងមួយសប្តាហ៍ ដោយគ្មានពេលសម្រាកឬទទួលទានអាហារបាន គ្រប់គ្រាន់ទេ។ ប្រជាជនជួនកាលត្រូវធ្វើការតាំងពីព្រលឹមស្រាងៗរហូតដល់ពាក់កណ្តាលយប់ទើបឈប់សម្រាក។ ប្រសិនបើគ្មានពន្លឺខែវិញ ប្រជាជនអាចធ្វើការងារកសិកម្មបន្តទៀត តាមរយៈការអុចភ្លើងបំភ្លឺវាលស្រែ។ ប្រសិនបើនរណាម្នាក់ តវ៉ានឹងការងារដែលប្រធាន សហករណ៍ដាក់ឱ្យធ្វើ អ្នកនោះនឹងត្រូវចោទប្រកាន់ថាជាខ្មាំងរបស់បដិវត្តន៍និងត្រូវបញ្ជូនទៅ "អប់រំ"។ អ្នកដែលប្រព្រឹត្តកំហុសដដែលៗ ឬប្រព្រឹត្តកំហុសធ្ងន់ធ្ងរ នឹងត្រូវនាំយកទៅសម្លាប់ចោល។ ការប្រព្រឹត្តបែបនេះ គឺផ្ទុយទាំងស្រុងទៅនឹងមាត្រា១២ នៃរដ្ឋធម្មនុញ្ញកម្ពុជា ប្រជាធិបតេយ្យ ដែលមានសេចក្តីជាអាទិ៍ថា៖



**កងចល័តបុរស កំពុងសែងដីនៅការដ្ឋានមួយកន្លែងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (នៅរវាងឆ្នាំ១៩៧៥-១៩៧៨)។**

(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



**កសិករ កំពុងកៀរប្រមូលអំបិលក្នុងស្រែអំបិល នៅខេត្តកំពត ក្នុងរបបខ្មែរក្រហម (រវាងឆ្នាំ១៩៧៥-១៩៧៨)។**

(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

- ប្រជាជនកម្ពុជាគ្រប់រូប មានសិទ្ធិជីវភាពពេញទីខាងសម្ភារ ខាងស្មារតី និងខាងវប្បធម៌ ដែលត្រូវបានកែប្រែឱ្យរីកចម្រើនកាន់តែខ្ពស់ ឡើងជានិច្ច។ ប្រជាជនកម្ពុជាគ្រប់រូប សុទ្ធតែត្រូវធានាអះអាងខាងជីវភាពទាំងអស់។
- កម្មករគ្រប់រូប ជាម្ចាស់រោងចក្រ។
- កសិករគ្រប់រូប ជាម្ចាស់ស្រែចម្ការ។
- ពលករផ្សេងទៀត មានសិទ្ធិមានការងារធ្វើទាំងអស់។
- ភាពគ្មានការងារធ្វើ មិនមានដាច់ខាតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

## ៦. បន្សុទ្ធកម្ម និងការសម្លាប់រង្គាល

ខ្មែរក្រហម តែងតែស្រាវជ្រាវរកចាប់ខ្មាំង ហើយជឿជាក់ថាខ្មាំងមាននៅគ្រប់ទីកន្លែងទាំងអស់ទូទាំងប្រទេស។ ជនសង្ស័យ ជាច្រើននាក់ ត្រូវបានចោទប្រកាន់ថា ជាភ្នាក់ងារសម្ងាត់របស់អាមេរិក(សេ-អ៊ី-អា) ភ្នាក់ងារសម្ងាត់របស់សូវៀត(កា-ហ្សេ-បេ) ឬក៏ភ្នាក់ងារ សម្ងាត់របស់វៀតណាម។

ការប៉ះទង្គិចជាមួយវៀតណាមក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ បាននាំទៅដល់ការធ្វើបន្សុទ្ធកម្មដ៏ធំធេងមួយ។ នៅចុងឆ្នាំ១៩៧៧ បន្ទាប់ពី ប៉ុល ពត វិលត្រឡប់មកពីប្រទេសចិនវិញ កងទ័ពវៀតណាមបានវាយចូលប្រទេសកម្ពុជាភាគបូព៌ា។ ៣-៤ខែក្រោយមក កងទ័ពវៀតណាមបានដកថយទៅវិញ ដោយបានកៀរយកប្រជាជនកម្ពុជារាប់រយនាក់ទៅជាមួយផង។ បន្ទាប់មក ខ្មែរក្រហមបានចោទ ប្រជាជននិងកម្មាភិបាលភូមិភាគបូព៌ាថាបានចូលដៃចូលជើងជាមួយវៀតណាម។ ហេតុការណ៍នេះ បានជំរុញឱ្យមានការចាប់ខ្លួននិងការ សម្លាប់មនុស្សជាច្រើននាក់ រួមទាំងអ្នកដែលស្មោះត្រង់នឹងខ្មែរក្រហម និងដៃគូនយោបាយជើងចាស់ដ៏យូរលង់ដូចជា សោ ភឹម ទៀតផង។

បន្ទុទ្ធកម្មដ៏សាហាវយង់ឃ្នងបំផុតនៅក្នុងភូមិភាគនេះ បានកើតឡើងនៅឆ្នាំ១៩៧៨ បន្ទាប់ពីកងពលមួយចំនួននៃភូមិភាគនេះបានធ្វើការបះបោរប្រឆាំងនឹងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។ ពីខែមិថុនាដល់ខែកញ្ញា ឆ្នាំ១៩៧៨ ស្របពេលដែលការប៉ះទង្គិចជាមួយវៀតណាមកំពុងតែបន្ត តំបន់ភាគច្រើននៅក្នុងភូមិភាគនេះបានក្លាយទៅជាសមរភូមិរវាងកងទ័ពរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យនិងកងទ័ពបះបោរ។ មនុស្សប្រហែល១សែននាក់ក្នុងភូមិភាគបូព៌ា ត្រូវបានសម្លាប់និងបានស្លាប់នៅក្នុងសមរភូមិ។ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ បានបញ្ជូនយោធាខ្មែរក្រហមពីភូមិភាគនិរតីឱ្យទៅធ្វើការបង្ក្រាបជនក្បត់នៅភូមិភាគបូព៌ា។ ប្រជាជនរាប់ពាន់នាក់បានរត់ទៅកាន់ព្រំដែនវៀតណាម ដើម្បីគេចខ្លួនពីការសម្លាប់រង្គាលដែលផ្ទុះឡើង បន្ទាប់ពីការមកដល់នៃកងទ័ពទាំងនេះ។

បន្ទុទ្ធកម្មក៏កើតមានឡើងដែរនៅភូមិភាគឧត្តរក្នុងឆ្នាំ១៩៧៧។ បន្ទុទ្ធកម្មនេះផ្តោតទៅលើបញ្ញវន្ត និងអ្នកដែលមានជាប់ពាក់ព័ន្ធនឹង កុយ ធួន ដែលធ្វើជាលេខាភូមិភាគឧត្តររហូតដល់ដើមឆ្នាំ១៩៧៦។ ក្នុងអំឡុងពេលធ្វើបន្ទុទ្ធកម្មនេះ អង្គការបានចាប់ខ្លួនរដ្ឋមន្ត្រីក្រសួងព័ត៌មានឈ្មោះ ហ៊ូ នឹម, ទីវ អុល (គ្រូរបស់ កុយ ធួន) និងមិត្តភក្តិរបស់គាត់ជាច្រើននាក់ទៀតរួមមាន ភោគ ឆាយ និង ឌឿន ជាដើម មានគម្រោងធ្វើរដ្ឋប្រហារ និងការបះបោរបី-បួនលើក (ជាពិសេសការបះបោររបស់ជនជាតិចាម) ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[១៦]។ ប៉ុន្តែផែនការទាំងនេះសុទ្ធតែទទួលបរាជ័យ ហើយបានធ្វើឱ្យការស្រាវជ្រាវរកខ្មាំងបង្កប់ផ្ទៃក្នុងមានសភាពកាន់តែខ្លាំងក្លាឡើងៗ ដែលនាំទៅដល់ការធ្វើបន្ទុទ្ធកម្មនៅទូទាំងប្រទេស។

សាន់ តីម៉ាណាស់ រស់នៅខេត្តកំពង់ចាម បានរំឭកអំពីការសម្លាប់រង្គាលរបស់ខ្មែរក្រហមទៅលើជនជាតិភាគតិចចាម ជាពិសេសការសម្លាប់ក្រុមគ្រួសាររបស់អ្នកស្រីផ្ទាល់ ក្នុងអំឡុងពេលនៃការបះបោរ៖



កម្មាភិបាលសិល្បៈនារីខ្មែរក្រហម ថតរូបនៅក្បែរបឹងមួយ ដែលមានវិហារអ៊ីស្លាមនៅពីក្រោយ ក្នុងឆ្នាំ១៩៧៧។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



កម្មករកំពុងបំពេញការងារនៅរោងចក្រផលិតចានដែកមួយកន្លែង ក្នុងអំឡុងរបបខ្មែរក្រហម (ចន្លោះឆ្នាំ១៩៧៥-១៩៧៨)។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

*នៅសម័យសង្គមរាស្ត្រនិយម មានគ្រួសារជនជាតិចាមរាប់ពាន់គ្រួសាររស់នៅក្នុងភូមិរបស់ខ្ញុំ។ ពួកខ្មែរក្រហមបានសម្លាប់ពួកគេស្ទើរអស់។ ប្រជាជននៅក្នុងភូមិខ្ញុំនិងភូមិកោះផល ទទួលរងនូវអំពើព្រៃផ្សៃនេះច្រើនជាងគេ ពីព្រោះពួកយើងបះបោរប្រឆាំងនឹងពួកខ្មែរក្រហម។ ចំពោះគ្រួសារខ្ញុំវិញ ពួកវាសម្លាប់ឪពុកម្តាយខ្ញុំ កូនខ្ញុំ២នាក់ ចៅ២នាក់ និងបងប្អូនបង្កើតរបស់ខ្ញុំទាំងអស់។ កូនប្រុសរបស់ខ្ញុំឈ្មោះ មូសា ត្រូវខ្មែរក្រហមនាំយកទៅ បន្ទាប់ពីការបះបោរហើយក៏បាត់ខ្លួនរហូត។ ខ្ញុំឮពាក្យចចាមអារ៉ាមថា វាត្រូវបានសម្លាប់ក្នុងឆ្នាំ១៩៧៨ នៅពេលវាតាមរកខ្ញុំ។ កូនស្រីរបស់ខ្ញុំឈ្មោះ រ៉ហ្វីអះ ព្រមទាំងប្តីនិងកូន២នាក់ទៀត ត្រូវបានសម្លាប់ដោយគ្មានមូលហេតុ។*

*បន្ទាប់មក ពួកខ្មែរក្រហមបានបញ្ជូនគ្រួសាររបស់ខ្ញុំទៅភូមិស្រែវាល ក្នុងស្រុកស្ទឹងត្រង់។ មុនដំបូង ពួកវាចាត់តាំងខ្ញុំឱ្យទៅកាប់ដើមឈើជាមួយអ្នកជម្លៀសមកពីភ្នំពេញ។ មនុស្សជាច្រើនត្រូវបានសម្លាប់ដោយសារតែពួកគេធ្វើការមិនបានល្អ ឬត្រូវដើមឈើដួលរលំសង្កត់លើ។ បន្ទាប់មក ខ្ញុំត្រូវបានចាត់តាំងឱ្យចិញ្ចឹមជ្រូក។ ខ្ញុំបានប្រកែកដោយអះអាងថាខ្ញុំខ្លាចជ្រូកណាស់។ ប៉ុន្តែ ពួកវាបង្ខំខ្ញុំឱ្យធ្វើ ហើយគំរាមកំហែងខ្ញុំថាអង្គការនឹងបញ្ជូនខ្ញុំទៅរៀនសូត្រ ប្រសិនបើខ្ញុំមិនធ្វើ។ ពួកខ្មែរក្រហមថែមទាំងបង្ខំឱ្យខ្ញុំហូបសាច់ជ្រូកទៀតផង ប៉ុន្តែខ្ញុំប្រកែកដោយនិយាយថាខ្ញុំមិនដែលហូបសាច់សត្វទេតាំងពីតូចមក។ តាំងពីពេលនោះមក ពួកវាបានបដិសេធមិនឱ្យអាហារអ្វីទាំងអស់មកខ្ញុំ។ ខ្ញុំបានសុំអំបិលខ្លះ ប៉ុន្តែពួកវានិយាយថា របបអំបិលបានដាក់នៅក្នុងសម្លសាច់ជ្រូកអស់ហើយ។ ខ្លួនរបស់ខ្ញុំឡើងហើម។ ជាសំណាងល្អខ្ញុំបានរួចរស់ជីវិតពីរបបនេះ។ ខ្ញុំបានវិលត្រឡប់មកស្រុកកំណើតរបស់ខ្ញុំវិញនៅឆ្នាំ១៩៧៩។*



ឌុច ប្រធានមន្ទីរសន្តិសុខស-២១ និងនីរសារឈ្មោះ សុខ ក្នុងឆ្នាំ១៩៧៧។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



កងការពារខ្មែរក្រហម ថតនៅខាងមុខវិមានឯករាជ្យ ក្នុងទីក្រុងភ្នំពេញ (រវាងឆ្នាំ១៩៧៥-១៩៧៨)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជំពូកទី៩

# ប្រព័ន្ធសន្តិសុខ

## ១. មន្ទីរសន្តិសុខ

ទោះបីជាបន្សុទ្ធកម្មនៅភូមិភាគបូព៌ាក្នុងឆ្នាំ១៩៧៨ គឺជាព្រឹត្តិការណ៍ព្រៃផ្សៃបំផុតក្នុងរបបកម្ពុជាប្រជាធិបតេយ្យយ៉ាងណាក៏ដោយ ក៏នៅមានប្រជាជនរាប់សែននាក់ផ្សេងទៀតត្រូវបានចាប់ខ្លួន ហើយក្នុងករណីជាច្រើនទៀត ត្រូវបានសម្លាប់ចោលនៅតាមតំបន់ផ្សេងៗទៀតនៅទូទាំងប្រទេស។ មន្ទីរសន្តិសុខរបស់ខ្មែរក្រហមដែលរួមមានជិត២០០កន្លែង ត្រូវបានបង្កើតឡើងស្ទើរគ្រប់កន្លែងទាំងអស់លើផ្ទៃប្រទេស។ "មន្ទីរសន្តិសុខ" ជាពាក្យដែលខ្មែរក្រហមប្រើប្រាស់ សម្រាប់ជំនួសពាក្យ "គុក" ។

មន្ទីរសន្តិសុខក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានរៀបចំឡើងជា៥កម្រិត ដែលកម្រិតនីមួយៗត្រូវបានប្រើប្រាស់ជាកន្លែងឃុំឃាំងកន្លែងសួរចម្លើយ និងកន្លែងសម្លាប់។ អ្នកទោសដែលជាប់ឃុំក្នុងមន្ទីរសន្តិសុខ៣កម្រិតដំបូង(កម្រិតតំបន់ ស្រុក និងឃុំឬសហករណ៍) ភាគច្រើនជាអតីតទាហាននិងមន្ត្រីរដ្ឋការរបស់រដ្ឋាភិបាល លន់ នល់ ហើយអ្នកទោសផ្សេងទៀតគឺជាប្រជាជនសាមញ្ញដែលត្រូវបានចោទប្រកាន់ពីបទលួច

របស់របរឬលួចចំណីអាហារ រត់ចោលកន្លែង ឬនិយាយអាក្រក់ពីអង្គការ។ មន្ទីរសន្តិសុខកម្រិតភូមិភាគ មានឃុំឃាំងអ្នកទោសរាប់ពាន់នាក់ ជាយុទ្ធជនខ្មែរក្រហមនិងក្រុមគ្រួសារ ព្រមទាំងអ្នកដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើសផ្សេងៗនៅក្នុងភូមិភាគ។ មន្ទីរសន្តិសុខកម្រិតខ្ពស់បំផុត គឺជាមន្ទីរសន្តិសុខមជ្ឈិម មានទីតាំងនៅក្នុងក្រុងភ្នំពេញដែលមានឈ្មោះសម្ងាត់ថា"មន្ទីរស-២១"។ អ្នកទោសនៅក្នុងមន្ទីរស-២១ស្ទើរតែទាំងអស់ គឺជាអតីតកម្មាភិបាលនិងកងទ័ពខ្មែរក្រហម ដែលជាប់ចោទពីបទក្បត់បដិវត្តន៍។

នៅមន្ទីរសន្តិសុខថ្នាក់ក្រោម ការធ្វើទណ្ឌកម្មមិនសូវជាធ្ងន់ធ្ងរប៉ុន្មានទេ ដោយសារជាទូទៅអ្នកទោសត្រូវបានបញ្ជូនពីមន្ទីរសន្តិសុខទៅជំរំពលកម្ម ដែលនៅទីនោះអ្នកទោសត្រូវបានចាត់តាំងឱ្យសាងសង់ផ្ទះ ដាំបន្លែបង្ការ ឬចម្អិនម្ហូបអាហារ។ អ្នកទោសជាច្រើនដែលជាប់ឃុំក្នុងមន្ទីរសន្តិសុខទាំងនេះ ត្រូវបានដោះលែងវិញនៅមុនឆ្នាំ១៩៧៦។ ប៉ុន្តែចាប់តាំងពីឆ្នាំនោះមក ស្ទើរតែពុំមានអ្នកទោសណាម្នាក់ នៅថ្នាក់តំបន់និងថ្នាក់ស្រុកត្រូវបានដោះលែងឡើយ ហើយមានអ្នកទោសតិចតួចណាស់ដែលអាចរួចជីវិតពីមន្ទីរស-២១។

## ២. ខ្មាំងរបស់អង្គការ

ខ្មែរក្រហមចង់ឱ្យបដិវត្តន៍របស់ខ្លួន និងប្រជាជនកម្ពុជាទាំងអស់មានភាពស្អាតស្អំ។ ប្រជាជនទាំងអស់ ត្រូវតែស្អាតស្អំ ទាំងសតិអារម្មណ៍និងប្រវត្តិរូប។ កសិករក្រីក្រ ត្រូវបានខ្មែរក្រហមចាត់ទុកថាជាអ្នកបដិវត្តន៍ដ៏ស្អាតស្អំបំផុត។ ខ្មែរក្រហម មិនទុកចិត្តអ្នកផ្សេងក្រៅពីកសិករក្រទាំងនេះឡើយ។ ប្រជាជន ដែលបានប្រព្រឹត្តកំហុសតូចតាច ដូចជាការរអ៊ូរទាំអំពីការធ្វើការលំបាកឬក៏ការលួចម្ហូបអាហារ ត្រូវបានចាត់ទុកថាជាខ្មាំងរបស់អង្គការ និងជាញឹកញាប់អ្នកទាំងនោះបានក្លាយទៅជាមុខសញ្ញាដែលត្រូវយកទៅសម្លាប់ចោល។ មេដឹកនាំខ្មែរក្រហមបានបែងចែកសត្រូវរបស់ខ្លួនជាពីរប្រភេទ "សត្រូវខាងក្នុង" និង "សត្រូវខាងក្រៅ"។

**សត្រូវខាងក្នុង** គឺជាប្រភេទ "ប្រជាជនថ្មី" ឬ "ប្រជាជន១៧មេសា" និងអ្នកដែលធ្លាប់ធ្វើការក្នុងរបបចាស់ ដែលខ្មែរក្រហមចាត់ទុកថាជាពួកមូលធននិយមនិងពួកសក្តិភូមិនិយម។ ជំពូកប្រជាជនទាំងនេះក៏រួមបញ្ចូលទាំងអ្នកដែលមិនមានដើមកំណើតជាជនជាតិដែរ។ សត្រូវខាងក្នុងទាំងនេះធ្វើឱ្យមជ្ឈិមបក្ស[១៧] មានការខ្វល់ខ្វាយជាងអ្វីៗទាំងអស់។ ប្រភេទមនុស្សទាំងនេះ រួមមាន៖

**មន្ត្រីរដ្ឋការរបស់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ៖** ក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានធ្វើការសម្លាប់រង្គាលអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរជាច្រើនពាន់នាក់។ ខ្មែរក្រហមធ្វើការសម្លាប់ចាប់ពីថ្នាក់ដឹកនាំជាន់ខ្ពស់រហូតដល់កូនទាហាន។ អ្នកដែលធ្លាប់បម្រើឱ្យរដ្ឋាភិបាលសាធារណរដ្ឋខ្មែរទាំងប៉ុន្មានសុទ្ធតែជាមុខសញ្ញាដែលត្រូវសម្លាប់។ ជាទូទៅ សូម្បីតែសមាជិកគ្រួសារនិងសាច់ញាតិរបស់អ្នករដ្ឋការទាំងនេះក៏ត្រូវសម្លាប់ដែរ។ ទោះជាយ៉ាងណាក្តី ជាសំណាងល្អ អតីតទាហាននិងអ្នករដ្ឋការរាប់ពាន់នាក់បានខិតខំលាក់អត្តសញ្ញាណរបស់ខ្លួន ហើយបានរួចរស់ជីវិតមួយគ្រា ឬរួចរស់ជីវិតរហូតដល់ថ្ងៃដួលរលំរបស់របបកម្ពុជាប្រជាធិបតេយ្យ។

**ក្រុមជនជាតិភាគតិច៖** ខ្មែរក្រហមចង់បានជនជាតិខ្មែរដែលមិនមានជាប់ពាក់ព័ន្ធជាមួយរដ្ឋាភិបាលចាស់ក្នុងការអនុវត្តផែនការបដិវត្តន៍របស់ខ្លួន។ ជនជាតិភាគតិចរស់នៅក្នុងប្រទេសកម្ពុជាដទៃទៀត ដែលមិនទទួលបានការទុកចិត្តឬមានការសង្ស័យពីបក្ស ត្រូវបានធ្វើទុក្ខបុកម្នេញ។

**ក) ជនជាតិភាគតិចតំបន់ភ្នំ៖** មុនពេលឡើងកាន់អំណាចនៅឆ្នាំ១៩៧៥ មេដឹកនាំខ្មែរក្រហមភាគច្រើនធ្លាប់បានរស់នៅក្នុងចំណោមជនជាតិភាគតិចតំបន់ភ្នំក្នុងភូមិភាគឦសាន។ មេដឹកនាំខ្មែរក្រហមទាំងនេះ មានការជឿទុកចិត្តលើជនជាតិភាគតិចតំបន់ភ្នំទាំងនេះណាស់ ដោយយល់ឃើញថា ជនជាតិទាំងនេះមានចិត្តស្មោះត្រង់។ ជនជាតិភាគតិចមួយចំនួន បានក្លាយជាកងការពាររបស់ ប៉ុល ពត ទៀតផង។ ប៉ុន្តែ ទោះបីជារបបនេះបានអះអាងថាស្រលាញ់ស្មោះស្ម័គ្រនិងជឿទុកចិត្តលើជនជាតិតំបន់ភ្នំយ៉ាងណាក៏ដោយ ក៏ខ្មែរក្រហមបានចាប់ផ្តើមធ្វើការផ្លាស់ទីលំនៅជនជាតិភាគតិចក្នុងខេត្តមណ្ឌលគិរីឱ្យទៅរស់នៅផ្តុំគ្នាក្នុងស្រុកកោះញែក នៅដើមឆ្នាំ១៩៧២ ដែលបណ្តាលឱ្យប្រជាជនស្លាប់ជាច្រើន។ អ្នកដែលជំទាស់មិនព្រមទៅ ត្រូវបានសម្លាប់ចោល។

ផ្សុស ប្រៃ ជនជាតិព្នងរស់នៅក្នុងខេត្តមណ្ឌលគិរី រៀបរាប់ពីស្ថានភាពគ្រួសាររបស់គាត់ បន្ទាប់ពីមានត្រូវបានបង្ខំឱ្យផ្លាស់ប្តូរទីលំនៅក្នុងរបបខ្មែរក្រហមថា ៖

> *ក្មួយស្រីរបស់ខ្ញុំអាយុ១៥ឆ្នាំត្រូវខ្មែរក្រហមបាញ់សម្លាប់ ដោយសារតែនាងស្រែកថានាងមិនចង់ទៅរស់នៅកន្លែងផ្សេង។ ខ្ញុំត្រូវបានបំបែកចេញពីគ្រួសារឱ្យទៅធ្វើស្រែចម្ការនៅកន្លែងជាច្រើន។ នៅក្នុងស្រុកកោះញែក ប្រជាជនធ្វើការទាំងថ្ងៃទាំងយប់ ដោយទទួលបានរបបអាហារតិចតួចនិងមានការហត់ហេវអស់កម្លាំងជាខ្លាំង។ កូនស្រីរបស់ខ្ញុំដែលទើបតែឆ្លងទន្លេហើយមិនមានអ្វីហូបក្រៅតែពីក្តួចនោះទេ។ ដូច្នេះហើយប្តីរបស់នាងទៅរកអង្ករបាន៨កំប៉ុងនិងមាន់មួយពីភូមិផ្សេង។ ប្រធានឃុំបានចោទកូនប្រសាខ្ញុំថាហូបឯកជន។ សមាជិកគ្រួសារកូនស្រីខ្ញុំទាំងអស់ត្រូវអង្គការចាប់ខ្លួន។ ក្នុងភូមិឡាំទឹក ប្រជាជនពីរនាក់ត្រូវបានចាប់យកទៅសម្លាប់ចោល ព្រោះពួកគេបានហូបផ្លិតឃ្មុំដោយមិនចែកអ្នកភូមិ។*

**ខ) ជនជាតិភាគតិចចាម៖** ខ្មែរក្រហមបានបង្ខំឱ្យជនជាតិចាមចាកចេញពីលំនៅឋានរបស់ខ្លួន ហើយទៅរស់នៅលាយឡំគ្នាជាមួយសហគមន៍ជនជាតិខ្មែរ។ ជនជាតិចាម ត្រូវបានហាមប្រាមមិនឱ្យនិយាយភាសាចាម ឬគោរពបូជាសាសនាអ៊ីស្លាម។ ខ្មែរក្រហមបានសម្លាប់មេដឹកនាំសាសនាអ៊ីស្លាម (ហាកឹម) និងជនជាតិចាមទាំងឡាយណា ដែលត្រូវបានសង្ស័យថាជាអ្នកប្រឆាំងនឹងគោលនយោបាយខ្លួនអស់ជាច្រើន។ ជាងនេះទៅទៀត ខ្មែរក្រហមបានបង្ខំឱ្យជនជាតិចាមបរិភោគសាច់ជ្រូក ដែលផ្ទុយទៅនឹងការហាមប្រាមរបស់សាសនាអ៊ីស្លាម។ ស្ថិតក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ជនជាតិចាមរាប់ម៉ឺននាក់បានស្លាប់ដោយការសម្លាប់ ដោយជំងឺ ការអត់ឃ្លាន និងការធ្វើការហួសកម្លាំង[១៨]។

**គ) ជនជាតិភាគតិចវៀតណាម៖** ជនជាតិវៀតណាម ត្រូវបានបណ្តេញចេញពីប្រទេសកម្ពុជាក្នុងទ្រង់ទ្រាយធំក្នុងឆ្នាំ១៩៧៥។ ជនជាតិវៀតណាមមួយចំនួនដែលបានរៀបការជាមួយជនជាតិខ្មែរ បានរស់នៅក្នុងប្រទេសកម្ពុជាបន្តទៅទៀត។ ក្នុងឆ្នាំ១៩៧៧និងឆ្នាំ១៩៧៨ ខ្មែរក្រហមបានចាប់ផ្តើមសម្លាប់ជនជាតិវៀតណាមដែលសេសសល់ទាំងនេះយ៉ាងរង្គាល ហើយមានតែជនជាតិវៀតណាមមួយចំនួនតូចប៉ុណ្ណោះដែលបានរួចរស់ជីវិត។ ជនជាតិភាគតិចវៀតណាមត្រូវបានសម្រាំងយកទៅសម្លាប់ ដោយសារតែខ្លួនជាជនជាតិវៀតណាម។

**ឃ) ជនជាតិភាគតិចចិន៖** សមាជិកនៃសហគមន៍នេះ ដែលជាអ្នកជំនួញនិងជាសហគ្រិនក្រុមហ៊ុន ក៏ត្រូវបានបង្ខំឱ្យធ្វើដំណើរទៅកាន់ទីជនបទដើម្បីធ្វើការងារកសិកម្មដែរ។ ជនជាតិភាគតិចចិនត្រូវខ្មែរក្រហមប្រព្រឹត្តមកលើជនជាតិចិនយ៉ាងឃោរឃៅ នៅពេលដែលអ្នកទាំងនេះមិនអាចទ្រាំទ្រនឹងការងារលំបាកបាន។ ប៉ុន្តែជនជាតិចិនមិនត្រូវបានសម្រាំងជ្រើសរើសដើម្បីយកទៅសម្លាប់ចោលទេ។

**បញ្ញវន្ត៖** មេដឹកនាំខ្មែរក្រហមដែលមួយចំនួនជាបញ្ញវន្ត បានចាត់ទុកបញ្ញវន្តដទៃទៀតថាជាសត្រូវដ៏ចម្បងរបស់ប្រទេស និងជាជំពូកជនពុករលួយដែលធ្វើឱ្យប្រទេសជាតិក្លាយទៅជាអាយ៉ងរបស់បរទេស។ បញ្ញវន្តជាច្រើនបានក្លាយជាមុខសញ្ញាសម្លាប់របស់ខ្មែរក្រហម។ អ្នកដែលអាចត្រូវចាត់បញ្ចូលក្នុងជំពូក "អ្នកចេះដឹង" ត្រូវតែធ្វើពុតជាមនុស្សល្ងង់ខ្លៅ។ បញ្ញវន្តអាចរួចរស់ជីវិតបាន លុះត្រាណាតែអ្នកទាំងនោះអាចលាក់បាំងចំណេះវិជ្ជានិងអាជីពការងាររបស់ខ្លួន។ សាស្ត្រាចារ្យនិងនិស្សិតមហាវិទ្យាល័យរាប់ពាន់នាក់ ត្រូវបានសម្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។



**កងសន្តិសុខមន្ទីរ ស-២១ និងទីប្រឹក្សាចិន ឈរនៅក្បែររថយន្តហ្ស៊ីប និងរថយន្តដឹកអ្នកទោស ដែលត្រូវបានជឿជាក់ថា ជារថយន្តដឹកអ្នកទោសយកទៅសម្លាប់នៅវាលពិឃាត (រវាងឆ្នាំ១៩៧៥-១៩៧៨)។** (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងសៀវភៅ "ជីវិតកូនថ្លៃ កូនត្រូវតែរស់" វិស្វករ ពិន យ៉ាថៃ បានរៀបរាប់ពីបទពិសោធន៍ដែលគាត់បានជួបប្រទះក្នុងរបបខ្មែរក្រហម។ ក្នុងអំឡុងពេលជម្លៀសឆ្នាំ១៩៧៥ គ្រួសាររបស់គាត់ដែលមានសមាជិកដប់ប្រាំបីនាក់ ត្រូវបានបង្ខំឱ្យផ្លាស់ទីលំនៅជាច្រើនដង ដែលនៅចុងក្រោយគ្រួសារគាត់បានទៅដល់ខេត្តពោធិ៍សាត់។ ពិន យ៉ាថៃ ជាមនុស្សតែម្នាក់គត់ក្នុងគ្រួសារដែលនៅរស់រានមានជីវិត ហើយបានលួចរត់គេចទៅប្រទេសថៃនៅដើមឆ្នាំ១៩៧៧។ មូលហេតុមួយដែលធ្វើឱ្យ ពិន យ៉ាថៃ រួចរស់ជីវិតបាន គឺដោយសារគាត់អាចលាក់បាំងវិជ្ជាជីវៈរបស់គាត់។ លោកបានរៀបរាប់ដូច្នេះថា ៖

*ថ្ងៃមួយ នៅភូមិវាលវង់ក្នុងខេត្តពោធិ៍សាត់ ប្រធានភូមិបានរៀបចំប្រជុំនយោបាយដ៏គួរឱ្យធុញទ្រាន់ម្តងទៀត។ គាត់បានប្រកាសថាសម្តេចព្រះ នរោត្តម សីហនុ បានយាងនិវត្តចូលប្រទេសវិញហើយ ហើយកំពុងតែរៀបចំរដ្ឋាភិបាលថ្មីមួយ ដូច្នេះអង្គការសូមស្នើឱ្យអ្នកឯកទេស បញ្ញវន្ត អតីតនាយទាហាន វេជ្ជបណ្ឌិត វិស្វករ និងនិស្សិត អញ្ជើញមកចុះឈ្មោះក្នុងបញ្ជីពិសេសមួយ។ មនុស្សប្រហែលសែសិបនាក់បានលើកដៃ ដោយរួមទាំងអតីតទាហាន ដែលបានខិតខំលាក់អត្តសញ្ញាណរបស់ខ្លួនតាំងពីយូរមកហើយ។ ខ្ញុំមានការរារែកក្នុងចិត្ត ប៉ុន្តែខ្ញុំអាចទប់អារម្មណ៍ខ្លួនឯងបាន ហើយមិនបានលើកដៃនឹងគេទេ។ ចាប់តាំងពីពេលនោះមក យើងមិនដែលបានទទួលដំណឹងអ្វីពីអ្នកទាំងនោះទេ។ អ្នកភូមិបានខ្សឹបខ្សៀវប្រាប់គ្នាថា "អតីតមន្ត្រីជាន់ខ្ពស់និងអ្នកឯកទេសទាំងនោះត្រូវខ្មែរក្រហមសម្លាប់អស់ទៅហើយ"។[១៩]*


**កម្មាភិបាលសួរចម្លើយនៅមន្ទីរស-២១។ ពីឆ្វេងទៅស្តាំ៖ ទុយ, ណាន, មិនស្គាល់ឈ្មោះ និងទិត្យ (រវាងឆ្នាំ១៩៧៥-១៩៧៨)។** (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**អ្នកដែលខ្មែរក្រហមចោទថាជាជនក្បត់ជាតិ៖** កម្មាភិបាលខ្មែរក្រហមជាច្រើននាក់ត្រូវបានចោទថាជាជនក្បត់បដិវត្តន៍ និងចូលដៃជាមួយវៀតណាម។ ប្រជាជនសាមញ្ញដែលធ្វើខុសបន្តិចបន្តួច ក៏ត្រូវចោទថាជាជនក្បត់បដិវត្តន៍ដែរ។ ជាទូទៅ បទឧក្រិដ្ឋដែលកម្មាភិបាល និងប្រជាជនទាំងនេះបានសារភាពរួមមាន លួចមកលេងផ្ទះដោយមិនបានប្រាប់ប្រធានក្រុម ធ្វើឱ្យបែកបាក់ឧបករណ៍ផ្ទះបាយ លួចចំណីអាហារ និយាយរិះគន់អង្គការ មកធ្វើការយឺតយ៉ាវមិនទាន់ពេលវេលា ធ្វើការមិនបានល្អ ត្អូញត្អែរពីលក្ខខណ្ឌរស់នៅពាក់គ្រឿងអលង្ការ មានទំនាក់ទំនងស្នេហាខុសវិន័យបក្សយំសោកស្តាយស្រណោះបងប្អូនឬមិត្តភក្តិដែលបានស្លាប់ ឬបង្ហាញទឹកចិត្តក្នុងការគោរពជំនឿសាសនាជាដើម។ ប្រជាជនមួយចំនួនដែលធ្លាក់ខ្លួនឈឺដោយសារធ្វើការធ្ងន់ធ្ងរ ឬហូបមិនគ្រប់គ្រាន់ ត្រូវខ្មែរក្រហមចោទប្រកាន់ថាកុហកធ្វើពុតជាឈឺ និង ត្រូវបានចាត់ទុកថាជាមនុស្សខ្ជិលច្រអូសឬឈឺសតិអារម្មណ៍។ អ្នកទាំងនេះជាញឹកញាប់ត្រូវបានបាត់ខ្លួនដោយគ្មានដំណឹងអ្វីទាំងអស់។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ការធ្វើការងារច្រើនជាងឬតិចជាងការកំណត់របស់អង្គការគឺមានន័យស្មើសេចក្តីស្លាប់ ដូចពាក្យស្លោកខ្មែរក្រហមនិយាយថា "អង្គការថាម៉េច ត្រូវធ្វើយ៉ាងហ្នឹង! អង្គការដាក់ទិស ត្រូវអនុវត្តឱ្យបានសម្រេច! មិត្តមិនបាច់តថ្លៃទេ!"។

**សត្រូវខាងក្រៅ** សំដៅទៅលើសហរដ្ឋអាមេរិកនិងសម្ព័ន្ធមិត្តដូចជាប្រទេសថៃ និងប្រទេសសង្គមនិយម មួយចំនួន ជាពិសេសប្រទេសវៀតណាមនិងអតីតសហភាពសូវៀត។ ខ្មែរក្រហមយល់ថាប្រទេសទាំងអស់នេះមានគោលបំណងឈ្លានពាន និងប៉ុនប៉ងចង់យកកម្ពុជាដាក់ក្រោមអាណានិគម។ ខ្មែរក្រហមបានចោទប្រកាន់មនុស្សជាច្រើននាក់រួមទាំង កម្មាភិបាលនិងកងទ័ពរបស់ខ្លួនផងថាបានបម្រើឱ្យមនោគមន៍វិជ្ជារបស់ប្រទេសទាំងនេះ។ ខ្មែរក្រហមបានហៅអ្នកទាំងនេះថាជា «ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង»។ អ្នកទាំងនោះរួមមានអ្នកដែលមកពីប្រទេសដែលប្រឆាំងនឹងរបបសង្គមនិយមដឹកនាំដោយសហរដ្ឋអាមេរិកនិងប្រទេសសេរីនិយម ឬប្រទេសអនុត្តរភាពនិយម ដូចជាអតីតសហភាពសូវៀត វៀតណាម និងសម្ព័ន្ធមិត្តដទៃទៀត។ មនុស្សភាគច្រើនដែលត្រូវបានចាត់ទុកថាជាសត្រូវបង្កប់ស៊ីរូងផ្ទៃក្នុង ត្រូវបានចោទប្រកាន់ដោយច្រឡំថា បានធ្វើការឱ្យភ្នាក់ងារសម្ងាត់សេ-អ៊ី-អា របស់សហរដ្ឋអាមេរិក ភ្នាក់ងារសម្ងាត់កា-ហ្សេ-បេ របស់សហភាពសូវៀត និងជាភ្នាក់ងារសម្ងាត់របស់វៀតណាម។ ខ្មែរក្រហមក៏បានចាត់ទុកអ្នកដែលអាចនិយាយភាសាបរទេសថាជាភ្នាក់ងារសម្ងាត់ដែរ។ ការចោទប្រកាន់នេះបានក្លាយទៅជាវិធីមួយដ៏មានប្រសិទ្ធភាព សម្រាប់កម្មាភិបាលមូលដ្ឋាន យកធ្វើជាលេសសម្លាប់ប្រជាជនណាម្នាក់ដែលខ្លួនស្អប់ខ្ពើម។

## ៣. ការចាប់ខ្លួននិងការឃុំខ្លួន


**គំនូរមួយផ្ទាំង បង្ហាញអំពីទង្វើដ៏ព្រៃផ្សៃលើកុមារ នៅក្នុងអំឡុងរបបខ្មែរក្រហម។ នៅពេលដែលកងសន្តិសុខមន្ទីរ ស-២១ បញ្ជូនអ្នកទោសជាឪពុកម្តាយយកទៅសម្លាប់នៅវាលពិឃាតជើងឯក កូនៗរបស់អ្នកទោសទាំងនោះ ក៏ត្រូវកងសន្តិសុខសម្លាប់ដែរ ដោយចាប់ជើងបោកនឹងគល់ឈើមួយដើមនៅក្នុងបរិវេណនេះ។ គំនូរនេះ ជាអំណោយរបស់ ចេមស៍ មីហ្សឺស្គី ជល់លោកឆាំង យុ ក្នុងឆ្នាំ២០០០។** (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅចុងឆ្នាំ១៩៧៦ និងដើមឆ្នាំ១៩៧៧ ការស្រាវជ្រាវរកខ្មាំងបង្កប់ផ្ទៃក្នុងបានក្លាយជាកិច្ចការចម្បងរបស់ខ្មែរក្រហម។ ខ្មែរក្រហមបានបញ្ចុះបញ្ចូលអ្នកភូមិឱ្យស៊ើបការណ៍ពីគ្នាទៅវិញទៅមក ដោយប្រើប្រាស់ពាក្យស្លោក "ត្រូវបេះតាមដានគ្នាទៅវិញទៅមក។ ត្រូវរាយការណ៍ជូនអង្គការ"។ មធ្យោបាយផ្សេងៗទៀតដែលខ្មែរក្រហមប្រើក្នុងការស្វែងរកចាប់ខ្លួនខ្មាំងបង្កប់រួមមាន ការឈ្លបយកការណ៍ របាយការណ៍ពីអ្នកយកការណ៍ ការធ្វើប្រវត្តិរូបផ្ទាល់ខ្លួនញឹកញាប់ និងចម្លើយសារភាព។

នៅពេលដែលខ្មាំងត្រូវបានរកឃើញ ឈ្មោះរបស់អ្នកទាំងនេះនឹងត្រូវរាយការណ៍ទៅគណៈកម្មាធិការឃុំ ឬគណៈកម្មាធិការស្រុក ហើយបន្ទាប់មកអ្នកទាំងនេះនឹងត្រូវចាប់ខ្លួន។ អង្គការកម្រចាប់ខ្លួននរណាម្នាក់ជាសាធារណៈណាស់។ ប្រសិនបើមានសមាជិកណាម្នាក់នៅក្នុងសហករណ៍មួយត្រូវបានសង្ស័យ កម្មាភិបាលសហករណ៍នោះនឹងប្រាប់អ្នកនោះថា "អង្គការអញ្ជើញអ្នកទៅរៀនសូត្រ"។ ក្រោមលេសអញ្ជើញនេះ ជនរងគ្រោះជាច្រើនត្រូវបានចាប់បញ្ជូនទៅកាន់មន្ទីរឃុំឃាំងនិងសម្លាប់ចោលជាញឹកញាប់ ដោយមិនមានការស្រាវជ្រាវឱ្យបានហ្មត់ចត់ថាតើអ្នកទាំងនោះពិតជាបានប្រព្រឹត្តកំហុសបែបនោះមែនឬក៏មិនមែនទេ។ ខ្មែរក្រហមនិយាយថា "សុខចិត្តចាប់ខុស១០ មិនឱ្យលែងខុស១"។

## ៤. ការសួរចម្លើយ និងការធ្វើទារុណកម្ម

ជាទូទៅ អ្នកដែលជាប់ចោទពីបទល្មើសស្រាលៗ ឬជាប់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខថ្នាក់ទាប តែងទទួលបានរបបអាហារមិនគ្រប់គ្រាន់ កើតមានជំងឺគ្មានការព្យាបាល និងទទួលរងអំពើព្រៃផ្សៃផ្សេងៗទៀត។ ទោះបីជាមានអ្នកទោសជាច្រើននាក់ស្លាប់ក្នុងស្ថានភាពបែបនេះក៏ដោយ ក៏មានអ្នកទោសមួយចំនួនទៀតបានរួចផុតពីការធ្វើទារុណកម្មនិងការសម្លាប់ដែរ។ នៅមន្ទីរសន្តិសុខកម្រិតខ្ពស់របស់ខ្មែរក្រហម ដូចជាមន្ទីរស-២១ ការសួរចម្លើយ និងការធ្វើទារុណកម្ម គឺជាសកម្មភាពធម្មតាប្រចាំថ្ងៃ។

ជូ សូភា រស់នៅក្នុងខេត្តកំពង់ចាមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សូភា ត្រូវបានចាប់ខ្លួនក្នុងខែឧសភា ឆ្នាំ១៩៧៧ ដោយមិនដឹងមូលហេតុអ្វីទាំងអស់។ សូភា បានរៀបរាប់ពីការចាប់ខ្លួននិងស្ថានភាពរបស់គាត់កាលនៅក្នុងគុកស្រុកត្បូងឃ្មុំយ៉ាងដូច្នេះថា៖

*ថ្ងៃមួយ កងសន្តិសុខ៤នាក់បានមកដល់កងរបស់ខ្ញុំ ហើយបានស្នើខ្ញុំក្នុងសម្តីសុភាពរាបសារថា ឱ្យទៅជួយតខ្សែភ្លើង។ នៅពេលខ្ញុំចេញមកដល់ក្រៅ កងសន្តិសុខស្ទុះមកភ្ជង់កាំភ្លើងតម្រង់រកខ្ញុំ ហើយចងដៃខ្ញុំ។ ពួកគេបានចាប់ខ្ញុំយកទៅដាក់គុក។ បន្ទាប់ពីស្នាក់នៅក្នុងគុកអស់រយៈពេលសែសិបថ្ងៃ ខ្មែរក្រហមបញ្ជូនខ្ញុំមកសួរចម្លើយដែលមានសភាពឃោរឃៅជាងមុនទៅទៀត។ កងសន្តិសុខ បានយកខ្សែភ្លើងមកឆក់ខ្ញុំដើម្បីសួរចម្លើយ។ ជួនកាលគេវាយខ្ញុំយ៉ាងខ្លាំង ធ្វើឱ្យខ្ញុំសន្លប់ជាច្រើនសា។ ទោះជាធ្វើទណ្ឌកម្មខ្ញុំខ្លាំងយ៉ាងណាក៏ដោយ ក៏ខ្ញុំនៅតែឆ្លើយថាមិនដឹង។ បន្ទាប់មក ពួកគេបញ្ជូនខ្ញុំទៅមន្ទីរសួរចម្លើយថ្មីមួយទៀត។ ខ្ញុំនៅទីនោះរយៈពេលដប់ពីរថ្ងៃ។ ចាប់ពីពេលនោះមក ពួកគេលែងសួរចម្លើយឬធ្វើទារុណកម្មខ្ញុំទៀតហើយ។ ខ្លួនប្រាណខ្ញុំចុះស្គមយ៉ាងខ្លាំង។ បីថ្ងៃក្រោយមក ខ្មែរក្រហមដោះលែងខ្ញុំ ដោយនិយាយថាអង្គការមានការភ័ន្តច្រឡំ។ ប៉ុន្តែខ្ញុំត្រូវសន្យាថានឹងមិនប្រាប់អ្នកណាទាំងអស់អំពីស្ថានភាពនៅក្នុងគុក។ ប្រសិនបើមានអ្នកណាម្នាក់សួរខ្ញុំ ចម្លើយរបស់ខ្ញុំគឺ «មិនដឹង មិនឮ មិនឃើញ»។[២០]*

## ៥. ការសម្លាប់

ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនប្រហែលប្រាំសែននាក់ត្រូវបានសម្លាប់ ក្រោមការចោទប្រកាន់ពីបទប្រឆាំងបដិវត្តន៍និងអង្គការ។ "ប្រជាជនថ្មី" រាប់ពាន់នាក់ដែលមិនមានបទពិសោធន៍ឬជំនាញក្នុងការធ្វើស្រែចម្ការបានបាត់ខ្លួន។ ប្រជាជនត្រូវបាននាំយកទៅព្រៃជ្រៅ ឬទីវាលឆ្ងាយពីភូមិស្រុកដើម្បីសម្លាប់ បន្ទាប់ពីអ្នកទាំងនោះបានប្រព្រឹត្តនូវអំពើដែលខ្មែរក្រហមចាត់ទុកថាជាកំហុសធ្ងន់ ឬបានបញ្ចេញកាយវិការខឹងសម្បានឹងកម្មាភិបាលដឹកនាំរបស់ខ្លួន។ ជនរងគ្រោះខ្លះត្រូវបានកប់ទាំងរស់ ហើយស្លាប់ដោយថប់ដង្ហើម។



សាកសពអ្នកទោសមិនស្គាល់អត្តសញ្ញាណម្នាក់ នៅមន្ទីរស-២១។ រូបថតនេះ ថតដោយអ្នកថតរូបជនជាតិវៀតណាមម្នាក់ឈ្មោះ ហូ វ៉ាន់តាយ ក្នុងពេលបំពេញបេសកកម្មជាមួយកងទ័ពវៀតណាមនៅក្នុងទីក្រុងភ្នំពេញ។ កងទ័ពវៀតណាមបានរកឃើញមន្ទីរ ស-២១ នៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៩ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំនៅដើមឆ្នាំ១៩៧៩។ ជើងទាំងសងខាងរបស់អ្នកទោសត្រូវជាប់ខ្នោះដែកដែលចាក់សោភ្ជាប់នឹងគ្រែដែក។ ខ្លួនប្រាណរបស់សាកសពមានសភាពហើមទៅហើយ។ កៅអីដែលដាក់នៅចន្លោះជើងទាំងពីររបស់សាកសព ទំនងជាកៅអីសម្រាប់ដាក់ឱ្យអ្នកទោសសរសេរចម្លើយសារភាពពីប្រវត្តិក្បត់បក្សរបស់ខ្លួន។ គិតត្រឹមថ្ងៃនៃការបោះពុម្ពសៀវភៅនេះ ការិយាល័យសហព្រះរាជអាជ្ញានៃសាលាក្តីខ្មែរក្រហម បានឱ្យដឹងថា ចំនួនអ្នកទោសនៅមន្ទីរស-២១ មានចំនួន ១៨ ០៦៣នាក់។ ប្រភព៖ ហូ វ៉ាន់តាយ/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

មនុស្សស្ទើរគ្រប់រូបដែលត្រូវបានរកឃើញថាជាអ្នកធ្លាប់មានការរៀនសូត្រជ្រៅជ្រះត្រូវបានបញ្ជូនទៅសម្លាប់ចោល។ ជាទូទៅ គ្មាននរណាម្នាក់ហ៊ានពាក់វ៉ែនតា ឬនិយាយភាសាបរទេសឡើយ ព្រោះទាំងនេះជាសញ្ញាបង្ហាញថាជាអ្នកចេះដឹង។ ជាពិសេស អ្នកដែលមកពីទីក្រុងត្រូវតែលាក់ប្រវត្តិនិងចំណេះដឹងរបស់ខ្លួន ហើយធ្វើពុតជាមនុស្សល្ងង់ខ្លៅ។

ការសម្លាប់មនុស្ស ត្រូវបានធ្វើឡើងច្រើនបែបច្រើនសណ្ឋាន។ អ្នកខ្លះត្រូវខ្មែរក្រហមចោទថាបានក្បត់បដិវត្តន៍ឬជាខ្មាំង ត្រូវបានបញ្ជូនទៅកាន់មន្ទីរសួរចម្លើយ។ បន្ទាប់ពីនៅទីនោះបានរយៈពេលពីរ-បីខែ អ្នកទោសនឹងត្រូវបញ្ជូនយកទៅវាលពិឃាត ដែលអ្នកទោសត្រូវបានបង្ខំឱ្យលុតជង្គង់នៅមាត់រណ្តៅ មុននឹងត្រូវសម្លាប់ដោយវាយចំផ្នែកខាងក្រោយនៃក្បាលជាមួយនឹង ប៉ែល ចបកាប់ ឬដំបង។ ជួនកាល អ្នកទោសរហូតដល់ទៅមួយរយនាក់ ត្រូវបានបាញ់សម្លាប់ក្នុងពេលតែមួយ ហើយកប់ក្នុងរណ្តៅតែមួយ។ អ្នកខ្លះទៀតត្រូវបានធ្វើឱ្យថប់ដង្ហើមស្លាប់ដោយយកថង់ផ្លាស្ទិកច្រកក្បាល។ នៅជនបទដែលមានអណ្តូងជាច្រើននៅក្នុងព្រៃ អ្នកទោសត្រូវបានដឹកតាមឡានធំទៅដល់មាត់អណ្តូង ហើយបន្ទាប់មកកងឈ្លបក៏រុញ ឬវាយទម្លាក់អ្នកទោសទាំងនោះទៅក្នុងអណ្តូងតែម្តង។

ពេលខ្លះ សមាជិកគ្រួសារទាំងអស់ត្រូវបានចាប់និងនាំយកទៅសម្លាប់ចោល ដោយសារតែកំហុសដែលបានប្រព្រឹត្តឡើងដោយសមាជិកម្នាក់។ ខ្មែរក្រហមបានស្វែងរកចាប់ខ្លួនសមាជិកទាំងអស់យកទៅសម្លាប់ក្រោមទ្រឹស្តីថា "ដកស្មៅ ត្រូវដកទាំងឫស"។

ម៉ម ផៃប៊ូន ប្រជាពលរដ្ឋរស់នៅខេត្តកោះកុង បានរៀបរាប់អំពីសមាជិកគ្រួសាររបស់គាត់ចំនួនបួននាក់ ដែលត្រូវបាននាំយកទៅសម្លាប់ចោលថា៖

*ប្អូនស្រីរបស់ខ្ញុំម្នាក់អាយុ៧ឆ្នាំត្រូវបានអង្គការសម្លាប់ចោល ព្រោះនាងបានលួចពោតខ្ចីមួយផ្លែហូប។ អង្គការវាយនាងនឹងត្បូងចប ហើយកប់ក្បែរចម្ការពោត។ រសៀលមួយ ពេលខ្ញុំកំពុងដេញគោកាត់ព្រៃ ខ្ញុំធុំក្លិនស្អុយសាកសពរលួយ។ ខ្ញុំដើររកមើលក្រែងប្រទះឃើញអ្នកធ្លាប់ស្គាល់គ្នា។ មិននឹកស្មានថានោះជាសាកសពឪពុកខ្ញុំ។ គាត់ត្រូវកាប់នឹងកាំបិតជិតដាច់កចេញពីស្មា។ នៅក្បែរសពឪពុកខ្ញុំ មានសាកសពពីរផ្សេងទៀតដែលត្រូវសម្លាប់ដោយកាត់ផ្តាច់កដូចគ្នា។ រំលងពីនោះបានប្រហែលជាងពីរខែ ជីដូនខ្ញុំអាយុជាង៧០ឆ្នាំបានស្លាប់។ គាត់ត្រូវបានចោទថាលួចបបរក្មេងហូប ហើយត្រូវមេកងវាយពីរដំបង។ សពរបស់គាត់ត្រូវបានរុំនឹងបាវយកទៅកប់ចោល។ ក្រោយពីមរណភាពរបស់ជីដូនខ្ញុំតែប៉ុន្មានថ្ងៃ ម្តាយខ្ញុំក៏ស្លាប់ទៀត។ គាត់ស្លាប់ដោយសារការងារលំបាកនិងគ្មានអាហារហូបគ្រប់គ្រាន់។ ខ្ញុំឱបគាត់ជាមួយសម្រែកយំសោកស្តាយ។*[២១]



មន្ទីរស-២១ ឬ មន្ទីរសន្តិសុខមជ្ឈិម របស់ខ្មែរក្រហម មានទីតាំងស្ថិតនៅក្នុងអតីតអនុវិទ្យាល័យទួលស្លែង ដែលជាសាលារៀនសម្រាប់សិស្សស្រី។ រូបថតនេះ ថតនៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៩ ភ្លាមៗបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ។ ប្រភព៖ ហូ វ៉ាន់តាយ/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

ជំពូកទី១០

# មន្ទីរស-២១

មន្ទីរសន្តិសុខដ៏សំខាន់បំផុតមួយក្នុងចំណោមមន្ទីរសន្តិសុខទាំងអស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានស្គាល់ថាជា "មន្ទីរសន្តិសុខស-២១"។ អក្សរ "ស" តំណាងឱ្យពាក្យ "សន្តិសុខ" ហើយលេខ "២១" ជាកន្ទុយលេខអាយកូមពីរខ្ទង់ចុងក្រោយរបស់ សមមិត្ត ណាត ជាអតីតប្រធានមន្ទីរ ស-២១។ មន្ទីរសន្តិសុខនេះ មានទីតាំងស្ថិតនៅប៉ែកខាងត្បូងទីក្រុងភ្នំពេញ (សង្កាត់ទួលស្វាយព្រៃ)។

មន្ទីរស-២១ ជាគុកសម្ងាត់សម្រាប់ឃុំឃាំង សួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់អ្នកទោសដែលត្រូវបានបញ្ជូនមកដាក់នៅទីនេះ។ បន្ទាប់ពីពាក់កណ្តាលឆ្នាំ១៩៧៦ មិនមានអ្នកទោសណាម្នាក់ត្រូវបានដោះលែងពីគុកនេះទេ។ ក្នុងចំណោមអ្នកទោសប្រហែល ១៤ ០០០នាក់ មានអ្នកទោសប្រហែល១២នាក់ប៉ុណ្ណោះ ដែលនៅរស់រានមានជីវិតបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ។ អ្នកទោសទាំងនោះត្រូវបានទុកជីវិត ព្រោះមានជំនាញពិសេសដែលមានប្រយោជន៍ដល់មន្ទីរស-២១។ មួយចំនួននៃអ្នកទាំងនោះ គឺជាជាងគំនូរ ជាងជួសជុលនាឡិកា និងជាងចម្លាក់។

## ១. អគារនៅក្នុងមន្ទីរស-២១

មន្ទីរស-២១ គឺជាអតីតវិទ្យាល័យចៅពញាយ៉ាត ដែលបានសាងសង់ឡើងក្នុងឆ្នាំ១៩៦២។ គុកនេះស្ថិតនៅលើផ្ទៃដីដែលមានបណ្តោយ ៦០០ម៉ែត្រនិងទទឹង៤០០ម៉ែត្រ។ នៅពីក្រោយរបងសាលានេះ មានអគារធ្វើពីឈើប្រក់ស្បូវពីរខ្នង ដែលជាអតីតសាលាបឋមសិក្សាទួលស្វាយព្រៃ។ អគារទាំងអស់នេះបង្កើតបានទៅជាមន្ទីរស-២១។

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មន្ទីរស-២១ ហ៊ុមព័ទ្ធដោយរបងស័ង្កសី និងលួសបន្លាដែលមានភ្ជាប់ចរន្តអគ្គិសនី។ នៅក្នុងបរិវេណគុកមានអគារធំៗចំនួន៤។ បន្ទប់រៀនជាន់ក្រោម ត្រូវបានបែងចែកទៅជាបន្ទប់តូចៗដែលមានទំហំ០,៨ម៉ែត្រគុណនឹង២ម៉ែត្រ ទុកសម្រាប់ឃុំឃាំងអ្នកទោសម្នាក់ៗ។ បន្ទប់រៀនជាន់ទីមួយដែលមានទំហំ៨ម៉ែត្រគុណនឹង៦ម៉ែត្រ ត្រូវបានប្រើប្រាស់សម្រាប់ដាក់អ្នកទោសរួម។ នៅជាន់ទីពីរបន្ទប់នីមួយៗមានទំហំធំជាងហើយដាក់អ្នកទោសពី៤០ទៅ៥០នាក់។ បន្ទប់មួយត្រូវបានប្រើប្រាស់ជាការិយាល័យធ្វើការរបស់ ឌុច ដែលជាប្រធានគុក ហើយបន្ទប់មួយទៀតត្រូវបានប្រើប្រាស់ជាការិយាល័យឯកសារនិងការិយាល័យរដ្ឋបាលទូទៅ។ ផ្ទះមួយចំនួនដែលនៅក្បែរគុក ត្រូវបានប្រើប្រាស់ជាកន្លែងសួរចម្លើយនិងធ្វើទារុណកម្ម។

## ២. អ្នកទោស

អ្នកទោសភាគច្រើននៅមន្ទីរស-២១ ត្រូវបានចោទប្រកាន់ពីបទក្បត់បក្សឬក្បត់បដិវត្តន៍ ឬ ធ្លាប់បានធ្វើការឱ្យកម្មាភិបាលក្បត់ដែលត្រូវបានចាប់ខ្លួនរួចហើយ។ មួយរយៈកាលកន្លងទៅ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាមានការសង្ស័យនិងមានការមិនទុកចិត្តកាន់តែខ្លាំងឡើងៗចំពោះកម្មាភិបាលនិងកងទ័ពរបស់ខ្លួន។ ឧទាហរណ៍ នៅខែតុលា ឆ្នាំ១៩៧៦ ក្នុងពេលមានដំណើរការរឹតបន្តឹងសន្តិសុខជាតិ ប៉ុល ពត បានធ្វើការចាប់ខ្លួនកម្មាភិបាលជាន់ខ្ពស់បក្សជាច្រើនរូប ហើយនាំយកទៅដាក់ឃុំឃាំងនៅក្នុងមន្ទីរ ស-២១។ ថ្នាក់ដឹកនាំជាន់ខ្ពស់ខ្មែរក្រហមយល់ឃើញថា សត្រូវមាននៅគ្រប់ទីកន្លែងទាំងអស់ក្នុងផ្ទៃប្រទេស ហើយបានធ្វើការចាប់ខ្លួនសមាជិកកុម្មុយនីស្តជាច្រើននាក់ក្នុងមួយខែៗ។ ក្រៅពីអ្នកទោសជាជនជាតិខ្មែរដែលជាប់ឃុំឃាំងនៅក្នុងគុកទួលស្លែងនៅមានអ្នកទោសជាជនបរទេសចំនួនប្រហែល ៤០០នាក់ ដែលភាគច្រើនជាអ្នកទោសជនជាតិវៀតណាម។



**រូបថតនេះ បង្ហាញពីកងសន្តិសុខខ្មែរក្រហមនៅក្នុងបរិវេណមន្ទីរ ស-២១ ចំនួន៤នាក់កំពុងបំពេញតួនាទីរបស់ខ្លួន ដែលក្នុងនេះមានកងសន្តិសុខស្ត្រីម្នាក់កំពុងកាប់ដី និងម្នាក់ទៀតកំពុងឈរកាន់ដងចបនៅពីមុខស្នាមរាងជារណ្តៅ។ ចំណែកកងសន្តិសុខពីរនាក់ទៀត កំពុងឈរពិនិត្យមើលសកម្មភាព។ រូបថត ថតក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៨។** (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កម្មាភិបាលដែលបម្រើការក្នុងមន្ទីរ ស-២១ មួយចំនួន បានក្លាយជាអ្នកទោសនៅទីនោះដែរ ដោយសារមូលហេតុខ្ជិលច្រអូសក្នុងការរៀបចំឯកសារ ធ្វើឱ្យខូចម៉ាស៊ីននិងឧបករណ៍ដទៃទៀត ឬវាយអ្នកទោសរហូតដល់ស្លាប់ដោយគ្មានការអនុញ្ញាតពេលសួរចម្លើយ។ ចម្លើយសារភាពភាគច្រើននៅមន្ទីរស-២១ គឺជាចម្លើយមិនពិត ពីព្រោះអ្នកទោសភាគច្រើនមិនបានប្រព្រឹត្តកំហុសអ្វីធ្ងន់ធ្ងរទេ ហើយអ្នកទោសបានសារភាពដើម្បីឱ្យតែរួចខ្លួនពីទារុណកម្មប៉ុណ្ណោះ។

ខៀវ ចេស ហៅ ពៅ រស់នៅក្នុងខេត្តកំពង់ឆ្នាំង ជាអតីតអ្នកយាមនៅមន្ទីរស-២១ បានរៀបរាប់ពីប្រវត្តិរបស់គាត់ប្រាប់ថា៖

> នៅឆ្នាំ១៩៧៧ មិត្តភក្តិរបស់ខ្ញុំពីរនាក់ ហុង និង មឿន បានប្រព្រឹត្តកំហុស ហើយត្រូវបានយកទៅសម្លាប់ចោល។ បន្ទាប់ពីនោះមក អង្គការចាប់ខ្លួនខ្ញុំព្រោះខ្ញុំជាមិត្តភក្តិរបស់អ្នកទាំងពីរហើយបញ្ជូនខ្ញុំទៅព្រៃស។ ពួកគេបានសួរចម្លើយខ្ញុំក្រែងលោខ្ញុំមានជាប់ពាក់ព័ន្ធជាមួយអ្នកទាំងពីរ ប៉ុន្តែខ្ញុំឆ្លើយថា "អត់មានទេ"។ អ្នកសួរចម្លើយឈ្មោះ សែម ផល។ គាត់បានដឹងច្បាស់ណាស់ថាខ្ញុំខំធ្វើការនិងស្មោះត្រង់។ ដូច្នេះហើយខ្ញុំត្រូវបានដោះលែង ហើយត្រូវបានបញ្ជូនទៅកងពល ៥០២ ដើម្បីបើកឡានដឹកគ្រាប់ទៅតាយនិញ ទៅវៃជាមួយវៀតណាម។
>
> ជីវិតនៅមន្ទីរស-២១ ពោរពេញទៅដោយភាពភ័យខ្លាច។ យើងមិនហ៊ាននិយាយលេងរកគ្នាទេ។ យើងមិនទុកចិត្តអ្នកណាទាំងអស់ សូម្បីមិត្តភក្តិជិតស្និទ្ធរបស់យើងក៏ដោយ។ គ្រប់គ្នាត្រូវខិតខំធ្វើការ។ ក្រៅពីការយាមកាម យើងត្រូវដាំបន្លែនិងចិញ្ចឹមជ្រូក។ យើងត្រូវប្រុងប្រយ័ត្នបំផុតពេលធ្វើការ។ កំហុសបន្តិចបន្តួច ដូចជាដោកឬផ្អែកនឹងជញ្ជាំងអាចធ្វើឱ្យយើងស្លាប់បាន។

## ៣. បទបញ្ញត្តិសម្រាប់អ្នកទោស

បទបញ្ញត្តិនេះត្រូវបានបិទនៅលើជញ្ជាំងក្នុងបរិវេណគុក។

**វិន័យសន្តិបាល( នគរបាលសន្តិសុខ )នៅមន្ទីរស-២១**

១) សួរអីឆ្លើយហ្នឹង មិនបង្វែរសំណួររបស់អញ។
២) មិនឱ្យដោះស្រាយ យកលេសនេះលេសនោះតាមគំនិតឯងលាក់ឬប្រកែក តមាត់មិនបានដាច់ខាត។
៣) មិនឱ្យធ្វើល្ងង់ មិនយល់បញ្ហា ព្រោះឯងជាមនុស្សហ៊ានប្រឆាំងនឹងបដិវត្តន៍។
៤) សួរភ្លាម ឆ្លើយភ្លាម មិនឱ្យដំអក់មួយនាទីឡើយ។
៥) រឿងខ្វះខាត កំហុសបន្តិចបន្តួច ដូចជាសីលធម៌ ខូចនេះខូចនោះក៏មិនឱ្យនិយាយ រឿងខ្លឹមសារបដិវត្តន៍ ក៏មិនឱ្យនិយាយ។
៦) វ៉ៃ ឬឆក់ខ្សែភ្លើងមិនឱ្យស្រែកដាច់ខាត។
៧) មិនឱ្យធ្វើអ្វីទាំងអស់ គឺអង្គុយស្ងៀមរង់ចាំបញ្ជាអញ អត់បញ្ជាកុំធ្វើ អញបញ្ជាអីធ្វើនឹងភ្លាម ប្រកែកច្រិមច្រុមមិនបានទេ។
៨) កុំយកលេសកម្ពុជាក្រោម បាំងមុខមាត់ក្បត់របស់អាឯងឱ្យសោះ។
៩) គ្រប់បញ្ហាខាងលើ មិនធ្វើតាម គឺមួយថ្ងៃរងរំពាត់ ខ្សែភ្លើងឆក់រាប់មិនឈ្នះទេ។
១០) ប្រឆាំងវិន័យអញមួយចំណុច ត្រូវរងរំពាត់ដប់រំពាត់ ឬឆក់ខ្សែភ្លើងប្រាំឆាប់។

បទបញ្ញត្តិមួយទៀតសម្រាប់អ្នកទោសត្រូវបានបិទនៅអគារ "ខ-គ-ឃ"។

**បម្រាមនៅអគារ"ខ-គ-ឃ"**

១) មិនឱ្យនិយាយទាក់ទងគ្នាដាច់ខាត ទោះជាស្គាល់ ឬមិនស្គាល់។
២) បើចង់ធ្វើអ្វី ត្រូវមានការអនុញ្ញាតពីអ្នកយាម។
៣) មិនឱ្យរ៉ូវរ៉ាងទីកន្លែងនៅ។
៤) ពេលអ្នកយាមឬអ្នកផ្សេងៗចូល ត្រូវដេកទាំងអស់។
៥) ពេលដេក ត្រូវដាក់ដៃក្រោយខ្នង។ កុំសេរី។









ដំណើរស្វែងរកការពិតអស់ជាង៤០ឆ្នាំ របស់កូនស្រីម្នាក់តាមរយៈរូបថតដែលបន្សល់ពីរបបខ្មែរក្រហម។ នេះជារូបថត ចាន់ គឹមស្រ៊ុន ហៅ សាង ដែលត្រូវបានចាប់ខ្លួននិងឃុំខ្លួនក្នុងមន្ទីរ ស-២១ នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៧៨។ ប្ដីរបស់ គឹមស្រ៊ុន ឈ្មោះ សេក សាត ក៏ត្រូវបានចាប់ខ្លួននិងជាប់ឃុំឃាំងនៅមន្ទីរ ស-២១ ដែរ គឺនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៧៨។ សេក សាយ ដែលកាលនោះមានអាយុ១១ឆ្នាំ គឺជាកូនស្រីច្បងដែលបានឃើញហេតុការណ៍កងសន្តិសុខខ្មែរក្រហម មកនាំឪពុកម្ដាយនិងប្អូនប្រុសអាយុប្រាំខែរបស់ខ្លួន ចាកចេញទៅ។ គឹមស្រ៊ុន ត្រូវបានសម្លាប់ ហើយកូនតូចរបស់គាត់ ក៏ត្រូវបានសម្លាប់ជាមួយនឹងម្ដាយដែរ។ រូបថតមួយសន្លឹកនេះ មិនត្រឹមតែបានលងបន្លាច សេក សាយ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបង្ហាញអំពីអារម្មណ៍ឈឺចាប់ វិបត្តិផ្លូវចិត្ត ភាពសោកសង្រេង និងទារុណកម្មផ្លូវកាយ ដែលបង្កលើជនរងគ្រោះនៅមុនពេលត្រូវសម្លាប់។ រូបថត ចាន់ គឹមស្រ៊ុន ត្រូវបានដាក់តាំងបង្ហាញ នៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង។
ប្រភព៖ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

សេក សាយ ជាកូនស្រីរបស់អ្នកទោសមន្ទីរស-២១ ឈ្មោះ សេក សាត ហៅ ប្រាក់ អតីតគណៈតំបន់១៣ និង ចាន់ គឹមស្រ៊ុន ហៅ សាង។ សេក សាយ រស់នៅក្នុងខេត្តកំពង់ស្ពឺ និងកំពុងកាន់រូបថតម្ដាយនិងឪពុករបស់ខ្លួននៅឆ្នាំ២០១៩។ សេក សាយ គឺជាកូនស្រីតែម្នាក់គត់ ដែលរស់រានមានជីវិតពីរបបខ្មែរក្រហម។ ឪពុក ម្ដាយ និងប្អូនប្រុស ត្រូវខ្មែរក្រហមសម្លាប់ក្នុងឆ្នាំ១៩៧៨។ ប្អូនស្រីរបស់ សេក សាយ ឈ្មោះ ច្រឹប បានស្លាប់ដោយសារជំងឺ នៅក្រោយពេលបន្តិចពីរបបខ្មែរក្រហមដួលរលំ។
ប្រភព៖ សុភ័ក្ត្រ ភាណា/មជ្ឈមណ្ឌលឯកសារកម្ពុជា

សេក សាត ហៅ ប្រាក់ អតីតគណៈតំបន់១៣ នៃរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានឃាត់ខ្លួននិងឃុំខ្លួននៅមន្ទីរស-២១។ រឿងរ៉ាវរបស់ សេក សាត បង្ហាញអំពីសាវតារដ៏ស្មុគស្មាញរបស់ជនរងគ្រោះជាច្រើនដទៃទៀតរបស់ខ្មែរក្រហម។ ក្នុងករណីជាច្រើន ជនរងគ្រោះគឺជាកម្មាភិបាលខ្មែរក្រហម។ ការសិក្សាស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ទាក់ទងនឹង សេក សាត បង្ហាញថា គាត់គឺជាមនុស្សម្នាក់ក្នុងចំណោមមនុស្សជាច្រើននាក់ ដែលចូលរួមក្នុងចលនាខ្មែរក្រហមក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៦០ដល់១៩៧០ ដើម្បីតស៊ូប្រឆាំងនឹងភាពអយុត្តិធម៌ក្នុងសង្គម។ នៅចុងបញ្ចប់ គាត់ត្រូវបានចាប់ខ្លួននៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៧៨។ ប្រភព៖ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

## ៤. ស្ថានភាពនៅក្នុងមន្ទីរស-២១

នៅពេលបញ្ជូនទៅដល់មន្ទីរស-២១ អ្នកទោសទាំងអស់ត្រូវបានថតរូបនិងតម្រូវឱ្យសរសេរប្រវត្តិរូបលម្អិតចាប់តាំងពីកុមារភាពរហូតដល់ថ្ងៃចាប់ខ្លួន។ អ្នកទោសត្រូវដោះសម្លៀកបំពាក់ចេញ ទុកតែខោក្នុងមួយ ហើយសម្ភារជាប់ខ្លួនទាំងប៉ុន្មានត្រូវបានរឹបអូសយកទាំងអស់។ បន្ទាប់មកអ្នកទោស នឹងត្រូវនាំយកទៅដាក់ឃុំក្នុងបន្ទប់ ដែលនៅទីនោះអ្នកទោសទាំងអស់ត្រូវដាក់ខ្នោះជើងភ្ជាប់ដោយច្រវាក់ទៅនឹងជញ្ជាំង ឬឥដ្ឋ។ ចំណែកអ្នកទោសឃុំឃាំងនៅក្នុងបន្ទប់ធំវិញ ត្រូវបានដាក់ខ្នោះជើងដោយរនុកដែកវែងមួយរួមគ្នា។ ខ្នោះជើងទាំងនេះ ត្រូវភ្ជាប់ទៅនឹងរនុកដែកឆ្លាស់គ្នា ដូច្នេះអ្នកទោសត្រូវដេកដាក់ក្បាលទល់គ្នា។ អ្នកទោសត្រូវដេកផ្ទាល់នឹងឥដ្ឋ ដោយគ្មានកន្ទេល ម៉ុង ឬភួយទេ។ អ្នកទោសត្រូវបានហាមប្រាមមិនឱ្យនិយាយរកគ្នា។

វ៉ាន់ ណាត អ្នកនៅរស់រានមានជីវិតម្នាក់ បានរៀបរាប់ពីជីវិតរបស់គាត់នៅក្នុងមន្ទីរស-២១ ថា ៖

> *នៅក្នុងមន្ទីរស-២១ ខ្ញុំត្រូវបានដាក់ខ្នោះជើងភ្ជាប់ទៅនឹងរនុកដែកវែងមួយជាមួយអ្នកទោសជាងសាមសិបនាក់ទៀត។ ខ្មែរក្រហមឱ្យយើងហូបពីរដងក្នុងមួយថ្ងៃ។ អ្នកទោសគ្រប់រូបទទួលបានរបបបបរ៤ស្លាបព្រាតូចនិងសម្លលាយស្លឹកឈើខ្លះ។ ការនិយាយគ្នាត្រូវបានហាមឃាត់ដាច់ខាត។ ប្រសិនបើអ្នកណាម្នាក់ចង់ក្រោកអង្គុយឬផឹកទឹក គេត្រូវសុំការអនុញ្ញាតពីអ្នកយាមជាមុនសិន។ ការធ្វើអ្វីមួយដែលមិនមានការអនុញ្ញាតពីអ្នកយាម នឹងត្រូវទទួលការវាយដំជាទម្ងន់។ គេឱ្យយើងមុជទឹករៀងរាល់បួនថ្ងៃម្តង។ ពួកគេយកទុយោមកបាញ់ជះពីមាត់ទ្វារ។ ប្រសិនបើយើងនៅឆ្ងាយពីមាត់ទ្វារ យើងនឹងមិនបានទទឹកគ្រប់គ្រាន់ទេ។ ជារៀងរាល់ថ្ងៃ អ្នកទោសត្រូវបាននាំយកទៅសួរចម្លើយ ហើយមួយចំនួនមិនដែលឃើញត្រឡប់មកវិញទេ ប៉ុន្តែយើងឃើញអ្នកទោសថ្មីៗត្រូវបាននាំចូលមកជំនួសវិញ។[២២]*
>
> *នៅវេលាម៉ោងបួនកន្លះព្រឹក អ្នកទោសត្រូវស្រាតខោដើម្បីឱ្យអ្នកយាមត្រួតពិនិត្យ។ អ្នកយាមត្រូវពិនិត្យមើលក្រែងលោខ្នោះជើងរលុង ឬក្រែងលោអ្នកទោសមានលាក់វត្ថុអ្វីដែលគេអាចប្រើដើម្បីធ្វើអត្តឃាត។ មួយរយៈកាលកន្លងមកមានអ្នកទោសជាច្រើនបានសម្លាប់ខ្លួនឯង។ ដូច្នេះអ្នកយាមត្រូវមានការប្រុងប្រយ័ត្នខ្ពស់ក្នុងការត្រួតពិនិត្យមើលខ្នោះជើងនិងបន្ទប់។*

ស្ថានភាពរស់នៅក្នុងមន្ទីរស-២១ មានភាពកខ្វក់ដែលធ្វើឱ្យអ្នកទោសភាគច្រើនកើតស្រែង កមរមាស់ និងចៃ។ មិនមានថ្នាំព្យាបាលទេនៅក្នុងគុក។ កម្មាភិបាលពេទ្យប្រចាំនៅមន្ទីរស-២១ សុទ្ធតែមិនបានទទួលការហាត់រៀនត្រឹមត្រូវ ហើយធ្វើការព្យាបាលគ្រាន់តែដើម្បីពន្យារការស្លាប់របស់អ្នកទោសប៉ុណ្ណោះ បន្ទាប់ពីរងរបួសធ្ងន់ក្នុងអំឡុងពេលសួរចម្លើយ។

អ្នកទោសត្រូវបានបិទមុខជិត ពេលត្រូវនាំពីកន្លែងឃុំឃាំងទៅកន្លែងសួរចម្លើយ។ អ្នកយាមនិងអ្នកទោសមិនអនុញ្ញាតឱ្យនិយាយគ្នាឡើយ។ ជាងនេះទៅទៀត នៅក្នុងបរិវេណគុក មនុស្សដែលនៅក្រុមផ្សេងគ្នា ក៏មិនត្រូវបានអនុញ្ញាតឱ្យធ្វើការទាក់ទងគ្នាដែរ។

## ៥. ការសួរចម្លើយ

វិធីសាស្ត្រសួរចម្លើយនិងធ្វើទារុណកម្មដ៏ឃោរឃៅជាច្រើន ត្រូវបានប្រើប្រាស់ជាមួយអ្នកទោសដែលជាប់ឃុំឃាំងនៅមន្ទីរស-២១ ដើម្បីទទួលបានចម្លើយសារភាព។ ជួនកាល អ្នកទោសត្រូវបានវាយដោយដៃ ដំបង មែកឈើ ខ្សែភ្លើងឬធក់ខ្សែភ្លើង។ វិធីសាស្ត្រធ្វើទារុណកម្មផ្សេងទៀតដែលប្រើនៅមន្ទីរស-២១មាន អុចភ្លើងបារី បង្ខំឱ្យស៊ីលាមកឬផឹកទឹកនោម យកម្ជុលចាក់ចូលសាច់ និងចងព្យួរដៃឡើងលើពេញមួយថ្ងៃ ឬព្យួរជើងឡើងលើដាក់ក្បាលចុះក្រោម។ អ្នកទោសខ្លះទៀតត្រូវបានឆូតសាច់នឹងកាំបិត ឬយកថង់ច្រកក្បាលខ្ទប់ច្រមុះ។ វិធីសាស្ត្រដទៃទៀតដូចជាដកក្រចកដៃរួចចាក់អាកុលពីលើ ឬជ្រមុជទឹក ត្រូវបានប្រើប្រាស់សម្រាប់ចម្រាញ់យកចម្លើយសារភាព។ អ្នកទោសមួយចំនួនត្រូវស្លាប់ក្នុងអំឡុងពេលធ្វើទារុណកម្ម។

អ្នកទោសជាស្ត្រី ត្រូវបានធ្វើទារុណកម្មដោយកាត់ដោះ ឬបង្ខំឱ្យស្រាតខោអាវចេញ។ អ្នកទោសជាស្ត្រីមួយចំនួនត្រូវអ្នកសួរចម្លើយចាប់រំលោភ ទោះជាការរំលោភផ្លូវភេទគឺជាទង្វើផ្ទុយនឹងគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យក៏ដោយ។ អ្នកសួរចម្លើយដែលត្រូវរកឃើញថាបានប្រព្រឹត្តអំពើនេះត្រូវបានសម្លាប់ចោល។

នៅក្នុងចម្លើយសារភាព អ្នកទោសត្រូវរៀបរាប់ពីប្រវត្តិរូបផ្ទាល់ខ្លួន។ ប្រសិនបើជាសមាជិកបក្ស អ្នកទោសត្រូវបង្ហាញកាលបរិច្ឆេទច្បាស់លាស់នៃការចូលបដិវត្តន៍ និងរៀបរាប់ពីកិច្ចការដែលខ្លួនបានធ្វើ។ បន្ទាប់មក អ្នកទោសត្រូវរៀបរាប់ពីសកម្មភាពក្បត់របស់ខ្លួនតាមលំដាប់លំដោយ។ ក្នុងផ្នែកទីបីនៃចម្លើយសារភាព អ្នកទោសតម្រូវឱ្យរៀបរាប់ពីការរួមគំនិតក្បត់មិនបានសម្រេចរបស់ខ្លួន ឬកិច្ចសន្ទនាក្បត់ផ្សេងៗ។ នៅចុងបញ្ចប់នៃចម្លើយសារភាព អ្នកទោសតម្រូវឱ្យសរសេរបញ្ចូលនូវឈ្មោះបណ្តាញក្បត់ផ្សេងទៀត ដែលត្រូវជាមិត្តភក្តិ មិត្តរួមការងារ ឬមនុស្ស ដែលអ្នកទោសធ្លាប់ស្គាល់។ ចម្លើយសារភាពខ្លះ មានរាយឈ្មោះមនុស្សដែលពាក់ព័ន្ធរហូតដល់ទៅជាងមួយរយនាក់។ អ្នកដែលមានឈ្មោះក្នុងបញ្ជីភាគច្រើនត្រូវបានចាប់យកមកសួរចម្លើយ។

ដោយសារតែទារុណកម្មនៅមន្ទីរ ស-២១ មានសភាពសាហាវព្រៃផ្សៃពេក អ្នកទោសតែងតែសារភាពនូវអ្វី ដែលខ្លួនអាចគិតឃើញ ទោះជាចម្លើយនោះខុសក៏ដោយ។ អ៊ំ សំណាង កម្មកររទេះភ្លើងបានសារភាព ពីកិច្ចសន្ទនាក្បត់របស់ តុន កម្មករជួសជុលរទេះភ្លើងថា ៖

> តុន ជាកម្មករចាស់។ វាមិនពេញចិត្តនឹងបដិវត្តន៍ដូចគ្នាវាឯទៀតដែរ។ រាល់ថ្ងៃ វាតែងឃោសនាដូចតទៅនេះ ៖
>
> - ពួកអាអស់នេះ ដល់ឯងបង្រៀនបច្ចេកទេសវាចេះច្រើន ចង់ដេញក្បាលឯងចេញ។
> - ឱ្យតែយ៉ាងនេះចុះ ថ្ងៃណាមួយ ពួកហ្អែងត្រូវរលាយដូចអំបិលត្រូវទឹក។
> - សព្វថ្ងៃ កម្មករចាស់ប្រៀបដូចសំរាមក្រោមបាតជើងវា។ វាចង់ជាន់ពេលណាក៏បាន ស្រេចតែនឹងចិត្តវា។
> - ពួកវាពូកែខាងអំនួតនិងទ្រឹស្តី តែខ្ជិលធ្វើការ។
> - ធ្វើការគ្រាន់តែដូរបាយស៊ីបានហើយ ខូចស្អីក៏ខូចទៅ។[២៣]
> - ក្រៅពីនេះ វាពង្រឹងខ្លួន ត្រៀមវាយបដិវត្តន៍ពេលណាមានទ័ពមកពីក្រៅ។

ជា ហឿង សាស្ត្រាចារ្យដែលត្រូវជម្លៀសទៅស្រុកបារាយណ៍ ខេត្តកំពង់ធំ បានសារភាពពីសកម្មភាពក្បត់របស់ តាំង ឡុញ អតីតអ្នកធ្វើការក្រសួងប្រៃសណីយ៍ ក្រោយមកធ្វើទាហានពាក់សក្តិពីរថា ៖

> ជម្លៀសទៅដល់ភូមិកំណើតវិញ តាំង ឡុញ ដើរប្រមូលជើងដើម្បីប្រឆាំងបដិវត្តន៍។ វាបានធ្វើវិច្ឆេទកម្ម ប្រឆាំងយើងជាបន្តបន្ទាប់ ៖
>
> - ណែនាំឱ្យបក្សពួកលែងគោឱ្យស៊ីស្មៅ។
> - ណែនាំឱ្យបក្សពួកកម្ទេចចានតិចៗជាបណ្តើរៗ។
> - ណែនាំឱ្យសម្លាប់ទាម្តង១ឬ២ ហើយរាយការណ៍ថាងាប់។
> - យកផ្ទះខ្លួនជាកន្លែងសរសេរត្រាក់ ហើយបានយកត្រាក់ទៅបាចតាមការដ្ឋាន។[២៤]



**កងការពារវ័យក្មេងនៅមន្ទីរស-២១។ (ជួរមុខ) ពីឆ្វេងទៅស្តាំ ចាប់ពីទីពីរទៅ៖ សមមិត្ត ភន, សមមិត្ត ហ៊ុយ, សមមិត្ត រ៉ន, សមមិត្ត ខុម និង សមមិត្ត តេវ។ (ជួរក្រោយ) ទីមួយពីស្តាំ៖ សមមិត្ត អ៊ឹម និង ទីពីរពីស្តាំ៖ សមមិត្ត យ៉ាន។ កងការពារដទៃទៀតមិនស្គាល់អត្តសញ្ញាណ។ (១៩៧៥-១៩៧៨)**

(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## ៦. រចនាសម្ព័ន្ធចាត់តាំងនៅក្នុងមន្ទីរ ស-២១

កម្មាភិបាលប្រហែលមួយពាន់នាក់នៅបម្រើការក្នុងមន្ទីរស-២១។ ក្នុងនោះ មនុស្សប្រហែលបី-បួនរយនាក់បម្រើការជាកម្មាភិបាលទូទៅ ដោយរួមទាំងអ្នកដាំបន្លែបង្ការសម្រាប់បំពេញសេចក្តីត្រូវការក្នុងគុកផង។ ក្រៅពីនេះ គឺជាកងកម្លាំងធ្វើការក្នុងបរិវេណគុក ដែលធ្វើការនៅក្នុងអង្គភាពមួយក្នុងចំណោមអង្គភាពទាំងបីរបស់គុក និងរួមទាំងកម្មាភិបាលបម្រើនៅការិយាល័យរបស់មន្ទីរស-២១ ផង។

អង្គភាពនៅមន្ទីរស-២១ រួមមាន អង្គភាពរៀបចំឯកសារ អង្គភាពការពារ និងអង្គភាពសួរចម្លើយ។ អង្គភាពរៀបចំឯកសារ មានតួនាទីចម្លងចម្លើយសារភាពចេញពីកាស្សែត វាយអត្ថបទចម្លើយសារភាពរបស់អ្នកទោស សង្ខេបអត្ថបទចម្លើយសារភាព និងរៀបចំទុកដាក់ឯកសារ។ កម្មាភិបាលបម្រើការនៅក្នុងផ្នែកថតរូប មានតួនាទីថតរូបអ្នកទោសពាក់កណ្តាលខ្លួន នៅពេលអ្នកទោសត្រូវបានបញ្ជូនមកដល់ភ្លាម ថតរូបអ្នកទោសដែលស្លាប់ក្នុងបន្ទប់ឃុំឃាំង និងថតរូបអ្នកទោសសំខាន់ៗក្រោយពេលសម្លាប់ហើយ។ រូបថតរាប់ពាន់សន្លឹកនៅសេសសល់រហូតមកដល់សព្វថ្ងៃ ប៉ុន្តែរាប់ពាន់សន្លឹកផ្សេងទៀតបានបាត់បង់។

អង្គភាពការពារ គឺជាអង្គភាពធំបំផុតនៅមន្ទីរស-២១។ កងសន្តិសុខនៅក្នុងអង្គភាពនេះភាគច្រើនជាក្មេងជំទង់។ កងសន្តិសុខភាគច្រើនមានការលំបាកក្នុងការគោរពបទបញ្ជាដ៏តឹងតែងរបស់អង្គភាព។ កងសន្តិសុខមិនត្រូវបានអនុញ្ញាតឱ្យនិយាយជាមួយអ្នកទោស សួរឈ្មោះ ឬវាយតប់អ្នកទោសឡើយ។ កងសន្តិសុខត្រូវបានហាមឃាត់មិនឱ្យលួចមើលឬលួចស្តាប់ការសួរចម្លើយ ហើយត្រូវតែគោរពឱ្យបានខ្ជាប់ខ្ជួននូវបទបញ្ជា៣០ចំណុចដែលហាមប្រាមមិនឱ្យលួចដេក អង្គុយលេង ឬផ្អែកនឹងជញ្ជាំងក្នុងពេលធ្វើការងារ។ កងសន្តិសុខ ត្រូវដើរទៅដើរមក ធ្វើការយាមល្បាត និងពិនិត្យពិច័យអ្វីៗគ្រប់យ៉ាងដោយប្រុងប្រយ័ត្នបំផុត។ កងសន្តិសុខណាម្នាក់ដែលបានប្រព្រឹត្តកំហុសធ្ងន់ធ្ងរ នឹងត្រូវចាប់ខ្លួន សួរចម្លើយ យកទៅឃុំឃាំង និងយកទៅសម្លាប់ចោល។ ភាគច្រើននៃអ្នកធ្វើការនៅមន្ទីរស-២១ មានការភ័យខ្លាចយ៉ាងខ្លាំងចំពោះកំហុសផ្សេងៗដែលអាចកើតមានឡើង និងភ័យខ្លាចចំពោះទារុណកម្ម និងការសម្លាប់ចោល។

អង្គភាពសួរចម្លើយ ចែកចេញជាបីក្រុមគឺ ក្រុមរងក្តៅ ក្រុមរងត្រជាក់ និងក្រុមរងអង្កៀម។ ក្រុមរងក្តៅ (ជួនកាលត្រូវបានហៅថា "កងកាច") អាចប្រើទារុណកម្មក្នុងពេលសួរចម្លើយបាន។ ផ្ទុយទៅវិញ ក្រុមត្រជាក់ (ជួនកាលត្រូវបានហៅថា "កងស្លូត") មិនត្រូវបានអនុញ្ញាតឱ្យប្រើទារុណកម្មដើម្បីសួរចម្លើយទេ។ ប្រសិនបើក្រុមនេះមិនអាចធ្វើឱ្យអ្នកទោសសារភាព គេនឹងបញ្ជូនអ្នកទោសទៅក្រុមរងក្តៅ។ ក្រុមរងអង្កៀម ធ្វើការជាមួយករណីធ្ងន់ធ្ងរ និងសំខាន់ៗ។

ការសួរចម្លើយមានរយៈពេលវែង។ ជួនកាល ដំណើរការនេះបន្តធ្វើរហូតដល់យប់អាធ្រាត្រ។ អ្នកសួរចម្លើយទាំងនោះចេះអាន និងចេះសរសេរ ហើយជាទូទៅមានអាយុប្រហែលជាង ២០ឆ្នាំ។

**ឌុច (ឈ្មោះដើម កាំង ហ្គេកអ៊ាវ)**

ឌុច កើតក្នុងឆ្នាំ១៩៤៥ នៅខេត្តកំពង់ធំ។ ឌុច រៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិ និងបានជាប់ចំណាត់ថ្នាក់ជាសិស្សពូកែគណិតវិទ្យាលេខ២ ទូទាំងប្រទេស។ ឌុច ធ្វើជាគ្រូបង្រៀនគណិតវិទ្យា នៅសាលារៀនមួយក្នុងខេត្តកំពង់ធំ។ ក្នុងឆ្នាំ១៩៦៤ ឌុច ធ្វើការនៅសាលាគរុកោសល្យ បន្ទាប់ពី សុន សេន បានរត់ចូលព្រៃ។ ឌុច ចូលជាសមាជិកបក្សកុម្មុយនីស្តកម្ពុជានៅឆ្នាំ១៩៧០។ ជាចុងក្រោយ ឌុច បានកាន់តំណែងជាប្រធានមន្ទីសន្តិសុខដ៏អសោចមួយ ដែលមានឈ្មោះថា ស-២១ (ឬ ទួលស្លែង)។

ឌុច បានផ្តាច់ខ្លួនចេញពីក្រុមខ្មែរក្រហម ក្នុងទសវត្សរ៍ឆ្នាំ១៩៨០ ហើយបានក្លាយខ្លួនជាគ្រិស្តបរិស័ទ។ ឌុច ត្រូវបានចាប់ខ្លួននៅខែឧសភា ឆ្នាំ១៩៩៩។ ក្នុងខែកុម្ភៈ ឆ្នាំ២០០៥ ឌុច ត្រូវបានកាត់ទោសពីបទឧក្រិដ្ឋកម្មសង្គ្រាម និងការធ្វើទុក្ខបុកម្នេញទៅលើជនបរទេស ក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ឌុច ត្រូវបានកាត់ទោសដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយនៅក្នុងឆ្នាំ២០១២ តុលាការកំពូលសម្រេចកាត់ទោស ឌុច ឱ្យជាប់ពន្ធនាគារអស់មួយជីវិតពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ នៅក្នុងសំណុំរឿង០០១។

**សុន សេន (សមមិត្ត ខៀវ)**

សុន សេន កើតនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៣០ នៅខេត្តត្រាវិញ ប្រទេសវៀតណាមខាងត្បូង។ ប្រពន្ធរបស់ សុន សេន ឈ្មោះ យុន យ៉ាត (ហៅសមមិត្តនារី អាត) ជារដ្ឋមន្ត្រីក្រសួងអប់រំ និងវប្បធម៌ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សុន សេន បានទៅសិក្សានៅប្រទេសបារាំងពីឆ្នាំ១៩៥០ដល់ឆ្នាំ១៩៥៦ ហើយបានចូលជាសមាជិកបក្សកុម្មុយនីស្តបារាំង។ ក្នុងឆ្នាំ១៩៦៣ សុន សេន បានភៀសខ្លួនចូលព្រៃដើម្បីគេចពីការតាមចាប់ខ្លួន។ សុន សេន បានក្លាយទៅជាអគ្គបញ្ជាការកងកម្លាំងរំដោះជាតិប្រជាជនកម្ពុជា ក្នុងឆ្នាំ១៩៧១។

ក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ សុន សេន ជាឧបនាយករដ្ឋមន្ត្រីទីបី ទទួលបន្ទុកការពារជាតិនិងគ្រប់គ្រងផ្ទាល់ទៅលើមន្ទីរស-២១។ សុន សេន និងក្រុមគ្រួសារត្រូវបានសម្លាប់តាមបញ្ជារបស់ ប៉ុល ពត នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៧។

## ៧. ថ្នាក់ដឹកនាំមន្ទីរស-២១

មន្ទីរ ស-២១ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងការពារជាតិដឹកនាំដោយ សុន សេន (ហៅ សមមិត្ត ខៀវ)។ មុនពេលចូលជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា សុន សេន ធ្លាប់បានទៅសិក្សានៅប្រទេសបារាំងនិងធ្លាប់ធ្វើជាគ្រូបង្រៀន។

មេដឹកនាំជាន់ខ្ពស់នៅមន្ទីរស-២១រួមមាន ឌុច (ប្រធានមន្ទីរស-២១), ឃឹម វ៉ាត ហៅ ហ៊ (អនុប្រធានមន្ទីរស-២១), ម៉ម ណៃ (អនុប្រធានមន្ទីរស-២១), ប៉េង (បញ្ជាការលើអ្នកយាម), ចាន់ (ប្រធានអង្គភាពសួរចម្លើយ) និង ប៉ុន (អ្នកសួរចម្លើយ)។ ប៉ុន ជាអ្នកសួរចម្លើយអ្នកទោសសំខាន់ៗជាច្រើនរូបរួមមាន កែវ មាស, ណៃ សារ៉ាន់, ហ៊ូ នឹម, ទីវ អុល និង ភោគ ឆាយ។ មេដឹកនាំគុកទាំងនេះសុទ្ធតែជាអតីតគ្រូបង្រៀន។

## ៨. ការសម្លាប់នៅមន្ទីរស-២១

អ្នកទោសភាគច្រើនត្រូវជាប់ឃុំឃាំងនៅក្នុងមន្ទីរ ស-២១ ក្នុងរយៈពេលពីពីរទៅបីខែ។ ទោះបីជាយ៉ាងនេះក៏ដោយ កម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហមមួយចំនួន បានជាប់ឃុំឃាំងនៅក្នុងមន្ទីរស-២១ រាប់ខែ ហើយផ្តល់ជាចម្លើយសារភាពវែងរាប់រយទំព័រ។ បន្ទាប់ពីត្រូវបាននាំខ្លួនមកដល់មន្ទីរស-២១បានពីរ-បីថ្ងៃ អ្នកទោសទាំងអស់ត្រូវនាំយកទៅសួរចម្លើយ ដោយគ្មានខ្វល់ខ្វាយគិតគូរពីការពិតអ្វីឡើយ។ អ្នកទោសទាំងអស់ ត្រូវតែសារភាពថាខ្លួនគឺជាជនក្បត់បដិវត្តន៍ និងធ្លាប់បានប្រព្រឹត្តបទល្មើសទាំងឡាយដែលអ្នកសួរចម្លើយសូត្រឱ្យថាតាម។ បន្ទាប់ពីការសួរចម្លើយចប់សព្វគ្រប់ហើយ អ្នកទោសនឹងត្រូវនាំយកទៅ "កម្ទេចចោល" ដែលជាពាក្យប្រើក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជំនួសឱ្យពាក្យ "សម្លាប់"។

នៅឆ្នាំដំបូងនៃដំណើរការរបស់មន្ទីរ ស-២១ សាកសពអ្នកទោសត្រូវបានកប់នៅក្បែរមន្ទីរ។ ប៉ុន្តែ ចាប់តាំងពីចុងឆ្នាំ១៩៧៦មក មិនមានដីទំនេរសម្រាប់កប់សពនៅក្បែរគុកទៀតទេ ហេតុដូច្នេះហើយអ្នកទោសត្រូវបានដឹកតាមរថយន្តទ្រុងនៅពេលយប់ទៅកាន់បឹងជើងឯក (ស្ថិតនៅចម្ងាយ១៣គីឡូម៉ែត្រ ភាគនិរតីនៃទីក្រុងភ្នំពេញ) ដែលនៅកន្លែងនោះអ្នកទោស ត្រូវបានវាយនឹងត្បូងចប ខ្នងពូថៅ ឬដំបង ឬបាញ់សម្លាប់ចោលតែម្តង។ ជាទូទៅ បន្ទាប់ពីអ្នកទោសត្រូវបានសម្លាប់រួច កងសន្តិសុខដែលដឹកអ្នកទោសពីមន្ទីរស-២១ទៅ បានកប់សាកសពទាំងនោះនៅក្នុងរណ្តៅសាកសពរួម ដែលរណ្តៅតូចៗអាចផ្ទុកសាកសពបានប្រាំមួយនាក់ ឯរណ្តៅធំៗអាចផ្ទុកសាកសពបានរហូតដល់ទៅជាងមួយរយនាក់។

មន្ទីរស-២១ និងបឹងជើងឯក ត្រូវបានប្រែក្លាយទៅជាសារមន្ទីរប្រល័យពូជសាសន៍ដោយរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាក្រោមជំនួយឧបត្ថម្ភរបស់វៀតណាមក្នុងឆ្នាំ១៩៧៩។



**ពីឆ្វេងទៅស្តាំ៖ ប្រតិភូប៉េរូ, សួង ស៊ីគឿន អ្នកបកប្រែរបស់ ខៀវ សំផន និង ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋ (ប្រមុខរដ្ឋ) នៅក្នុងអំឡុងទស្សនកិច្ចរបស់ប៉េរូ ក្នុងឆ្នាំ១៩៧៦។** (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## ជំពូកទី១១

# ទំនាក់ទំនងការបរទេស

កម្ពុជាប្រជាធិបតេយ្យបានធ្វើទំនាក់ទំនងការទូតជាមួយប្រទេស ចិន កូរ៉េខាងជើង វៀតណាម ឡាវ រ៉ូម៉ានី យូហ្គោស្លាវី អាល់បានី និង អេហ្ស៊ីប។ ប្រទេសទាំងអស់នេះ មានស្ថានទូតក្នុងទីក្រុងភ្នំពេញ។ ក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ឯកអគ្គរដ្ឋទូតទាំងអស់ លើកលែងតែឯកអគ្គរដ្ឋទូតចិន ត្រូវបានបង្ខាំងឱ្យនៅតែក្នុងស្ថានទូតរៀងៗខ្លួន។

កម្ពុជាប្រជាធិបតេយ្យបានបើកស្ថានទូតរបស់ខ្លួននៅប្រទេសចិន កូរ៉េខាងជើង វៀតណាម (រហូតដល់ខែធ្នូឆ្នាំ១៩៧៧) និងឡាវ។ ក្នុងចំណោមប្រទេសទាំងនេះ ទំនាក់ទំនងជាមួយចិននិងកូរ៉េខាងជើងមានលក្ខណៈល្អប្រសើរ ហើយទំនាក់ទំនងជាមួយឡាវមានលក្ខណៈល្អបង្គួរ។ ប៉ុន្តែ ទំនាក់ទំនងជាមួយវៀតណាមកាន់តែមានលក្ខណៈអាក្រក់ទៅៗ ដោយសារតែការប៉ះទង្គិចគ្នានៅតាមបណ្តោយព្រំដែន និងការខ្វែងគំនិតគ្នាខាងមនោគមវិជ្ជា។ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាភាគច្រើន ជាអ្នកប្រឆាំងនឹងវៀតណាម ហើយមេដឹកនាំណាដែលធ្លាប់រស់នៅ ឬធ្លាប់មានទំនាក់ទំនងជាមួយវៀតណាម នឹងត្រូវធ្វើបន្សុទ្ធកម្ម (លើកលែងតែ សុន សេន និង អៀង សារី)។ អ្នកទាំងនោះ ត្រូវបានចោទប្រកាន់ថា "ក្បាលយួន ខ្លួនខ្មែរ"។ ប្រទេសទាំងពីរក៏មានការខ្វែងគំនិតគ្នាដែរទៅលើបញ្ហាថា តើនរណាជាអ្នកកាន់កាប់រ៉ែប្រេងកាតនៅក្នុងដែនសមុទ្រខ្មែរ។ បក្សកុម្មុយនីស្តកម្ពុជា មានបំណងចង់ដណ្តើមយកកម្ពុជាក្រោម[25] ពីវៀតណាមមកវិញ។ បក្សក៏មិនពេញចិត្តចំពោះគំនិតរបស់វៀតណាមដែលចង់បង្កើតសហព័ន្ធឥណ្ឌូចិនដែរ។

ការប៉ះទង្គិចគ្នារវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាម បានចាប់ផ្តើមឡើងនៅចុងឆ្នាំ១៩៧៥។ បន្ទាប់ពីនោះ ការប្រយុទ្ធគ្នាដ៏ខ្លាំងក្លាបានផ្ទុះឡើងនៅកោះត្រល់ (ឬហៅជាភាសាវៀតណាមថា ហ្វូកុក)។ នៅពាក់កណ្តាលឆ្នាំ១៩៧៦ កម្ពុជាប្រជាធិបតេយ្យ បានបង្កើនទំនាក់ទំនងកាន់តែជិតស្និទ្ធជាមួយប្រទេសចិន ហើយជម្លោះរវាងកម្ពុជាប្រជាធិបតេយ្យនិងវៀតណាម បានក្លាយទៅជាផ្នែកមួយនៃជម្លោះរវាងចិននិងសូវៀត ដែលនៅពេលនោះរដ្ឋាភិបាលក្រុងមូស្គូគាំទ្រវៀតណាម ហើយរដ្ឋាភិបាលក្រុងប៉េកាំងគាំទ្រកម្ពុជាប្រជាធិបតេយ្យ។ នៅចុងឆ្នាំ១៩៧៦ កម្ពុជាប្រជាធិបតេយ្យទទួលបានជំនួយយោធាយ៉ាងច្រើនសន្ធឹកសន្ធាប់ពីចិន។ នៅឆ្នាំ១៩៧៧ កងទ័ពកម្ពុជាប្រជាធិបតេយ្យ បានបើកការវាយប្រហារទៅលើភូមិមួយចំនួនរបស់វៀតណាម ដែលស្ថិតនៅតាមបណ្តោយព្រំដែនជាមួយកម្ពុជា និងបានសម្លាប់ប្រជាជនស្លូតត្រង់រាប់រយនាក់។ ទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ ត្រូវបានកាត់ផ្តាច់ទាំងស្រុងនៅចុងឆ្នាំ១៩៧៧។

នៅឆ្នាំ១៩៧៨ កម្ពុជាប្រជាធិបតេយ្យបានខិតខំពង្រីកទំនាក់ទំនងការទូតរបស់ខ្លួន ហើយពាណិជ្ជកម្មក្រៅប្រទេសនៅពេលនោះបានឈានដល់កម្រិតកំពូល។ ប្រទេសដែលធ្លាប់ធ្វើទំនាក់ទំនងពាណិជ្ជកម្មជាមួយកម្ពុជាប្រជាធិបតេយ្យមានប្រទេសចិន កូរ៉េខាងជើង ថៃ ជប៉ុន ហុងកុង ម៉ាដាហ្គាស្កា បង់ក្លាដែស និង សឹង្ហបុរី។ ទំនិញនាំចេញសំខាន់ៗរបស់កម្ពុជាប្រជាធិបតេយ្យ រួមមាន៖ ស្រូវ ជ័រកៅស៊ូ ឈើ និងសរីរាង្គសត្វដ៏កម្រ(ស្បែក, ភ្លុក, ស្នែក)។ ចំណែកទំនិញនាំចូលវិញរួមមាន គ្រឿងសព្វាវុធ រថក្រោះ កាំភ្លើងធំ ម៉ាស៊ីនសម្រាប់ធ្វើស្រែចម្ការ ផលិតផលគីមី និងក្រណាត់។

ទំនិញនាំចេញភាគច្រើនរបស់កម្ពុជាប្រជាធិបតេយ្យ មានចំនួនតិចតួចខ្លាំងណាស់ បើប្រៀបធៀបទៅនឹងការនាំចេញនៅមុនឆ្នាំ១៩៧០ ហើយត្រូវបាននាំចេញទៅកាន់ប្រទេសចិន ដែលជាប្រទេសតែមួយគត់ដែលមានឥទ្ធិពលមកលើកម្ពុជាប្រជាធិបតេយ្យ។ ពីឆ្នាំ១៩៧៧ដល់ចុងឆ្នាំ១៩៧៨ ចិនបានផ្តល់ឱ្យកម្ពុជាប្រជាធិបតេយ្យនូវរថក្រោះនិងរថយន្តរាប់រយគ្រឿង អាវុធធុនធ្ងន់ គ្រាប់ផ្លោង និងគ្រាប់កាំភ្លើងរាប់ពាន់តោន និងយន្តហោះប្រតិកម្មចំនួនប្រាំមួយគ្រឿង។ រដ្ឋាភិបាលចិនក៏បានផ្តល់ឱ្យកម្ពុជាប្រជាធិបតេយ្យនូវការជួសជុលផ្លូវរថភ្លើងមួយខ្សែពីក្រុងភ្នំពេញទៅក្រុងកំពង់សោម និងធ្វើព្រលានយន្តហោះថ្មីមួយទៀតនៅខេត្តកំពង់ឆ្នាំង។ ក្រៅពីទំនាក់ទំនងពាណិជ្ជកម្ម ជំនួយយោធា និងជំនួយហិរញ្ញវត្ថុ ចិនក៏បានបញ្ជូនអ្នកជំនាញរាប់ពាន់នាក់ឱ្យមកធ្វើជាអ្នកបច្ចេកទេស និងជាទីប្រឹក្សារបស់កម្ពុជាប្រជាធិបតេយ្យ។ អ្នកជំនាញទាំងនោះ បានជួយបង្ហាត់បង្រៀនក្បួនយោធា បច្ចេកទេសពេទ្យ និងបច្ចេកទេសក្នុងរោងចក្រដល់កម្មាភិបាលខ្មែរក្រហម។ កម្ពុជាប្រជាធិបតេយ្យបានស្នើដល់ចិនឱ្យបញ្ជូនកងទ័ពមកជួយច្បាំងជាមួយវៀតណាម ប៉ុន្តែចិនបានពន្យារពេល ហើយស្នើឱ្យមានបទឈប់បាញ់ និងធ្វើការចរចាគ្នា។ កម្ពុជាប្រជាធិបតេយ្យបានច្រានចោលសំណើនេះ។

### អៀង សារី (ហៅសមមិត្ត វ៉ាន់)

អៀង សារី កើតក្នុងឆ្នាំ១៩៣០ នៅខេត្តត្រាវិញ ប្រទេសវៀតណាមខាងត្បូង។ ក្នុងឆ្នាំ១៩៥០ អៀង សារី បានទទួលអាហារូបករណ៍ទៅសិក្សានៅប្រទេសបារាំង ជាកន្លែងដែល អៀង សារី បានស្គាល់ អៀង ធីរិទ្ធ និងក្រោយមកបានរៀបការជាមួយគ្នា។ អៀង សារី បានក្លាយទៅជាសមាជិកបក្សកុម្មុយនីស្តបារាំង។ នៅឆ្នាំ១៩៥៧ អៀង សារី បានវិលត្រឡប់មកប្រទេសកម្ពុជាវិញ ហើយបានចូលជាសមាជិកបក្សប្រជាជនបដិវត្តន៍ខ្មែរ។ អៀង សារី បង្រៀននៅវិទ្យាល័យកម្ពុជបុត្រ រហូតដល់ឆ្នាំ១៩៦៣ ដែលនៅពេលនោះបានរត់ចូលព្រៃតស៊ូ។ ក្រោយមក អៀង សារី បានក្លាយជាមេបញ្ជាការកងទ័ពនៅភូមិភាគឦសាន។

ក្នុងឆ្នាំ១៩៧៦ អៀង សារី ត្រូវបានតែងតាំងជាឧបនាយករដ្ឋមន្ត្រីទីមួយ ទទួលបន្ទុកកិច្ចការបរទេស។ អៀង សារី ក៏ជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស និងគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស។ អៀង សារី បានចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ១៩៩៦។

អៀង សារី ត្រូវបានចាប់និងឃុំខ្លួនក្រោមដីកាឃាត់ខ្លួនរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅឆ្នាំ២០០៧ដោយត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ជាមួយនឹងប្រពន្ធរបស់ខ្លួន គឺ អៀង ធីរិទ្ធ ដែលត្រូវបានឃាត់ខ្លួនដូចគ្នាពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ អៀង ធីរិទ្ធ ត្រូវបានប្រកាសថាមិនមាននីតិសម្បទាផ្នែកស្មារតីគ្រប់គ្រាន់ដើម្បីបន្តដំណើរការសវនាការដោយសារតែជំងឺវង្វេងវង្វាន់ធ្ងន់ធ្ងរ។ ជាលទ្ធផលដោយសារតែកង្វះខាតសមត្ថភាពផ្នែកស្មារតី អៀង ធីរិទ្ធ ត្រូវបានដោះលែងពីពន្ធនាគារ ហើយបានស្លាប់នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៥។ អៀង សារី បានស្លាប់នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៣ ដោយជំងឺចាស់ជរាក្នុងពេលដំណើរការសវនាការលើសំណុំរឿងរបស់ខ្លួនមិនទាន់ត្រូវបានបញ្ចប់នៅឡើយ។ អ្នកទាំងពីរពុំបានជាប់ទោសណាមួយដែលសម្រេចតាមច្បាប់តុលាការស្តីពីឧក្រិដ្ឋកម្មដែលបានចោទទេ។



**ប្រជាជនកម្ពុជានៅក្នុងខេត្តសៀមរាប សប្បាយរីករាយចំពោះការដួលរលំនៃរបបខ្មែរក្រហម ក្នុងឆ្នាំ១៩៧៩។ អ្នកខ្លះ ស្វែងរកព័ត៌មាននៅក្នុងកាសែតដើម្បីបញ្ជាក់ អំពីដំណឹងដែលថា របបនេះពិតជាដួលរលំ។** ប្រភព៖ ទីភ្នាក់ងារសារព័ត៌មានវៀតណាម/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

ជំពូកទី១២

# ការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ

## ១. មូលហេតុបីយ៉ាងនៃការដួលរលំរបស់កម្ពុជាប្រជាធិបតេយ្យ

**សុខភាពទ្រុឌទ្រោមរបស់ប្រជាជន៖** ផែនការបួនឆ្នាំរបស់កម្ពុជាប្រជាធិបតេយ្យបញ្ជាក់ថា កម្ពុជានឹងផលិតស្រូវឱ្យបានបីតោនក្នុងមួយហិកតារៀងរាល់ឆ្នាំ។ តួលេខនេះមានចំនួនច្រើនលើសទិន្នផលមុនសម័យបដិវត្តន៍។ នៅពេលទិន្នផលស្រូវមិនបានគ្រប់ផែនការកំណត់ កម្មាភិបាលនៅទូទាំងប្រទេសបានធ្វើរបាយការណ៍ក្លែងក្លាយ។ បន្ទាប់មក កម្មាភិបាលទាំងនេះនឹងបញ្ជូនស្រូវយ៉ាងច្រើនទៅតាមចំនួនផែនការកំណត់ ដោយទុកឱ្យប្រជាជនទទួលរងការអត់ឃ្លាន។

ដោយសារតែប្រតិបត្តិការទូទាំងប្រទេសជាការសម្ងាត់នោះ ធ្វើឱ្យផែនការក្នុងការប្រមូលទិន្នផលស្រូវឱ្យបានបីតោនក្នុងមួយហិកតាមិនអាចអនុវត្តបាន។ តំបន់ទាំងអស់ទូទាំងប្រទេសមិនត្រូវបានអនុញ្ញាតឱ្យចែករំលែកព័ត៌មានគ្នាទៅវិញទៅមក ឬត្រួតពិនិត្យមើលថា



**ជួរមុខពីឆ្វេងទៅស្តាំ៖ សមមិត្ត ជា ស៊ីម, សមមិត្ត ហេង សំរិន និង សមមិត្ត ហ៊ុន សែន ចូលរួមក្នុងពិធីរំលឹកខួបការចងចាំ និងអបអរសាទរនៃរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា (២ធ្នូ) ក្នុងទសវត្សរ៍ឆ្នាំ១៩៨០។**
ប្រភព៖ រូបថតដកស្រង់ចេញពីទំព័រសារព័ត៌មានគ្មានព្រំដែន ចុះផ្សាយថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៧។



**យុទ្ធនារីនៃរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា កំពុងហ្វឹកហ្វឺនរបៀបប្រើប្រាស់កាំភ្លើងវែង ដើម្បីប្រយុទ្ធប្រឆាំងនឹងសត្រូវ នៅក្នុងឆ្នាំ១៩៧៩។**
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

តើមានបញ្ហាអ្វីខ្លះកំពុងកើតមានឡើងនោះទេ។ មជ្ឈិមបក្សកម្រចុះមកមើលស្ថានភាពរស់នៅរបស់ប្រជាជន ឬរៀបចំផែនការឱ្យកម្មាភិបាលថ្នាក់ក្រោមរបស់ខ្លួនអនុវត្តណាស់។ មេដឹកនាំថ្នាក់លើហាក់ដូចជាជឿទាំងស្រុងនូវអ្វីដែលថ្នាក់ក្រោមបានរាយការណ៍។ ចំណែកថ្នាក់ក្រោមមិនហ៊ានរាយការណ៍ព័ត៌មានមិនល្អណាមួយទៅថ្នាក់លើឡើយ។ មន្ត្រីជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាជឿជាក់ថា បក្សមិនដែលប្រព្រឹត្តកំហុស និងមិនដែលសម្រេចចិត្តខុសទាល់តែសោះ។ រាល់បញ្ហាដែលកើតមានឡើង ត្រូវបានមេដឹកនាំទាំងនោះចោទប្រកាន់ថាជាកំហុសរបស់ជនបរទេសឬជនក្បត់។ ដោយសារតែលក្ខខណ្ឌរស់នៅកាន់តែមានសភាពយ៉ាប់យ៉ឺនទៅៗ ប្រជាជនរាប់ម៉ឺនសែននាក់បានស្លាប់ជាបន្តបន្ទាប់ ដោយការធ្វើការហួសកម្លាំង និងគ្មានអាហារ បរិភោគគ្រប់គ្រាន់។

**បន្សុទ្ធកម្ម ៖** នៅពាក់កណ្តាលឆ្នាំ១៩៧៦ សមាជិកសំខាន់ៗជាច្រើនរូបរបស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានធ្វើបន្សុទ្ធកម្ម។ ចាប់ពីពេលនោះមក ប៉ុល ពត និងសហការីជឿថាការបះបោរប្រឆាំងនឹងថ្នាក់ដឹកនាំបក្សកាន់តែកើតមានច្រើនឡើងៗ។ ថ្នាក់ដឹកនាំទាំងនេះជឿថា សត្រូវរបស់ខ្លួនមាននៅគ្រប់ទីកន្លែង។ គណៈភូមិភាគ គណៈតំបន់ និងមេបញ្ជាការកងទ័ពជាច្រើនរូប ត្រូវបានចាប់ខ្លួននិងសម្លាប់។ សភាពការណ៍កាន់តែមានសភាពធ្ងន់ធ្ងរទៅៗក្នុងឆ្នាំ១៩៧៧ នៅពេលដែល ប៉ុល ពត បញ្ជាឱ្យធ្វើការសម្លាប់កម្មាភិបាលភូមិភាគបូព៌ា និងធ្វើបន្សុទ្ធកម្មទៅលើប្រជាជនដែលរស់នៅក្នុងភូមិភាគនេះស្ទើរគ្មានសល់។ នៅពេលវៀតណាមវាយចូលភូមិភាគនេះនៅចុងឆ្នាំ១៩៧៧ ប្រជាជនសេសសល់ពីការធ្វើបន្សុទ្ធកម្ម ត្រូវបានចោទថាបានចូលដៃជាមួយវៀតណាម ហើយត្រូវបានមជ្ឈិមបក្សចាត់ទុកថាជាមនុស្ស "ក្បាលយួន ខ្លួនខ្មែរ"។ ហេតុដូច្នេះហើយ ទើបមជ្ឈិមបក្សបញ្ជូនកងទ័ពជាច្រើនមកវាយប្រហារភូមិភាគបូព៌ា ដែលបានសម្លាប់ប្រជាជនរាប់ម៉ឺននាក់។ ប្រជាជនរាប់ពាន់នាក់បានរត់ភៀសខ្លួនទៅវៀតណាម។



**ជនជាតិភាគតិចព្នងស្ពាយ «កាផា» (កន្ត្រកស្ពាយពីក្រោយខ្នងធ្វើពីឫស្សី) ទទួលអំណោយពីទីប្រឹក្សាវៀតណាម (ពាក់អាវស) និងកងកម្លាំងនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា (ពាក់ឯកសណ្ឋានយោធា) នៅក្នុងខេត្តមណ្ឌលគិរី ឆ្នាំ១៩៧៩។** (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ការប៉ះទង្គិចជាមួយវៀតណាម ៖ នេះគឺជាមូលហេតុធំបំផុតនៃការដួលរលំរបស់កម្ពុជាប្រជាធិបតេយ្យ។ នៅឆ្នាំ១៩៧៥ កម្ពុជាប្រជាធិបតេយ្យចាប់ផ្តើមបង្កបញ្ហានៅតាមព្រំដែនបណ្តើរៗជាមួយវៀតណាម។ ការប្រយុទ្ធគ្នាដ៏ខ្លាំងក្លាបានផ្ទុះឡើងនៅពាក់កណ្តាលឆ្នាំ១៩៧៧ គឺនៅពេលដែលខ្មែរក្រហមបានបាញ់ផ្លោងទៅលើខេត្តចូវដុក ខេត្តហាទៀង និងខេត្តមួយចំនួនទៀតរបស់វៀតណាមដែលបណ្តាលឱ្យគ្រោះថ្នាក់ដល់ប្រជាជនស៊ីវិល និងកងទ័ពវៀតណាមដែលមិនបានត្រៀមខ្លួនជាមុនអស់ជាច្រើននាក់។ ប្រជាជនវៀតណាមរាប់ពាន់នាក់បានរត់ចូលទៅក្នុងផ្ទៃប្រទេស។ ក្នុងអំឡុងពេលតែពីរ-បី ថ្ងៃនៃការវាយប្រហារ ប្រជាជនស៊ីវិលវៀតណាមប្រហែល១ ០០០នាក់បានរងរបួសឬស្លាប់។

នៅខែធ្នូឆ្នាំ១៩៧៧ វៀតណាមបានប្រើយន្តហោះនិងកាំភ្លើងធំបើកការវាយប្រហារទ្រង់ទ្រាយធំមួយមកលើកម្ពុជាប្រជាធិបតេយ្យដោយដណ្តើមកាន់កាប់បានតំបន់ចំពុះទា (ចំពុះសេក) ក្នុងខេត្តស្វាយរៀង។ កងទ័ពវៀតណាមបានវាយសម្រុកចូលក្នុងទឹកដីកម្ពុជាប្រជាធិបតេយ្យចម្ងាយជាង២០គីឡូម៉ែត្រពីព្រំដែន ហើយបានកាន់កាប់ទីរួមខេត្តស្វាយរៀង។ ជាការឆ្លើយតបចំពោះព្រឹត្តិការណ៍នេះ កម្ពុជាប្រជាធិបតេយ្យបានកាត់ផ្តាច់ចំណងការទូតជាមួយប្រទេសវៀតណាម ហើយបានបញ្ជាឱ្យអ្នកការទូតវៀតណាមទាំងអស់នៅក្នុងទីក្រុងភ្នំពេញ ចាកចេញពីប្រទេសកម្ពុជា។ ខ្មែរក្រហមយល់ព្រមធ្វើការចរចា លុះត្រាតែកងទ័ពវៀតណាមទាំងអស់ដកចេញពីទឹកដីកម្ពុជាប្រជាធិបតេយ្យជាមុនសិន។ មួយរយៈកាលក្រោយមកទៀត វៀតណាមបានដកទ័ពចេញពីប្រទេសកម្ពុជា ដោយកៀរអ្នកទោស និងប្រជាជនស៊ីវិលរាប់ពាន់នាក់យកទៅជាមួយផង។ គ្មានការចរចាណាមួយត្រូវបានធ្វើឡើងទេ។

វៀតណាមបានចោទប្រកាន់ខ្មែរក្រហមថា បានធ្វើការវាយប្រហារទៅលើខេត្តរបស់ខ្លួនទាំងប្រាំបី ដែលស្ថិតនៅតាមបណ្តោយព្រំដែនជាប់កម្ពុជា។ វៀតណាមបានជំរុញឱ្យមានការបង្កើតកម្លាំងបដិបក្ខមួយ ដើម្បីធ្វើការបះបោរប្រឆាំងនឹងខ្មែរក្រហម។ វៀតណាមក៏បានចាប់ផ្តើមហ្វឹកហ្វឺនជនជាតិកម្ពុជាដែលរស់នៅក្នុងប្រទេសវៀតណាម ដើម្បីចូលរួមក្នុងប្រតិបត្តិការយោធានិងបង្កើតកម្លាំងស្នូលសម្រាប់របបថ្មីមួយ។ ប្រទេសទាំងពីរបានប្រយុទ្ធគ្នាពេញមួយរយៈកាលនៃឆ្នាំ១៩៧៨។

នៅថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៨ វិទ្យុក្រុងហាណូយដែលផ្សាយជាភាសាខ្មែរ បានអំពាវនាវឱ្យប្រជាជនកម្ពុជាទាំងអស់ក្រោកឈរឡើងប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ។ វៀតណាមបានជ្រើសរើសប្រជាជនខ្មែរមួយចំនួនដែលបានភៀសខ្លួនទៅវៀតណាម ឱ្យបម្រើក្នុងជួរកងទ័ពដឹកនាំដោយវៀតណាម។ ភាគច្រើននៃជនជាតិខ្មែរទាំងនេះ គឺជាកម្មាភិបាល កងទ័ព និងប្រជាជនមកពីភូមិភាគបូព៌ា។ មកត្រឹមពេលនេះ ទឹកដីមួយផ្នែកនៃភូមិភាគបូព៌ា ស្ថិតនៅក្រោមការគ្រប់គ្រងរបស់វៀតណាម ហើយទឹកដីមួយផ្នែកទៀតស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងកម្លាំងបះបោរដែលប្រឆាំងនឹងខ្មែរក្រហម។

**តាម៉ុក (ឈ្មោះដើម ឈិត ជឿន)**

តាម៉ុក កើតនៅឆ្នាំ១៩២៦នៅខេត្តតាកែវ។ តាម៉ុក បានបួសរៀនអស់ជាច្រើនឆ្នាំ និងបានរៀបការជាមួយប្អូនជីដូនមួយរបស់ខ្លួនឈ្មោះ អ៊ុក ឃឹម ហើយមានកូនបួននាក់។ នៅឆ្នាំ១៩៤៩ តាម៉ុក គឺជាប្រធានខ្មែរឥស្សរៈស្រុកក្នុងខេត្តតាកែវ។ តាម៉ុក បានចូលជាសមាជិកបក្សកុម្មុយនីស្តនៅឆ្នាំ១៩៦៣។ ពីឆ្នាំ១៩៦៨ ដល់ ឆ្នាំ១៩៧៨ តាម៉ុក គឺជាលេខាភូមិភាគនិរតី។

នៅខែវិច្ឆិកា ឆ្នាំ១៩៧៨ តាម៉ុក ត្រូវបានតែងតាំងជាអនុលេខាទីពីរបក្សកុម្មុយនីស្តកម្ពុជា។ បន្ទាប់ពីការដួលរលំរបស់កម្ពុជាប្រជាធិបតេយ្យ តាម៉ុក មិនដែលស្នើសុំការលើកលែងទោស ហើយមិនដែលមានបំណងចុះចូលជាមួយរដ្ឋាភិបាលទេ។ តាម៉ុក ត្រូវបានចាប់ខ្លួនដោយកងទ័ពរាជរដ្ឋាភិបាល នៅក្បែរព្រំដែនថៃ នៅខែមីនា ឆ្នាំ១៩៩៩ និងបញ្ជូនមកដាក់ក្នុងមន្ទីរឃុំឃាំងរងចាំការកាត់ទោស។ តាម៉ុក ស្លាប់ ដោយជំងឺ នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦។

នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៧៨ វិទ្យុក្រុងហាណូយបានផ្សព្វផ្សាយពីការបង្កើតឡើងនូវរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា។[២៦] មេបញ្ជាការទ័ពវៀតណាម វ៉ាន់ ទៀនយុង បានធ្វើការវាយប្រហារយ៉ាងខ្លាំងក្លាមកលើកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៨។ ទ័ពរបស់ វ៉ាន់ ទៀនយុង បានវាយកាន់កាប់ខេត្តក្រចេះ ក្នុងរយៈពេល៩ថ្ងៃ និងខេត្តកំពង់ចាមក្នុងរយៈពេលមួយសប្តាហ៍។ បន្ទាប់មក នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពវៀតណាមនិងកងទ័ពរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា វាយដណ្តើមបានទីក្រុងភ្នំពេញ និងស្ទើរតែពេញផ្ទៃប្រទេសទាំងមូលក្នុងពេលបន្តបន្ទាប់គ្នា។ កងទ័ពទាំងពីរបានរៀបចំធ្វើមហាសន្និបាតមួយដើម្បីបង្កើតក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា ឱ្យធ្វើជារដ្ឋាភិបាលបណ្តោះអាសន្ន។

## ២. កម្ពុជាប្រជាធិបតេយ្យក្រោយឆ្នាំ១៩៧៩

នៅដើមឆ្នាំ១៩៧៩ រដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវបានបង្កើតឡើង ដើម្បីគ្រប់គ្រងប្រទេសក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ របបនេះ បានផ្លាស់ប្តូរឈ្មោះទៅជារដ្ឋកម្ពុជា នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៩។[២៧] មេដឹកនាំនិងកងទ័ពរបស់កម្ពុជាប្រជាធិបតេយ្យ បានរត់ភៀសខ្លួនចេញពីទីក្រុងភ្នំពេញឆ្ពោះទៅភាគពាយ័ព្យប្រទេសដោយថ្មើរជើង រថយន្ត និងរថភ្លើង។ ខ្មែរក្រហមបានកៀរប្រជាជនរាប់ម៉ឺននាក់ដោយបង្ខំឱ្យទៅជាមួយខ្លួន។ ក្នុងអំឡុងពេលនៃការជម្លៀសជាលើកចុងក្រោយនេះ ប្រជាជនជាច្រើននាក់បានស្លាប់ដោយសារអត់អាហារ ជំងឺ ឬរបួស។

ប្រជាជនជាច្រើនបានស្វះស្វែងរកផ្លូវត្រឡប់មកភូមិកំណើតរបស់ខ្លួនវិញ។ សម្តេចព្រះនរោត្តម សីហនុ និងព្រះញាតិវង្សានុវង្ស ត្រូវបានជម្លៀសតាមយន្តហោះទៅកាន់ប្រទេសចិន។

ខ្មែរក្រហមបានរៀបចំអង្គការចាត់តាំងរបស់ខ្លួនឡើងវិញនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ដោយមានជំនួយយោធាពីបរទេស។ រហូតដល់ឆ្នាំ១៩៩០ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុញ្ញាតឱ្យតំណាងរបស់កម្ពុជាប្រជាធិបតេយ្យ នៅបន្តកាន់កាប់អាសនៈរបស់កម្ពុជានៅមហាសន្និបាតអង្គការសហប្រជាជាតិ ទោះបីជាមានការជំទាស់ពីសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសម្ព័ន្ធមិត្តសង្គមនិយមមួយចំនួនក៏ដោយ។

នៅឆ្នាំ១៩៧៩ ខ្មែរក្រហមបានប្រកាសពីការបង្កើត "រណសិរ្សមហាសាមគ្គីជាតិ ស្នេហាជាតិ និងប្រជាធិបតេយ្យ" ប៉ុន្តែមិនទទួលបានការគាំទ្រពីប្រជាជនឡើយ។ នៅពេលជាមួយគ្នានេះ ចលនាតស៊ូមិនមែនកុម្មុយនីស្តដំបូងមួយឈ្មោះថា "រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ" ត្រូវបានបង្កើតឡើង ដឹកនាំដោយសម្តេច សឺន សាន ដែលជាអតីតនាយករដ្ឋមន្ត្រីក្នុងសម័យសង្គមរាស្ត្រនិយម (១៩៥៥-១៩៧០)។[២៨]

ក្រុមអ្នកតស៊ូរាជានិយមមួយដែលមានឈ្មោះថា "រណសិរ្សបង្រួបបង្រួមជាតិដើម្បីកម្ពុជាមួយដែល ឯករាជ្យ អព្យាក្រឹត្យ សន្តិភាព និងសហប្រតិបត្តិការ" ហៅកាត់ថា "ហ្វុនស៊ីនប៉ិច" ក៏ត្រូវបានបង្កើតឡើងដែរ ក្នុងពេលបន្តបន្ទាប់គ្នានោះ ក្រោមព្រះរាជកិច្ចដឹកនាំរបស់សម្តេចព្រះ នរោត្តម សីហនុ។ ក្រុមរាជានិយម ហ្វុនស៊ិនប៉ិច ក្រុមរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ និងក្រុមខ្មែរក្រហម បានរួបរួមគ្នាបង្កើតរដ្ឋាភិបាលចម្រុះត្រីភាគី ដែលមានសម្តេចព្រះ នរោត្តម សីហនុ ជាប្រធាន, ខៀវ សំផន ជាអនុប្រធាន និង សម្តេច សឺន សាន ជានាយករដ្ឋមន្ត្រី។ គោលបំណងរួមរបស់រដ្ឋាភិបាលនេះ គឺដើម្បីប្រមូលកម្លាំងធ្វើការតស៊ូរំដោះប្រទេសកម្ពុជាពីការជ្រៀតជ្រែករបស់វៀតណាម។ រដ្ឋាភិបាលចម្រុះត្រីភាគី ដែលមានក្រុមខ្មែរក្រហមជាក្រុមធំជាងគេនោះ បានកាន់កាប់អាសនៈរបស់កម្ពុជានៅអង្គការសហប្រជាជាតិ។

បន្ទាប់ពីការចរចាអស់រយៈពេលជាច្រើនឆ្នាំមក ភាគីជម្លោះកម្ពុជាទាំងអស់បានយល់ព្រមចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីស នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ហើយយល់ព្រមឱ្យមានការរៀបចំការបោះឆ្នោតជាតិមួយ ក្រោមការចាត់ចែង និងត្រួតពិនិត្យរបស់អាជ្ញាធរ

បណ្ដោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា ហៅកាត់ថា "អ៊ុនតាក់"។ ក្រុមខ្មែរក្រហមបានធ្វើពហិការមិនចូលរួមការបោះឆ្នោតជាតិដែលរៀបចំឡើងដោយអ៊ុនតាក់ទេ ហើយបដិសេធមិនព្រមរំសាយកងទ័ពរបស់ខ្លួនឡើយ។ ក្រោយការបោះឆ្នោតជាសកលឆ្នាំ១៩៩៣ កងទ័ពខ្មែរក្រហមបានបន្តប្រយុទ្ធប្រឆាំងនឹងកងកម្លាំងរបស់រាជរដ្ឋាភិបាលកម្ពុជា អស់ជាច្រើនឆ្នាំបន្តទៀត។

នៅខែសីហា ឆ្នាំ១៩៩៦ អៀង សារី បានចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ដោយនាំយកទាំងកងទ័ពមួយចំនួនមកជាមួយផង។ មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមួយចំនួនទៀតដូចជា កែ ពក, នួន ជា, និង ខៀវ សំផន បានចុះចូលជាមួយរដ្ឋាភិបាលក្នុងឆ្នាំ១៩៩៨។ បន្ទាប់ពី ប៉ុល ពត ស្លាប់នៅឆ្នាំ១៩៩៨ តាម៉ុក ជាមេខ្មែរក្រហមតែម្នាក់គត់ដែលបដិសេធមិនព្រមចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ហើយត្រូវបានចាប់ខ្លួននៅខែមីនា ឆ្នាំ១៩៩៩។ មកត្រឹមដំណាក់កាលនេះ មេដឹកនាំខ្មែរក្រហមដែលនៅរស់ទាំងអស់បានសារភាពចុះចាញ់ ឬត្រូវបានចាប់ខ្លួន ហើយចលនាខ្មែរក្រហមទាំងមូលបានដួលរលំជាស្ថាពរ។ ប្រជាពលរដ្ឋខ្មែរដែលរស់នៅតាមតំបន់ត្រួតត្រារបស់ខ្មែរក្រហមទាំងអស់បានធ្វើមាតុភូមិនិវត្តន៍ និងរួបរួមជាមួយរាជរដ្ឋាភិបាលកម្ពុជាវិញ។



**ប្រជាជនកម្ពុជា ធ្វើដំណើរដ៏វែងឆ្ងាយត្រឡប់ទៅកាន់ស្រុកកំណើតវិញ បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហមនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ រូបថតនេះថតនៅខាងមុខរោងភាពយន្តលុច្ស។** ប្រភព៖ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា



**ឯកសារមួយនេះនិងឯកសារដែលនៅសេសសល់ដទៃទៀតបង្ហាញអំពីព័ត៌មានជាច្រើនស្ដីពីរបបកម្ពុជាប្រជាធិបតេយ្យ។ ឯកសារទាំងនេះបានឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីរបៀប និងមូលហេតុដែលប្រជាជនជាច្រើនបានស្លាប់បាត់បង់ជីវិត។ នៅក្នុងន័យនេះ ឯកសារនីមួយៗតំណាងឱ្យជីវិតរបស់ប្រជាជនកម្ពុជាដែលស្លាប់នៅក្នុងរបបខ្មែរក្រហម។ មានឯកសាររបៀបនេះរាប់លានសន្លឹកទៀត។**

(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




អគារសន្និសីទ ឬសាលមហោស្រពចតុមុខជាតិ ដែលបានសាងសង់ឡើងនៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៦១ ត្រូវបានប្រើប្រាស់ជាសាលប្រជុំសភា (សភាតំណាងប្រជាជនកម្ពុជា) របស់ខ្មែរក្រហម និងជាទីតាំងដែលខ្មែរក្រហមធ្វើសេចក្តីសម្រេចបង្កើតរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងឆ្នាំ១៩៧៦។ នៅឆ្នាំ១៩៧៩ អគារដដែលនេះ ត្រូវបានប្រើប្រាស់ជា តុលាការប្រជាជនបដិវត្តន៍ ដើម្បីកាត់ទោស ប៉ុល ពត និង អៀង សារី ពីបទប្រល័យពូជសាសន៍។ ស្លាកនៅខាងលើច្រកចូលសរសេរថា "តុលាការ ប្រជាជន បដិវត្តន៍"។ បច្ចុប្បន្ន អគារនេះ គឺជាទីតាំងសម្តែងសិល្បៈ ឬហៅថា សាលចតុមុខ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជំពូកទី១៣

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និង កងស្ម័គ្រចិត្ត វៀតណាមបានមកដល់ប្រទេសកម្ពុជា និងបានកាន់កាប់ទីក្រុងភ្នំពេញ ជាសញ្ញាប្រាប់ថា របបខ្មែរក្រហមដែលត្រូវបានស្គាល់ថាជារបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានបញ្ចប់ទាំងស្រុង។ ខណៈខ្មែរក្រហមមិនអាចគ្រប់គ្រងប្រទេសតទៅទៀតបាន ខ្មែរក្រហមបានព្យាយាមបង្កើតកម្លាំងទ័ពព្រៃ បង្កអសន្តិសុខជាងមួយទសវត្សរ៍បន្តទៀត។

ក្នុងឆ្នាំ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជាបានស្នើសុំជំនួយពីអង្គការសហប្រជាជាតិ ក្នុងគោលបំណងបង្កើតតុលាការមួយ ដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ហើយនៅខែវិច្ឆិកា ឆ្នាំ១៩៩៨ អង្គការសហប្រជាជាតិ បានបញ្ជូនក្រុមអ្នកជំនាញរបស់ខ្លួនមកកាន់ប្រទេសកម្ពុជា និងប្រទេសថៃ ដើម្បីបញ្ជាក់ពីឫសគល់ឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងរបបខ្មែរក្រហម។ អ្នកជំនាញបានរកឃើញភ័ស្តុតាងនិងសាក្សី



ប្រជាជនកម្ពុជា ប្រមូលផ្តុំគ្នាមើលការផ្តន្ទាទោសទៅលើកងកម្លាំងខ្មែរក្រហមម្នាក់ ដែលត្រូវបានចាប់ខ្លួនដោយទាហាននៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

គ្រប់គ្រាន់ ដើម្បីតាក់តែងនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងមេដឹកនាំខ្មែរក្រហម។ អ្នកជំនាញ បានប្រាប់ឱ្យដឹងថា អង្គការសហប្រជាជាតិ ផ្តល់លទ្ធភាពចាំបាច់ដល់ការរៀបចំតុលាការអន្តរជាតិមួយ ក្នុងការស៊ើបអង្កេតនិងកាត់ទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ខណៈដែលសហគមន៍អន្តរជាតិចង់បានតុលាការអន្តរជាតិមួយ រដ្ឋាភិបាលកម្ពុជាយល់ឃើញថា តុលាការក្នុងស្រុកគឺជាវិធីល្អបំផុតក្នុងការដោះស្រាយឧក្រិដ្ឋកម្មទាំងនេះ។

នៅឆ្នាំ២០០១ រដ្ឋសភាជាតិកម្ពុជា បានអនុម័តច្បាប់ស្តីពីការបង្កើតតុលាការក្នុងស្រុកមួយ មានឈ្មោះថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (តុលាការកូនកាត់) ដើម្បីទទួលខុសត្រូវក្នុងការកាត់ក្តីបុគ្គលប្រព្រឹត្តបទល្មើស ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ នៅឆ្នាំ២០០៣ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា បានឈានដល់កិច្ចព្រមព្រៀងមួយស្តីអំពីនីតិវិធីដែលសហគមន៍អន្តរជាតិ អាចជួយនិងចូលរួមក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ អង្គជំនុំជម្រះវិសាមញ្ញនេះនឹងក្លាយជាតុលាការកម្ពុជាដែលត្រូវបានបង្កើតឡើងក្រោមច្បាប់កម្ពុជា ដោយមានការចូលរួមនិងជំនួយពីអង្គការសហប្រជាជាតិ។ តុលាការនេះជាតុលាការឯករាជ្យមួយមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិឡើយ ប៉ុន្តែជាតុលាការដែលអនុវត្តតាមស្តង់ដារយុត្តិធម៌អន្តរជាតិ ដែលរួមបញ្ចូលទាំងចៅក្រម មន្ត្រីច្បាប់ និងបុគ្គលិករដ្ឋបាលកម្ពុជានិងអន្តរជាតិ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (តុលាការកូនកាត់) មានស្ថាប័នសំខាន់ៗចំនួនបួន ដោយស្ថាប័ននីមួយៗមានទាំងភាគីកម្ពុជានិងភាគីអន្តរជាតិបំពេញការងារ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារួមមាន ស្ថាប័នតុលាការចំនួនបី (អង្គបុរេជំនុំជម្រះ, អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល), ការិយាល័យសហចៅក្រមស៊ើបអង្កេត, ការិយាល័យសហព្រះរាជអាជ្ញា និងការិយាល័យរដ្ឋបាល។ ក្រៅពីស្ថាប័នទាំងនេះ មានមេធាវីការពារក្តី ត្រូវបានបង្កើតឡើងដើម្បីផ្តល់ដល់ជនជាប់ចោទ ហើយមេធាវីការពារជនរងគ្រោះ ត្រូវបានចាត់តាំងឡើងដើម្បីជួយដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលតំណាងឱ្យជនរងគ្រោះឬសមាជិកគ្រួសារដែលនៅរស់រានមានជីវិតរបស់ជនរងគ្រោះពាក់ព័ន្ធនឹងករណីជាក់លាក់មួយ។

**ការិយាល័យសហចៅក្រមស៊ើបអង្កេត៖** ទទួលខុសត្រូវចំពោះការស៊ើបអង្កេត ដើម្បីសម្រេចថាតើជនណាខ្លះ អាចត្រូវបានកាត់ទោស និងកាត់ទោសពីបទប្រព្រឹត្តឧក្រិដ្ឋកម្មអ្វី។

**ការិយាល័យសហព្រះរាជអាជ្ញា៖** ទទួលខុសត្រូវចំពោះការនាំយកដីកាចោទប្រកាន់ និងធ្វើការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ។

**ការិយាល័យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖** គឺតំណាងឱ្យផលប្រយោជន៍របស់ក្រុមដើមបណ្តឹងរដ្ឋប្បវេណី។ នៅពេលដែលមនុស្សម្នាក់ត្រូវបានទទួលស្គាល់ថាជាដើមបណ្តឹងរដ្ឋប្បវេណី អ្នកនោះនឹងក្លាយជា "ភាគី" នៃកិច្ចដំណើរការនីតិវិធី។ ដើម្បីទទួលបានងារជាដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះត្រូវតែបង្ហាញថាខ្លួនបានទទួលរងនូវភាពឈឺចាប់បង្កដោយអំពើឧក្រិដ្ឋកម្មផ្ទាល់ ដែលត្រូវបានចោទប្រកាន់ក្នុងករណីជាក់លាក់ណាមួយនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ខណៈដែលដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននាក់គឺជាជនរងគ្រោះនៃរបបខ្មែរក្រហម សមាជិកគ្រួសារជាច្រើននាក់ដែលជាសាច់ញាតិរបស់អ្នកស្លាប់ក្នុងសម័យខ្មែរក្រហម ក៏ត្រូវបានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទទួលស្គាល់ថាជាដើមបណ្តឹងរដ្ឋប្បវេណីដែរ។ ការិយាល័យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទទួលខុសត្រូវខ្ពស់ចំពោះតុលាការ ចំពោះការតស៊ូមតិ យុទ្ធវិធី និងការផ្តល់បទបង្ហាញនៅក្នុងតុលាការស្តីពីផលប្រយោជន៍របស់ក្រុមដើមបណ្តឹងរដ្ឋប្បវេណី។

**ការិយាល័យរដ្ឋបាល៖** គាំទ្រដល់កិច្ចដំណើរការរបស់តុលាការ តាមរយៈកិច្ចការរដ្ឋបាលផ្សេងៗ រួមបញ្ចូល ការជ្រើសរើសនិងការបណ្តុះបណ្តាលមន្ត្រីតុលាការ ការដោះស្រាយបញ្ហាសារពើពន្ធរបស់តុលាការ ការគាំទ្រដល់ទំនាក់ទំនងខាងក្នុងនិងខាងក្រៅតុលាការ ការកត់ត្រា ការគ្រប់គ្រង និងការថែរក្សានិងរក្សាទុកភស្តុតាង ការរក្សាសុវត្ថិភាពនិងសន្តិសុខរបស់មន្ត្រីតុលាការ ព្រមទាំងបរិវេណទាំងមូលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការអភិវឌ្ឍនិងការអនុវត្តកិច្ចការគាំទ្រសាក្សីនិងអ្នកជំនាញ និងនីតិវិធីសុវត្ថិភាព ការឃុំខ្លួន និងសេវាកម្មទូទៅផ្សេងទៀតដូចជាឧបករណ៍ គ្រឿងបរិក្ខារ ការផ្គត់ផ្គង់ និងការផ្តល់ជាមធ្យោបាយធ្វើដំណើរ។

**អង្គភាពគាំពារជនរងគ្រោះ៖** ទទួលខុសត្រូវជួយជនរងគ្រោះក្នុងការដាក់ពាក្យបណ្តឹង, សុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ផ្តល់ព័ត៌មាន និងជំនួយទូទៅដល់ជនរងគ្រោះ ជាពិសេសដើមបណ្តឹងរដ្ឋប្បវេណី។

**អង្គភាពគាំពារការពារក្តី៖** ទទួលខុសត្រូវក្នុងការសម្របសម្រួលការគាំទ្រពីមេធាវីជាតិនិងអន្តរជាតិ ក្នុងការការពារជនជាប់ចោទនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ មេធាវីការពារក្តី មានភាពឯករាជ្យពីតុលាការ ហើយអង្គភាពគាំពារការការពារក្តីមានទំនាក់ទំនងទៅនឹងដំណើរការការពារក្តីដែលផ្តោតទៅលើអង្គហេតុរបស់កូនក្តី។

**អង្គបុរេជំនុំជម្រះ៖** មានចៅក្រមចំនួនប្រាំរូប ក្នុងនោះមានចៅក្រមកម្ពុជាបីរូបដែលមួយរូបជាប្រធាន និងចៅក្រមបរទេសពីររូប។ តួនាទីរបស់អង្គបុរេជំនុំជម្រះ គឺដើម្បីដោះស្រាយបញ្ហាមុនពេលជំនុំជម្រះ ឬភាពមិនចុះសម្រុងគ្នា ដែលលើកឡើងដោយសហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេត។



**បន្ទប់សវនាការ នៃតុលាការប្រជាជនបដិវត្តន៍ (បច្ចុប្បន្ន គឺជាសាលមហោស្រពចតុមុខ) ក្នុងឆ្នាំ១៩៧៩។ កែវ ចិន្តា ដែលជាប្រធានតុលាការ អង្គុយនៅចំកណ្តាលចំណោមមនុស្ស១១នាក់នៅលើវេទិកា។** (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**អង្គជំនុំជម្រះសាលាដំបូង៖** មានចៅក្រមចំនួនប្រាំរូប ក្នុងនោះមានចៅក្រមកម្ពុជាបីរូបដែលមួយរូបជាប្រធាន និងចៅក្រមបរទេសពីររូប។ តួនាទីរបស់អង្គជំនុំជម្រះសាលាដំបូង គឺពិនិត្យភស្តុតាង និងពិចារណាសក្ខីកម្មរបស់សាក្សី និងអំណះអំណាងរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះសាលាដំបូង នឹងចេញសេចក្តីសម្រេចលើពិរុទ្ធភាព ឬភាពគ្មានទោសកំហុសរបស់ជនជាប់ចោទ។ សាលក្រមដែលមានពិរុទ្ធភាព តម្រូវឱ្យមានការបោះឆ្នោតគាំទ្រយ៉ាងតិចពីសំណាក់ចៅក្រមចំនួនបួនរូប ក្នុងចំណោមចៅក្រមទាំងប្រាំរូប។

**អង្គជំនុំជម្រះតុលាការកំពូល៖** មានតួនាទីជំនុំជម្រះក្តីលើបណ្តឹងសាទុក្ខចុងក្រោយ។ អង្គជំនុំជម្រះតុលាការកំពូល មានចៅក្រមចំនួនប្រាំពីររូប ក្នុងនោះមានចៅក្រមកម្ពុជាបួនរូប ដែលមួយរូបធ្វើជាប្រធាន និងចៅក្រមបរទេសបីរូប។

**យុត្តាធិការ៖** អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានយុត្តាធិការលើជនប្រព្រឹត្តបទឧក្រិដ្ឋពីរប្រភេទគឺ៖ (១) មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និង(២) អ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់ជាតិនិងអន្តរជាតិ។ យុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានកំណត់ត្រឹមឧក្រិដ្ឋកម្មជាក់លាក់ដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តនៅក្នុងចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ ក្រោមច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះនេះមានអំណាចក្នុងការនាំយកជនសង្ស័យមកជំនុំជម្រះ ពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ លើសពីនេះទៅទៀត ស្ថិតក្រោមច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះមានយុត្តាធិការក្នុងការនាំខ្លួនជនជាប់ចោទមកជំនុំជម្រះ ពីបទបំផ្លាញទ្រព្យសម្បត្តិវប្បធម៌ ស្របតាមអនុសញ្ញាទីក្រុងឡាអេឆ្នាំ១៩៥៤ ស្តីពីការការពារទ្រព្យសម្បត្តិវប្បធម៌ក្នុងករណីមានជម្លោះប្រដាប់អាវុធ និងឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកការពារដែលត្រូវបានការពារជាអន្តរជាតិ ដោយអនុលោមតាមអនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៦១ ស្តីពីទំនាក់ទំនងការទូត។



**គំនរលលាដ៍ក្បាល និងឆ្អឹងជនរងគ្រោះនៃរបបខ្មែរក្រហម រក្សាទុកនៅក្នុងអគារបាក់បែកមួយនាបរិវេណមន្ទីរសន្តិសុខខ្មែរក្រហមឬគុកសង់ ក្នុងខេត្តកណ្តាល ឆ្នាំ១៩៨០។** ប្រភព៖ ដេវីដ ហក/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

## ១. គោលការណ៍ច្បាប់ បញ្ញត្តិ និងច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

*អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រើប្រាស់គោលការណ៍ច្បាប់ បញ្ញត្តិ និងច្បាប់ជាច្រើន ដកស្រង់មកពីច្បាប់កម្ពុជា សន្ធិសញ្ញាអន្តរជាតិនិងសេចក្តីសម្រេចរបស់តុលាការ និងច្បាប់អន្តរជាតិ។ ការអធិប្បាយខាងក្រោម បង្ហាញអំពីសេចក្តីសង្ខេបនៃបញ្ញត្តិជាមូលដ្ឋានមួយចំនួនដែលត្រូវបានប្រើប្រាស់ នៅក្នុងច្បាប់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងសន្ធិសញ្ញាពាក់ព័ន្ធដទៃទៀត ដូចជាកតិកាសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ ដែលប្រទេសកម្ពុជាជាភាគីមួយក្នុងកតិកាសញ្ញានេះ។ ការអធិប្បាយនេះ គឺសម្រាប់បម្រើដល់គោលបំណងអប់រំតែប៉ុណ្ណោះ និងមិនឆ្លុះបញ្ចាំងពីសេចក្តីសង្ខេបពេញលេញនៃគោលការណ៍ច្បាប់ បញ្ញត្តិ និងច្បាប់សំខាន់ៗរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឡើយ ហើយក៏មិនឆ្លុះបញ្ចាំងអំពីការបកស្រាយផ្លូវការ ឬជំហររបស់រាជរដ្ឋាភិបាលកម្ពុជា អង្គការសហប្រជាជាតិ ឬអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរ។ អ្នកអានត្រូវបានលើកទឹកចិត្តឱ្យអានច្បាប់ពាក់ព័ន្ធនិងការបកស្រាយរបស់រដ្ឋាភិបាលកម្ពុជា អង្គការសហប្រជាជាតិ និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រាប់ជំហរផ្លូវការបច្ចុប្បន្ន។*

**ការសន្មតថាគ្មានទោស៖** ជនជាប់ចោទណាក៏ដោយ ត្រូវបានចាត់ទុកថាជាមនុស្សគ្មានទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ (មាត្រា៣៥ថ្មី នៃច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា)។

**សវនាការដែលប្រព្រឹត្តទៅដោយត្រឹមត្រូវ និងឆាប់រហ័ស៖** ជនជាប់ចោទ ត្រូវបានធានាពីសិទ្ធិទទួលបានការជំនុំជម្រះក្តី ដោយត្រឹមត្រូវនិងឆាប់រហ័ស។ កតិកាសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ (មាត្រា៣៣ថ្មី នៃច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា)។

**សន្តិសុខរបស់ជនសង្ស័យ និងការការពារជនរងគ្រោះនិងសាក្សី៖** រាជរដ្ឋាភិបាលកម្ពុជា នឹងធានាសន្តិសុខដល់ជនសង្ស័យដែលបង្ហាញខ្លួននៅចំពោះមុខតុលាការ ហើយតុលាការនឹងផ្តល់ការការពារជនរងគ្រោះនិងសាក្សី ដែលនឹងរួមបញ្ចូលទាំងការការពារអត្តសញ្ញាណរបស់ជនរងគ្រោះផង (មាត្រា៣៣ថ្មី នៃច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា)។

**នីតិវិធីត្រឹមត្រូវនៃច្បាប់៖** បុគ្គលគ្រប់រូប ត្រូវមានភាពស្មើគ្នានៅចំពោះមុខតុលាការ និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ចំពោះការសម្រេចចិត្តចោទប្រកាន់ពីបទឧក្រិដ្ឋព្រហ្មទណ្ឌណាមួយទៅលើបុគ្គល ឬសិទ្ធិរបស់បុគ្គល និងកាតព្វកិច្ចរបស់បុគ្គលនៅក្នុងបណ្តឹងផ្លូវច្បាប់ បុគ្គលគ្រប់រូបនឹងមានសិទ្ធិទទួលបានការជំនុំជម្រះដោយត្រឹមត្រូវនិងជាសាធារណៈ ដោយតុលាការដែលមានសមត្ថភាពឯករាជ្យ និងមិនលម្អៀង ដែលបង្កើតឡើងដោយច្បាប់ (មាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ ដែលត្រូវបានដាក់បញ្ចូលជាឯកសារយោង នៅក្នុងច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា)។

**ការទទួលខុសត្រូវរបស់បុគ្គល៖** ជនសង្ស័យ ត្រូវទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្ត។ តួនាទីឬឋានៈរបស់ជនសង្ស័យ មិនអាចជួយជននោះឱ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ឬជួយបន្ធូរបន្ថយទណ្ឌកម្មដល់ជននេះបានឡើយ។ លើសពីនេះទៅទៀត ថ្នាក់លើ(មេដឹកនាំ) អាចត្រូវបានរកឃើញថាមានការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងដោយអ្នកក្រោមបង្គាប់ ប្រសិនបើថ្នាក់លើនោះបានដាក់បញ្ជានិងគ្រប់គ្រងលើអ្នកក្រោមបង្គាប់ និងបានដឹង(ឬមានហេតុផលដឹង) អំពីសកម្មភាពរបស់អ្នកក្រោមបង្គាប់របស់ខ្លួន។ ថ្នាក់លើក៏ត្រូវជាអ្នកទទួលខុសត្រូវដែរ ប្រសិនបើខ្លួនខកខានមិនបានចាត់វិធានការចាំបាច់និងសមស្រប ដើម្បីបង្ការអំពើឧក្រិដ្ឋឬដាក់ទណ្ឌកម្មចំពោះអ្នកប្រព្រឹត្តបទឧក្រិដ្ឋ។ ប្រការដែលថាជនសង្ស័យបានប្រព្រឹត្តអំពើឧក្រិដ្ឋ ទៅតាមបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យឬរបស់ថ្នាក់លើណាមួយ មិនអាចជួយជនសង្ស័យនេះ ឱ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋបានឡើយ (មាត្រា២៩ នៃច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា)។

**គ្មានបទឧក្រិដ្ឋណាដែលគ្មានច្បាប់កាត់ទោសនោះទេ៖** ស្ថិតក្រោមច្បាប់ជាតិឬច្បាប់អន្តរជាតិ គ្មានជនណាម្នាក់ ត្រូវទទួលទោសព្រហ្មទណ្ឌដោយសារតែសកម្មភាពឬកំហុសស្រាលៗណាមួយរបស់ខ្លួន ដែលមិនបង្កបង្កើតទៅជាបទឧក្រិដ្ឋព្រហ្មទណ្ឌ ក្នុងអំឡុងពេលនៃការប្រព្រឹត្តកើតឡើង (មាត្រា១៥ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ ដែលត្រូវបានដាក់បញ្ចូលជាឯកសារយោង នៅក្នុងច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា)។

**តម្លាភាព៖** សវនាការត្រូវធ្វើឡើងជាសាធារណៈ លើកលែងតែក្នុងកាលៈទេសៈពិសេស ដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រេចថា ត្រូវបិទទ្វារជំនុំជម្រះជាសម្ងាត់ក្រោមមូលហេតុត្រឹមត្រូវទៅតាមនីតិវិធីជាធរមាន ដោយហេតុថាការផ្សព្វផ្សាយជាសាធារណៈធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌។ នៅពេលដែលផលប្រយោជន៍យុត្តិធម៌អាចជួយដល់ការជំនុំជម្រះជាសម្ងាត់បាន ពេលនោះហើយដែលអត្តសញ្ញាណរបស់សាក្សីអាចត្រូវបានការពារ (មាត្រា៣៤ថ្មី នៃច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា)។

**យុត្តិធម៌ដោយគ្មានការអូសបន្លាយពេល៖** ជនសង្ស័យ គួរតែត្រូវបានទទួលការជំនុំជម្រះដោយគ្មានការអូសបន្លាយពេលវេលា (មាត្រា៣៥ថ្មី នៃច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា)។

## សិទ្ធិការពារក្តីជនជាប់ចោទ៖

**ការរៀបចំមេធាវីការពារក្តីរបស់ជនជាប់ចោទ៖** ជនជាប់ចោទ ត្រូវមានពេលវេលានិងលក្ខណៈគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន និងទាក់ទងជាមួយមេធាវីការពារដែលខ្លួនបានជ្រើសរើស (មាត្រា៣៥ថ្មី នៃច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា)។

**សិទ្ធិជនជាប់ចោទក្នុងការការពារខ្លួន៖** ជនជាប់ចោទ ត្រូវបានជំនុំជម្រះដោយមានវត្តមានខ្លួនផ្ទាល់ និងការពារខ្លួនដោយខ្លួនឯង ឬតាមរយៈមេធាវីដែលជ្រើសរើសដោយខ្លួនឯង ត្រូវបានប្រាប់ឱ្យដឹងអំពីសិទ្ធិ និងទទួលបានជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ ប្រសិនបើជនជាប់ចោទគ្មានលទ្ធភាពជួលដោយខ្លួនឯង (មាត្រា៣៥ថ្មី នៃច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា)។

**ពិនិត្យភស្តុតាងដាក់បន្ទុក៖** ជនជាប់ចោទ មានសិទ្ធិពិនិត្យមើលភស្តុតាងដាក់បន្ទុក និងទទួលបាននូវការចូលរួម និងការពិនិត្យភស្តុតាងដោះបន្ទុកក្នុងលក្ខខណ្ឌដូចគ្នា និងភស្តុតាងដាក់បន្ទុកដែរ (មាត្រា៣៥ថ្មី នៃច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា)។

**ជំនួយពីអ្នកបកប្រែភាសា៖** ជនជាប់ចោទ ត្រូវមានការជួយឧបត្ថម្ភដោយសេរីពីអ្នកបកប្រែភាសា ប្រសិនបើជនជាប់ចោទមិនយល់ ឬមិនអាចនិយាយបាននូវភាសាដែលប្រើនៅក្នុងតុលាការ (មាត្រា៣៥ថ្មី នៃច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា)។

ជនជាប់ចោទ មិនត្រូវបង្ខំឱ្យផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ឬបង្ខំឱ្យឆ្លើយសារភាពថាមានកំហុស (មាត្រា៣៥ថ្មី នៃច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា)។

**ជំនួយការប្រឹក្សា៖** ជនសង្ស័យ មានសិទ្ធិទទួលបានការការពារពីមេធាវីដែលជ្រើសរើសដោយខ្លួនឯងដោយខានមិនបាន និងមានជំនួយផ្នែកច្បាប់ដល់ខ្លួនដោយឥតគិតថ្លៃ ប្រសិនបើខ្លួនគ្មានលទ្ធភាពគ្រប់គ្រាន់ដើម្បីពឹងមេធាវី (មាត្រា២៤ថ្មី នៃច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា)។

**សេចក្តីជូនដំណឹង៖** ជនជាប់ចោទ ត្រូវបានជូនដំណឹងភ្លាមៗ និងលម្អិតស្តីពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ចំពោះខ្លួន (មាត្រា៣៥ថ្មី នៃច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា)។



**លលាដ៍ក្បាលជនរងគ្រោះនៃរបបខ្មែរក្រហម ដែលបានប្រមែប្រមូលនៅក្នុងឆ្នាំ១៩៨២ ត្រូវបានដាក់តម្កល់នៅក្នុងអគារធ្វើពីឈើនៃអតីតមន្ទីរសន្តិសុខក្រាំងតាចាន់ របស់ខ្មែរក្រហម នៅក្នុងត្រាំកក់ ខេត្តតាកែវ។ មន្ទីរសន្តិសុខនេះ ស្ថិតនៅក្រោមការស៊ើបអង្កេតរបស់សាលាក្តីខ្មែរក្រហម សម្រាប់សំណុំរឿង០០២។**
ប្រភព៖ ម៉ៃឡាំ/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

ជំពូកទី១៤

# សំណុំរឿងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សំណុំរឿង ០០១,០០២, ០០៣ និង០០៤

*ជំពូកនេះ ផ្តែកលើសេចក្តីសម្រេច និងការវិនិច្ឆ័យនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ការកំណត់អំពីពិរុទ្ធភាព ឬភាពគ្មានទោសកំហុសរបស់ជនជាប់ចោទណាម្នាក់ ដែលមានឈ្មោះនៅក្នុងជំពូកនេះ ដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងសាលដីការបស់អង្គជំនុំជម្រះសាលាដំបូង ហើយប្រសិនបើសមស្របត្រូវបានបញ្ជាក់ ឬកែប្រែដោយអង្គជំនុំជម្រះតុលាការកំពូល គឺជាកំណត់ហេតុដែលមានកាតព្វកិច្ចស្របច្បាប់តែមួយគត់នៃព្រឹត្តិការណ៍ដែលបានលើកឡើងនៅក្នុងជំពូកនេះ។ អ្នកអាន ត្រូវបានលើកទឹកចិត្តឱ្យអានឯកសារស្តីពីសេចក្តីសម្រេច និងការវិនិច្ឆ័យដែលពាក់ព័ន្ធរបស់អង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល សម្រាប់កំណត់ហេតុដែលមានកាតព្វកិច្ចស្របច្បាប់ជាផ្លូវការនៃសំណុំរឿង ០០១, ០០២, ០០៣ និង ០០៤។*

## ១. សំណុំរឿង ០០១

សំណុំរឿង ០០១ ពាក់ព័ន្ធនឹងការជំនុំជម្រះក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច។ ឌុច គឺជាអតីតប្រធានមន្ទីរសន្តិសុខ ស-២១ ក្នុងទីក្រុងភ្នំពេញ។ មន្ទីរសន្តិសុខ ស-២១ គឺជាសាលារៀនដែលខ្មែរក្រហមប្រើប្រាស់ជាមន្ទីរសន្តិសុខ (គុក)។ មនុស្សរាប់ពាន់នាក់ បានទទួលរងនូវស្ថានភាពអមនុស្សធម៌ ភាពអត់ឃ្លាន និងទារុណកម្មដ៏ឃោរឃៅនិងឈឺចាប់។ អ្នកទោសរាប់ពាន់នាក់ បានស្លាប់ឬត្រូវសម្លាប់។ ក្នុងឆ្នាំ១៩៩៩ ឌុច ត្រូវបានចាប់ខ្លួនពីសំណាក់អាជ្ញាធរ កម្ពុជា និងបានបញ្ជូនមកដាក់ឃុំឃាំងក្នុងតុលាការយោធារហូតដល់ឆ្នាំ២០០៧ មុនពេលដែលគាត់ត្រូវបានបញ្ជូនខ្លួនមកកាន់មន្ទីរឃុំឃាំងបណ្តោះអាសន្នរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តាមដីកាបង្គាប់របស់សហចៅក្រមស៊ើបអង្កេត។ នៅខែសីហា ឆ្នាំ២០០៨ ឌុច ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋព្រហ្មទណ្ឌ ហើយការជំនុំជម្រះក្តីទៅលើផ្នែកសំខាន់ៗនៃបទឧក្រិដ្ឋរបស់ ឌុច បានចាប់ផ្តើមនៅខែមីនា ឆ្នាំ២០០៩។ ក្នុងអំឡុងពេលនៃដំណើរការសវនាការ តុលាការបានស្តាប់សក្ខីកម្មពីសាក្សីជំនាញចំនួន៩រូប សាក្សីអង្គហេតុចំនួន១៧រូប សាក្សីអត្តចរិក៧រូប និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន២២រូប។ លើសពីនេះទៀត ឯកសារប្រហែលមួយពាន់ឯកសារ ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ និងត្រូវបានដាក់ឱ្យពិនិត្យ។ មិនដូចជនជាប់ចោទឯទៀតឡើយ ឌុច គឺជាសាក្សីម្នាក់ដែលមានការសហការល្អក្នុងការផ្តល់ភ័ស្តុតាងជាច្រើនប្រឆាំងខ្លួនឯង ក៏ដូចជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដទៃទៀត។

នៅខែកក្កដា ឆ្នាំ២០១០ ឌុច ត្រូវបានអង្គជំនុំជម្រះសាលាដំបូង រកឃើញថាមានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩។ អង្គជំនុំជម្រះសាលាដំបូង បានកាត់ទោស ឌុច ឱ្យជាប់ពន្ធនាគាររយៈពេល៣៥ឆ្នាំ ប៉ុន្តែទោសនេះត្រូវបន្ថយ៥ឆ្នាំ។

នៅឆ្នាំ២០១២ ក្រោមបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធសេចក្តីសម្រេចជាច្រើនរបស់អង្គជំនុំជម្រះសាលាដំបូង ជាពិសេសទាក់ទងនឹងការកាត់ទោស ឌុច។ អង្គជំនុំជម្រះតុលាការកំពូល បានផ្តន្ទាទោសឌុចឱ្យជាប់ពន្ធនាគារអស់មួយជីវិត ដោយបញ្ជាក់ថាអង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសឆ្គងផ្លូវច្បាប់ ដោយមិនបានផ្តល់ទម្ងន់គ្រប់គ្រាន់ចំពោះភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែល ឌុច បានប្រព្រឹត្ត និងស្ថានទម្ងន់ទោសក្នុងករណីនេះ ហើយថាបានភ្ជាប់ទម្ងន់ច្រើនពេកទៅនឹងស្ថានភាពបន្ធូរបន្ថយទោស។



**ខ្នោះសម្រាប់ដាក់កជើងអ្នកទោសនៃរបបខ្មែរក្រហមដែលបានបន្សល់ទុកនៅវត្តចំពុះក្អែកក្នុងឆ្នាំ១៩៨២។ ក្នុងរបបខ្មែរក្រហម វត្តនេះស្ថិតនៅក្នុងស្រុកកៀនស្វាយ ខេត្តកណ្តាល។ បច្ចុប្បន្ន វត្តនេះស្ថិតនៅក្នុងខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។** ប្រភព៖ ម៉ៃឡាំ/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

ដូចដែលអង្គជំនុំជម្រះតុលាការកំពូល នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបញ្ជាក់ថា៖

> *ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយ កាំង ហ្កេកអ៊ាវ គឺពិតជាស្ថិតក្នុងចំណោមអំពើអាក្រក់បំផុតនៅក្នុងប្រវត្តិសាស្ត្ររបស់មនុស្សជាតិ។ អ្នកទាំងនោះ សមនឹងទទួលបានការពិន័យយ៉ាងធ្ងន់ធ្ងរបំផុត ដើម្បីផ្តល់នូវការឆ្លើយតបប្រកបដោយភាពត្រឹមត្រូវ និងគ្រប់គ្រាន់សម្រាប់ប្រឆាំងនឹងបទឧក្រិដ្ឋទាំងឡាយ ដែលបានកើតឡើងចំពោះជនរងគ្រោះក្រុមគ្រួសារ និងសាច់ញាតិ ប្រជាជនកម្ពុជា និងមនុស្សជាតិទាំងអស់។ សហព្រះរាជអាជ្ញា មិនបាននិយាយបំផ្លើសឡើយ នៅពេលដែលមន្ទីរស-២១ ត្រូវបានហៅថា "រោងចក្រសម្លាប់មនុស្ស"។ កាំង ហ្កេកអ៊ាវ បានបញ្ជា និងប្រតិបត្តិការរោងចក្រនៃសេចក្តីស្លាប់នេះ អស់រយៈពេលជាង៣ឆ្នាំ។ គាត់ទទួលខុសត្រូវចំពោះការបញ្ចប់ជីវិតមនុស្សយ៉ាងតិច ១២ ២៧២នាក់ រួមទាំងស្ត្រីនិងកុមារ ដោយគ្មានធម៌មេត្តា។*

នៅទីបំផុត ឌុច ត្រូវបានគេរកឃើញថាមានពិរុទ្ធភាព ហើយត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិតចំពោះឧក្រិដ្ឋកម្មដូចខាងក្រោម៖

**ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ**

- ការធ្វើទុក្ខបុកម្នេញក្រោមហេតុផលនយោបាយ។
- ការបំផ្លិចបំផ្លាញ (រាប់បញ្ចូលទាំងឃាតកម្ម)។
- ការដាក់ឱ្យធ្វើជាទាសករ។ការដាក់ពន្ធនាគារ។
- ការធ្វើទារុណកម្ម។
- ការប្រព្រឹត្តអំពើអមនុស្សធម៌ផ្សេងទៀត។

**ការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩**

- ការសម្លាប់ដោយចេតនា។
- ការធ្វើទារុណកម្ម និងទង្វើអមនុស្សធម៌។
- ការបង្កដោយចេតនាដែលបណ្តាលឱ្យមានការឈឺចាប់យ៉ាងខ្លាំងឬរងរបួសយ៉ាងធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព។
- ការដកហូតដោយចេតនានូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងត្រឹមត្រូវរបស់អ្នកទោសសង្គ្រាម ឬជនស៊ីវិល។
- ការបង្ខាំងជនស៊ីវិលដោយខុសច្បាប់។

ដើមបណ្តឹងរដ្ឋប្បវេណីសរុបចំនួន៦៤រូប ត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០១ ហើយនៅក្នុងបណ្តឹងសាលាឧទ្ធរណ៍ តុលាការកំពូលបានផ្តល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១០រូបបន្ថែមទៀត ដែលត្រូវបានបដិសេធដោយអង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះសាលាដំបូង បានផ្តល់សំណងដូចខាងក្រោម៖

(១) ដាក់បញ្ចូលឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលស្គាល់និងសមាជិកគ្រួសារដែលស្លាប់ ទៅក្នុងសាលក្រម និង

(២) ចងក្រងនិងផ្សព្វផ្សាយរាល់ពាក្យសូមអភ័យទោស និងការទទួលស្គាល់ពីការទទួលខុសត្រូវរបស់ ឌុច។

សេចក្តីសម្រេចនេះ ត្រូវបានបញ្ជាក់ទទួលស្គាល់ដោយអង្គជំនុំជម្រះតុលាការកំពូល។

## ២. សំណុំរឿង ០០២

នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេត បានចោទប្រកាន់ អៀង សារី, នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ។ នៅខែមិថុនា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង បានបើកសវនាការដំបូងសម្រាប់សំណុំរឿង០០២។ ក្នុងផ្នែកខ្លះ ដោយសារតែមានភាពស្មុគស្មាញនៃរឿងក្តីនិងអាយុរបស់ជនជាប់ចោទ ទើបអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានសម្រេចបំបែកសំណុំរឿង០០២ យ៉ាងហោចណាស់ទៅជាពីរគឺសំណុំរឿង០០២វគ្គ០១ និងសំណុំរឿង០០២វគ្គ០២ សម្រាប់ការជំនុំជម្រះពីរផ្សេងគ្នា។ សំណុំរឿង០០២វគ្គ០១ បានចាប់ផ្តើមដំណើរការនៅក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយបានផ្តោតជាចម្បងទៅលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលជាប់ទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំពីទីក្រុងភ្នំពេញ និងតំបន់ផ្សេងទៀត ក៏ដូចជាការសម្លាប់រង្គាលទៅលើទាហាននៃរបបសាធារណរដ្ឋខ្មែរនៅទីតាំងសម្លាប់មនុស្ស ទួលពោធិ៍ជ្រៃ។



**ទីមួយពីខាងស្តាំ ពាក់អាវស៖ ឧត្តមសេនីយ៍ តឹង យុនសាន ប្រធានអ្នកជំនាញការចិននៅកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ឧត្តមសេនីយ៍រូបនេះ បានស្លាប់ដោយសារជំងឺគ្រុនចាញ់នៅកម្ពុជាក្នុងឆ្នាំ១៩៧៥)។ ទីពីរពីខាងស្តាំ៖ នួន ជា ប្រធានសភាតំណាងប្រជាជន និងជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា។ ទីបីពីខាងស្តាំ៖ អៀង សារី ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេស។ ទីបួនពីខាងស្តាំ៖ សុន សេន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារជាតិ។ នៅចុងក្រោយគេបង្អស់៖ វន វ៉េត ឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីសេដ្ឋកិច្ច។ (នៅរវាងឆ្នាំ១៩៧៥-១៩៧៨)។** (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

### សំណុំរឿង០០២វគ្គ០១

នៅខែវិច្ឆិកា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា អៀង ធីរិទ្ធ មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមការជំនុំជម្រះ ដោយសារតែហេតុផលស្ថានភាពសុខភាពចុះខ្សោយ និងបាត់បង់ការចងចាំ។ ជាលទ្ធផល អង្គជំនុំជម្រះវិសាមញ្ញបានសម្រេចចិត្តបំបែកសំណុំរឿងនេះចេញ ហើយដាក់នៅក្រោមការត្រួតពិនិត្យរបស់អង្គជំនុំជម្រះវិសាមញ្ញដដែល។ ចៅក្រមជាតិ និងអន្តរជាតិនៃអង្គជំនុំជម្រះសាលាដំបូង មិនអាចឈានដល់ការព្រមព្រៀងមួយស្តីពីការបន្តឃុំខ្លួន និងលក្ខខណ្ឌដោះលែងនោះទេ។ ដូច្នេះដើម្បីចៀសវាងការក័ន្តប្រទ្បំ អង្គជំនុំជម្រះវិសាមញ្ញបានឯកភាពជាឯកច្ឆន្ទក្នុងការដោះលែង អៀង ធីរិទ្ធ នៅខែកញ្ញា ឆ្នាំ២០១២។ ទោះបីជាយ៉ាងដូច្នេះក៏ដោយ អង្គជំនុំជម្រះវិសាមញ្ញបានគូសបញ្ជាក់ថា "ការរកឃើញថាមិនមានកាយសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមក្នុងសវនាការបាន គឺមិនមែនជាការរកឃើញនូវពិរុទ្ធភាព ឬភាពគ្មានទោសកំហុសរបស់ជនជាប់ចោទឡើយ[២៩]។ នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៥ អៀង ធីរិទ្ធ បានស្លាប់ដោយសារជំងឺវង្វេងវង្វាន់។

នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ ២០១៣ អៀង សារី បានទទួលមរណភាពដោយជំងឺ ក្នុងពេលដែលខ្លួនកំពុងស្ថិតក្នុងដំណើរការនៃការជំនុំជម្រះក្តី។ អនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ការកាត់ទោស អៀង សារី ត្រូវបានបិទបញ្ចប់។ លើសពីនេះទៀត តាមវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការស្លាប់របស់ អៀង សារី ក៏បានពន្លត់នូវរាល់បណ្តឹងរដ្ឋប្បវេណីដទៃទៀត។[៣០]

នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា នួន ជា និង ខៀវ សំផន មានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងសំណុំរឿង០០២ វគ្គ០១ ហើយអ្នកទាំងពីរត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិត។ អង្គជំនុំជម្រះតុលាការកំពូល បានដកចេញការដាក់ពិរុទ្ធភាពមួយចំនួន និងតម្កល់ការផ្តន្ទាទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិត។ នៅក្នុងសំណុំរឿង០០២វគ្គ០១ នួន ជា និង ខៀវ សំផន ត្រូវបានរកឃើញថាមានពិរុទ្ធភាពពាក់ព័ន្ធនឹង ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលទាក់ទងនឹងការបំផ្លិចបំផ្លាញ (រាប់បញ្ចូលទាំងឃាតកម្ម) ការធ្វើទុក្ខបុកម្នេញក្រោមហេតុផលនយោបាយនិងអំពើអមនុស្សធម៌ផ្សេងទៀត (រួមមានការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ, ការបាត់ខ្លួនដោយបង្ខំនិងការប្រយុទ្ធប្រឆាំងទៅនឹងសេចក្តីថ្លៃថ្នូររបស់មនុស្ស)។

ដើមបណ្តឹងរដ្ឋប្បវេណីសរុបចំនួន ៣ ៨៦៩នាក់ ត្រូវបានទទួលស្គាល់នៅក្នុងសំណុំរឿង០០២វគ្គ០១។ ដោយបានស្តាប់អ្នកជំនាញបង្ហាញភស្តុតាង អង្គជំនុំជម្រះសាលាដំបូង បានបង្ហាញថាការឈឺចាប់កើតឡើងចំពោះដើមបណ្តឹងរដ្ឋប្បវេណី ជាលទ្ធផលនៃឧក្រិដ្ឋកម្មបង្កដោយជនជាប់ចោទ បានរួមចំណែកដល់ការកើតមានរោគសញ្ញានៃជំងឺផ្លូវចិត្តដែលបានកើតមានក្នុងរយៈពេលយូរអង្វែង ដូចដែលបានរាយការណ៍ដោយដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននាក់រួចមកហើយ។ ព្រោះតែឧក្រិដ្ឋកម្មបង្កដោយជនជាប់ចោទ ទើបអង្គជំនុំជម្រះវិសាមញ្ញបានផ្តល់សំណងផ្លូវចិត្ត និងសំណងសមូហភាពដល់ដើមបណ្តឹងរដ្ឋប្បវេណី។ សំណងសមូហភាព និងសំណងផ្លូវចិត្ត គឺជាដំណើរការនៃ (ក) ការទទួលស្គាល់ភាពឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលជាលទ្ធផលនៃការប្រព្រឹត្តបទឧក្រិដ្ឋដែលជនជាប់ចោទត្រូវបានផ្តន្ទាទោស និង (ខ) ការផ្តល់អត្ថប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី ដែលជាវិធីដោះស្រាយនូវភាពឈឺចាប់ដែលបានកើតមាន។ ជារួមគម្រោងសំណងចំនួន១៣ត្រូវបានស្នើដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទៅកាន់អង្គជំនុំជម្រះសាលាដំបូងដើម្បីពិនិត្យឡើងវិញ។ នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះបានទទួលស្គាល់គម្រោងសំណងចំនួន១១ក្នុងចំណោមគម្រោងសំណងទាំងអស់។ គម្រោងសំណងចំនួនពីរ មិនត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះឡើយ ព្រោះមិនបានបំពេញតាមលក្ខខណ្ឌនៃការទទួលបាននូវមូលនិធិខាងក្រៅគ្រប់គ្រាន់ មុនពេលចេញសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។

អង្គជំនុំជម្រះតុលាការកំពូល បានបដិសេធការផ្តន្ទាទោសរបស់ចុងចោទធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូង សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ទាក់ទងនឹងការសម្លាប់ ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងដំណាក់កាលទីពីរនៃការផ្លាស់ប្តូរទីលំនៅប្រជាជន។ លើសពីនេះទៀត អង្គជំនុំជម្រះតុលាការកំពូល បានបដិសេធការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ទាក់ទងនឹងការធ្វើទុក្ខបុកម្នេញក្រោមហេតុផលនយោបាយ ដោយបានរកឃើញថាមិនមានភស្តុតាងគ្រប់គ្រាន់ក្នុងការបញ្ជាក់បន្ថែមពីការសង្ស័យសមហេតុផលថាចុងចោទបានប្រព្រឹត្តដោយចេតនាចំពោះការសម្លាប់មនុស្សទ្រង់ទ្រាយធំ។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថា តើការកាត់ទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិតគួរតែត្រូវបានកាត់បន្ថយដែរឬទេ បើផ្អែកតាមកំហុសឆ្គងរបស់អង្គជំនុំជម្រះសាលាដំបូង។ នៅក្នុងការពិនិត្យឡើងវិញចំពោះលទ្ធផលនៃដំណើរការសវនាការទាំងនេះ អង្គជំនុំជម្រះតុលាការកំពូល បានពិចារណាអំពីឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរនិងធំធេង ក៏ដូចជាភាពខ្វះខាតក្នុងការពិចារណាដ៏ត្រឹមត្រូវចំពោះជោគវាសនាចុងក្រោយរបស់ប្រជាជនកម្ពុជា ជាពិសេសក្រុមដែលងាយរងគ្រោះបំផុត។ អង្គជំនុំជម្រះតុលាការកំពូល ក៏បានពិចារណាអំពីតួនាទីសំខាន់របស់ជនជាប់ចោទ និងអង្គហេតុដែលអំពើឧក្រិដ្ឋមិនមែនជាព្រឹត្តិការណ៍ដាច់ដោយឡែកពីគ្នា ប៉ុន្តែបានកើតឡើងក្នុងរយៈពេលយ៉ាងយូរ។ ដោយសារមូលហេតុទាំងនេះ ទើបអង្គជំនុំជម្រះតុលាការកំពូលធ្វើសេចក្តីសន្និដ្ឋានថា ការដាក់ទោសជាប់ពន្ធនាគារអស់មួយជីវិតសម្រាប់ជនជាប់ចោទម្នាក់ៗ គឺសមរម្យបំផុត។[៣១]



**ឧបាសក ឧបាសិកា និងព្រះសង្ឃ ប្រារព្ធពិធីតាមប្រពៃណីព្រះពុទ្ធសាសនា នៅខាងមុខលលាដ៍ក្បាលជនរងគ្រោះដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម។ ក្នុងព្រះពុទ្ធសាសនា មានការជឿជាក់ថា អ្នកដែលបានស្លាប់ដោយសារតែគ្រោះកាច អាចនឹងពិបាកចាប់កំណើតសាជាថ្មីណាស់។ រូបថតនេះ ថតក្នុងឆ្នាំ១៩៨២។**

ប្រភព៖ ម៉ៃឡាំ/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

## សំណុំរឿង០០២វគ្គ០២

នៅខែតុលា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូង បានបើកសវនាការលើកដំបូង ដើម្បីជំនុំជម្រះលើសំណុំរឿង០០២ វគ្គ០២ ។ សំណុំរឿងនេះ ផ្តោតលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងអំពើប្រល័យពូជសាសន៍ដែលបានប្រព្រឹត្តឡើងនៅសហករណ៍ ការដ្ឋានការងារ មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សមួយចំនួន ដែលជាប់ទាក់ទងទៅនឹងក្រុមមនុស្សដែលជាក្រុមគោលដៅជាក់លាក់ ដូចជា ជនជាតិចាម ជនជាតិវៀតណាម អ្នកកាន់ព្រះពុទ្ធសាសនា និងអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ អង្គជំនុំជម្រះសាលាដំបូង ក៏បានពិចារណាលើគោលនយោបាយរបស់ខ្មែរក្រហម ចំពោះការរៀបចំ អាពាហ៍ពិពាហ៍។ អង្គជំនុំជម្រះ បានស្តាប់សក្ខីកម្មចំនួន១៨៥នាក់ រួមមាន សាក្សី១១៤នាក់ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៦៣នាក់ និងអ្នកជំនាញ



R00625

**រូបភាពទំព័រមុខនៃញត្តិស្តីអំពី «ឧក្រិដ្ឋកម្មរបស់បនវាទទីនិយមចិនប៉េកាំង និងបន ប៉ុល ពត, អៀង សារី និង ខៀវ សំផន ជាបរិវារ ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៨ មកលើប្រជាជនក្នុងភូមិអំពិលទឹក» ដែលបានដាក់ស្នើដើម្បីគាំទ្រតុលាការប្រជាជនបដិវត្តន៍ នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហម។ ឯកសារដែលត្រូវបានរកឃើញនៅក្នុងឆ្នាំ១៩៨៣នេះ ពិពណ៌នាថា តើភាគីខាងលើ គឺខ្មែរក្រហម និង «រដ្ឋាភិបាលប៉េកាំង» បានប្រព្រឹត្តទង្វើខុសឆ្គងអ្វីខ្លះ មកលើអ្នកភូមិអំពិលទឹក? ឯកសារនេះ ត្រូវបានរកឃើញនៅក្នុងឆ្នាំ១៩៨៣។**(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចំនួន៨នាក់ ព្រមទាំងឯកសារភស្តុតាងចំនួន៥ ០០០ឯកសារ ត្រូវបានទទួលយកសម្រាប់ការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូង។

នួន ជា ត្រូវបានចោទប្រកាន់ថាបានបម្រើការជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា ហើយគាត់ក៏ជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិមបក្ស និងគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានសភាតំណាងប្រជាជន។ គាត់ក៏ត្រូវបានចោទប្រកាន់ថាមានតួនាទីជានាយករដ្ឋមន្ត្រីស្តីទីនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដែរ។ ខៀវ សំផន ត្រូវបានចោទប្រកាន់ថាបានបម្រើការក្នុងមុខតំណែងផ្សេងៗក្នុងបក្សកុម្មុយនីស្តកម្ពុជា និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ រួមទាំងមុខតំណែងជា ប្រធានគណៈប្រធានរដ្ឋ និងប្រធានការិយាល័យនយោបាយ ៨៧០ (មន្ទីរ៨៧០)។ គាត់ក៏ត្រូវបានចោទប្រកាន់ថាបានបម្រើការជាសមាជិកគណអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា។

នួន ជា និងខៀវ សំផន ត្រូវបានរកឃើញថាបានប្រព្រឹត្តបទឧក្រិដ្ឋជាច្រើនប្រឆាំងនឹងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ (លើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩) និងអំពើប្រល័យពូជសាសន៍ ដោយបានចូលរួមក្នុងសហឧក្រិដ្ឋកម្មព្រហ្មទណ្ឌរួមជាមួយមេដឹកនាំជាន់ខ្ពស់ដទៃទៀត។ គោលបំណងរួមនៃសហឧក្រិដ្ឋកម្មព្រហ្មទណ្ឌរួម គឺដើម្បីអនុវត្តបដិវត្តន៍សង្គមនិយមជឿនលឿននៅកម្ពុជាតាមរយៈ "បដិវត្តន៍មហាលោតផ្លោះមហាអស្ចារ្យ" និងការពារបក្សពីសត្រូវតាមរយៈមធ្យោបាយចាំបាច់។ ជាផ្នែកមួយនៃសហឧក្រិដ្ឋកម្មព្រហ្មទណ្ឌរួមនេះ ជនជាប់ចោទបានគាំទ្រ និងជំរុញការបង្កើតគោលនយោបាយទាក់ទងនឹងអំពើប្រល័យពូជសាសន៍ទៅលើជនជាតិវៀតណាម ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដូចជាការសម្លាប់រង្គាល ការបំផ្លិចបំផ្លាញ ការធ្វើឱ្យទៅជាទាសករ ការនិរទេសឬការផ្លាស់ប្តូរទីលំនៅប្រជាជន ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញក្រោមហេតុផលនយោបាយ សាសនា និងពូជសាសន៍ និងការប្រព្រឹត្តអំពើអមនុស្សធម៌ដទៃទៀត ដូចជាប្រឆាំងនឹងសេចក្តីថ្លៃថ្នូររបស់មនុស្ស។ ជនជាប់ចោទក៏បានចូលរួមក្នុងការបង្កើតគោលនយោបាយ ដែលនាំទៅដល់ការបាត់ខ្លួនដោយបង្ខំ ការផ្លាស់ប្តូរទីលំនៅប្រជាជនដោយបង្ខំ ការរៀបការដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ។

ក្នុងនាមជា "មនុស្សជំនិតដ៏ស្មោះត្រង់របស់ ប៉ុល ពត" នួន ជា ត្រូវបានរកឃើញថា បានជួយជាចម្បងក្នុងការរៀបចំ អនុវត្ត និងផ្សព្វផ្សាយគោលបំណងរួមនៃសហឧក្រិដ្ឋកម្មព្រហ្មទណ្ឌ។ គាត់ត្រូវបានរកឃើញថា បានចូលរួមក្នុងការបោសសម្អាត និងការដាក់ឱ្យដំណើរការមន្ទីរ

សន្តិសុខ ស-២១។ ទោះបីជា ខៀវ សំផន មិនសូវមានអំណាចក៏ដោយ យ៉ាងហោចណាស់ក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ម្នាក់ ខៀវ សំផន ត្រូវបានរកឃើញថាបានចូលរួមចំណែក និងគាំទ្រដល់សហឧក្រិដ្ឋកម្មព្រហ្មទណ្ឌ។ តាមរយៈសុន្ទរកថានិងសេចក្តីថ្លែងការណ៍ជាសាធារណៈជាច្រើនរបស់ខ្លួន ខៀវ សំផន បានលើកទឹកចិត្តនិងញុះញង់ឱ្យមានការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយទោះបីជាគាត់មិនទាន់ក្លាយជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជាក៏ដោយ ខៀវ សំផន តែងតែបានចូលរួមនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ដែលទាក់ទងនឹងការពិភាក្សាពីការប្រព្រឹត្តិឧក្រិដ្ឋកម្មរួម។

**សហករណ៍ ការដ្ឋានការងារ និងទីតាំងសម្លាប់៖** អង្គជំនុំជម្រះសាលាដំបូង បានពិចារណាលើបទឧក្រិដ្ឋដែលបានកើតឡើងនៅតាមទីតាំងឧក្រិដ្ឋកម្មជាក់លាក់មួយចំនួននៅទូទាំងប្រទេស ដូចជា សហករណ៍ត្រាំកក់ ការដ្ឋានលើកទំនប់ត្រពាំងថ្ម ការដ្ឋានលើកទំនប់១មករា ការដ្ឋានសាងសង់អាកាសយានដ្ឋានកំពង់ឆ្នាំង មន្ទីរស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល។ ជនជាប់ចោទទាំងពីរ ត្រូវបានផ្តន្ទាទោសពីបទជួយទំនុកបម្រុង និងញុះញង់ឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ទាក់ទងនឹងការស្លាប់របស់មនុស្សនៅតាមការដ្ឋានការងារ សហករណ៍ និងមន្ទីរសន្តិសុខទាំងឡាយ ដែលជាលទ្ធផលនៃលក្ខខណ្ឌរស់នៅក្នុងទីតាំងឧក្រិដ្ឋកម្មទាំងនោះ រួមមានការខ្វះខាតស្បៀងអាហារនិងទឹក ព្រមទាំងខ្វះការថែទាំសុខភាព ក៏ដូចជាការដាក់កម្រិតឱ្យធ្វើពលកម្មធ្ងន់ធ្ងរ។

**ការកំណត់ក្រុមមនុស្សគោលដៅជាក់លាក់៖** អង្គជំនុំជម្រះសាលាដំបូង បានរកឃើញថានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានគោលនយោបាយក្នុងការកំណត់ក្រុមមនុស្សជាក់លាក់ សម្រាប់គោលបំណងបង្កើតសង្គម ដែលគ្មានជំនឿ និងរស់នៅស្មើភាពគ្នាដោយគ្មានការបែងចែកថ្នាក់។ អង្គជំនុំជម្រះ បានរកឃើញថាខ្មែរក្រហមបានផ្តោតលើជនជាតិចាម ជនជាតិវៀតណាម អ្នកគោរពព្រះពុទ្ធសាសនា និងអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនិងក្រុមគ្រួសារ។ ទាំង នួន ជា និង ខៀវ សំផន ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិវៀតណាម។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូង មិនអាចកំណត់ឬទាញសេចក្តីសន្និដ្ឋានថា នួន ជា មានចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍លើជនជាតិចាមក៏ដោយ អង្គជំនុំជម្រះបានរកឃើញថា "យ៉ាងហោចណាស់ នួន ជា មានហេតុផលដើម្បីដឹងថាអំពើប្រល័យពូជសាសន៍បាននិងកំពុងកើតមានឡើង ឬទំនងជាកើតមានឡើងប្រឆាំងទៅនឹងជនជាតិចាម" ដោយសារតែគាត់មានការទទួលខុសត្រូវខ្ពស់។ ដូច្នេះ នួន ជា ក៏ត្រូវបានផ្តន្ទាទោសពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ប្រឆាំងជនជាតិចាម និងក្រុមអ្នកគោរពសាសនាដែរ។

**ការរៀបចំអាពាហ៍ពិពាហ៍៖** អង្គជំនុំជម្រះសាលាដំបូង បានរកឃើញថាមានគោលនយោបាយផ្សព្វផ្សាយទូទាំងប្រទេស ដើម្បីរៀបចំអាពាហ៍ពិពាហ៍និងគ្រួសារ។ បក្សកុម្មុយនីស្តកម្ពុជាបានបង្កើតគោលនយោបាយនេះ ដើម្បីជំនួសតួនាទីរបស់ឪពុកម្តាយ និងបង្កើនចំនួនមនុស្សតាមរយៈការបង្ខំឱ្យរៀបការនិងការបង្កើតកូន។ មនុស្សត្រូវបានបង្ខំឱ្យរៀបការក្នុងបរិយាកាសភ័យខ្លាច ហើយការរៀបចំពិធីរៀបការ ត្រូវបានធ្វើឡើងដោយអាជ្ញាធរមូលដ្ឋាន ដើម្បីបង្ខិតបង្ខំឱ្យរួមភេទប្រឆាំងទៅនឹងឆន្ទៈរបស់គូស្រករដែលទើបរៀបការរួច។ គូស្រករណាដែលមិនបានរួមភេទជាមួយគ្នាទេ គូស្រករនោះ ត្រូវ "ធ្វើការអប់រំកែប្រែ" ឬ ត្រូវព្រមានតាមរយៈការធ្វើទារុណកម្ម ឬត្រូវនាំយកទៅសម្លាប់ចោល។

**ការកាត់ទោសរបស់អង្គជំនុំជម្រះសាលាដំបូង៖** អង្គជំនុំជម្រះ បានរកឃើញថាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣ ៨៦៥នាក់ ក៏ដូចជាជនរងគ្រោះភាគច្រើនលើសលុបទទួលរងការឈឺចាប់ឥតឧបមា ដែលជាលទ្ធផលទទួលរងពីឧក្រិដ្ឋកម្មបង្កដោយ នួន ជា និង ខៀវ សំផន។ ចំពោះឧក្រិដ្ឋកម្មដែលបានបង្កឡើងនេះ អង្គជំនុំជម្រះសាលាដំបូង បានផ្តន្ទាទោសជនជាប់ចោទទាំងពីរ ឱ្យជាប់ពន្ធនាគារអស់មួយជីវិត។ ជនជាប់ចោទ ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ទាក់ទងនឹងការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជនដោយបង្ខំ ហើយអ្នកទាំងពីរត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិតចំពោះឧក្រិដ្ឋកម្មទាំងនេះ។ អង្គជំនុំជម្រះសាលាដំបូង បានប្របាច់បញ្ចូលគ្នារវាងការកាត់ទោសក្នុងសំណុំរឿង០០២ វគ្គ០១ និងការកាត់ទោសនៅក្នុងសំណុំរឿង០០២វគ្គ០២ ដើម្បីបង្កើតជាទម្រង់តែមួយនៃការកាត់ទោស នួន ជា និង ខៀវ សំផន ឱ្យជាប់ទោសអស់មួយជីវិត។



**នីរសាររបស់ អ៊ឹម ចែម គណៈស្រុកព្រះនេត្រព្រះ ក្នុងខេត្តបាត់ដំបង (បច្ចុប្បន្នខេត្តបន្ទាយមានជ័យ) ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ក្នុងចំណោមនីរសាទាំងបីនាក់ មានពីរនាក់មានឈ្មោះ សុខ ដូចគ្នា។ រូបថតនៅចន្លោះឆ្នាំ ១៩៧៥-១៩៧៨។**
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



**អោ អាន ហៅ តាអាន គឺជាអនុលេខាភូមិភាគកណ្តាល និងជាលេខាតំបន់៤១ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ តាអាន គឺជា "ជនជាប់ចោទ" ម្នាក់ ក្នុងសំណុំរឿង០០៤វគ្គ០២ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។** ប្រភព៖ វ៉ាន់ថាន់ ពៅដារ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា



**អ៊ឹម ចែម គឺជាគណៈស្រុកព្រះនេត្រព្រះ និងជាអនុលេខាតំបន់៥ ភូមិភាគពាយ័ព្យ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អ៊ឹម ចែម ជា "ជនជាប់ចោទ" ម្នាក់ ក្នុងសំណុំរឿង០០៤ វគ្គ០១ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ សំណុំរឿងនេះត្រូវបានបិទបញ្ចប់នៅពេលក្រោយមក ដោយសារតែអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កំណត់ថាអង្គជំនុំជម្រះមិនមានយុត្តាធិការណាមួយអនុវត្តលើ អ៊ឹម ចែម។** ប្រភព៖ ដី ទេវិទ្ធ/មជ្ឈមណ្ឌលឯកសារកម្ពុជា



**យឹម ទិត្យ គឺជាគណៈតំបន់១៣ ភូមិភាគនិរតី, ជាគណៈស្រុកគិរីវង្ស, ជាអនុលេខាភូមិភាគពាយ័ព្យ និងជាគណៈតំបន់១, តំបន់៣ និងតំបន់៤ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ យឹម ទិត្យ ជា "ជនជាប់ចោទ" ម្នាក់ក្នុងសំណុំរឿង០០៤ វគ្គ០៣ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។** ប្រភព៖ វ៉ាន់ថាន់ ពៅដារ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា

នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៩ នួន ជា បានស្លាប់ដោយសារជរាភាពខណៈដែលខ្លួនបានដាក់ពាក្យបណ្តឹងប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿង០០២វគ្គ០២។ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនទាន់ចេញសេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ឬ ខៀវ សំផន សម្រាប់សំណុំរឿង០០២វគ្គ០២ នៅឡើយទេ។



**មាស មុត គឺជាសមាជិកគណៈមជ្ឈិមបក្ស, ជាលេខាធិការរងប្រធានកងពល១៦៤ (រួមបញ្ចូលទាំងកងទ័ពជើងទឹក) និងជាលេខាតំបន់ស្វយ័តកំពង់សោម ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ មាស មុត គឺជា "ជនជាប់ចោទ" ម្នាក់ក្នុងសំណុំរឿង០០៣ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។** ប្រភព៖ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ៣. សំណុំរឿង ០០៣ និង ០០៤

សំណុំរឿង ០០៣ និង ០០៤ ត្រូវបានបង្កើតឡើងនៅខែកញ្ញា ឆ្នាំ២០០៩ នៅពេលដែលសហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ដីកាបញ្ជូនរឿងឱ្យស៊ើបសួរទៅកាន់សហចៅក្រមស៊ើបអង្កេត ស្នើសុំឱ្យបើកការស៊ើបអង្កេត លើឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងជនសង្ស័យចំនួនប្រាំនាក់។ មាស មុត និង ស៊ូ មេត ត្រូវបានដាក់ឈ្មោះថាជាជនសង្ស័យក្នុងសំណុំរឿង០០៣។ អោ អាន, អ៊ឹម ចែម និង យឹម ទិត្យ ត្រូវបានដាក់ឈ្មោះថាជាជនសង្ស័យក្នុងសំណុំរឿង០០៤។

### សំណុំរឿង០០៣

សំណុំរឿង០០៣ ពាក់ព័ន្ធនឹងជនជាប់ចោទឈ្មោះ ស៊ូ មេត និង មាស មុត។ ក្នុងខែមិថុនា ឆ្នាំ២០១៥ ការស៊ើបអង្កេតរបស់តុលាការប្រឆាំងនឹង ស៊ូ មេត ត្រូវបានបញ្ចប់បន្ទាប់ពីគាត់បានស្លាប់។ ទោះបីជាយ៉ាងដូច្នោះក្តី ការស៊ើបអង្កេតរបស់តុលាការប្រឆាំងនឹង មាស មុត នៅតែបន្តធ្វើឡើង។ ក្នុងខែធ្នូ ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចោទប្រកាន់ មាស មុត ពីបទឧក្រិដ្ឋដូចតទៅ៖ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងនោះរួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល

ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ដទៃទៀត (ដូចជាការប្រព្រឹត្តអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ អាពាហ៍ពិពាហ៍ដោយបង្ខំ ការរំលោភផ្លូវភេទ និងការវាយប្រហារលើសេចក្តីថ្លៃថ្នូរជាមនុស្សដោយសារស្ថានភាពនៃការឃុំខ្លួន) អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ក្នុងនោះរួមមានការធ្វើមនុស្សឃាតដោយចេតនា ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព ការធ្វើទារុណកម្ម និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ និងការរំលោភលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ក្នុងនោះរួមមាន អំពើមនុស្សឃាតដោយចេតនា។ បទឧក្រិដ្ឋទាំងនេះ ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឡើងនៅកន្លែងផ្សេងៗគ្នា រួមមាន៖ នៅមន្ទីរសន្តិសុខផ្សេងៗគ្នា ក្នុងនោះរួមមានមន្ទីរសន្តិសុខស-២១ មន្ទីរសន្តិសុខវត្តឥន្ទញាណ ការដ្ឋានស្ទឹងហាវ សហករណ៍តំបន់រាម រួមមាន ការដ្ឋាននៅកងកេងនិងបិតត្រាង ទីតាំងសម្លាប់មនុស្សចម្ការទុរេន មន្ទីរសន្តិសុខទឹកសាប និងកំពង់សោម។ លើសពីនេះទៀត ឧក្រិដ្ឋកម្មទាំងនេះ ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឡើងលើសមាជិកកងពលលេខ ១៦៤ ៥០២ ១១៧ និង ៣១០។ មាស មុត ក៏ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យនៅលើកោះនិងជុំវិញកោះដែលកម្ពុជាប្រជាធិបតេយ្យ អះអាងថាជារបស់ខ្លួន។



កែ ពក ជាអតីតលេខាភូមិភាគកណ្តាល (ភូមិភាគឧត្តរ)។ កែ ពក មានតួនាទីផ្ទាល់និងយ៉ាងសំខាន់ក្នុងការសម្លាប់កម្មាភិបាលនៃបក្សកុម្មុយនីស្តកម្ពុជា តាមរយៈការស៊ើបអង្កេត និងជួយសម្រួលដល់ការឃាត់ខ្លួនជនក្បត់ជាប់សង្ស័យ នៅក្នុងភូមិភាគរបស់ខ្លួន។
ប្រភព៖ ហេង ស៊ីនិត/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

សេចក្តីសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ បានអះអាងថា ភស្តុតាងបង្ហាញថា មាស មុត គួរតែស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយសារតែបុគ្គលរូបនេះជា"មេដឹកនាំជាន់ខ្ពស់"ផង និងជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត"របស់របបកម្ពុជាប្រជាធិបតេយ្យផង ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅចន្លោះថ្ងៃទី១៧ មេសា ១៩៧៥ ដល់ថ្ងៃទី៦ មករា ១៩៧៩។ សហព្រះរាជអាជ្ញាជាតិ មិនយល់ស្របចំពោះសេចក្តីសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិឡើយ។ ជាពិសេស សហព្រះរាជអាជ្ញាជាតិបានទាញហេតុផលថា មាស មុត មិនមែនជាកម្មវត្ថុនៃយុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ។ លើសពីនេះទៀត សហព្រះរាជអាជ្ញាជាតិបានអះអាងថា ការនាំយក មាស មុត ទៅជំនុំជម្រះ នឹងមិនបម្រើដល់ផលប្រយោជន៍យុត្តិធម៌ឡើយ។ ប្រសិនបើ មាស មុត ត្រូវបានបញ្ជូនទៅជំនុំជម្រះ សហព្រះរាជអាជ្ញាជាតិ មានជំនឿថាប្រាកដជាមានការរំខានដោយបញ្ហានយោបាយក្នុងស្រុក និងអាចមានភាពរីករាលក្នុងសង្គមកាន់តែធ្ងន់ធ្ងរ។ ជាមួយនឹងដីកាដំណោះស្រាយផ្សេងៗគ្នា បញ្ហានេះអាចនឹងត្រូវប្តឹងឧទ្ធរណ៍ទៅកាន់អង្គបុរេជំនុំជម្រះ។

## សំណុំរឿង ០០៤

សំណុំរឿង ០០៤ ពាក់ព័ន្ធនឹងជនជាប់ចោទ យឹម ទិត្យ អ៊ឹម ចែម និង អោ អាន។ ក្នុងខែធ្នូ ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចោទប្រកាន់ យឹម ទិត្យ ពីបទឧក្រិដ្ឋដូចតទៅ៖ អំពើប្រល័យពូជសាសន៍ខ្មែរក្រោម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងនោះរួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញមកលើ "ប្រជាជន១៧មេសា" "ការជម្លៀសនៅភូមិភាគបូព៌ា" កម្មាភិបាលភូមិភាគពាយ័ព្យ ក្រុមគ្រួសារនិងអ្នកក្រោមបង្គាប់របស់ខ្លួន ក៏ដូចជាការធ្វើទុក្ខបុកម្នេញមកលើខ្មែរក្រោម និងជនជាតិវៀតណាម និងអំពើអមនុស្សធម៌ដទៃទៀត រួមទាំងការរៀបការដោយបង្ខំ ការបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ដែលបានប្រព្រឹត្តឡើងជាផ្នែកមួយនៃជម្លោះប្រដាប់អាវុធអន្តរជាតិរវាងកម្ពុជាប្រជាធិបតេយ្យ និងសាធារណរដ្ឋសង្គមនិយមវៀតណាមក្នុងនោះរួមមាន ការធ្វើមនុស្សឃាតដោយចេតនា និងការនិរទេស (ឬការផ្លាស់ប្តូរទីលំនៅជនស៊ីវិលខុសច្បាប់) ការរំលោភលើក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ ក្នុងនោះរួមមានអំពើមនុស្សឃាតដោយចេតនា ឧក្រិដ្ឋកម្មទាំងនោះ ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅទីតាំងផ្សេងៗគ្នានៅភូមិភាគនិរតីនិងពាយ័ព្យ។

អ៊ឹម ចែម ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋដូចតទៅ៖ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងនោះរួមមានការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ដទៃទៀត (បាត់ខ្លួនដោយបង្ខំ រំលោភផ្លូវភេទ រៀបការដោយបង្ខំ និងបង្ខាំងក្នុងស្ថានភាពអមនុស្សធម៌)។ លើសពីនេះទៀត អ៊ឹម ចែម ត្រូវបានចោទប្រកាន់ពីបទរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ក្នុងនោះរួមមាន ការធ្វើមនុស្សឃាតដោយចេតនា ការប្រព្រឹត្តអំពើអមនុស្សធម៌ ការបង្កឱ្យមានការឈឺចាប់ឬរបួសស្នាមយ៉ាងធ្ងន់ធ្ងរដល់រាងកាយឬសុខភាព ការដកហូតសិទ្ធិក្នុងការជំនុំជម្រះក្តីដោយត្រឹមត្រូវនិងយុត្តិធម៌ និងការឃុំឃាំងជនស៊ីវិលដោយខុសច្បាប់។ ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ត្រូវបានប្រព្រឹត្តនៅទីតាំងផ្សេងៗគ្នា ក្នុងភូមិភាគនិរតី និងពាយ័ព្យ។

អោ អាន (ឈ្មោះហៅក្រៅ តាអាន) ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋដូចជា អំពើប្រល័យពូជសាសន៍លើជនជាតិចាម, ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញលើ "ប្រជាជន១៧មេសា" អតីតទាហានលន់ នល់ ព្រមទាំងកម្មាភិបាលភូមិភាគកណ្តាល(ឧត្តរចាស់) និងក្រុមគ្រួសារ ក៏ដូចជាអ្នកក្រោមបង្គាប់ ប្រជាជនមកពីភូមិភាគបូព៌ា ដែលត្រូវបានចាត់ទុកថាមិនស្អាតស្អំ"សមាសភាពមិនល្អ" និង"ខ្មាំងស៊ីរូងផ្ទៃក្នុង" ការធ្វើទុក្ខបុកម្នេញមកលើប្រជាជនចាម និងប្រជាជនវៀតណាម និងអំពើអមនុស្សធម៌ដទៃទៀត រួមមាន អាពាហ៍ពិពាហ៍ដោយបង្ខំ ការរំលោភផ្លូវភេទ ការបាត់ខ្លួនដោយបង្ខំ ការធ្វើបាបរាងកាយ ពលកម្មដោយបង្ខំ និងការឃុំឃាំងក្នុងស្ថានភាពអមនុស្សធម៌។ លើសពីនេះទៀត អោ អាន ត្រូវបានកាត់ទោសពីបទបានប្រព្រឹត្តបទល្មើសទាក់ទងនឹងការរំលោភលើក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ រួមមាន មនុស្សឃាតដោយចេតនា។

សំណុំរឿង ០០៤ ត្រូវបានបំបែកជា៣សំណុំរឿងផ្សេងគ្នា ទាក់ទងនឹងជនជាប់ចោទម្នាក់ៗ។

## សំណុំរឿង០០៤វគ្គ០១

នៅខែកុម្ភៈ ឆ្នាំ២០១៦ សំណុំរឿង០០៤វគ្គ០១ ត្រូវបានបង្កើតឡើងសម្រាប់ករណី អ៊ឹម ចែម ហើយនៅខែកុម្ភៈ ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេត បានច្រានចោលសំណុំរឿងប្រឆាំង អ៊ឹម ចែម ជាមូលហេតុដែលសហព្រះរាជអាជ្ញាអន្តរជាតិបានប្តឹងឧទ្ធរណ៍។ នៅក្នុងការពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិអង្គបុរេជំនុំជម្រះ មិនអាចទទួលបានសម្លេងភាគច្រើនលើអង្គហេតុនៃបណ្តឹងឧទ្ធរណ៍នេះទេ ព្រោះចៅក្រមជាតិ លោក ប្រាក់ គឹមសាន, លោក ន័យ ថុល និងលោក ហួត វុទ្ធី យល់ស្របចំពោះការច្រានចោលរបស់សហចៅក្រមស៊ើបអង្កេត ហើយចៅក្រមអន្តរជាតិ លោក បៃ កាងជិន ( Baik Kang Jin ) និងលោក អូលីវីយេ ប៊ូវ៉ាលេ ( Olivier Beauvallet ) មិនយល់ស្របចំពោះការច្រានចោលនេះ ហើយគិតថា អ៊ឹម ចែម គួរតែត្រូវបានចាត់ទុកថាជាកម្មវត្ថុនៃយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ អង្គបុរេជំនុំជម្រះ បានច្រានចោលសំណុំរឿង០០៤វគ្គ០១ ប្រឆាំង អ៊ឹម ចែម ដោយឈរលើមូលដ្ឋានថាអង្គបុរេជំនុំជម្រះខ្វះដែនសមត្ថកិច្ចក្នុងការអនុវត្តកិច្ចការនេះ។



លលាដ៍ក្បាល និងឆ្អឹងជនរងគ្រោះនៃរបបខ្មែរក្រហម នៅខេត្តស្វាយរៀងក្នុងឆ្នាំ១៩៨២។
ប្រភព៖ ម៉ៃឡាំ/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រួមគ្នាជីករក និងប្រមែប្រមូលឆ្អឹងសាកសពជនរងគ្រោះដែលបន្សល់ពីរបបខ្មែរក្រហម នៅក្នុងខេត្តស្វាយរៀង នៅឆ្នាំ១៩៨២។
ប្រភព៖ ម៉ៃឡាំ/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា



អ្នកភូមិម្នាក់ កំពុងអានទស្សនាវដ្ដី «ស្វែងរកការពិត» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅឆ្នាំ២០០៩។ ប្រភព៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

## សំណុំរឿង ០០៤ វគ្គ០២

នៅខែធ្នូ ឆ្នាំ២០១៦ សំណុំរឿង ០០៤ វគ្គ០២ ត្រូវបានបង្កើតឡើងសម្រាប់ដំណើរការនីតិវិធីប្រឆាំងនឹងអោ អាន។ ក្នុងខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេត បានចេញដីកាដំណោះស្រាយចំនួន២ ដាច់ដោយឡែកពីគ្នា ក្នុងករណីប្រឆាំងនឹង អោ អាន។ សហចៅក្រមស៊ើបអង្កេតជាតិបានកំណត់ថា អោ អាន មិនស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ និងបានច្រានចោលសំណុំរឿងនេះ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកំណត់ថា អោ អាន ពិតជាស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ព្រោះថា អោ អាន ត្រូវបានរកឃើញថា គឺជាមនុស្សម្នាក់ដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយផ្អែកទៅលើឋានៈនិងតួនាទីនិងការប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងររបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហេតុដូច្នេះហើយ ទើបសហចៅក្រមស៊ើបអង្កេតអន្តរជាតិចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១៨ សេចក្ដីសម្រេចដាច់ដោយឡែករបស់សហចៅក្រមស៊ើបអង្កេត ត្រូវបានប្ដឹងឧទ្ធរណ៍ទៅកាន់អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលកំពុងបើកសវនាការលើបណ្ដឹងទាំងនេះ។

## សំណុំរឿង ០០៤ វគ្គ០៣

នៅខែមិថុនា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេត បានបញ្ចប់ការស៊ើបអង្កេតរយៈពេល៨ឆ្នាំ ប្រឆាំងនឹង យឹម ទិត្យ ហើយនៅចុងខែឧសភានិងដើមខែមិថុនា ឆ្នាំ២០១៨ សហព្រះរាជអាជ្ញាជាតិនិងអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួនក្នុងសំណុំរឿង ០០៤ ពាក់ព័ន្ធនឹងការស៊ើបអង្កេតសំណុំរឿង យឹម ទិត្យ។ សហព្រះរាជអាជ្ញាជាតិបានអះអាងថា យឹម ទិត្យ មិនមែនជាមេដឹកនាំជាន់ខ្ពស់ ឬជាមនុស្សដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ។ ដូច្នេះ យឹម ទិត្យ ត្រូវស្ថិតនៅក្រៅដែនសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ សហព្រះរាជអាជ្ញាអន្តរជាតិបានជំទាស់ក្នុងរឿងនេះ។ នៅខែមិថុនា ឆ្នាំ២០១៩ សហចៅក្រមស៊ើបអង្កេតជាតិនិងអន្តរជាតិ បានចេញមតិពីរផ្សេងគ្នា។ សហចៅក្រមស៊ើបអង្កេតជាតិបានកំណត់ថា យឹម ទិត្យ មិនស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឡើយ ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនយល់ស្របចំពោះនីតិវិធីនេះទេ ព្រោះ យឹម ទិត្យ ត្រូវបានរកឃើញថាស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ជាមួយនឹងដីកាដំណោះស្រាយផ្សេងគ្នានេះ សំណុំរឿងនេះអាចនឹងត្រូវប្ដឹងសាទុក្ខទៅកាន់អង្គបុរេជំនុំជម្រះ។ ទោះបីជាសហចៅក្រមស៊ើបអង្កេតជាតិនិងអន្តរជាតិ មានការខ្វែងគំនិតគ្នាទាក់ទងនឹងជំហានជាបន្តបន្ទាប់ទៀតសម្រាប់សំណុំរឿង០០៤យ៉ាងណាក៏ដោយ ចៅក្រមស៊ើបអង្កេតទាំងពីរប្រភេទនេះ បានចុះហត្ថលេខាលើដីកាបញ្ចប់ការស៊ើបអង្កេតដែលនៅសេសសល់ក្នុងសំណុំរឿងនេះ។





កំណត់សម្គាល់៖ នៅលើខ្នងរូបថតមានអក្សរសរសេរដោយដៃរបស់ ឌុច រាយការណ៍ទៅកាន់ថ្នាក់លើ អំពីចម្លើយសារភាពរបស់ នួន យឿន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



កាំង ហ្គេកអ៊ាវ ហៅ ឌុច អតីតប្រធានមន្ទីរស-២១ កំពុងផ្ដល់បទសម្ភាសន៍ដល់ ស៊ីរ៉ិ សាវីណា បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅឯមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងឆ្នាំ២០១២។ ក្នុងពេលផ្ដល់បទសម្ភាសន៍ ឌុច បានបង្ហាញរូបថតរបស់ ទូន សុខផល្លា (ខាងស្ដាំ, កើតនៅឆ្នាំ១៩៤១ និងស្លាប់នៅឆ្នាំ១៩៧៧) និង នួន យឿន (ខាងឆ្វេង, កើតនៅឆ្នាំ១៩៤៤និងស្លាប់នៅឆ្នាំ១៩៧៧) ថតនៅសាលមហោស្រពទន្លេបាសាក់ក្នុងឆ្នាំ១៩៧១។ ទូន សុខផល្លា (មន្ត្រីរដ្ឋាភិបាល) និង នួន យឿន (គ្រូបង្រៀនមុខវិជ្ជាប្រវត្តិសាស្ត្រ) ត្រូវបានចាប់ខ្លួននិងបញ្ជូនទៅកាន់មន្ទីរស-២១ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ក្រោយមកទៀត ខ្មែរក្រហមបានសម្លាប់អ្នកទាំងពីរនៅក្នុងឆ្នាំ១៩៧៧។ ប្រភព៖ អេង កុកថាយ/មជ្ឈមណ្ឌលឯកសារកម្ពុជា

ជំពូកទី១៥

# ពាក្យសូមអភ័យទោសរបស់ កាំង ហ្គេកអ៊ាវ ហៅ “ឌុច”

**សេចក្ដីផ្ដើម**

*ខុសពីជនជាប់ចោទពីបទឧក្រិដ្ឋកម្មផ្សេងៗទៀត នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឌុច បានទទួលស្គាល់ជាសាធារណៈនូវការទទួលខុសត្រូវរបស់ខ្លួនចំពោះបទឧក្រិដ្ឋភាគច្រើន ដែលខ្លួនបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហម។ ក្នុងកាលៈទេសៈខ្លះ ឌុច បានស្នើសុំឱកាសមួយដើម្បីសូមអភ័យទោសចំពោះជនរងគ្រោះឬ សមាជិកគ្រួសាររបស់ជនរងគ្រោះ។ មនុស្សជាច្រើន មានមតិខុសគ្នាៗចំពោះហេតុផលដែល ឌុច សារភាពទោសកំហុស និង សូមអភ័យទោស។ អ្នកខ្លះជឿជាក់ថា ការសូមអភ័យទោសរបស់ ឌុច មានជាប់ទាក់ទងទៅនឹងការផ្លាស់ប្ដូរជំនឿសាសនាទៅជាប្រណិប័តន៍សាសនាគ្រិស្ត។ អ្នកខ្លះទៀតយល់ឃើញថា ឌុច ឆ្លៀតយកឱកាសកេងចំណេញពីកាតព្វកិច្ចព្រះពុទ្ធសាសនា ក្នុងការលើកលែងទោសចំពោះអ្នកទាំងឡាយណាដែលបានស្នើសុំការអភ័យទោស។ ទន្ទឹមនឹងនេះ មានការជឿជាក់ដែរថា ការសូមអភ័យទោសនិងការសារភាពរបស់ ឌុច គឺស្ថិតក្នុងហេតុផលដើម្បីទទួលការបន្ធូរបន្ថយទោស ឬ ដើម្បីរួចផុតពីទោសជាប់ពន្ធនាគាររបស់ខ្លួន។*

## ១. ពាក្យសូមអភ័យទោសលើកទី១

«ដំបូង ខ្ញុំសូមបញ្ជាក់អំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៅកម្ពុជាខ្លះ។ តាមតម្រាយ(គន្លង)ដែលសហព្រះរាជអាជ្ញា លោកមានប្រសាសន៍រួចមកហើយ។ ខ្ញុំសូមបញ្ជាក់ថា ប្រជាជនកម្ពុជារងទុក្ខវេទនាដោយការកាប់សម្លាប់នេះយូរឆ្នាំហើយ គឺចាប់តាំងពីឆ្នាំ១៩៦៦ ដែលឧត្តមសេនីយ៍ លន់ នល់ គាត់កាប់សម្លាប់កសិករនៅសំឡូត។ បន្ទាប់មកទៀតរដ្ឋប្រហារ ១៨មីនា ភាគីនយោបាយទាំងអស់ ប្រណាំងប្រជែងគ្នាកាប់សម្លាប់ប្រជាជនកម្ពុជារហូតដល់ថ្ងៃ១៧ មេសា ១៩៧៥ ទើបឧក្រិដ្ឋកម្មនេះវាធ្លាក់ផ្ដាច់មុខទៅលើបក្សកុម្មុយនីស្តកម្ពុជា។ នេះតម្រាយ(គន្លង) ប្រវត្តិសាស្ត្រដែលខ្ញុំសូមលើកជូនអង្គប្រជុំ ស្របតាមតម្រាយដែលសហព្រះរាជអាជ្ញាព្រឹកមិញ លោកមានប្រសាសន៍។

តទៅនេះ ខ្ញុំសូមបញ្ជាក់អំពីគោលជំហរខ្ញុំ ដូចតទៅ៖ ពីថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ៦ មករា ១៩៧៩ បក្សកុម្មុយនីស្តកម្ពុជា ជាអ្នកទទួលខុសត្រូវផ្ដាច់មុខលើឧក្រិដ្ឋកម្មនៅកម្ពុជា។ ភ័ស្តុតាងសំខាន់គឺលក្ខន្តិកៈបក្សឆ្នាំ១៩៧៦។ ទំព័រទី១នៃលក្ខន្តិកៈនេះ សរសេរជាអាទិ៍ថា "ក្រោយពីដឹកនាំសម្រេចបដិវត្តន៍ប្រជាធិបតេយ្យបានទាំងស្រុងនិងជាស្ថាពរនៅថ្ងៃ១៧ មេសា ១៩៧៥ មក បក្សកុម្មុយនីស្តកម្ពុជា ដឹកនាំបដិវត្តន៍សង្គមនិយមនិងកសាងសង្គមនិយមតទៅទៀត ដោយផ្ដាច់មុខ ដាច់ខាតនិងគ្រប់ផ្នែក" នេះជាភ័ស្តុតាង ដែលខ្ញុំសូមលើកជូនជាតិប្រជាជនតាមរយៈអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ទី១) ខ្ញុំសូមវិភាគអំពីឧក្រិដ្ឋកម្មទូទាំងប្រទេសពីថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ៦ មករា ១៩៧៩។ ក្រោយ ១៧ មេសា ១៩៧៥ ប៉ុល ពត កើតចិត្តភ្លើតភ្លើនខ្លាំងណាស់ បានលើកមាគ៌ាដែលប៉ះពាល់អាយុមនុស្ស នេះគឺមកពីប៉ុល ពត គាត់មានសព្វមានគ្រប់ សំខាន់គឺមានបក្ខជនរាប់ម៉ឺននាក់នៅក្នុងកណ្ដាប់ដៃគាត់។ ឧក្រិដ្ឋកម្មជំនាន់នោះធំធេងណាស់។ ដោយឡែកការបាត់បង់អាយុជីវិត មានទៅដល់ជាងមួយលាននាក់។ ដោយខ្ញុំជាបក្ខជនមួយរូបរបស់បក្សកុម្មុយនីស្តកម្ពុជា ខ្ញុំទទួលស្គាល់ថា "ខ្ញុំពិតជាមានតួនាទីទទួលខុសត្រូវខាងផ្លូវចិត្ត លើឧក្រិដ្ឋកម្មដែលបក្សកុម្មុយនីស្តកម្ពុជាប្រព្រឹត្តនៅជំនាន់នោះ" ខ្ញុំសូមសម្ដែងនូវវិប្បដិសារីសោកស្ដាយយ៉ាងឈឺចាប់បំផុតចំពោះឧក្រិដ្ឋកម្មគ្រប់យ៉ាង ដែលបក្សកុម្មុយនីស្តកម្ពុជាប្រព្រឹត្តពីថ្ងៃ១៧ មេសា ១៩៧៥ ដល់ ៦ មករា ១៩៧៩។



ប្លង់ស្ថាបត្យកម្មរបស់សារមន្ទីរវាលពិឃាត ជើងឯក សម្រាប់តម្កល់ឆ្អឹងនិងលលាដ៍ក្បាលដែលបានមកពីការគាស់រណ្ដៅសាកសព។ ប្លង់នេះ ទទួលបានការឯកភាព ពិនិត្យត្រឹមត្រូវ និងយល់ព្រមដោយមន្ត្រីមានសមត្ថកិច្ច ដូចជាប្រធានគណៈកម្មាធិការប្រជាជនបដិវត្តន៍ លោក មុត ម៉ារ៉េត, នាយកមន្ទីរវប្បធម៌រដ្ឋធានី លោក ជុំ កាណាល់ និងនាយករងអចិន្ត្រៃយ៍មន្ទីររៀបចំដែនដីនិងសំណង់ក្រុងភ្នំពេញ លោក គ្រី បេងហុង ក្នុងឆ្នាំ១៩៨៨។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ប្រជាជនខ្មែរអ៊ីស្លាម កំពុងអានទស្សនាវដ្ដី «ស្វែងរកការពិត» នៅក្នុងពេលធ្វើវេទិកាអប់រំសាធារណៈ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងឆ្នាំ២០០៩។ ប្រភព៖ អេង កុកថាយ/មជ្ឈមណ្ឌលឯកសារកម្ពុជា

ទី២) ខ្ញុំសូមបញ្ជាក់ដោយឡែកអំពីឧក្រិដ្ឋកម្មនៅស-២១។ ខ្ញុំសូមទទួលស្គាល់នូវការទទួលខុសត្រូវរបស់ខ្ញុំតាមផ្លូវច្បាប់។ ខ្ញុំសូមបញ្ជាក់ថា តាមផ្លូវច្បាប់ចំពោះឧក្រិដ្ឋកម្មទាំងអស់ ដែលកើតមាននៅស-២១ សំខាន់គឺសកម្មភាពធ្វើទារុណកម្ម និងសម្លាប់ផ្ដាច់ផ្ដោចអាយុជីវិតមនុស្ស។ តាមតម្រាយដែលខ្ញុំបានធ្វើរួចមកហើយ នៅវេលាដែលលោកសហចៅក្រមស៊ើបអង្កេត នាំខ្ញុំទៅសម្ដែងសកម្មភាពរំឭកព្រឹត្តិការណ៍ចាស់ឡើងវិញនៅជើងឯកនិងនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង គឺខ្ញុំសូមអនុញ្ញាតចូលសុំទោសជនរងគ្រោះដែលនៅរស់រានមានជីវិត និងសុំទោសក្រុមគ្រួសារទាំងអស់ដែលបានស្លាប់បាត់បង់ជីវិតយ៉ាងអាណោចអធ័មនៅស-២១។ ពេលនេះ ខ្ញុំសូមអស់លោកទាំងនោះ លោកមេត្តាទទួលដឹងឮថាខ្ញុំចង់សុំទោស។ សូមលោកមេត្តាយកបំណងនេះទៅពិចារណា។ ខ្ញុំមិនទាន់ទាមទារសុំឱ្យលោកអត់ទោសឱ្យខ្ញុំនៅពេលឥឡូវនេះទេ។ ខ្ញុំដឹងហើយថា ឧក្រិដ្ឋកម្មរបស់ខ្ញុំទៅលើជីវិតមនុស្ស ជាពិសេសទៅលើជីវិតស្ត្រីនិងកុមារ ជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរមិនអាចអត់ឱនឱ្យបានទេ។ សំណូមពរបច្ចុប្បន្ននេះ របស់ខ្ញុំគឺសូមអស់លោក លោកមេត្តាទុកទ្វារចូលសុំទោសឱ្យនៅចំហ។

ទី៣) វិប្បដិសារីដ៏សែនចុកចាប់របស់ខ្ញុំ រំឭកអតីតកាលពេលណា ខ្ញុំសែនខ្លោចផ្សាពេលនោះ។ ខ្ញុំតក់ស្លុតណាស់កាលណាខ្ញុំនឹកដល់សកម្មភាពកន្លងមក ដែលខ្ញុំបានទទួលអនុវត្តនិងបានបញ្ជាឱ្យអនុវត្ត ដែលសុទ្ធតែជាសកម្មភាពប៉ះពាល់ដល់អាយុជីវិតជនស្លូតត្រង់យ៉ាងច្រើនក្នុងនោះរួមមានទាំងស្ត្រីនិងកុមារផង។ ទោះបីខ្ញុំធ្វើដោយគោរពតាមបញ្ជារបស់អង្គការក៏ដោយ ក៏ខ្ញុំពិតជាទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនេះ។ ខ្ញុំជឿថា មនុស្សម្នាទូទៅនៅពេលនេះ ចាត់ទុកខ្ញុំថាកំសាក ថាអមនុស្សធម៌ ខ្ញុំទទួលពាក្យនេះស្មោះនិងដោយគោរព។ នៅសម័យស-២១នោះ ខ្ញុំចាត់ទុកជីវិតខ្ញុំនិងជីវិតគ្រួសារខ្ញុំ សំខាន់លើសជីវិតអ្នកជាប់ឃុំឃាំងនៅស-២១នោះ។ ប្រកែកប្រណាំងនឹងបទបញ្ជាពីខាងលើ ទោះបីដឹងថា បទបញ្ជានោះឧក្រិដ្ឋក៏ដោយ ក៏ខ្ញុំមិនដែលហ៊ាននឹកនាដល់ដែរនៅជំនាន់នោះ។ នេះជាបញ្ហាស្លាប់រស់របស់ខ្ញុំនិងគ្រួសារខ្ញុំ។ ក្នុងឋានៈខ្ញុំជាប្រធានស-២១ ខ្ញុំអត់ហ៊ានគិតគូរកេលទ្ធភាពអ្វី ក្រៅពីអនុវត្តតាមបទបញ្ជារបស់ថ្នាក់លើទេ។ ទោះបីខ្ញុំដឹងថាការអនុវត្តនោះនាំទៅរកការបាត់បង់អាយុជីវិតមនុស្សរាប់ពាន់នាក់ក៏ដោយ។ បច្ចុប្បន្ននេះ ខ្ញុំមានវិប្បដិសារីសោកស្ដាយយ៉ាងជ្រាលជ្រៅ ព្រមទាំងខ្មាសអៀន ព្រមទាំងមានសភាពអៀសក្នុងឋានៈជាអ្នកមានខ្លួនមានទោស ដឹងថាខ្លួនជាអ្នកមានទោសចំពោះជាតិប្រជាជនកម្ពុជាទាំងមូល។ ចំពោះគ្រួសារជនរងគ្រោះទាំងអស់ ដែលបានបាត់បង់ជីវិតនៅស-២១ ព្រមទាំងចំពោះគ្រួសារខ្ញុំផ្ទាល់ ដែលមានសមាជិកមួយចំនួនបាត់បង់ជីវិតទៅក៏ដោយ។»[៣២]

## ២. ពាក្យសូមអភ័យទោសលើកទី២

«ខ្មោចជនរងគ្រោះដែលសម្លាប់នៅមន្ទីរម-១៣ វាអត់ដែលទៅណាឆ្ងាយអំពីទីតាំងរបស់មន្ទីរម-១៣ហ្នឹងទេ យ៉ាងច្រើនមួយរយម៉ែត្រ។ ដូច្នេះមន្ទីរម-១៣ វាមានកន្លែងវាបី គឺកន្លែងទីមួយ នៅថ្មគប់ត្រង់ម្តុំអន្លង់វែង។ កន្លែងទីពីរ គឺនៅតាលាវ ដែលយើងខ្ញុំកម្ទេច ឬហៅថា "សម្លាប់" តិចបំផុត ហើយកន្លែងទីបី នៅត្រពាំងគ្រោក ភូមិត្រពាំងគ្រោក គឺចន្លោះស្ទឹងនិងត្រពាំងប្រាប។ ភ័ស្តុតាងដែលនៅសល់ វាអាចបញ្ជាក់បានថា ខ្មោចហ្នឹងវាមានអាយុពីអង្គាលមក? ហើយវាមានចំនួនប៉ុន្មានច្បាស់លាស់? សម្រាប់បញ្ជាក់នូវសេចក្តីដែលខ្ញុំសារភាពការស្មោះត្រង់ជូនជាតិប្រជាជនរបស់ខ្ញុំ។ ឯចំណែកសពផ្សេងទៀតនៅកន្លែងផ្សេងទៀត វាជាសពរបស់មនុស្សខ្មែរ ជាសពខ្មែរដែលស្លាប់ទៅ ដោយសារស្នាដៃបក្សកុម្មុយនីស្តកម្ពុជា។ ខមាទោស ខ្ញុំសូមអភ័យទោសជដែល អត់ប្រកែកទេ ក៏ប៉ុន្តែទន្ទឹមនឹងនេះ ខ្ញុំក៏សម្តែងការសោកស្តាយប៉ុណ្ណោះ ហើយនិងរំលែកទុក្ខចំពោះក្រុមគ្រួសារញាតិមិត្តនៃសព។»[៣៣]

## ៣. ពាក្យសូមអភ័យទោសលើកទី៣

«ការអនុវត្តនយោបាយនេះនៅទូទាំងប្រទេស ក៏ដូចជានៅស-២១។ នៅស-២១ វាមានឧក្រិដ្ឋកម្មទៅលើមនុស្សយ៉ាងតិចណាស់ក៏មួយម៉ឺនពីរពាន់បីរយប៉ែតសិប(១២ ៣៨០)នាក់ដែរ។ នៅទូទាំងប្រទេស ខ្ញុំមិនទាន់មានតួលេខច្បាស់លាស់ទេ តែខ្ញុំជឿថា ជាងមួយលាននាក់។ នេះជាការអនុវត្តមាគ៌ានយោបាយខុស។ ខុសនេះ ខ្ញុំខុសនឹងគេដែរ។ មិនមែនរឿងមេតែម្នាក់ទេ។ មានតួនាទីរបស់ខ្ញុំនៅក្នុងទូទាំងប្រទេស តួនាទីរបស់ខ្ញុំក្នុងថ្នាក់(ឋានៈ) ជាសមាជិកបក្សម្នាក់ ខ្ញុំអត់ចោលទេ ការទទួលស្គាល់កំហុសនេះ។ កំហុសនេះ គឺជាកំហុសក្នុងការអនុវត្តមាគ៌ាមហាឧក្រិដ្ឋ។ ដូចខ្ញុំបានបញ្ជាក់ព្រឹកមិញអ៊ីចឹង ឧក្រិដ្ឋជាងមាគ៌ារបស់ពួកអាក្រុមបួននាក់នៃមហាបដិវត្តន៍វប្បធម៌ចិនទៅទៀត ធ្វើឱ្យប៉ះពាល់ដល់អាយុជីវិតមនុស្សជាងមួយម៉ឺននាក់។ ខ្ញុំចាំអត់ភ្លេចទេរឿងអស់ទាំងនេះ។ នេះសូមសារភាពជូនតុលាការជូនជាតិប្រជាជនកម្ពុជាឱ្យលោកយល់បញ្ហានេះ។ នេះខ្ញុំអត់ចោលទេវិប្បដិសារី។ វិប្បដិសារី គឺក្នុងការអនុវត្តមាគ៌ានយោបាយខុសនេះឯង។»[៣៤]



បណ្តុំរូបថតអ្នកទោសមន្ទីរស-២១។ រូបថតឯកសារទាំងនេះ បន្សល់ទុកពីរបបខ្មែរក្រហម និងរកឃើញដោយកងកម្លាំងវៀតណាម។ នៅពេលអ្នកទោសត្រូវនាំខ្លួនមកកាន់មន្ទីរស-២១ កងសន្តិសុខបានកត់ឈ្មោះនិងថតរូបអ្នកទាំងនោះទុកជាឯកសារ។ រូបថតទាំងអស់នេះ កំពុងដាក់បង្ហាញនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជំពូកទី១៦

# ផលប៉ះពាល់ពីការសម្លាប់រង្គាល អំពើប្រល័យពូជសាសន៍ និងការបំពានសិទ្ធិមនុស្សមកលើបុគ្គលម្នាក់ៗ

## សេចក្តីផ្តើម

របបខ្មែរក្រហម បានប្រព្រឹត្តអំពើគួរឱ្យភ័យខ្លាចជាច្រើន ដែលបន្តយាយីមកលើអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជះឥទ្ធិពលមកលើមនុស្សជំនាន់ក្រោយដែលកើតមិនទាន់របបនេះ។ ស្របពេលដែលមានការពិពណ៌នារបស់ប្រវត្តិវិទូ ស្តីអំពីសារសំខាន់ក្នុងការសិក្សាស្វែងយល់ពីសង្គមជាតិមួយដែលទទួលរងការឈឺចាប់ តាមរយៈការចាប់មនុស្សដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ភាពអត់ឃ្លាន និងការសម្លាប់រង្គាលក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម សិស្សានុសិស្សក៏ត្រូវតែសិក្សាស្វែងយល់ពីរឿងរ៉ាវរបស់អ្នករស់រានមានជីវិតម្នាក់ៗដែរ។ រឿងរ៉ាវទាំងនេះ ផ្តល់ឱកាសដល់សិស្សានុសិស្សក្នុងការយល់ដឹងអំពីប្រវត្តិសាស្ត្រ តាមរយៈបទពិសោធន៍ឆ្លងកាត់របបខ្មែរក្រហមរបស់អ្នករស់រានមានជីវិត ឬអ្នកដែលកើតក្រោយរបបនេះ។ រឿងរ៉ាវដែលបានបង្ហាញខាងក្រោម គឺជាសេចក្តីសង្ខេប និងដកស្រង់ចេញពីសក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ រឿងរ៉ាវខ្លះ បានឆ្លុះបញ្ចាំងអំពីការសង្កេតនិងផ្នត់គំនិតរបស់កម្មាភិបាលខ្មែរក្រហម។ ឯរឿងរ៉ាវខ្លះទៀតឆ្លុះបញ្ចាំងអំពីជនរងគ្រោះផ្ទាល់ឬសមាជិកគ្រួសារនៃជនរងគ្រោះដែលបានបាត់បង់ជីវិត។ រឿងរ៉ាវនីមួយៗគឺដាច់ដោយឡែកពីគ្នា។ អ្នកអាន ត្រូវធ្វើការឆ្លុះបញ្ចាំងអំពីរឿងរ៉ាវរបស់បុគ្គលនីមួយៗ និងវិភាគថា តើរឿងរ៉ាវទាំងនោះ មានភាពសមស្របនៅក្នុងប្រវត្តិសាស្ត្រទូទៅនៃរបបនេះយ៉ាងដូចម្តេច។

## ១. សំណុំរឿង០០១

### លោកស្រី ជូឡុង អង់តូនីញ៉ា៖ ដើមបណ្តឹងរដ្ឋប្បវេណី (ធ្វើសក្ខីកម្មនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩)

ខ្ញុំនិយាយតំណាងឱ្យគ្រួសាររបស់ខ្ញុំ និងតំណាងឱ្យកូនស្រីទាំងពីររបស់បងស្រីរបស់ខ្ញុំ គឺ រង្សី ដែលត្រូវបានសម្លាប់។ អ្នកទាំងពីរមានឈ្មោះថា វិសាកា និងនីរីនកា។ ខ្ញុំសង្ឃឹមថា ខ្ញុំអាចពាំនាំសម្តីរបស់បងស្រីរបស់ខ្ញុំ ដែលលែងនៅទីនេះទៀតហើយ ដើម្បីលើកឡើងអំពីគាត់ ក្នុងគោលបំណងការពារនិងគាំទ្រដល់គាត់។ ខ្ញុំចង់ជម្រាបលោកតុលាការថា តើគាត់ជាមនុស្សរបៀបម៉េច ហើយថាក្រុមគ្រួសារនឹកគាត់កម្រិតណា។ យើងមានបង បងស្រីប្រាំពីរនាក់ក្នុងគ្រួសារ។ ឪពុករបស់ខ្ញុំ សម្តេចចក្រី ញឹក ជូឡុង បានចំណាយពេលមួយជីវិតសម្រាប់ប្រទេសជាតិ។ គាត់គឺជាមន្ត្រីជាន់ខ្ពស់មួយរូបនៃរដ្ឋបាលគ្រប់គ្រងរបស់សម្តេចព្រះនរោត្តម សីហនុ។ បន្ទាប់មក គាត់បានក្លាយជាអគ្គរដ្ឋទូត រដ្ឋមន្ត្រី នាយករដ្ឋមន្ត្រី និងប្រមុខរាជកងទ័ព ដែលប្រកបដោយស្វាមីភក្តិចំពោះសម្តេចឪ។ រង្សី គឺជាកូនស្រីទីពីរ ហើយគាត់បានរៀបការកាលពីគាត់នៅមានវ័យក្មេង ជាមួយនឹងស្វាមីឈ្មោះ លឹម គីម៉ារី។ អ្នកទាំងពីរមានកូនបីនាក់គឺកូនស្រីពីរនាក់ឈ្មោះ វិសាកា នីរីនកា និងកូនប្រុសម្នាក់ឈ្មោះ មេត្តា។ បងស្រីរបស់ខ្ញុំ គឺជាតំណាងនៃមន្ទីរពិសោធន៍មួយរបស់អាល្លឺម៉ង់។ គាត់ក៏ជាពិធីការនីនៃវិទ្យុបារាំង។ បងថ្លៃខ្ញុំ លឹម គីម៉ារី ធ្វើការឱ្យធនាគារពាណិជ្ជកម្មមួយ។ នៅខែមីនា ឆ្នាំ១៩៧០ របប លន់ នល់ បានចេញសេចក្តីសម្រេចថា មិនអនុញ្ញាតឱ្យក្រុមគ្រួសារជូឡុង ចូលស្រុកខ្មែរទៀតទេ ពីព្រោះតែ ឪពុកខ្ញុំមានចំណងជាមួយនឹងព្រះបាទ សីហនុ។ រង្សី និងបងថ្លៃខ្ញុំរស់នៅក្នុងប្រទេសកម្ពុជា ហើយនៅក្នុងឆ្នាំ១៩៧៣ ខណៈដែលសង្គ្រាមស៊ីវិលកំពុងពុះពោរ រង្សី បានបញ្ជូនកូនរបស់ខ្លួនទៅរស់នៅជាមួយនឹងជីដូនជីតានៅទីក្រុងប៉ារីស ដោយសារតែហេតុផលសន្តិសុខ។ នៅក្នុងឆ្នាំ១៩៧៤ យើងបានស្នើឱ្យ រង្សី មករស់នៅជាមួយគ្នានៅប្រទេសបារាំង ពីព្រោះថាសង្គ្រាមស៊ីវិលចាប់ផ្តើមឡើងកាន់តែខ្លាំង ក៏ប៉ុន្តែគាត់បាននិយាយថាគាត់មានការងារនៅទីក្រុងភ្នំពេញ ហើយនៅប្រទេសបារាំងគាត់ពុំមានឋានៈអ្វីទាំងអស់។ ពេលចុងក្រោយបង្អស់ដែលយើងបានជួបគ្នា គឺនៅក្នុងរដូវក្តៅឆ្នាំ១៩៧៤។ នៅខែមេសា ឆ្នាំ១៩៧៥ នៅឯប៉ារីស យើងបានដឹងថាខ្មែរក្រហមបានកាន់កាប់ទីក្រុងភ្នំពេញ។ នៅចន្លោះឆ្នាំ១៩៧៥និង១៩៧៩ គឺជារយៈពេលទន្ទឹងរង់ចាំមួយដ៏សែនយូរ។ យើងមិនបានដឹងថា បងស្រីនិងបងថ្លៃខ្ញុំស្ថិតនៅទីណាទេ។ យើងនៅតែមានសង្ឃឹម។ យើងបានប្រាប់កូនរបស់អ្នកទាំងពីរថា "កុំបារម្ភ។ នៅពេលក្មួយៗមានវ័យ១៦ឆ្នាំ ក្មួយៗនឹងជួបជាមួយឪពុកម្តាយ ហើយយើងនឹងបង្កើតក្រុមគ្រួសាររបស់ក្មួយជាថ្មី។" ក្មួយស្រីរបស់ខ្ញុំ នីរីនកា បានទុកចិត្ត ហើយទន្ទឹងរង់ចាំនូវថ្ងៃខួបកំណើតអាយុ១៦ឆ្នាំ ថានឹងជួបឪពុកម្តាយរបស់ខ្លួនវិញ។ នៅពេលដែលប្អូនជីដូនមួយខ្ញុំទៅកាន់(គុក)ទួលស្លែង គាត់បានរកឃើញចម្លើយសារភាពច្បាប់ដើម ព្រមទាំងរូបថតមួយសន្លឹករបស់បងស្រីខ្ញុំ។ គាត់បាននិយាយថា បងស្រីខ្ញុំបានទទួលរងទារុណកម្មដ៏ធ្ងន់ធ្ងរ។ គាត់មិនបាននិយាយលម្អិតទេ ព្រោះថានោះជារឿងរ៉ាវដ៏គួរឱ្យរន្ធត់។ បងថ្លៃខ្ញុំ ក៏ត្រូវបានសម្លាប់នៅទួលស្លែងដែរ។ ឪពុករបស់ខ្ញុំមានទុក្ខព្រួយថាមានកំហុសមិនអាចជួយកូនរបស់គាត់បាន។ ម្តាយរបស់ខ្ញុំក៏មិនយល់ពីអ្វី គាត់នៅតែឆ្ងល់រហូតដល់ថ្ងៃនេះ ថាហេតុអ្វីបានគេសម្លាប់កូនរបស់គាត់។ វិសាកា និង នីរីនកា គឺថាមានការរងគ្រោះក្នុងផ្លូវចិត្ត មិនមានសេចក្តីក្លាហាននឹងមកតុលាការនេះបានទេ។ ចាប់តាំងពីពេលនោះមក យើងត្រូវព្យាយាមរស់រានតាមដែលអាចធ្វើទៅបាន។ យើងបានព្យាយាមរស់នៅជាមួយគ្នា ប៉ុន្តែ យើងទុកជីវិតជាឯកជន។ ក្រៅពីអ្វីៗក្នុងជីវិតរបស់យើង បងស្រីនិងបងថ្លៃរបស់ខ្ញុំ នៅតែត្រូវលើកឡើង។ យើងរំឮកអំពីវិញ្ញាណក្ខន្ធរបស់អ្នកទាំងពីរ។ យើងតែងតែនិយាយអំពីគាត់ទាំងពីរនេះជាញឹកញាប់ ដើម្បីឱ្យគាត់បានចូលរួមនៅក្នុងជីវិតរបស់យើង។ កូនរបស់ខ្ញុំក៏នៅក្នុងបន្ទប់នេះដែរ ក៏ប៉ុន្តែ គាត់មិនអាចជួបមីងរបស់គាត់នោះទេ។ តាមរយៈសំណុំឯកសារនៅទួលស្លែង គាត់បានស្លាប់នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៦ ។[៣៥]

### លោក ប្រាក់ ខន៖ សាក្សី (ធ្វើសក្ខីកម្មនៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩)

មន្ទីរស-២១ ដែលខ្ញុំចូលមកដំបូង គឺទីតាំងនៅទួលស្លែង ប៉ុន្តែគេឱ្យមកមុនដំបូង គឺនៅយាមខាងក្រៅ គឺតាមផ្លូវមេភ្លើង លូទឹកស្អុយ និងកន្លែងវិទ្យុសំបុកឃ្មុំសព្វថ្ងៃលើផ្លូវ៣៦០ហ្នឹង[៣៦]។ កាលហ្នឹង ប្រធានខ្ញុំគឺ ហ៊ឹម ហ៊ុយ ។[៣៧] នៅស-២១ ខ្ញុំបានឃើញ ដែក ប៊ូ ជាអ្នកចាប់កុមារ និងមានយកជនជាតិវៀតណាមមក។ កាលហ្នឹងដូចជាប្រជាជន មានប្តី មានប្រពន្ធ មានកូនអាយុប្រហែលជាប្រាំពីរ-ប្រាំបីខែ។ ដែក ប៊ូ ហ្នឹងក៏យកកូនចេញពីម្តាយទៅ។ យើងយកទៅទម្លាក់ពីលើអគារ ពីលើមកធ្លាក់មកដី ហើយប្រើខ្ញុំឱ្យយកកប់។[៣៨] បច្ចេកទេសទារុណកម្មកាលណោះគេបង្រៀនឱ្យធ្វើទារុណកម្មចៀសវាងស្លាប់ ដាច់ចម្លើយ ស្លាប់ផុតចម្លើយ បើមិនអឺចឹងយើងត្រូវទទួលទោស។ យើងត្រូវបានបង្រៀនឱ្យធ្វើទារុណកម្មវាយអ្នកទោសនឹងរំពាត់ ឱ្យធក់ខ្សែភ្លើង ឬក៏ប្រកស្បោងឱ្យថប់ដង្ហើម។[៣៩]

### លោកស្រី ហាវ សោភា៖ ដើមបណ្តឹងរដ្ឋប្បវេណី (ធ្វើសក្ខីកម្មនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩)



**ហាវ សោភា កំពុងសំឡឹងមើលទិដ្ឋភាពមន្ទីរស-២១សព្វថ្ងៃ ដែលជាកន្លែងឃុំឃាំងឪពុករបស់គាត់ក្នុងរបបខ្មែរក្រហម។ សោភា រស់នៅខេត្តកំពង់ធំ។ គាត់ជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបនៃសំណុំរឿង០០១ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។** ប្រភព៖ គ្រី ស៊ុយហៀង/មជ្ឈមណ្ឌលឯកសារកម្ពុជា

ឪពុករបស់ខ្ញុំធ្វើជាយោធានៅអង្គភាពគ-៩៥។ នៅឆ្នាំ១៩៧៥ ខាងអង្គភាពគាត់បានបញ្ជូនគាត់មកពីខេត្តកំពង់ធំទៅកាន់រាជធានីភ្នំពេញ។ គាត់នៅភ្នំពេញ នៅមណ្ឌលបឹងត្របែក។ ដល់ថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៧៦ មានការចាប់ខ្លួនគាត់តែម្តង។ នៅពេលដែលឪពុករបស់ខ្ញុំត្រូវបានចាប់ខ្លួន ខ្ញុំពុំទាន់ចាប់កំណើតនៅឡើយទេ។ តាមអ្វីដែលម្តាយរបស់ខ្ញុំប្រាប់ ឪពុកខ្ញុំបានផ្តាំថា ប្រសិនបើគាត់ត្រូវចាប់ខ្លួន ម្តាយខ្ញុំត្រូវតស៊ូរស់ រស់ដើម្បីជីវិតទៅថ្ងៃមុខ។ គាត់ធ្លាប់ផ្តាំឱ្យម្តាយខ្ញុំរៀបការគ្រួសារថ្មី។ គេយកឪពុកខ្ញុំទៅ២១ថ្ងៃ ទើបខ្ញុំកើត។ ម៉ែគាត់មិនដែលដឹងថា ឪពុកខ្ញុំមានកំហុសអ្វីទេ ដែលត្រូវគេចាប់ទៅហ្នឹងនោះ។ ចាប់តាំងពីថ្ងៃចាប់ខ្លួនឪពុកខ្ញុំទៅ ម្តាយខ្ញុំនៅទន្ទឹងរង់ចាំឪពុកខ្ញុំរហូត។ ខ្ញុំកើតបានប្រាំបួនខែ អង្គការនិយាយប្រាប់ម្តាយខ្ញុំថា គ្រួសារមិត្តត្រូវគេកម្ទេចហើយ ក៏ប៉ុន្តែម៉ែគាត់ចាំដំណឹងឪពុកខ្ញុំអស់ជាច្រើនឆ្នាំទៀត។ ទោះគាត់ដឹងថា គេសម្លាប់ប្តីគាត់ហើយ តែចិត្តមួយ គាត់នៅតែសង្ឃឹមថ្ងៃណាមួយឪពុកខ្ញុំនឹងវិលមកវិញ វិលមកជុំជាមួយគ្រួសារវិញ។ ក្រោយមកទើបយើងដឹងថា ឪពុកខ្ញុំបានបាត់បង់ជីវិតនៅស-២១។ នៅពេលដែលម្តាយខ្ញុំដឹងថាឪពុកខ្ញុំបានស្លាប់នៅស-២១ គាត់ស្ទើរតែស្រែកយំនៅទីនោះ ប៉ុន្តែគាត់ខំទប់អារម្មណ៍ ទប់ចិត្តគាត់ទាំងអារម្មណ៍សោកសៅ។ នៅឆ្នាំ២០០៦ យើងបានបញ្ជាក់ថា ឪពុកខ្ញុំពិតជាបានស្លាប់នៅស-២១ នៅពេលដែលយើងបានឃើញចម្លើយសារភាពរបស់ឪពុកខ្ញុំនៅមន្ទីរស-២១ តាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា។ ម្តាយខ្ញុំមិនបានរៀបអាពាហ៍ពិពាហ៍សាជាថ្មីទេ ហើយគាត់ក៏គ្មានបំណងរៀបការជាមួយបុរសណាទៀតដែរ។ ចាប់តាំងពីឪពុកខ្ញុំត្រូវបានចាប់ខ្លួន គ្រួសារយើងបានជួបនូវការលំបាកទាំងផ្នែកសេដ្ឋកិច្ច ទាំងផ្នែកផ្លូវកាយ និងទាំងផ្នែកផ្លូវចិត្ត។ ដោយសារតែឪពុកខ្ញុំមិនដែលត្រឡប់មកវិញ យើងគ្មានថវិកាគ្រប់គ្រាន់ដើម្បីទ្រទ្រង់ការសិក្សារបស់ខ្ញុំទេ។ ដូច្នេះហើយ ខ្ញុំបានឈប់រៀននៅថ្នាក់ទី៧។ ខ្ញុំធ្លាប់ប្រាថ្នាធ្វើជាគ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ក៏ប៉ុន្តែការប្រាថ្នានោះបានត្រឹមតែគិតនៅក្នុងចិត្ត ការស្រមៃតែប៉ុណ្ណឹងឯង ព្រោះតាំងពីពេលនោះរហូតមក ខ្ញុំមិនបានចូលសាលារៀនទៀតទេ។ ខ្ញុំធ្លាប់យល់សប្តិឃើញឪពុករបស់ខ្ញុំ ទោះបីជាខ្ញុំពុំធ្លាប់ជួបគាត់ក៏ដោយ។ ម្តាយខ្ញុំនិងខ្ញុំមានតែរូបថតឪពុកខ្ញុំមួយសន្លឹកប៉ុណ្ណោះ។ យើងនៅសល់តែរូបថតគាត់មួយសន្លឹក ព្រោះថាខ្មែរក្រហមធ្លាប់ប្រាប់ម្តាយខ្ញុំ ឱ្យដុតឯកសារនិងរូបថតរបស់ឪពុកខ្ញុំចោលទាំងអស់ ប្រសិនបើមិនអឺចឹងទេ ម្តាយខ្ញុំនឹងត្រូវយកទៅសម្លាប់។[៤០]

### លោក ឈួន ផល៖ សាក្សី (ធ្វើសក្ខីកម្មនៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៩)

ខ្ញុំត្រូវបានចាត់តាំងជាអ្នកយាមគុកម្នាក់នៅមន្ទីរស-២១ ដែលត្រូវបានហៅថា គុកទួលស្លែង។ ខ្ញុំឈរយាមនៅក្នុងអគារលេខ២ ដែលជាអគារលាតសន្ធឹងពីទិសបូព៌ាទៅទិសបស្ចិម។ អគារនេះមានបីជាន់។ ជួនកាល ខ្ញុំត្រូវបានចាត់តាំងឱ្យយាមនៅជាន់ខាងលើ ឬពេលខ្លះទៀតនៅជាន់ខាងក្រោម។ នៅពេលដែលខ្ញុំយាមល្បាត ខ្ញុំមិនធ្លាប់ឃើញអ្នកទោសស្លាប់ទេ។ ខ្ញុំបានឃើញអ្នកទោសដែលមានរូបរាងស្គមរីងរៃ ព្រោះអ្នកទាំងនោះពុំបានទទួលអាហារគ្រប់គ្រាន់។ របបអាហារមានទម្រង់ជាបបរ។ ខ្ញុំមិនមែនជាអ្នកទទួលបន្ទុកចែកអាហារដល់អ្នកទោសទេ។ មានអ្នកដទៃទៀតដែលទទួលខុសត្រូវចែកចាយអាហារដល់អ្នកទោស។ ខ្ញុំគ្រាន់តែទទួលខុសត្រូវត្រួតពិនិត្យនិងល្បាតនៅទីតាំងនេះប៉ុណ្ណោះ។ អ្នកទោសនៅក្នុងបន្ទប់នានា ទាំងនៅក្នុងបន្ទប់រួមឬបន្ទប់ដាច់ដោយឡែក។ តាមដែលខ្ញុំចាំ អ្នកទោសប្រុសត្រូវដាក់ខ្នោះជាជួររួមគ្នា។ ជាឧទាហរណ៍ របាដែកវែងមួយត្រូវបានដាក់ភ្ជាប់លើក្រុមអ្នកទោសចំនួនប្រាំពីរនាក់។ អ្នកទោសមិនត្រូវបានអនុញ្ញាតឱ្យឈរទេ លុះត្រាតែទទួលបានការអនុញ្ញាតឱ្យឈរពីអ្នកយាម។ អ្នកទោសមិនបានស្លៀកសម្លៀកបំពាក់សមរម្យដូចយើងទេ។ អ្នកទាំងនោះទទួលបានសម្លៀកបំពាក់ដាច់ដោច ហើយអ្នកខ្លះមានខោវែងស្លៀក។ អ្នកខ្លះស្លៀកតែខោខ្លីប៉ុណ្ណោះ។ ចំណែកអ្នកខ្លះទៀតស្លៀកសម្លៀកបំពាក់រហែក។ ខ្ញុំបានសង្កេតលើអ្នកទោសដែលត្រូវបានយកទៅសួរចម្លើយ។ អ្នកខ្លះត្រូវបានវាយដំ។ ឯអ្នកខ្លះទៀតមិនត្រូវបានវាយដំទេ។ ខ្ញុំឃើញស្នាមជាំនិងរបួស។ អ្នកទោសខ្លះមិនមានស្នាមជាំ ឬរបួសនៅពេលត្រឡប់មកវិញទេ។ ខ្ញុំគិតថា នេះអាស្រ័យលើអង្គការ ឬថ្នាក់លើថាតើត្រូវធ្វើទារុណកម្មឬទេ លើអ្នកទោសទាំងនោះ។[៤១]

## ២. សំណុំរឿង ០០២

### សាក្សី TCCP-223[៤២] (ធ្វើសក្ខីកម្មនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦)

ថ្ងៃនេះ ខ្ញុំនឹងរៀបរាប់នូវសេចក្ដីលម្អិតអំពីអ្វីដែលបានកើតឡើងនៅក្នុងឆ្នាំ១៩៧៧។ តាមអ្វីដែលខ្ញុំដឹង នៅពេលដែលខ្មែរក្រហមធ្វើបន្សុទ្ធកម្ម ខ្មែរក្រហមធ្វើបន្សុទ្ធកម្មលើមនុស្សនៅភូមិភាគឧត្ដរមុនគេ។ បន្ទាប់ពីធ្វើបន្សុទ្ធកម្មលើក្រុមខាងលើរួច ខ្មែរក្រហមបានធ្វើបន្សុទ្ធកម្មលើមនុស្សនៅភូមិភាគពាយ័ព្យទៀត។

ខ្មែរក្រហមចាប់ផ្ដើមធ្វើបន្សុទ្ធកម្មលើកម្មាភិបាលថ្នាក់ក្រោម រួចដាក់កម្មាភិបាលមកពីភូមិភាគពាយ័ព្យជំនួសវិញ។ ខ្មែរក្រហមបានចាត់តាំងឱ្យកម្មាភិបាលភូមិភាគនិរតី បន្សាំខ្លួនជាមួយនឹងការងាររបស់កម្មាភិបាលនៅខេត្តបាត់ដំបង។

នៅក្នុងអំឡុងពេលបន្សុទ្ធកម្ម ខ្មែរក្រហមបានប្រើពាក្យថា "បញ្ជូនអ្នកទាំងនោះឱ្យទៅរៀនសូត្រ" ក៏ប៉ុន្តែអ្នកដែលត្រូវបានបញ្ជូនទៅរៀនសូត្រទាំងនោះ បានបាត់ខ្លួននិងមិនដែលត្រឡប់មកវិញជារៀងរហូត។ សកម្មភាពនេះត្រូវបានប្រព្រឹត្តលើអ្នកថ្នាក់លើដែលទទួលបន្ទុកលើភូមិភាគនានា ហើយបន្សុទ្ធកម្មនៅតែកើតមានជាបន្តបន្ទាប់។[៤៣]

### សាក្សី TCCP-1063 (ធ្វើសក្ខីកម្មនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៩)

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំត្រូវបានជម្លៀសចេញពីខេត្តស្វាយរៀង។ នៅពេលនោះ គឺនៅពេលដែលកងទ័ពខ្មែរក្រហមបានចូលមកកាន់ខេត្តស្វាយរៀង។ ខ្មែរក្រហមបានបណ្ដេញ និងបង្ខំឱ្យប្រជាជនចាកចេញពីខេត្តស្វាយរៀង។ ខ្មែរក្រហមបានស្រែកដាក់យើងថា បងប្អូនពុកម៉ែត្រូវចាកចេញពីទីក្រុង បើមិនអ៊ីចឹងទេ នឹងត្រូវបាញ់សម្លាប់ទាំងអស់។ បន្ទាប់ពីខ្ញុំបានចាកចេញពីទីកន្លែងកំណើតនិងមកដល់ផ្លូវធំ ខ្ញុំបានឃើញបុរសវ័យចំណាស់ម្នាក់ដើរពុំរួច។ បុរសម្នាក់នេះដើរមិនចង់រួចផង ខ្មែរក្រហមក៏ស្រែកដាក់គាត់ថា៖ "ហេតុអីបានធ្វើអីចឹង? ម៉េចបានជាដើរអ៊ីចឹង? អ្នកឯង នឹងត្រូវគេបាញ់សម្លាប់។" ភ្លាមៗបន្ទាប់ពីការគំរាមកំហែង បុរសវ័យចំណាស់ម្នាក់នោះក៏ត្រូវបាញ់សម្លាប់ ហើយដួលទៅលើដីនៅខាងមុខខ្ញុំ។ ខ្ញុំមានការភិតភ័យយ៉ាងខ្លាំងនៅពេលនោះ។ ខ្ញុំមានការភ័យតក់ស្លុត ដូច្នេះហើយខ្ញុំក៏បន្តដំណើរទៅមុខទៀត។

ប្រជាជនទាំងអស់ រួមទាំងរូបខ្ញុំផង ស្ថិតនៅក្នុងស្ថានភាពដូចគ្នា។ ទាំងអស់គ្នាត្រូវបានជម្លៀស។ យើងមិនបានយករបស់មកតាមច្រើនទេ ក្រៅពីសម្លៀកបំពាក់ខ្លះនិងអង្ករខ្លះ ព្រោះយើងត្រូវបានបង្ខំឱ្យចាកចេញ។ យើងត្រូវបានប្រាប់ថា យើងនឹងត្រូវចាកចេញតែពីរបីថ្ងៃប៉ុណ្ណោះ យើងនឹងត្រូវអនុញ្ញាតឱ្យវិលមកកាន់ផ្ទះសម្បែងវិញហើយ។ គេប្រាប់យើងថា មិនចាំបាច់យករបស់របរអ្វីទៅតាមខ្លួនទេ។ យើងមានការភិតភ័យ ហើយយើងត្រូវតែចាកចេញ។ បន្ទាប់ពីយើងមកដល់ភូមិតាជ័យ យើងត្រូវបានអនុញ្ញាតឱ្យសម្រាកនៅទីនោះរយៈពេលប្រមាណមួយខែ។ បន្តិចក្រោយមក ខ្មែរក្រហមបានដឹងថា បងប្រុសរបស់ខ្ញុំធ្លាប់ជាអតីតទាហាន លន់ នល់។ បងប្រុសខ្ញុំក៏ត្រូវយកទៅអប់រំនៅវត្តគ្រួស។ តាមការពិតទៅ គាត់មិនត្រូវបានបញ្ជូនទៅអប់រំទេ គឺគាត់ត្រូវបានបញ្ជូនទៅសម្លាប់។ គាត់ក៏បាត់ដំណឹងតាំងពីពេលនោះមក។ កន្លះខែក្រោយមក ឪពុកខ្ញុំត្រូវបានយកទៅ។ គាត់ក៏ត្រូវបានយកទៅអប់រំដែរ នៅឯវត្តតាជ័យ។[៤៤]

### លោក ស សារិន៖ ដើមបណ្ដឹងរដ្ឋប្បវេណី (ធ្វើសក្ខីកម្មនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៣)

យុវជនស្ម័គ្រចិត្តទាំងអស់ប្រមូលផ្ដុំគ្នាបាន១៣០នាក់ ចូលបម្រើបដិវត្តន៍ហ្នឹង ហើយរៀនក្បួនយុទ្ធសាស្ត្រហ្នឹងដើម្បីទៅប្រយុទ្ធជាមួយកងទ័ព លន់ នល់។ ក្នុងអំឡុងពេលនោះ ខ្ញុំគឺជាផ្នែកមួយនៃក្រុមសម្ដែងសិល្បៈ។ ក្រុមសិល្បៈសម័យហ្នឹង គឺត្រូវផ្សព្វផ្សាយតាមរយៈចម្រៀង។ យើងប្រាប់បងប្អូនអ្នកភូមិថាមកមើលសិល្បៈ តែយើងឆ្លៀតឱកាសហ្នឹងដើម្បីផ្សព្វផ្សាយនូវមាគ៌ានយោបាយរណសិរ្សហ្នឹង។ ខ្លួនខ្ញុំជាអ្នកផ្សព្វផ្សាយផ្ទាល់ គឺមានកូនសៀវភៅមួយតូច។ មុននឹងសិល្បៈសម្ដែង គឺឱ្យខ្ញុំហ្នឹងឡើងអានពីនយោបាយរណសិរ្ស។ ... ដំបូងនោះ ខ្ញុំនិយាយថា រណសិរ្សរួបរួមជាតិកម្ពុជា រួបរួមរាល់អង្គការ សាសនា ព្រះមហាក្សត្រ រាជវង្សានុវង្ស និងសមាជិកសង្គម ដោយមិនប្រកាន់ពូជសាសន៍ឬសាសនាទេ។ ហេតុនេះ រណសិរ្សនេះគឺជារណសិរ្សសេរីសម្រាប់អ្នករាល់គ្នា។ បន្ទាប់មក ខ្ញុំបន្តចែកចាយព័ត៌មានទាក់ទងនឹងប្រវត្តិតស៊ូរបស់អតីតអ្នកតស៊ូ រួមមាន អាចារ្យពេជ៏កំបោរ និងវីរបុរសខ្មែរដទៃទៀត រួចក៏ចាប់ផ្ដើមសម្ដែង។ អត្ថន័យស្នូលនៃសាររបស់យើងពេលនោះនូវរាល់មុនពេលសម្ដែង គឺដើម្បីផ្សព្វផ្សាយដល់ប្រជាជនអំពីរណសិរ្សដែលដឹកនាំដោយសម្ដេច សីហនុ ក៏ដូចជាសមាជិកដទៃទៀត រួមមាន ខៀវ សំផន, សម្ដេច ប៉ែន នុត, ហ៊ូ នឹម, និង ហ៊ូ យន់ ជាដើម។ ការផ្សព្វផ្សាយនេះកើតមានឡើងក្នុងអំឡុងចុងឆ្នាំ១៩៧១ និងឆ្នាំ១៩៧២។[៤៥]

### លោកស្រី តឹង សុខា៖ ដើមបណ្ដឹងរដ្ឋប្បវេណី (ធ្វើសក្ខីកម្មនៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២)

នៅក្នុងអំឡុងពេលជម្លៀសចេញពីទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺប្រៀបបានដូចទៅនឹងគ្រាប់បែកដែលបានបំផ្ទុះ ដើម្បីបំបែកគ្រួសារទាំងអស់នៅក្នុងទីក្រុងភ្នំពេញ។ យើងបានបែកចេញពីគ្នាដោយសារតែការផ្លាស់ទីភ្លាមៗ។ យើងបានបែកបាក់សមាជិកគ្រួសារ និងមិត្តភក្ដិ។ យើងក៏បានបាត់បង់ទៅភ្លាមៗនូវអ្វីៗដែលយើងរកបាននិងទ្រព្យសម្បត្តិទាំងអស់។[៤៦] នៅក្នុងឆ្នាំ១៩៧៦ ខ្ញុំបានបាត់បងកូនស្រី ឪពុកក្មេកនិងសាច់ថ្លៃពីរនាក់ ចំណែកឯស្វាមីរបស់ខ្ញុំបានធ្វើអត្តឃាត។ កូនស្រីម្នាក់ផ្សេងទៀតរបស់ខ្ញុំ និយាយអ្វីលែងកើត។ នាងបានក្លាយជាមនុស្សគ។[៤៧] ដំណាក់កាលទីពីរនៃការផ្លាស់ទី គឺជាដំណាក់កាលលំបាកលំបិនបំផុតសម្រាប់យើង។ ... កូនស្រីទីពីររបស់ខ្ញុំបានស្លាប់នៅក្នុងអំឡុងដំណាក់កាលទីពីរនៃការជម្លៀស ... គឺនៅពេលដែលយើងទៅដល់ខេត្តបាត់ដំបង។ នាងស្លាប់ដោយសារតែកង្វះអាហារ។ ខ្លួនប្រាណរបស់នាងឡើងហើម ព្រមទាំងកើតជំងឺរាករូសធ្ងន់ធ្ងរ។ ដោយសារតែគ្មានសេវាថែទាំសុខភាពសមស្រប នាងបានស្លាប់នៅដើមឆ្នាំ១៩៧៦។[៤៨]

### លោក សំ សិទ្ធី៖ សាក្សី[៤៩] (ធ្វើសក្ខីកម្មនៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៥)

ខ្ញុំជាជនរងគ្រោះម្នាក់នៃរបបខ្មែរក្រហម ដែលមានរយៈកាល៣ឆ្នាំ ៨ខែ និង២០ថ្ងៃ។ ខ្ញុំត្រូវបានបង្ខំឱ្យរើផ្ទះសម្បែងទៅកាន់តំបន់ភ្នំ។ បន្ទាប់ពីបានទៅដល់វត្តប្រកស្ដេច ខ្ញុំបានឮសេចក្ដីប្រកាសថា អតីតអ្នកបម្រើសេវាសាធារណៈ (មន្ត្រីរដ្ឋការស៊ីវិល) ទាហាន ឬសិស្ស-និស្សិតអាចទៅទទួលយកអង្ករដែលគេចែកនិងអាចវិលត្រឡប់ទៅកាន់ទីតាំងការងារដើមរបស់ខ្លួនវិញ។ បន្ទាប់ពីទទួលបានអង្ករ យើងត្រូវបាននាំទៅកាន់សហករណ៍រៀងៗខ្លួន។ បន្ទាប់ពីយើងបានមកដល់ព្រៃពេងខ្លា យើងបានដាក់របស់របររបស់យើងនៅជ្រោយម្ខាងទន្លេ និងបានធ្វើដំណើរទៅកាន់ជ្រោយម្ខាងទៀត។ នៅទីនោះ មានទាហានប្រដាប់អាវុធ ហើយយើងត្រូវតម្រូវឱ្យអង្គុយជាក្រុម។ ទាហានទាំងនោះ បាញ់កាំភ្លើងវែងតម្រង់មកយើងទាំងអស់គ្នា។ ម្ដាយរបស់ខ្ញុំអង្គុយនៅខាងមុខខ្ញុំ។ នៅពេលដែលទាហានបាញ់តម្រង់មកយើង គ្រាប់កាំភ្លើងមួយគ្រាប់បានបាញ់ចំទ្រូងរបស់គាត់បណ្ដាលឱ្យគាត់ដួលទៅលើដី។ បន្ទាប់មក ទាហានក៏បានវាយបោកក្បាលទារក ដើម្បីធានាថាទារកទាំងនោះស្លាប់។

ទាហានបានចោលសាកសពទាំងអស់ទៅក្នុងរណ្ដៅ ព្រមទាំងបានយកស្លឹកឈើមកគ្របពីលើ។ បន្ទាប់ពីទាហានបានចាកចេញពីទីនោះ ខ្ញុំមិនទាន់ស្លាប់ទេ។ ខ្ញុំធ្វើពុតជាស្លាប់។ បន្ទាប់ពីទាហានបានចាកចេញពីទីតាំងរណ្ដៅ ខ្ញុំបានវារឡើងចេញពីរណ្ដៅ។ មនុស្សបួននាក់ដទៃទៀតក៏នៅរស់នៅឡើយ ហើយអ្នកទាំងនោះក៏បាននាំគ្នាវារចេញពីរណ្ដៅដែរ។

## ករណី០០២ វគ្គ០២

### អ៊ី វុន៖ សាក្សី[៥០] (ធ្វើសក្ខីកម្មនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥)

នៅចន្លោះឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៩ ខ្ញុំត្រូវបានចាត់តាំងឱ្យធ្វើការនៅឯវាលស្រែ។ ខ្ញុំរស់នៅទីតាំងចម្ងាយប្រមាណ៣០០ម៉ែត្រពីវត្តខ្សាច់ ដែលត្រូវបានប្រើប្រាស់ជាឃ្លាំងផ្ទុកស្រូវ។ នៅក្នុងឆ្នាំ១៩៧៨ មានការកាប់សម្លាប់ជនជាតិវៀតណាមកើតឡើងនៅឯវត្តខ្សាច់កណ្ដាល។ មានបញ្ជីឈ្មោះមួយនៃបុគ្គលរស់នៅក្នុងភូមិ ដែលត្រូវបានជ្រើសរើសដោយគណៈស្រុក បន្ទាប់មកបញ្ជីនោះត្រូវបានបញ្ជូនទៅកាន់ថ្នាក់ភូមិ។

ខ្ញុំមិនដឹងថាតើ គេបានសួរសំណួរផ្សេងៗអំពីជាតិពន្ធុរបស់ប្រជាជនក្នុងតំបន់នោះឬយ៉ាងណាទេ។ ប្រធានភូមិបានទៅរកនិងជ្រើសរើសបុគ្គលជាក់លាក់ណាម្នាក់ ដែលក្រោយមកត្រូវបានប្រាប់ឱ្យទៅចូលរួមវគ្គអប់រំ។ ក្នុងទម្រង់គ្រួសារវិញ មានតែគ្រួសារចំនួនពីរប៉ុណ្ណោះ រួមមានគ្រួសាររបស់ ជុំ និងគ្រួសារមួយទៀតគឺគ្រួសាររបស់ ចន្ថា ដែលត្រូវបានជ្រើសរើសឱ្យទៅចូលរួមវគ្គសិក្សា។ គ្រួសារទាំងពីរគឺសុទ្ធសឹងតែជាប់សែស្រឡាយវៀតណាម។ បន្ថែមលើសពីនេះទៅទៀត ក៏មានប្រជាជនដទៃទៀតដែលមកពីគោលក្រោមនិងតំបន់ដទៃទៀតដែរ។ មនុស្សពីរនាក់បានរស់រានមានជីវិតពីការសម្លាប់រង្គាលនេះ។ ម្នាក់ឈ្មោះ យាយឡាង។ គាត់រស់នៅឯមង្គលបុរី ក៏ប៉ុន្តែគាត់បានស្លាប់ទៅហើយ។ ចំណែកឯម្នាក់ទៀតគឺកូនប្រុសរបស់គាត់ ឈ្មោះ គុណ។ អ្នកទាំងពីរជាប់សែស្រឡាយចិន។ នៅពីចម្ងាយ ខ្ញុំអាចមើលឃើញថាមានមនុស្សប្រមាណ១០ទៅ២០នាក់ប្រមូលផ្តុំនៅក្នុងវត្ត។ នៅថ្ងៃកាប់សម្លាប់ ខ្ញុំបានឮសំឡេងរបស់អ្នកទាំងនោះ។ ខ្ញុំមានការភិតភ័យយ៉ាងខ្លាំង។ ខ្ញុំបានឮសម្រែករបស់អ្នកទាំងនោះ។ ខ្ញុំនៅខាងក្រៅនិងបានឮអ្នកទាំងនោះយំយែករហូតដល់លែងឮសំឡេងអ្វីទាំងអស់ គឺនៅរយៈពេលជាងពីរម៉ោងក្រោយមក។ ខ្ញុំ(មិន) បានឃើញពេជ្ឈឃាដទេ ក៏ប៉ុន្តែខ្ញុំបានឃើញកំណាត់ឫស្សីប្រវែងជាងមួយម៉ែត្រ ដែលមានស្នាមឈាមពីលើ។ ខ្ញុំក៏បានឃើញរណ្តៅដែរ។ រណ្តៅនោះត្រូវបានចាក់ដីគ្របពីលើ។ រណ្តៅនោះមិនត្រូវបានគ្របសព្វទេ គឺមានអវៈយវៈលេចចេញមកក្រៅ។ ទាំងនោះគឺជាឆ្អឹងកែងដៃ។

## លោកស្រី សយ ណារឿន៖ ដើមបណ្តឹងរដ្ឋប្បវេណី[៩៧] (ធ្វើសក្ខីកម្មនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦)

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំត្រូវបានជម្លៀសចេញពីភូមិស្វាយទាប ទៅកាន់ភូមិអូរទឹកត្រជាក់ ក្នុងឃុំអូរន្ទួង ស្រុក៦២ ខេត្តកំពង់ចាម។ បន្ទាប់ពីការជម្លៀស ខ្ញុំត្រូវបានបំបែកចេញពីក្រុមគ្រួសារ ហើយខ្ញុំស្ថិតនៅក្នុងកងចល័ត។ ក្នុងកងនីមួយៗ មានស្ត្រីប្រមាណ២០ទៅ៣០នាក់។ ខ្ញុំបានទទួលរងទុក្ខវេទនាជាច្រើន។ ខ្ញុំត្រូវបានចាត់តាំងឱ្យកាប់ឆ្ការព្រៃ ដើម្បីធ្វើឱ្យដីព្រៃដែលឆ្ការរួចក្លាយជាភូមិថ្មី។ យើងមិនបានទទួលឧបករណ៍គ្រប់គ្រាន់ ដើម្បីកាត់ដើមឈើទេ ដោយយើងមានតែកាំបិតនិងពូថៅប៉ុណ្ណោះ។ ចំណែកឯដើមឈើអស់ទាំងនោះធំៗណាស់។ ស្ថានភាពរស់នៅនិងការងារមានភាពលំបាកលំបិន។ ក្នុងនាមជាស្ត្រីម្នាក់ ខ្ញុំពិតជាពិបាករស់ក្នុងស្ថានភាពនោះណាស់។ ឧទាហរណ៍ នៅពេលដែលខ្ញុំមករដូវ ខ្ញុំមិនមានអ្វីជួយដល់ខ្លួនខ្ញុំជាស្ត្រីទេ។ និយាយអំពីការហូបចុកវិញ ក្នុងមួយថ្ងៃ គេឱ្យតែអង្ករ១០កំប៉ុងប៉ុណ្ណោះដល់កងនីមួយៗ ដែលមានសមាជិក២០ទៅ៣០នាក់។

ខ្ញុំបានរៀបការនៅឆ្នាំ១៩៧៥ ដោយធ្វើឡើងក្នុងភូមិអូរថ្ម។ យើងកំពុងតែលើកទំនប់។ ថ្ងៃមួយ ប្រធានកងបានមករកខ្ញុំ និងប្រាប់ខ្ញុំកុំឱ្យស្លៀកខោទៅចូលរួមប្រជុំ។ គាត់បានប្រាប់ខ្ញុំឱ្យស្លៀកសំពត់។ ដូច្នេះ ខ្ញុំក៏បានស្លៀកសំពត់ខ្មៅនិងអាវខ្មៅ ព្រមទាំងបង់កក្រមាមួយ។ ខ្ញុំដើរតាមប្រធានកងរហូតទៅដល់ភូមិនោះ។ នៅពេលដែលយើងមកដល់ ខ្ញុំឃើញមនុស្សជាច្រើននៅទីនោះរួចទៅហើយ។ ខ្ញុំបានសួរប្រធានកងថា៖ "សមមិត្ត ហេតុអ្វីបានជាមានមនុស្សច្រើនម្ល៉េះ?" គាត់បានឆ្លើយតបថា៖ "មិត្តនឹងបានដឹងឥឡូវហើយ ព្រោះថ្នាក់លើអញ្ជើញមកធ្វើអធិបតីភាពក្នុងការជួបប្រជុំនេះ។" ខ្ញុំបានបន្តដំណើរទៅទៀត ហើយខ្ញុំបានឃើញបុរសអង្គុយនៅមួយជួរនិងស្ត្រីអង្គុយនៅមួយជួរទៀត។ ខ្ញុំក៏មានការសង្ស័យ ក៏ប៉ុន្តែខ្ញុំមិនហ៊ានសួរអ្វីទេ។ ក្រោយមកទៀត ថ្នាក់លើបានចាប់បើកអង្គប្រជុំ។ អ្នកទាំងនោះស្នើឱ្យយើងក្រោកឈរឡើងនិងធ្វើការប្តេជ្ញា។ គូនីមួយៗតម្រូវឱ្យធ្វើការប្តេជ្ញា។ ខ្ញុំក៏បានដឹងថា នេះគឺជាកម្មវិធីរៀបការ ហើយខ្ញុំក៏មានអារម្មណ៍ខ្លាចរអា។ ខ្លួនប្រាណរបស់ខ្ញុំញ័រនិងទៅជាត្រជាក់។ ខ្ញុំមានអារម្មណ៍ឈឺចាប់ ពីព្រោះឪពុកម្តាយខ្ញុំខិតខំធ្វើការដើម្បីចិញ្ចឹមបីបាច់រូបខ្ញុំ ក៏ប៉ុន្តែនៅពេលដែលខ្ញុំត្រូវរៀបការ លោកទាំងពីរបែរជាមិនបានដឹងឮទៅវិញ។ តើលោកទាំងពីរអាចដឹងបានដោយរបៀបណា បើខ្ញុំធ្វើការនៅឯការដ្ឋានហ្នឹង។ មនុស្សចំនួន៦០គូបានរៀបការនៅថ្ងៃនោះ។ ខ្ញុំមានអារម្មណ៍ឈឺចាប់ជាពន់ពេក ដោយត្រូវផ្គូផ្គងជាមួយមនុស្សដែលខ្ញុំមិនដែលស្គាល់សោះ។ ខ្ញុំមិនដឹងអ្វីសោះអំពីប្តីរបស់ខ្ញុំ មិនដឹងថាគាត់ជាមនុស្សល្អឬមនុស្សឃោរឃៅ។ នៅថ្ងៃនោះ យើងត្រូវបានចាប់គូ ដូចគេចាប់គូសត្វដូច្នឹងឯង។

នៅយប់នោះ គូស្រករដែលទើបរៀបការថ្មីថ្មោង ត្រូវបានដាក់នៅក្នុងផ្ទះស្បូវ។ ខ្ញុំអង្គុយឱបក្បាលជង្គង់នៅក្នុងផ្ទះនោះ។ ខ្ញុំមានការភ័យខ្លាច ព្រមទាំងបានឃើញកងឈ្លបប្រាំមួយ ប្រាំពីរនាក់ដើរទៅដើរមក។ ខ្ញុំបានឃើញគេយកគូស្រករមួយគូចេញពីផ្ទះមួយ។ ប្រមាណកន្លះម៉ោងក្រោយមក ឈ្លបទាំងនោះបានត្រឡប់មកវិញ តែមិនឃើញគូស្រករនោះទេ។ ខ្ញុំបានសន្និដ្ឋានថា គូស្រករនោះប្រហែលជាមិនត្រូវគ្នា។ ហេតុផលនេះហើយ បានជាឈ្លបនាំយកគូស្រករនោះចេញពីផ្ទះ។ ប៉ុន្មាននាទីក្រោយមក ឈ្លបក៏បាននាំមួយគូទៀតចេញទៅ។ ខ្ញុំគិតក្នុងចិត្តថា ទោះបីជាខ្លួនប្រាណខ្ញុំញ័រភ័យ ខ្ញុំត្រូវតែរស់បន្តទៀត។ ដូច្នេះហើយ ខ្ញុំក៏សុខចិត្តលះបង់ខ្លួនប្រាណឱ្យប្តីខ្ញុំ។ នៅពេលដែលខ្ញុំលះបង់ខ្លួនប្រាណ ខ្ញុំមានអារម្មណ៍ថប់ដង្ហើម។ ក្នុងនាមជាស្ត្រីខ្មែរ គ្មានអ្វីសំខាន់ជាងខ្លួនប្រាណយើងទេ។ ទោះបីជាខ្ញុំមានការភ័យខ្លាចនិងញ័រភ័យ ខ្ញុំគិតថាខ្ញុំត្រូវតែលះបង់ខ្លួនប្រាណឱ្យប្តីខ្ញុំ ដើម្បីបំពេញតាមតម្រូវការរបស់អង្គការ។

## លោក យន់ ប៊ីន៖ ដើមបណ្តឹងរដ្ឋប្បវេណី[៩២] (ធ្វើសក្ខីកម្មនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦)

បន្ទាប់ពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្ញុំរស់នៅក្នុងភូមិទួលមានជ័យ ក្នុងឃុំព្រះធាតុ។ ខ្ញុំត្រូវបានដាក់បញ្ចូលទៅក្នុងកងចល័ត និងត្រូវបានបញ្ជូនទៅរស់នៅលើកោះទន្សាយ។ ក្នុងកងចល័ត យើងត្រូវបានចាត់តាំងឱ្យធ្វើការនៅឯវាលស្រែ ដើម្បីជីកប្រឡាយនិងលើកភ្លឺ។ ខ្ញុំត្រូវតម្រូវឱ្យឆ្ការព្រៃនិងសាបព្រោះស្រូវ។ នៅពេលដែលខ្ញុំឆ្ការស្មៅនៅឯរោងសណ្តែកដី ខ្ញុំត្រូវបានកោះហៅឱ្យទៅចូលរួមវគ្គអប់រំមួយ។ ខ្ញុំត្រូវបានបញ្ជូនទៅជាមួយនឹងអ្នកដទៃប៉ុន្មាននាក់ទៀតទៅកាន់សាលាឃុំ ដោយគេបានយករទេះសេះដឹកយកយើងបញ្ជូនចេញពីទីនោះទៅកាន់កន្លែងដទៃ។ នៅពេលទៅដល់ ខ្ញុំបានឃើញប្រជាជនភូមិភាគនិរតីជាច្រើន ស្លៀកពាក់ឯកសណ្ឋានពណ៌ខ្មៅ និងក្រមាពណ៌ខៀវ-ស។ មានមនុស្សបួន-ប្រាំនាក់នៅទីនោះ។ អ្នកទាំងនោះបានកត់ឈ្មោះ តួនាទី និងភូមិឃុំរបស់យើង។ អ្នកទាំងនោះក៏បានចុះព័ត៌មាននោះនៅក្នុងសៀវភៅមួយក្បាល។ គេប្រាប់យើងកុំឱ្យភិតភ័យ។ យើងត្រូវនាំទៅចូលវគ្គអប់រំតែបួន-ប្រាំថ្ងៃប៉ុណ្ណោះ បន្ទាប់មកយើងនឹងអាចត្រឡប់ទៅវិញបាន។ យើងបានរង់ចាំរហូតដល់ពេលល្ងាច គឺនៅពេលមានឡានមួយមកដល់។ អ្នកទាំងនោះនិយាយថា អង្គការតម្រូវឱ្យចាប់ចងយើង ព្រោះខ្លាចថាយើងមានលាក់អាវុធ។ បន្ទាប់ពីចាប់យើងចង អ្នកទាំងនោះបានបោះយើងចូលទៅក្នុងឡាន។ ខ្ញុំមានការភិតភ័យ ពីព្រោះខ្ញុំដឹងថាខ្ញុំនឹងត្រូវគេយកទៅសម្លាប់។ ដូច្នេះហើយ ខ្ញុំបានព្យាយាមស្រាយចំណងចេញ។ ខ្មែរក្រហមមានបំណងចង់វាយខ្ញុំជាមួយនឹងស្នូកកាំភ្លើង ក៏ប៉ុន្តែម្នាក់និយាយថា ខ្ញុំគង់តែនឹងត្រូវសម្លាប់ អីចឹង គេគ្រាន់តែចងខ្សែបន្ថែមលើខ្លួនខ្ញុំទៅបានហើយ។ មនុស្សប្រមាណ៤០នាក់ស្ថិតនៅក្នុងឡាននោះ ដោយមានបួននាក់ជាស្ត្រី។ ឡានបានបរប្រមាណ១៥នាទីដើម្បីទៅដល់ទីតាំងសម្លាប់។ ពេលទៅដល់ ខ្មែរក្រហមយកមនុស្សចេញពីឡានម្នាក់ម្តងៗយកទៅ។ ពេលដល់វេនរបស់ខ្ញុំ ខ្មែរក្រហមយកខ្ញុំចេញពីឡាននិងបណ្តើរខ្ញុំទៅកាន់ទីតាំងសម្លាប់។ គេប្រាប់ឱ្យខ្ញុំអង្គុយចុះ ខ្ញុំក៏ធ្វើតាម។ ក្រោយមក គេវាយក្បាលខ្ញុំនឹងពូថៅ។ ខ្ញុំបានដួលទៅលើដី ហើយឈាមហូរស្រោចស្រព។ ខ្ញុំបាត់បង់ស្មារតី។ នៅពេលដែលខ្ញុំភ្ញាក់ដឹងខ្លួន មានសាកសពបី-បួននៅពីលើខ្លួនខ្ញុំ។ ខ្ញុំបានឃើញសាកសពជាច្រើននៅជុំវិញខ្លួន។ សាកសពខ្លះហើមនិងមានដង្កូវរុក។ ខ្ញុំព្យាយាមស្រាយខ្លួនចេញពីចំណង រួចខ្ញុំបានស្តាប់ឮទាហានខ្មែរក្រហម បញ្ជាមនុស្សឱ្យអង្គុយចុះរួចវាយក្បាលសម្លាប់អ្នកទាំងនោះ។ អ្នកខ្លះនៅក្នុងរណ្តៅ មិនទាន់ស្លាប់នៅឡើយ។ អ្នកទាំងនោះស្រែករកឪពុកម្តាយខ្លួន។ បន្ទាប់ពីទាហានបញ្ចប់ការវាយមនុស្សដែលត្រូវបាននាំមកកាន់ទីតាំងសម្លាប់ ទាហានក៏ស្រែកទៅកាន់អ្នកដែលនៅរស់ថា "ឯងនៅស្រែកធ្វើអី?" បន្ទាប់មក ទាហានក៏ចោលគ្រាប់បែកដៃទៅក្នុងរណ្តៅដើម្បីបញ្ចប់ជីវិតអ្នកទាំងអស់នោះ។ បន្ទាប់ពីគ្រាប់បែកផ្ទុះ មនុស្សមួយចំនួននៅរស់រាននៅឡើយ។ ដូច្នេះ ទាហានក៏បោះគ្រាប់បែកដៃមួយគ្រាប់ទៀតទៅក្នុងរណ្តៅ។ បន្ទាប់មកទីតាំងនោះប្រែជាស្ងប់ស្ងាត់។ ខ្ញុំគឺជាមនុស្សតែម្នាក់គត់ដែលរស់រានមានជីវិតចេញពីរណ្តៅនោះ។

## លោក ហ៊ឹម ម៉ាន៖ ដើមបណ្តឹងរដ្ឋប្បវេណី[៩៣] (ធ្វើសក្ខីកម្មនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥)

ប្រធានភូមិឈ្មោះ ថាំ បានប្រកាសថា ជនជាតិចាមត្រូវបានចាត់ទុកជាសត្រូវលេខមួយរបស់ខ្មែរក្រហម។ ខ្ញុំឆ្ងល់ថា ហេតុអ្វីបានជាប្រជាជនចាមត្រូវបានចាត់ទុកថាជាសត្រូវលេខមួយ។ ខ្ញុំមិនដឹងថា ហេតុអ្វីបានជាខ្មែរក្រហមចាត់ទុកជនជាតិចាមថាជាសត្រូវលេខមួយទេ។ ក្រោយមក ខ្ញុំសម្គាល់ឃើញថា ប្រជាជនចាមត្រូវបាននាំយកទៅនិងសម្លាប់ចោល។ នៅក្នុងអំឡុងជំនាន់ខ្មែរក្រហម ប្រជាជនចាមត្រូវបានបង្ខំឱ្យបរិភោគសាច់ជ្រូក ដែលចាត់ទុកថាជាសាច់មិនស្អាតនៅក្នុងសាសនាឥស្លាម។ សាសនាត្រូវបានបំផ្លាញ ហើយយើងត្រូវបានហាមឃាត់មិនឱ្យបន់ស្រន់ឬគោរពប្រណិប័តន៍សាសនាទេ។ ប្រជាជនចាមមិនហ៊ានទទួលកន្សែងរុំក្បាលឬបន់ស្រន់ទេ ថ្វីបើអ្នកខ្លះបានលួចបន់ស្រន់នៅពេលយប់ក៏ដោយ។ អ្នកទាំងនោះត្រូវតែប្រយ័ត្ន និងមិនត្រូវឱ្យខ្មែរក្រហមដឹងទេ។ យើងទទួលបានសាច់ជ្រូកហូប។ យើងត្រូវបានបញ្ជាឱ្យកាត់សក់ឱ្យខ្លី និងក្លាយខ្លួនជាផ្នែកនៃ "ប្រជាជាតិតែមួយ គឺប្រជាជាតិខ្មែរ"។ ក្រោយមក ស្ថានភាពកាន់តែអាក្រក់ទៅ។ ពុំចាំបាច់មានអ្នកនៅចាំទទួលបន្ទុកផ្នែកផ្ទះបាយទៀតទេ។ ប្រជាជនត្រូវធ្វើការធ្ងន់ធ្ងរដើម្បីទទួលបានការអាណិតអាសូរពីខ្មែរក្រហម។ ហេតុដូច្នេះហើយ គឺពុំចាំបាច់មានអ្នកនៅយាមផ្ទះបាយទៀតទេ។ ប្រជាជនទាំងអស់ សូម្បីតែប្រជាជនចាម បានរាយការណ៍អំពីជនជាតិចាមដទៃទៀត។ ពីមួយពេលទៅមួយពេល គ្រួសារចាមត្រូវបាននាំយកទៅជាបន្តបន្ទាប់។ ខ្ញុំមិនបានដឹងអំពីមូលហេតុនៃការបាត់ខ្លួនរបស់អ្នកទាំងនោះទេ។

ជំពូកទី១៧

# សេចក្តីបញ្ចប់

ឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺជាសោកនាដកម្មរបស់មនុស្សជាតិដ៏អាក្រក់បំផុតមួយ ក្នុងចំណោមសោកនាដកម្មទាំងឡាយក្នុងសតវត្សរ៍ទី២០។ របបនេះបានសម្លាប់ជីវិតមនុស្សអស់ប្រមាណជាងពីរលាននាក់ និងបានបន្សល់ទុកស្ត្រីមេម៉ាយ និងកុមារកំព្រារាប់រយពាន់នាក់។ ប្រជាជនខ្មែររាប់សែននាក់បានរត់ចេញពីប្រទេស ហើយបានក្លាយជាជនភៀសខ្លួន។ គ្រាប់មីនរាប់លានគ្រាប់ត្រូវបានបង្កប់ដោយយោធាខ្មែរក្រហម និងកងកម្លាំងរបស់រដ្ឋាភិបាល ដែលបានបណ្តាលឱ្យប្រជាជនរាប់ពាន់នាក់ស្លាប់ និងពិការចាប់តាំងពីទសវត្សឆ្នាំ១៩៨០រហូតមក។ ប្រជាពលរដ្ឋខ្មែរជាច្រើនមានបញ្ហាជំងឺផ្លូវចិត្ត ដោយសារតែការបាត់បង់សមាជិកគ្រួសារ ដែលធ្វើឱ្យប៉ះទង្គិចដល់ផ្លូវចិត្តយ៉ាងខ្លាំង។ កត្តាទាំងអស់នេះហើយ ជាឧបសគ្គដ៏ចម្បងមួយក្នុងការអភិវឌ្ឍប្រទេសកម្ពុជា។

មេដឹកនាំខ្មែរក្រហមទាំងអស់មានគំនិតជ្រុលនិយមហួសហេតុ ដែលខ្លួនទទួលយកពីមនោគមន៍វិជ្ជាកុម្មុយនីស្តរបស់ចិន វៀតណាម និងអតីតសហភាពសូវៀត។ មេដឹកនាំទាំងនេះបានបង្កើតឡើងនូវគោលនយោបាយជាច្រើនដែលប្រមាថដល់ជីវិតមនុស្ស បានធ្វើទុក្ខបុកម្នេញ និងសម្លាប់រង្គាលប្រជាជនយ៉ាងច្រើនសន្ធឹកសន្ធាប់។ មេដឹកនាំខ្មែរក្រហមទាំងនេះយល់ឃើញថា បដិវត្តន៍របស់ខ្លួន គឺជាផ្លូវតែមួយគត់ដែលអាចនាំយកកម្ពុជាទៅកាន់ឯករាជ្យភាពនិងសមភាពសង្គម។ ទោះបីជាខ្លួនបានចម្លងតាមមនោគមន៍វិជ្ជារបស់អតីតសហភាពសូវៀតនិងចិន ដូចជា សមូហភាវូបនីយកម្ម ការជម្លៀសប្រជាជនចេញពីទីក្រុងនិងទីប្រជុំជន ផែនការបួនឆ្នាំ និងបដិវត្តន៍មហាលោតផ្លោះមហាអស្ចារ្យជាដើមក៏ដោយ ក៏មេដឹកនាំទាំងនេះបានអះអាងថា បដិវត្តន៍របស់ខ្លួនមិនបានយកគំរូតាមមនោគមន៍វិជ្ជាខាងក្រៅណាមួយទេ។

ខ្មែរក្រហមមិនឱ្យតម្លៃទៅលើការសិក្សាតាមសាលារៀនទេ។ មានតែមេដឹកនាំមួយចំនួនតូចប៉ុណ្ណោះ ដែលមានកម្រិតវប្បធម៌ខ្ពស់ ហើយក្រៅពីនេះសុទ្ធតែជាមនុស្សដែលគ្មានបទពិសោធន៍ក្នុងការដឹកនាំរដ្ឋ។ កម្មាភិបាលថ្នាក់ក្រោមភាគច្រើន ជាមនុស្សមិនចេះអក្សរ ឬចេះអាននិងសរសេរបន្តិចបន្តួច។ ទោះបីជាមានឧបសគ្គយ៉ាងនេះក៏ដោយ ខ្មែរក្រហមតែងតែមានមហិច្ឆតាចង់សម្រេចកិច្ចការធំក្នុងរយៈពេលដ៏ខ្លី ដោយមិនបានពិចារណាអំពីធនធានដែលមាន ឬលទ្ធផលដែលបានមកពីគោលនយោបាយទាំងនេះឡើយ។ ក្នុងន័យនេះ ខ្មែរក្រហមបានប្រែក្លាយប្រទេសទាំងមូលទៅជាវាលស្រែ ហើយប្រែក្លាយប្រជាជនទាំងអស់ឱ្យទៅជាកសិករនិងជាអ្នកទោសរបស់អង្គការ។

សិទ្ធិនិងតម្រូវការជាមូលដ្ឋានរបស់ប្រជាជនមិនត្រូវបានយកចិត្តទុកដាក់ទេ។ ទ្រព្យសម្បត្តិឯកជន ត្រូវបានរឹបអូស។ ជំនឿសាសនា រូបបិយប័ណ្ណនិងប្រពៃណីទំនៀមទម្លាប់ បានក្លាយទៅជារបស់ឥតប្រយោជន៍។ ទំនាក់ទំនងជាមួយអន្តរជាតិស្ទើរតែត្រូវបានកាត់ផ្តាច់ទាំងស្រុង។ របបនេះមិនអនុញ្ញាតឱ្យមានការរិះគន់ចំពោះថ្នាក់ដឹកនាំឬគោលនយោបាយរបស់ជាតិឡើយ សូម្បីតែបន្តិចបន្តួចក៏ដោយ។ ខ្មែរក្រហមបានចាត់ទុកអ្នកចេះដឹង អ្នករដ្ឋការនៃរបបចាស់និងអ្នកដែលប្រឆាំងនឹងនយោបាយរបស់ខ្លួន ជាសត្រូវរបស់រដ្ឋឬជាជនក្បត់បដិវត្តន៍ដែលត្រូវតែកម្ទេចចោល។ មិនមានការលើកលែងទោស ហើយក៏មិនមានការផ្សះផ្សាជាតិដែរនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ខ្មែរក្រហមបានប្រែក្លាយប្រទេសឱ្យទៅជាជំរំឃុំឃាំងដ៏ធំមួយ ដែលក្រោយមកបានក្លាយទៅជាផ្នូររបស់ប្រជាជនខ្មែរជាងពីរលាននាក់ ដែលរួមបញ្ចូលទាំងកម្មាភិបាលនិងថ្នាក់ដឹកនាំជាន់ខ្ពស់របស់ខ្លួនមួយចំនួនផង។

នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងកម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដោយមានជំនួយពីកងទ័ពស្ម័គ្រចិត្តវៀតណាមបានចូលមកកាន់កាប់រាជធានីភ្នំពេញ និងបានបញ្ចប់របបគ្រប់គ្រងរបស់ខ្មែរក្រហមដែលត្រូវបានស្គាល់ថាជារបបកម្ពុជាប្រជាធិបតេយ្យ។ ខណៈដែលមិនអាចបន្តគ្រប់គ្រងប្រទេសតទៅទៀតបាន ខ្មែរក្រហម នៅតែបន្តចលនាតស៊ូក្នុងនាមជាចលនាទ័ពព្រៃអស់ជាងមួយទសវត្សរ៍បន្តទៀត។ ត្រឹមឆ្នាំ១៩៩៩ មេដឹកនាំខ្មែរក្រហមដែលនៅរស់រានមានជីវិតបានចុះចូល ឬ ត្រូវបានឃាត់ខ្លួន ហើយចលនាតស៊ូនោះត្រូវបានដួលរលំទាំងស្រុង។ ប្រជាជនដែលរស់នៅតាមតំបន់កាន់កាប់ដោយខ្មែរក្រហម បានរួមបញ្ចូល និងរួបរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា។

នៅឆ្នាំ១៩៩៧ រដ្ឋាភិបាលកម្ពុជាបានស្នើសុំជំនួយពីអង្គការសហប្រជាជាតិ ក្នុងគោលបំណងបង្កើតជាតុលាការមួយដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម។ នៅក្នុងឆ្នាំ១៩៩៨ អង្គការសហប្រជាជាតិបានបញ្ជូនក្រុមអ្នកជំនាញមួយក្រុម ដើម្បីកំណត់ពីសណ្ឋាននៃបទឧក្រិដ្ឋដែលកើតមាននៅក្នុងអំឡុងរបបខ្មែរក្រហម។ ក្រុមអ្នកជំនាញបានប្រមែប្រមូលភ័ស្តុតាងនិងសក្ខីកម្មពីសាក្សីបានគ្រប់គ្រាន់ដើម្បីផ្តល់ជាអនុសាសន៍ក្នុងការបង្កើតជាយន្តការកាត់ទោសលើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម។ ក្រុមអ្នកជំនាញបានផ្តល់ជាអនុសាសន៍ដល់អង្គការសហប្រជាជាតិឱ្យចាត់តាំងតុលាការអន្តរជាតិពិសេសមួយ ដើម្បីស៊ើបអង្កេតនិងកាត់ទោសពីបទប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

នៅឆ្នាំ២០០១ រដ្ឋសភាជាតិកម្ពុជា បានអនុម័តច្បាប់មួយក្នុងការបង្កើតតុលាការក្នុងស្រុក ហៅថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលនឹងទទួលខុសត្រូវលើការកាត់ទោសបុគ្គលដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ នៅក្នុងឆ្នាំ២០០៣ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានព្រមព្រៀងគ្នាថា តើសហគមន៍អន្តរជាតិគួរជួយនិងចូលរួមនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាយ៉ាងដូចម្តេចខ្លះ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាតុលាការកម្ពុជាដែលបង្កើតឡើងក្រោមច្បាប់កម្ពុជានិងមានការចូលរួមនិងជំនួយពីអង្គការសហប្រជាជាតិ។ តុលាការនេះនឹងប្រព្រឹត្តទៅដោយឯករាជ្យពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ក៏ប៉ុន្តែនឹងប្រើប្រាស់បទដ្ឋានអន្តរជាតិសម្រាប់យុត្តិធម៌ ព្រមទាំងរួមបញ្ចូលនូវតុលាការកម្ពុជានិងតុលាការអន្តរជាតិ មន្ត្រីផ្នែកច្បាប់ និងបុគ្គលិករដ្ឋបាល។

មន្ត្រីនៃការិយាល័យសហចៅក្រមស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានធ្វើការស៊ើបអង្កេតលើបុគ្គល ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងឧក្រិដ្ឋកម្មដទៃទៀតស្ថិតក្រោយយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ការស៊ើបអង្កេត ត្រូវបានរៀបចំឡើងក្នុងសំណុំរឿងចំនួន៤៖ សំណុំរឿង០០១ សំណុំរឿង០០២ សំណុំរឿង០០៣ និងសំណុំរឿង០០៤។

ក្នុងសំណុំរឿង០០១ កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រូវជាប់ពិរុទ្ធភាព ចំពោះតួនាទីរបស់ខ្លួនក្នុងការប្រព្រឹត្តអំពើឃោរឃៅនៅមន្ទីរសន្តិសុខស-២១។ ជាពិសេស ឌុច ត្រូវបានដាក់ឱ្យជាប់ពន្ធនាគារអស់មួយជីវិតពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩។ ក្នុងសំណុំរឿង០០២វគ្គ០១ នួន ជា និង ខៀវ សំផន ក៏ត្រូវបានដាក់ទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិត ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈការសម្លាប់រង្គាល (ការសម្លាប់ទ្រង់ទ្រាយធំ) ការសម្លាប់ផ្អែកលើហេតុផលនយោបាយ និងអំពើអមនុស្សធម៌ដទៃទៀត (រួមមាន ការជម្លៀសដោយបង្ខំ ការជំរុញឱ្យប្រជាជនបាត់ខ្លួន និងការវាយប្រហារប្រឆាំងនឹងកិត្តិយសរបស់មនុស្ស)។

សំណុំរឿង០០២/០២ បានបញ្ចប់ដំណើរការវិនិច្ឆ័យនៅអង្គជំនុំជម្រះសាលាដំបូង លើ នួន ជា និង ខៀវ សំផន ដែលអ្នកទាំងពីរត្រូវបានជាប់ទោសពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩។ យ៉ាងណាមិញ នៅឆ្នាំ២០១៩ នួន ជា បានស្លាប់ដោយជរាភាព ហើយតុលាការកំពូលក៏មិនបានវិនិច្ឆ័យនិងសម្រេចឱ្យបញ្ចប់លើបណ្តឹងរបស់ ខៀវ សំផន ក្នុងសំណុំរឿង០០២វគ្គ០២ ឬតុលាការអាចបញ្ចប់ការវិនិច្ឆ័យទោសនៅត្រឹមអង្គជំនុំជម្រះសាលាដំបូងចំពោះសំណុំរឿងនេះ ដោយសារតែមានការជាប់ពាក់ព័ន្ធទៅនឹង នួន ជា។

# វិន័យសម្រាប់អ្នកយាមនៅមន្ទីរស-២១

## ១. អំពីវិន័យការពារខ្មាំង

- ពេលយាម មិនឱ្យអង្គុយ ឬផ្អែក និងមិនឱ្យសរសេរអ្វីទាំងអស់ ត្រូវដើរចុះឡើងតាមមុខសញ្ញារបស់ខ្លួន។
- ពេលយាម មិនឱ្យសួរឈ្មោះខ្មាំងដាច់ខាត នៅក្នុងបន្ទប់ ឬក្នុងផ្ទះ។
- ពេលយាម មិត្តណាមានភារកិច្ចយាម មិនឱ្យដើរចោលកន្លែងយាម។ ពេលយាម មិនឱ្យមិត្តណាគ្មានភារកិច្ចយាម ចូលលុកលុយ បើកទ្វារឬបង្អួច មើលអ្នកទោសដាច់ខាត។
- ចំពោះអ្នកទោសដែលជាប់ឃុំឃាំង បើទោះស្គាល់ឬមិនស្គាល់ មិនឱ្យសាកសួរជាដាច់ខាត។
- ចំពោះខ្មាំងដែលជាប់នៅកន្លែងយើង មិនអនុញ្ញាតឱ្យសំឡុតឬវាយដាច់ខាត។ បើខ្មាំងសេរី អ្នកយាមនិយាយមិនស្តាប់ ស្នើរាយការណ៍ជាបន្ទាន់ឱ្យអ្នកទទួលខុសត្រូវជាផ្ទាល់ឬជាក្រដាស។
- បើខ្មាំងវាមានសកម្មភាពវាយសោ ចាក់សោ ចងក អារក អារដៃ បម្រុងនឹងលេបខ្មៅ និងមានប្រតិកម្មផ្សេងៗ ត្រូវមានវិធានការជាបន្ទាន់ ដាក់ខ្នោះដៃមកក្រោយ ហើយរាយការណ៍ ឱ្យអ្នកទទួលខុសត្រូវជាបន្ទាន់ដែរ។
- ពេលខ្មាំងរត់រួច ត្រូវរាយការណ៍ជាបន្ទាន់ ត្រូវតាមចាប់ភ្លាម មានវិធានការភ្លាម។
- ពេលយាមល្បាតការពារ កម្មាភិបាលក្រុមកងហា ត្រូវមានមុខនៅកន្លែងយាមតាមមុខសញ្ញា របស់ខ្លួនដែលបក្សប្រគល់ឱ្យ។
- ពេលយាម កម្មាភិបាលមិនឱ្យលួចដេក ឬអង្គុយផ្អែក ត្រូវដើរត្រួតពិនិត្យឱ្យជាប់ជាប្រចាំ។
- ពេលយាម កម្មាភិបាលនិងយុទ្ធជនត្រូវឆែកឆេរគ្រប់ពេលវេលា តាមការកំណត់ឱ្យបានដាច់ខាត គឺ២៤ម៉ោង ឆែកបួនដងជាកំហិត គឺ ៖ ព្រឹកពេលម៉ោង៦ម្តង ម៉ោង១១ថ្ងៃត្រង់ម្តង ទៀត ល្ងាចម៉ោង៦ម្តង និងយប់ម៉ោង១១ ម្តងទៀត។
- ពេលឆែកដោះខោអាវវាហើយ ត្រូវឱ្យវាស្លៀកពាក់វិញ ទើបអ្នកឆែកចេញពីបន្ទប់។
- ចំពោះខោអាវខ្មាំង ត្រូវឱ្យវាស្លៀកពាក់ទាំងអស់ មិនឱ្យដោះចេញពីខ្លួនឡើយ។
- ពេលយាមល្បាត កម្មាភិបាលត្រូវកាន់កូនសោដោយខ្លួនឯង មិនបណ្តែតបណ្តោយតាម ចិត្តខ្លួនខ្ជិល។ ដាច់ខាត មិនឱ្យបាត់កូនសោបើបាត់កូនសោ មិនត្រូវអារទេ ត្រូវរកកូន ឱ្យឃើញ ហើយត្រូវរាយការណ៍ អ្នកទោសរត់រួច កន្លែងបាត់កូនសោ ត្រូវទទួលខុសត្រូវ ចំពោះសមូហភាព។
- ពេលយាម ត្រូវស្លៀកពាក់ជាឯកសណ្ឋានយោធា មិនអនុញ្ញាតឱ្យស្លៀកខោខ្លីឬដោះអាវ។

## ២. អំពីសោខ្នោះ

- ចាក់សោខ្មាំង ត្រូវពិនិត្យសោ កង រនង ឱ្យបានល្អិត ទើបដោះខ្នោះដៃ ស្រាយមុខ។
- ពេលចាក់សោខ្មាំង កង រនង ត្រូវយកចេញពីក្នុងបន្ទប់មកទុកខាងក្រៅ មិនត្រូវឱ្យទុកខាងក្នុងទេ។
- ចាក់សោខ្មាំងយកមកចាក់អាចម៍ ត្រូវដាក់ច្រវាក់ដៃម្ខាងនិងជើងម្ខាងទៀត យើងមិនត្រូវដើរឆ្ងាយពីខ្មាំងទេ។
- ខ្មាំងដែលយកមកពីកន្លែងសួរចម្លើយវិញ ត្រូវឆែកឆេរខ្លួនវាឱ្យបានមធ្យ័ត និងនៅពេលប្តូរយាម ទាំងកង រនង។
- ច្រវាក់ត្រូវចាក់ឱ្យខ្លី យ៉ាងវែងកន្លះម៉ែត្រ បើករណីពិសេស ត្រូវខាងលើសម្រេច។

## ៣. ខាងវិធានការ

- ខ្មាំងវានៅតាមផ្ទះ មិនឱ្យវាទាក់ទងគ្នាបានទេ។
- ខ្មាំងដែលនៅកន្លែងយើង គឺដាច់ខាតមិនឱ្យវានិយាយគ្នា។
- ចំពោះអ្នកដែលមានភារកិច្ចខាងក្នុងគឺដាច់ខាតមិនអនុញ្ញាតឱ្យដើរចេញមកក្រៅទេ ប្រយ័ត្នខ្មាំង វាទាក់ទងគ្នាបាន ឬខ្មាំងវាមានប្រតិកម្មផ្សេងៗ។
- នៅតាមផ្ទះនីមួយៗ ត្រូវមានបញ្ជីឈ្មោះខ្មាំងនិងលេខបន្ទប់។
- ចំពោះអាវុធ ពេលយាមត្រូវដោះគ្រាប់ចេញពីបង់ដែលជាប់អាវុធ តែចំពោះបង់ដែលជាប់នឹងកាសេតត្រូវមានគ្រាប់ពេញ។
- អ្នកយាមជាប់ជាមួយខ្មាំងខាងក្នុងមិនឱ្យកាន់អាវុធ អនុញ្ញាតឱ្យកាន់ដំបង។
- អាវុធត្រូវមានអ្នកកាន់ច្បាស់លាស់។
- មិនត្រូវទុកអាវុធចោល ត្រូវកាន់ជាប់នឹងខ្លួន។
- មិនត្រូវទុកអាវុធនៅក្បែរខ្មាំង ឬស្ពាយអាវុធទៅឈរជិតខ្មាំង។
- ប្តូរយាមត្រូវប្រគល់ភារកិច្ចច្បាស់លាស់ និងរាយការណ៍ពីសភាពការណ៍អ្នកទោស និងសភាពការណ៍ផ្សេងៗទៀតឱ្យទៅអ្នកយាមថ្មី។
- ពេលប្តូរយាម ទើបអនុញ្ញាតឱ្យយកធុងអាចម៍និងធុងនោម និងឆែកឆេរ។ ភារកិច្ចនេះ អ្នកប្តូរយាមបំពេញ ហើយអ្នកយាមចាស់មិនទាន់ឱ្យទៅណាទេ ទាល់តែអ្នកប្តូរយាមបំពេញភារកិច្ចខ្លួនជាដំបូងនេះហើយ។

# ឯកសារយោង

## សន្ទានុក្រម

១ សម្តេចព្រះ នរោត្តម សីហនុ បានធ្វើសេចក្តីថ្លែងការណ៍មួយចំនួនទាក់ទងទៅនឹងវត្តមានរបស់ក្រុមខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា។ ក្នុងចំណោមសេចក្តីថ្លែងការណ៍ទាំងនោះ សេចក្តីថ្លែងការណ៍មួយមានចំណងជើងថា «ព្រះសារលិខិតនៃសម្តេចសហជីវិន ព្រះប្រមុខរដ្ឋ ទ្រង់ថ្លែងទៅកាន់សភាទាំងពីរ» ដែលនៅក្នុងសេចក្តីថ្លែងការណ៍នេះ ព្រះអង្គបានប្រើពាក្យ «ខ្មែរក្រហម» សំដៅទៅក្រុមកុម្មុយនីស្តដែលប្រឆាំងនឹងព្រះអង្គ។ សេចក្តីថ្លែងការណ៍នេះចេញផ្សាយដោយទស្សនាវដ្តីអ្នកជាតិនិយម លេខចេញផ្សាយថ្ងៃទី២៣ តុលា ១៩៦៧។ ឯកសារបណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា លេខD42188។

២ ការកំណត់តួលេខអំពីចំនួនប្រជាជនកម្ពុជា ដែលបានស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានភាពខុសៗគ្នា។ តាមរយៈការស្រង់ស្ថិតិតាមផ្ទះទូទាំងប្រទេស របបសាធារណរដ្ឋប្រជាមានិតកម្ពុជា(១៩៧៩-១៩៨៩)បានអះអាងថា ប្រជាជន កម្ពុជាជាង៣លាន៣សែននាក់បានស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងសៀវភៅ «របប ប៉ុល ពត៖ ពូជសាសន៍ អំណាច និងអំពើប្រល័យពូជសាសន៍នៅកម្ពុជាក្រោមរបបខ្មែរក្រហមឆ្នាំ១៩៧៥-១៩៧៩ (បោះពុម្ពដោយសាកលវិទ្យាល័យ យែល នៅរដ្ឋញូហេវែន និងក្រុងឡុងឆ្នាំ១៩៩៦) ប្រវត្តិវិទូ ប៊ែន គៀរនិន បានប៉ាន់ស្មានថាមានមនុស្សចំនួន១លាន៥សែននាក់បានស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ការកំណត់ចំនួនមនុស្សស្លាប់របស់គាត់ផ្អែកទៅលើបទសម្ភាសន៍ជាមួយប្រជាជន៥០០នាក់ ដែល១០០នាក់ជាជនភៀសខ្លួននៅប្រទេសបារាំងក្នុងឆ្នាំ១៩៧៩ និង៤០០នាក់ទៀតជាប្រជាជននៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ១៩៨០។ ក្រោយមក ប្រវត្តិវិទូ ប៊ែន គៀរនិន បាននិយាយថា យោងតាមការគណនារបស់អ្នកប្រជាសាស្ត្រ ចំនួនប្រជាជនដែលស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺមានក្នុងចន្លោះ១លាន៧សែននាក់។ ទីភ្នាក់ងារស៊ើបការសម្ងាត់សហរដ្ឋអាមេរិក សេ.អ៊ី.អា. នៅក្នុងរបាយការណ៍មួយដែលមានចំណងជើងថា "កម្ពុជា ៖ ការបាត់បង់ចំនួនប្រជាជន" (លេខចេញផ្សាយខែឧសភា ឆ្នាំ១៩៨០) បានសន្និដ្ឋានថាប្រជាជនកម្ពុជាប្រមាណ១លាន៤សែននាក់បានស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អ្នកស្រាវជ្រាវជាន់ខ្ពស់ ម៉ៃឃើល វីកឃឺរី នៅក្នុងសៀវភៅរបស់គាត់ដែលមានចំណងជើងថា "កម្ពុជាពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៨២" (បោះពុម្ពនៅអូអេសព្រីនធីងហៅ ទីក្រុងបាងកក ឆ្នាំ១៩៩៨) បានអះអាងថា ប្រជាជនខ្មែរដែលស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានចំនួនប្រហែល៧៤០ ០០០នាក់។ ការសិក្សារបស់គាត់ ផ្អែកទៅលើការស្រង់ចំនួនប្រជាជនឡើងវិញ ដោយប្រៀបធៀបចំនួនប្រជាជនមុនឆ្នាំ១៩៧៥ និងចំនួនប្រជាជនក្រោយឆ្នាំ១៩៧៩ ហើយដកចំនួនមនុស្សស្លាប់តាមធម្មជាតិ ពីចំនួនមនុស្សស្លាប់សរុប។

៣ ឧបទ្វីបឥណ្ឌូចិនគឺជាឈ្មោះដែលអាណានិគមបារាំងដាក់ឱ្យប្រទេសបីដែលខ្លួនត្រួតត្រា រួមមានប្រទេសវៀតណាម ប្រទេសឡាវ និងប្រទេសកម្ពុជា។ សង្គ្រាមឥណ្ឌូចិនលើកទីមួយបានចាប់ផ្តើមពីឆ្នាំ១៩៤៦ដល់ឆ្នាំ១៩៥៤ រវាងបារាំងនិងចលនាតស៊ូវៀតណាម(វៀតមិញ)ដឹកនាំដោយ ហូ ជីមិញ។ ជម្លោះនេះបានរីករាលដាលលើផ្ទៃប្រទេសទាំងមូល ហើយបានរាលដាលដល់ប្រទេសកម្ពុជានិងប្រទេសឡាវ។

៤ បក្សនេះត្រូវបានបង្កើតឡើងដោយ ហូ ជីមិញ នៅពេលដែលគាត់កំពុងរស់នៅទីក្រុងហុងកុង។ មុនដំបូង បក្សនេះមានឈ្មោះថាបក្សកុម្មុយនីស្តវៀតណាម ហើយឈ្មោះនេះត្រូវបានប្តូរមកជាបក្សកុម្មុយនីស្តឥណ្ឌូចិននៅ ខែកុម្ភៈ ឆ្នាំ១៩៣០។

៥ នៅឆ្នាំ១៩៥១ ដើម្បីពង្រឹងចលនាតស៊ូប្រឆាំងនឹងអាណានិគមបារាំងឱ្យកាន់តែខ្លាំងក្លាថែមទៀត និងទទួលបានការគាំទ្រពីប្រជាជន វៀតណាមបានបំបែកបក្សកុម្មុយនីស្តឥណ្ឌូចិនជាបីបក្ស ដែលតំណាងឱ្យប្រទេសទាំងបីក្នុងឧបទ្វីបឥណ្ឌូចិន រួមមាន៖ បក្សពលករវៀតណាម បក្សប្រជាជនបដិវត្តន៍ខ្មែរ និងបក្សប្រជាជនបដិវត្តន៍ឡាវ។ ទោះជាយ៉ាងនេះក្តី ចលនាតស៊ូក្នុងប្រទេសទាំងបីស្ថិតក្រោមការគ្រប់គ្រងរបស់វៀតណាមដដែល។

៦ រណសិរ្សរួបរួមដើម្បីឯករាជ្យនៅវៀតណាម ហៅកាត់ថា "វៀតមិញ" ត្រូវបានបង្កើតឡើងដោយ ហូ ជីមិញ នៅឆ្នាំ១៩៤១ ដើម្បីទាមទារឯករាជ្យពីបារាំង។

៧ កិច្ចព្រមព្រៀងនេះត្រូវបានតាក់តែងឡើងនៅឯសន្និសីទទីក្រុងហ្សឺណែវឆ្នាំ១៩៥៤ ដែលបានបញ្ចប់ជម្លោះនិងនាំមកវិញនូវសន្តិភាពក្នុងឧបទ្វីបឥណ្ឌូចិន។

៨ មិនទាន់មានឯកសារណាមួយបញ្ជាក់ឱ្យបានច្បាស់លាស់អំពីមូលហេតុនៃការបាត់ខ្លួនរបស់ ទូ សាមុត នៅឡើយទេ។

៩ ឯកសារលេខ D24008 តម្កល់នៅបណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា មានចំណងជើង «សមាសភាពសមាជិកគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា»។ ឯកសារនេះបង្ហាញពីសមាសភាពសមាជិកគណៈរដ្ឋមន្ត្រីមួយចំនួន រួមមាន ៖ សម្តេច ប៉ែន នុត (នាយករដ្ឋមន្ត្រី), ខៀវ សំផន (ឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងការពារជាតិ), សារិន ឆាក (រដ្ឋមន្ត្រីក្រសួងការបរទេស), ហ៊ូ យន់ (រដ្ឋមន្ត្រីក្រសួងមហាផ្ទៃទទួលបន្ទុករៀបចំជនបទនិងសហករណ៍), ហ៊ូ នឹម (រដ្ឋមន្ត្រីក្រសួងព័ត៌មាននិងឃោសនាការ), ថៅ សេង (រដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស), ចាន់ យូរ៉ាន់ (រដ្ឋមន្ត្រីក្រសួងអប់រំជាតិនិងយុវជន), ង៉ោ ហ៊ូ (រដ្ឋមន្ត្រីក្រសួងសុខាភិបាល កិច្ចការសាសនា និងសង្គមកិច្ច), ដួន មុំ (រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនិងហិរញ្ញវត្ថុ), ឧត្តមសេនីយ៍ ដួង សំអុល (រដ្ឋមន្ត្រីទទួលបន្ទុកកស្ទុភារយោធានិងគ្រឿងសព្វាវុធ), ហួត សម្បត្តិ (រដ្ឋមន្ត្រីក្រសួងសាធារណការទូរគមនាគមន៍ និងសាងសង់), ជា សាន (រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌និងកំណែទម្រង់តុលាការ), គាត ឈន់ (រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី), ដួន ប្រសិទ្ធ (រដ្ឋមន្ត្រីទទួលបន្ទុកសម្របសម្រួលការខិតខំប្រឹងប្រែងតស៊ូដើម្បីរំដោះជាតិ), ព្រះអង្គម្ចាស់ នរោត្តម ភូរិស្សារា (រដ្ឋមន្ត្រីកិត្តិយស), គង់ សុផល (អនុរដ្ឋមន្ត្រីក្រសួងការពារជាតិ), ប៉ុក ដឹសកុមារ (អនុរដ្ឋមន្ត្រីក្រសួងការបរទេស), វ៉ាន់ ពីនី (អនុរដ្ឋមន្ត្រីក្រសួងការបរទេស), សុក ធួក (អនុរដ្ឋមន្ត្រីក្រសួងមហាផ្ទៃទទួលបន្ទុករៀបចំជនបទនិង សហករណ៍), ទីវ អុល (អនុរដ្ឋមន្ត្រីក្រសួងព័ត៌មាននិងឃោសនាការ), អៀង ធីរិទ្ធ (អនុរដ្ឋមន្ត្រីក្រសួងអប់រំ ជាតិនិងយុវជន), ជូ ជេត (អនុរដ្ឋមន្ត្រីក្រសួងសុខាភិបាល កិច្ចការសាសនា និង សង្គមកិច្ច), និង កុយ ធួន (អនុរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)។ ស្ទើរតែគ្រប់សមាជិកគណៈរដ្ឋមន្ត្រីទាំងនេះមានតែឈ្មោះប៉ុណ្ណោះ។ អ្នកដែលមានសិទ្ធិសម្រេចកិច្ចការគ្រប់បែបយ៉ាងគឺគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាដែលមាន ប៉ុល ពត ជាលេខា និង នួន ជា ជាអនុលេខា។

១០ ខ្មែរហាណូយ គឺជាជនជាតិខ្មែរដែលធ្លាប់រស់នៅក្នុងប្រទេសវៀតណាមតាំងពីទសវត្សរ៍ឆ្នាំ១៩៥០។ អ្នកទាំងនេះបានវិលត្រឡប់មកកម្ពុជាវិញក្នុងអំឡុងពេលសង្គ្រាម (១៩៧០-១៩៧៥) ដើម្បីជួយខ្មែរក្រហមក្នុងការប្រយុទ្ធប្រឆាំងជាមួយរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ។

១១ មុនទទួលបានជ័យជម្នះ ខ្មែរក្រហមបានប្រកាសថា ខ្លួននឹងធ្វើការប្រហារជីវិតមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល លន់ នល់ តែប្រាំពីររូបប៉ុណ្ណោះ ដែលខ្មែរក្រហមហៅថា "មហាជនក្បត់"។ អ្នកទាំងនេះរួមមាន ប្រធានាធិបតី លន់ នល់, ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ, នាយករដ្ឋមន្ត្រី ឡុង បូរ៉េត, ចេង ហេង, អ៊ិន តាំ, សូស្តែន ហ្វែណង់ដេស, និង សឺន ង៉ុកថាញ់។

១២ មជ្ឈមណ្ឌលឯកសារកម្ពុជា។ "មន្ទីរ៨៧០៖ សេចក្តីណែនាំអំពីការប្រើពាក្យអង្គការ និងពាក្យបក្ស" ចេញផ្សាយថ្ងៃទីទី១១ ខែកក្កដា ឆ្នាំ១៩៧៧, ឯកសារលេខ D០១២៦៦។ «ពាក្យអង្គការ ឬពាក្យបក្ស» ប្រើតែចំពោះតែអង្គការចាត់តាំងប៉ុណ្ណោះ មិនត្រូវប្រើសម្រាប់បុគ្គលឡើយ។ ចំពោះបុគ្គល ត្រូវប្រើពាក្យសមមិត្តឈ្មោះនេះ ឬសមមិត្តតំណែងនេះ ឬសមមិត្តតំណាងអង្គការថ្នាក់នេះ។ ឧទាហរណ៍ សមមិត្ត តេង សមមិត្តលេខា សមមិត្តតំណាងអង្គការ។ល។"

១៣ ណាយ៉ាន់ ចាន់ដា, "សត្រូវបងប្អូនឯង៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម" បោះពុម្ពដោយរោងពុម្ព Macmillan នៅក្រុងញូយក ឆ្នាំ១៩៨៦។

១៤ ណាយ៉ាន់ ចាន់ដា បានកត់ត្រាថា នៅថ្ងៃទី២ ខែមករា ឆ្នាំ១៩៧៩ កងកុម្ម៉ង់ដូវៀតណាម បានឆ្លងកាត់ទន្លេចតុមុខក្បែរព្រះបរមរាជវាំង ដើម្បីចាប់ពង្រត់សម្តេចព្រះ នរោត្តម សីហនុយកទៅវៀតណាម ដើម្បីឱ្យព្រះអង្គដឹកនាំចលនាតស៊ូមួយក្រោមការជួយទំនុកបម្រុងរបស់វៀតណាម ប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ។ ប៉ុន្តែផែនការនេះត្រូវបរាជ័យ។ នៅថ្ងៃនោះដែរ ដោយសារសភាពការណ៍ដែលវៀតណាមវាយចូលកម្ពុជាកាន់តែមានសភាពធ្ងន់ធ្ងរនោះ ខៀវ សំផន បានជម្លៀសព្រះអង្គទៅកាន់ស្រុកស៊ីសុផុន ក្បែរព្រំដែនខ្មែរ-ថៃ។ ពីរថ្ងៃក្រោយមក ខៀវ សំផន បានទៅយាងព្រះអង្គចូលមកទីក្រុងភ្នំពេញវិញ ដោយនិយាយថា វៀតណាមបានដកថយវិញហើយ។ ថ្ងៃទី៥ ខែមករា ប៉ុល ពត បានយាងព្រះអង្គទៅជួបប្រជុំក្នុងគោលបំណងស្នើរសុំព្រះអង្គឱ្យធ្វើជាតំណាងរបស់កម្ពុជាប្រជាធិបតេយ្យនៅអង្គការសហប្រជាជាតិ ដើម្បីទាមទារការគាំទ្ររបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិប្រឆាំងនឹងការលុកលុយរបស់វៀតណាម។ ជាថ្នូរនឹងកិច្ចការដ៏មានសារសំខាន់នេះ ប៉ុល ពត យល់ព្រមអនុញ្ញាតឱ្យព្រះរាជវង្សានុវង្សទាំងអស់ចាកចេញពីកម្ពុជាជាមួយព្រះអង្គដែរ ទោះបីជាមានការជំទាស់ពី អៀង សារី ដែលចង់ទុកព្រះរាជវង្សានុវង្សទាំងអស់នៅក្នុងប្រទេសជាចំណាប់ខ្មាំងក៏ដោយ។ សម្តេចព្រះ នរោត្តម សីហនុ និងព្រះរាជវង្សានុវង្សរបស់ព្រះអង្គ បានចាកចេញឆ្ពោះទៅកាន់ប្រទេសចិនតាមជើងហោះហើររបស់ចិន នៅថ្ងៃទី៦ ខែមករា។

១៥ មជ្ឈមណ្ឌលឯកសារកម្ពុជា។ «សម័យប្រជុំសភាលើកដំបូងរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជនកម្ពុជា», ថ្ងៃទី១១-១៣ ខែមេសា ឆ្នាំ១៩៧៦, ឯកសារលេខ D២១២២៧។ គណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជនកម្ពុជារួមមាន ៖ នួន ជា (ប្រធាន), ងួន កង (អនុប្រធានទី១), ពៅ ស៊ូ (អុនប្រធានទី២) និង រស់ នឹម, ស ស៊ាន, ម៉ី ឆាំ, ខេង សុខ, ម៉ាត់ លី, ថង ស៊ី, និង រស់ ព្រាប (ជាសមាជិក)។ គណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យរួមមាន ៖ ខៀវ សំផន (ប្រធាន), សោ ភឹម (អនុប្រធានទី១) និង ញឹម រស់ (អនុប្រធានទី២)។ សមាសភាពសមាជិករដ្ឋាភិបាលកម្ពុជាប្រជា ធិបតេយ្យរួមមាន ៖ ប៉ុល ពត (នាយករដ្ឋមន្ត្រី), អៀង សារី (ឧបនាយករដ្ឋមន្ត្រីទី១និងជារដ្ឋមន្ត្រីក្រសួង ការបរទេស), វន វេត (ឧបនាយករដ្ឋមន្ត្រីទី២និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច), សុន សេន (ឧបនាយករដ្ឋមន្ត្រី ទី៣និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ), ហ៊ូ នឹម (រដ្ឋមន្ត្រីក្រសួងឃោសនាការនិងព័ត៌មាន), ជួន ជឿន (រដ្ឋមន្ត្រី ក្រសួងសុខាភិបាល), អៀង ធីរិទ្ធ (រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច), តូច ភឿន (រដ្ឋមន្ត្រីក្រសួងសាធារណការ), យុន យ៉ាត (រដ្ឋមន្ត្រីក្រសួងវប្បធម៌ អប់រំ និងសិក្សាធិការ)។ ក្រៅពីនេះ កម្ពុជាប្រជាធិបតេយ្យមានចាត់ តាំងគណៈកម្មាធិការមួយចំនួនដូចជា ៖ គណៈកម្មាធិការកសិកម្មដឹកនាំដោយ ជ័យ សួន, គណៈកម្មាធិការឧស្សាហកម្មដឹកនាំដោយ ចេង អន, គណៈកម្មាធិការពាណិជកម្មដឹកនាំដោយ កុយ ធួន, គណៈកម្មាធិការចម្ការកៅស៊ូ ដឹកនាំដោយសមមិត្ត ភួង, គណៈកម្មាធិការគមនាគមន៍ដឹកនាំដោយ ម៉ី ប្រាង និង គណៈកម្មាធិការថាមពល។ គណៈកម្មាធិការទាំងប្រាំមួយនេះស្ថិតក្រោមការគ្រប់គ្រងរបស់ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកខាងសេដ្ឋកិច្ច ហើយប្រធានគណៈកម្មាធិការនីមួយៗមានឋានៈស្មើនឹងរដ្ឋមន្ត្រី។ ទោះជាយ៉ាងនេះក្តី ស្ថាប័នខាងលើនេះមិនមានដំណើរការពេញលេញច្បាស់លាស់ទេ។

១៦ អ៊ីសា ឧស្មាន, "ការបះបោររបស់ជនជាតិចាម៖ រឿងរ៉ាវរបស់អ្នករស់រានមានជីវិតចេញពីភូមិ" អត្ថបទបោះពុម្ពផ្សាយនៅភ្នំពេញ លើកទី៩ របស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ២០០៦។

១៧ មជ្ឈិមបក្ស គឺជាពាក្យដែលបក្សកុម្មុយនីស្តកម្ពុជាប្រើសំដៅទៅលើថ្នាក់ដឹកនាំកំពូលរបស់រដ្ឋាភិបាល និងក្រសួងដែលមានអំណាចទាំងឡាយ។ ស្ថាប័នទាំងនេះ អាចជាគណៈកម្មាធិការមជ្ឈិម គណៈកម្មាធិការអចិន្ត្រៃយ៍ ឬកងទ័ព។

១៨ អ្នកស្រាវជ្រាវ អ៊ីសា ឧស្មាន បានប៉ាន់ស្មានតួលេខជនជាតិចាមដែលស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យថា មានចំនួនចន្លោះពី៤សែនទៅ៥សែននាក់។ ឧស្មាន បានអះអាងថា តួលេខនេះបានមកពីបទសម្ភាសន៍របស់ខ្លួន ជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់អ៊ីស្លាមជាច្រើនរូបដែលធ្លាប់ដឹងនិងបានប្រមូលស្ថិតិជនជាតិចាមនៅកម្ពុជា។ ថ្នាក់ដឹកនាំអ៊ីស្លាមទាំងនោះបាននិយាយថា ជនជាតិចាមមុនឆ្នាំ១៩៧៥មានចំនួនប្រហែល៧សែននាក់ ហើយនៅឆ្នាំ១៩៧៩ មានជនជាតិចាមនៅសេសសល់តែប្រមាណពី២សែនទៅ៣សែននាក់ប៉ុណ្ណោះ។ (សៀវភៅ «អ៊ូគូបា៖ យុត្តិធម៌សម្រាប់ជនជាតិចាមក្រោមរបបកម្ពុជាប្រជាធិបតេយ្យ» បោះពុម្ពនៅភ្នំពេញ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ២០០២)។ ប្រវត្តិវិទូ ប៊ែន គៀរនិន បានបង្ហាញចំនួនតួលេខនៃជនជាតិចាមដែលស្លាប់ ថាមានចំនួនតិចតួចជាង។ ប្រវត្តិវិទូ ប៊ែន គៀរនិន បាននិយាយថា ជនជាតិចាមក្នុងឆ្នាំ១៩៧៥ មានចំនួន២សែន៥ម៉ឺននាក់ ហើយយោងតាមអត្រាកំណើនជនជាតិចាម គាត់បានសន្និដ្ឋានថា ចំនួននេះអាចកើនឡើងដល់២សែន៦ម៉ឺននាក់ក្នុងឆ្នាំ១៩៧៩។ គាត់បានទាញសេចក្តីសន្និដ្ឋានថា ចំនួនជនជាតិចាមក្រោយឆ្នាំ១៩៧៩ មានប្រហែល១សែន៧ម៉ឺន៣ពាន់នាក់។ នេះមានន័យថា ជនជាតិចាមដែលស្លាប់ក្នុងរបបខ្មែរក្រហមមានចំនួនប្រហែល៨ម៉ឺន៧ពាន់នាក់។ («របប ប៉ុល ពត៖ ពូជសាសន៍, អំណាច និងអំពើប្រល័យពូជសាសន៍នៅកម្ពុជា ក្រោមរបបខ្មែរក្រហម ១៩៧៥-១៩៧៩ បោះពុម្ពនៅទីក្រុងញូហេវែន និងទីក្រុងឡុងដោយសាកលវិទ្យាល័យ យែល ឆ្នាំ១៩៩៦)។

១៩ ពិន យ៉ាថៃ, ជីវិតកូនថ្លៃ កូនត្រូវតែរស់៖ សោកនាដកម្មពិតនៅក្នុងរបបខ្មែរក្រហម។ (សៀវភៅបកប្រែជាភាសាខ្មែរ) បោះពុម្ពដោយ ស៊ីប៉ា (SIPAR) នៅភ្នំពេញ ឆ្នាំ២០០៣។

២០ ជូ សុភា, «ហេតុអ្វីខ្ញុំត្រូវជាប់ឃុំឃាំង», ជ័យលាភីលេខ២ ក្នុងការប្រកួតប្រជែងអត្ថបទដែលឧបត្ថម្ភដោយសមាគមអ្នកនិពន្ធខ្មែរ និងមជ្ឈមណ្ឌលឯកសារកម្ពុជា ខែមេសា ឆ្នាំ២០០៤។

២១ ម៉ម ផៃប៊ួន, «ជីវិតដែលនៅសេសសល់ និងស្រមោលអតីតកាល», ជ័យលាភីលេខ៤ ក្នុងការប្រកួតប្រជែងអត្ថបទដែលឧបត្ថម្ភដោយសមាគមអ្នកនិពន្ធខ្មែរ និងមជ្ឈមណ្ឌលឯកសារកម្ពុជា ខែមេសា ឆ្នាំ២០០៤។

២២ វ៉ាន់ ណាត, «រូបថតអ្នកទោសកម្ពុជា៖ មួយឆ្នាំនៅក្នុងមន្ទីរ ស-២១ របស់ខ្មែរក្រហម», បោះពុម្ពនៅបាងកក ដោយវ៉ាយឡូថស ឆ្នាំ១៩៩៨។

២៣ មជ្ឈមណ្ឌលឯកសារកម្ពុជា, «តុន, កម្មកររថភ្លើង» ឯកសារលេខ D០២៨៣១។

២៤ មជ្ឈមណ្ឌលឯកសារកម្ពុជា, «តាំ ឡាយ, អតីតកម្មករនៅក្រសួងប្រៃសណីយ៍។ ក្រោយមក ជាទាហានស័ក្តិ២ខាងបើកប្រាក់ខែ។ បច្ចុប្បន្ន ធ្វើការនៅភូមិជីអោក ស្រុកបារាយណ៍» ឯកសារលេខ D០២៨៤៥។

២៥ កម្ពុជាក្រោម ជាទឹកដីភាគខាងត្បូងរបស់អាណាចក្រខ្មែរ ដែលឥឡូវបានក្លាយទៅជាទីក្រុង ហូ ជីមិញ (ដែលខ្មែរនិយមហៅថាព្រៃនគរ)។ ទឹកដីនេះត្រូវបានដាក់ឈ្មោះថា កូសាំងស៊ីន នៅក្នុងជំនាន់អាណានិគមបារាំង។ រដ្ឋាភិបាលអាណានិគមបារាំងបានប្រគល់កម្ពុជាក្រោម ទៅឱ្យវៀតណាមក្នុងឆ្នាំ១៩៤៩។ ប្រជាជនខ្មែរជាច្រើន បាននិងកំពុងរស់នៅលើផ្នែកខ្លះនៃទឹកដីនេះ ប៉ុន្តែប្រជាជនភាគច្រើនជាជនជាតិវៀតណាម។

២៦ នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ ចលនាតស៊ូប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យ បានប្រារព្ធធ្វើមិទ្ទិញមួយនៅក្នុងស្រុកស្នួល ខេត្តក្រចេះ ដើម្បីប្រកាសពីការបង្កើត រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលក្រោយមកត្រូវបានហៅថាជា រណសិរ្សសាមគ្គី កសាង និងការពារជាតិកម្ពុជា។ ប្រជាជនចំនួន២០០នាក់ បានចូលរួមមិទ្ទិញនេះ ដើម្បីទទួលស្គាល់សមាជិកគណៈមជ្ឈិមបក្សទាំង១៤រូបនៃរណសិរ្សនេះ ដែលមានសមមិត្ត ហេង សំរិន ជាប្រធាន, សមមិត្ត ជា ស៊ីម ជាអនុប្រធាន និងសមមិត្ត រស់ សាមៃ ជាលេខាធិការ។

២៧ «សំណុំឯកសារវគ្គអប់រំនយោបាយរបស់គណបក្ស (ប្រជាជនកម្ពុជា)» , គណៈឃោសនាអប់រំ ឆ្នាំ២០១៧។ ដំណាក់កាលធំៗ៣នៃសភាពការណ៍កម្ពុជាឆ្នាំ១៩៧៩មកដល់បច្ចុប្បន្ន។ ដំណាក់ទី១ ពីឆ្នាំ ១៩៧៩-១៩៩១៖ ការពារការរស់ឡើងវិញរបស់ប្រជាជាតិ ស្តារ និងកសាងមាតុភូមិឡើងវិញ បង្កបុព្វបទសម្រាប់សន្តិភាព និងការបង្រួបបង្រួមជាតិ។ រដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលបានបដិសន្ធិឡើងក្រោយថ្ងៃជ័យជម្នះ៧មករា គឺជាសិទ្ធិអំណាចធ្វើជាម្ចាស់របស់ប្រជាជន ដើម្បីការពារ និងកសាងទឹកដីឡើងវិញ។ សាធារណរដ្ឋកម្ពុជាបានប្តូរឈ្មោះជា រដ្ឋកម្ពុជា នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៩។

២៨ សម្តេចបវរសេដ្ឋា សឺន សាន កើតនៅឆ្នាំ១៩១១ នៅកម្ពុជាក្រោម។ សម្តេច សឺន សាន ជានាយករដ្ឋមន្ត្រីក្នុងសម័យសង្គម រាស្ត្រនិយម ពីខែឧសភា ឆ្នាំ១៩៦៧ ដល់ខែមករា ឆ្នាំ១៩៦៨។ ក្នុងទសវត្សរ៍ ឆ្នាំ១៩៨០ សម្តេច សឺន សាន បានដឹកនាំ "រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ"។ បន្ទាប់ពីការចរចាសន្តិភាព ក្រុងប៉ារីស សម្តេច សឺន សាន បានបង្កើតនិងដឹកនាំ "គណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា" ចូលរួមក្នុងការបោះឆ្នោតជាតិឆ្នាំ១៩៩៣។ សម្តេច សឺន សាន បានទទួលមរណភាពដោយរោគាពាធនៅប្រទេសបារាំង នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០០ ក្នុងជន្មាយុ៨៩ឆ្នាំ។

២៩ សេចក្តីប្រកាសព័ត៌មាន៖ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១១), https://www.eccc.gov.kh/sites/default/files/media/ECCC%20PR-%20Ieng%20Thirith%20release%20-%20EN-%2018%20Nov%202011.pdf.

៣០ ការបញ្ឈប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង សារី សំណុំរឿង ០០២/ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ អង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣), https://www.eccc.gov.kh/sites/default/files/documents/courtdoc/2013-03-28%2014%3A29/E270_1_EN.PDF.

៣១ សាលដីកាលើបណ្តឹងសាទុក្ខ សំណុំរឿង ០០២ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ - អង្គជំនុំជម្រះតុលាការកំពូល នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ១១២០ (អង្គជំនុំជម្រះតុលាការកំពូលថ្ងៃទី ២៣ ខែវិច្ឆិកាឆ្នាំ ២០១៦), https://www.eccc.gov.kh/sites/default/files/documents/courtdoc/%5Bdate-in-tz%5D/F36_EN.pdf .

៣២ ការចងក្រងនូវពាក្យសូមអភ័យទោសរបស់ កាំង ហ្កេកអ៊ាវ ហៅឌុច នៅក្នុងអំឡុងពេលសវនាការកន្លងមក ប្រតិចារឹក (ភាសាខ្មែរ) (ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩), https://eccc.gov.kh/sites/default/files/documents/courtdoc/F28-1.1_KH.PDF [ចាប់ពីត្រង់នេះទៅហៅថា "ពាក្យថ្លែងសូមអភ័យទោស"]

៣៣ "ពាក្យថ្លែងសូមអភ័យទោស" កំណត់សម្គាល់ជើងទំព័រលេខ៩, ត្រង់ចំណុចទី៥។

៣៤ ដូចខាងលើ ត្រង់ទំព័រទី៦

៣៥ ព្រះរាជអាជ្ញា សំណុំរឿង កាំង ហ្កេកអ៊ាវ ហៅ "ឌុច" សំណុំរឿង០០១ ថ្ងៃទី១៨ ខែកក្កដាឆ្នាំ២០០៧/អវតក/TC ប្រតិចារិកនៃដំណើរស្តាប់ក្តីត្រង់ទំព័រទី៧-៣៦ (អង្គជំនុំជម្រះ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩) https://www.eccc.gov.kh/sites/default/files/documents/courtdoc/ E1_52.1_TR001_20090721_Final_EN_Pub.pdf

៣៦ ព្រះរាជអាជ្ញា សំណុំរឿង កាំង ហ្កេកអ៊ាវ ហៅ "ឌុច" សំណុំរឿង០០១ ថ្ងៃទី១៨ ខែកក្កដាឆ្នាំ២០០៧/អវតក/TC ប្រតិចារិកនៃដំណើរស្តាប់ក្តីត្រង់ទំព័រទី៥ (អង្គជំនុំជម្រះ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩) https://www.eccc.gov.kh/sites/default/files/documents/courtdoc/ E1_52.1_TR001_20090721_Final_EN_Pub.pdf

៣៧ ព្រះរាជអាជ្ញា សំណុំរឿង កាំង ហ្កេកអ៊ាវ ហៅ "ឌុច" សំណុំរឿង០០១ ថ្ងៃទី១៨ ខែកក្កដាឆ្នាំ២០០៧/អវតក/អង្គជំនុំជម្រះសាលាដំបូង ប្រតិចារិកនៃដំណើរស្តាប់ក្តីត្រង់ទំព័រទី១២ (អង្គជំនុំជម្រះ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩) https://www.eccc.gov.kh/sites/default/files/documents/courtdoc/ E1_52.1_TR001_20090721_Final_EN_Pub.pdf.

៣៨ ដូចខាងលើ

៣៩ ដូចខាងលើ ត្រង់ទំព័រទី១៧

៤០ ព្រះរាជអាជ្ញា សំណុំរឿង កាំង ហ្កេកអ៊ាវ ហៅ "ឌុច" សំណុំរឿង០០១ ថ្ងៃទី១៨ ខែកក្កដាឆ្នាំ២០០៧/អវតក/TC ប្រតិចារិកនៃដំណើរស្តាប់ក្តីត្រង់ទំព័រទី៤១-៩២ (អង្គជំនុំជម្រះ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩) https://www.eccc.gov.kh/sites/default/files/documents/courtdoc/ E1_64.1_TR001_20090818_Final_EN_Pub.pdf.

៤១ ព្រះរាជអាជ្ញា សំណុំរឿង កាំង ហ្កេកអ៊ាវ ហៅ "ឌុច" សំណុំរឿង០០១ ថ្ងៃទី១៨ ខែកក្កដាឆ្នាំ២០០៧/អវតក/TC ប្រតិចារិកនៃដំណើរស្តាប់ក្តីត្រង់ទំព័រទី១១-៦៧ (អង្គជំនុំជម្រះ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩) https://www.eccc.gov.kh/sites/default/files/documents/courtdoc/ E1_60.1_TR001_20090810_Final_EN_Pub.pdf.

៤២ ដោយសារមូលហេតុផ្សេងៗគ្នា ដូចជាសុវត្ថិភាពឯកជន និងផ្ទាល់ខ្លួន ឈ្មោះសាក្សីមួយចំនួនមិនត្រូវបានបង្ហាញជាសាធារណៈ ហើយបុគ្គលទាំងនោះត្រូវបានកំណត់ដោយលេខ។

៤៣ ព្រះរាជអាជ្ញា សំណុំរឿង នួន ជា, ខៀវ សំផន សំណុំរឿង០០២ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧/អវតក/TC ប្រតិចារិកនៃដំណើរស្តាប់ក្តីត្រង់ទំព័រទី៣២ (អង្គជំនុំជម្រះ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦) https://www.eccc.gov.kh/sites/default/files/ documents/courtdoc/%5Bdate-in-tz%5D/E1_500.1_TR002_20161121_Final_EN_Pub.pdf.

៤៤ ព្រះរាជអាជ្ញា សំណុំរឿង នួន ជា, ខៀវ សំផន សំណុំរឿង០០២ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧/អវតក/TC ប្រតិចារិកនៃដំណើរស្តាប់ក្តីត្រង់ទំព័រទី៣២ (អង្គជំនុំជម្រះ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦) https://www.eccc.gov.kh/sites/default/files/ documents/courtdoc/%5Bdate-in-tz%5D/E1_500.1_TR002_20161121_Final_EN_Pub.pdf.

៤៥ ព្រះរាជអាជ្ញា សំណុំរឿង នួន ជា, ខៀវ សំផន សំណុំរឿង០០២ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧/អវតក/TC ប្រតិចារិកនៃដំណើរស្តាប់ក្តីត្រង់ទំព័រទី៧-៨ (អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៣) https://www.eccc.gov.kh/sites/default/files/documents/courtdoc/2013-05-10%2009%3A57/E1_185.1_TR002_20130429_Final_EN_Pub.pdf.

៤៦ ព្រះរាជអាជ្ញា សំណុំរឿង នួន ជា, ខៀវ សំផន សំណុំរឿង០០២ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧/អវតក/TC ប្រតិចារិកនៃដំណើរស្តាប់ក្តីត្រង់ទំព័រទី៩៨ (អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៣) https://www.eccc.gov.kh/sites/default/files/documents/courtdoc/2013-05-10%2009%3A57/E1_185.1_TR002_20130429_Final_EN_Pub.pdf.

៤៧ ដូចខាងលើ ត្រង់ទំព័រទី៩៩។

៤៨ ព្រះរាជអាជ្ញា សំណុំរឿង នួន ជា, ខៀវ សំផន សំណុំរឿង០០២ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧/អវតក/TC ប្រតិចារិកនៃដំណើរស្តាប់ក្តីត្រង់ទំព័រទី៥១ (អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២)
https://www.eccc.gov.kh/sites/default/files/documents/courtdoc/2012-12-12%2016%3A36/E1_147.1_TR002_20121204_Final_EN_Pub%5B1%5D.pdf.

៤៩ ព្រះរាជអាជ្ញា សំណុំរឿង នួន ជា, ខៀវ សំផន សំណុំរឿង០០២ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧/អវតក/TC ប្រតិចារិកនៃដំណើរស្តាប់ក្តីត្រង់ទំព័រទី៣២ (តុលាការកំពូល ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៥) https://www.eccc.gov.kh/sites/default/files/ documents/courtdoc/2016-06-06%2019%3A58/F1_2.1_TR002_20150703_Final_EN_Pub%20%281%29.pdf.

៥០ ព្រះរាជអាជ្ញា សំណុំរឿង នួន ជា, ខៀវ សំផន សំណុំរឿង០០២ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧/អវតក/TC ប្រតិចារិកនៃដំណើរស្តាប់ក្តី (អង្គជំនុំជម្រះ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥) https://www.eccc.gov.kh/sites/default/ files/documents/courtdoc/2015-12-22%2018%3A00/E1_368.1_TR002_20151215_Final_EN_Pub.pdf.

៥១ ព្រះរាជអាជ្ញា សំណុំរឿង នួន ជា, ខៀវ សំផន សំណុំរឿង០០២ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧/អវតក/TC ប្រតិចារិកនៃដំណើរស្តាប់ក្តីត្រង់ទំព័រទី៣១-៦៥ (អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦) https://www.eccc.gov.kh/sites/default/files/ documents/courtdoc/%5Bdate-in-tz%5D/E1_489.1_TR002_20161025_Final_EN_Pub.pdf.

៥២ ព្រះរាជអាជ្ញា សំណុំរឿង នួន ជា, ខៀវ សំផន សំណុំរឿង០០២ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧/អវតក/TC ប្រតិចារិកនៃដំណើរស្តាប់ក្តីត្រង់ទំព័រទី៣-៤៣ (អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦) https://www.eccc.gov.kh/sites/default/files/ documents/courtdoc/%5Bdate-in-tz%5D/15-Aug-2016%20Transcript%20of%20hearing%20on%20the %20substance%20in%20Case%2000202%20-%2015%20August%202016.pdf.

៥៣ ព្រះរាជអាជ្ញា សំណុំរឿង នួន ជា, ខៀវ សំផន សំណុំរឿង០០២ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧/អវតក/TC ប្រតិចារិកនៃដំណើរស្តាប់ក្តីត្រង់ទំព័រទី៨-៤៣ (អង្គជំនុំជម្រះ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥) https://www.eccc.gov.kh/sites/default/ files/documents/courtdoc/2015-10-06%2022%3A41/E1_350.1_TR002_20150928_Final_EN_Pub.pdf.

## សៀវភៅបោះពុម្ព និងអត្ថបទ


អេលីហ្សាបែត បេ៊កខ័រ, "នៅពេលដែលសង្គ្រាមរលត់ទៅ ៖ កម្ពុជានិងបដិវត្តន៍ខ្មែរក្រហម" (បកប្រែជាភាសាខ្មែរ) ភ្នំពេញ, មជ្ឈមណ្ឌលឯកសារកម្ពុជា, បោះពុម្ពឆ្នាំ២០០៥។

ណាយ៉ាន់ ចាន់ដា, «សត្រូវបងប្អូនឯង៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម» បោះពុម្ពនៅញូយ៉ក ដោយរោងពុម្ព Macmillan ឆ្នាំ១៩៨៦។

ដេវីដ ឆេនដល័រ, "បងធំទីមួយ ៖ ប្រវត្តិរូបនយោបាយរបស់ ប៉ុល ពត" បោះពុម្ពនៅ ប៊ូលឌឺ ខូ, ការបោះពុម្ពរបស់សារព័ត៌មានវេសវ្យូ ឆ្នាំ១៩៩២។

_____ *"សោកនាដកម្មនៃប្រវត្តិសាស្ត្រខ្មែរ ៖ នយោបាយ សង្គ្រាម និង បដិវត្តន៍ ពីឆ្នាំ ១៩៤៥" បោះពុម្ពនៅញូហេវិន និងទីក្រុងឡុងដ៍, ការបោះពុម្ពរបស់សាកលវិទ្យាល័យ យែល ឆ្នាំ១៩៩១។*

_____ *"សម្លេងពីមន្ទីរស-២១ ៖ ភាពព្រឺខ្លាចនិងប្រវត្តិក្នុងគុកសម្ងាត់របស់ ប៉ុល ពត" អត្ថបទបកប្រែទី៣ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា, បោះពុម្ពនៅភ្នំពេញ ឆ្នាំ២០០៣។*

ឆាំង យុ "តើខ្ញុំរស់រានមានជីវិតពីរបបខ្មែរក្រហមដោយរបៀបណា?" អត្ថបទចេញផ្សាយក្នុងកាសែតភ្នំពេញប៉ុស្តិ៍, លេខចេញផ្សាយ ថ្ងៃទី៨-២១ ខែមេសា ឆ្នាំ២០០៥។

¬_____"ទួលពិសពុលដែលជាគុកទួលស្លែង" អត្ថបទចុះផ្សាយក្នុងកាសែតភ្នំពេញប៉ុស្តិ៍, លេខចេញផ្សាយថ្ងៃទី៣-២៥ ខែមីនា ឆ្នាំ១៩៩៧។

_____"តួនាទីរបស់អាស៊ាននៅក្នុងដំណើរការតុលាការកាត់ទោសខ្មែរក្រហម" សុន្ទរកថានៅវិទ្យាស្ថានសិក្សាស្រាវជ្រាវអាស៊ីអាគ្នេយ៍, សឹង្ហបុរី, ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៥។

វេនី ខកហ្លៀល, ប៉ាង ពីវ៉ែន, រ៉ា ឆៃរ៉ាន់, និង ស៊ឹម សុភ័ក្រ, "ជីវិតក្នុងភាពនឹងថ្កល់ ៖ រូបថត សេសសល់ពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា" ភ្នំពេញ, មជ្ឈមណ្ឌលឯកសារកម្ពុជា, បោះពុម្ព ផ្សាយឆ្នាំ២០០៤។

អៀ ម៉េងទ្រី, "ចំណងឧក្រិដ្ឋកម្ម ៖ ប្រព័ន្ធសន្តិសុខភូមិភាគនិរតីរបស់ខ្មែរក្រហម" អត្ថបទ បោះពុម្ពផ្សាយទី៧ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បោះពុម្ពនៅភ្នំពេញ ឆ្នាំ២០០៥។

ស្ទីវហ្វេន ហ៊ែដឌឺ និង ប្រ៊ែន ទិតធើម័រ "បេក្ខជនប្រាំពីរនាក់សម្រាប់ការកាត់សេចក្តី" អត្ថបទបោះពុម្ពផ្សាយលើកទី៤ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា, បោះពុម្ពនៅភ្នំពេញ ឆ្នាំ២០០៤។

ហ៊ុន សែន, "១០ឆ្នាំនៃដំណើរកម្ពុជា ១៩៧៩-១៩៨៩" ភ្នំពេញ, រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា, បោះពុម្ពឆ្នាំ១៩៨៩។

_____"១៣សតវត្សរ៍នៃដំណើរកម្ពុជា" ការផ្សាយរបស់កាសែតប្រជាជន, បោះពុម្ពនៅភ្នំពេញ ឆ្នាំ១៩៩១។

ហ៊ុយ វណ្ណៈ, "កងពលខ្មែរក្រហមលេខ៧០៣ ៖ ពីជ័យជម្នះឆ្ពោះទៅការបំផ្លាញខ្លួនឯង" អត្ថបទបោះពុម្ពផ្សាយលើកទី៣ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា, បោះពុម្ពនៅភ្នំពេញ ឆ្នាំ២០០៣។

ប៊ែន ឃៀនិន "តើ ប៉ុល ពត ឡើងកាន់អំណាចដោយរបៀបណា ៖ ប្រវត្តិចលនាកុម្មុយនីស្តនៅកម្ពុជា ១៩៣០-១៩៧៥" បោះពុម្ពនៅទីក្រុងញូហេវិន និងទីក្រុងឡុង, ការបោះពុម្ពផ្សាយរបស់សាកលវិទ្យាល័យ យែល ឆ្នាំ ១៩៩៦។

_____ "របប ប៉ុល ពត ៖ ជាតិសាសន៍ អំណាច និង អំពើប្រល័យពូជសាសន៍នៅកម្ពុជាក្រោមរបបខ្មែរក្រហម ១៩៧៥-១៩៧៩" បោះពុម្ពនៅទីក្រុងញូហេវិន និងទីក្រុងឡុង, ការបោះពុម្ពផ្សាយរបស់សាកលវិទ្យាល័យ យែល ឆ្នាំ ១៩៩៦។

ហង់រី ឡូកាដ "កូនសៀវភៅក្រហមរបស់ ប៉ុល ពត ៖ ពាក្យអង្គការ" បោះពុម្ពនៅទីក្រុងបាងកក, ការបោះពុម្ពផ្សាយរបស់ ស៊ីលវ៉ែមប៊ុក ឆ្នាំ២០០៤។

ភ្នាក់ងារស៊ើបការណ៍សម្ងាត់របស់សហរដ្ឋអាមេរិក «កម្ពុជា ៖ ការបាត់បង់ចំនួនប្រជាជន» ចេញផ្សាយខែឧសភា ឆ្នាំ១៩៨០។

វ៉ាន់ ណាត, "រូបគំនូររបស់ខ្មែរម្នាក់នៅក្នុងគុក ៖ មួយឆ្នាំក្នុងមន្ទីរស-២១របស់ខ្មែរក្រហម" បោះពុម្ពនៅទីក្រុងបាងកក, ការបោះពុម្ពផ្សាយរបស់ វ៉ាយទ្បូថស ឆ្នាំ១៩៩៨។

ម៉ៃឃើល វីកឃឺរី, "កម្ពុជាពីឆ្នាំ១៩៧៥-១៩៨២" បោះពុម្ពនៅទីក្រុងបាងកក, ការបោះពុម្ពផ្សាយរបស់ ព្រីនធីងហៅស៍ អូអេស ឆ្នាំ១៩៨៤។

ពិន យ៉ាថៃ, "ជីវិតកូនថ្លៃ កូនត្រូវតែរស់ ៖ សោកនាដកម្មដ៏ជាក់ស្តែងក្នុងរបបខ្មែរក្រហម" (អត្ថបទបកប្រែ)បោះពុម្ពនៅទីក្រុងភ្នំពេញ, ការបោះពុម្ពផ្សាយរបស់ គ្រឹះស្ថានបោះពុម្ពផ្សាយ ស៊ីប៉ា ឆ្នាំ២០០៣។

## ឯកសារបណ្ណសារដ្ឋាន

ឯកសារភាគច្រើនដែលត្រូវបានយកមកប្រើក្នុងការសរសេរអត្ថបទនេះ គឺយកចេញពីបណ្ណសារ ដ្ឋាននិងបណ្ណាល័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាឃ្លាំងតម្កល់ឯកសារដើមពីរបបកម្ពុជាប្រជា ធិបតេយ្យធំជាងគេបង្អស់នៅលើពិភពលោក។ ឯកសារដែលត្រូវបានជ្រើសរើសយកមកធ្វើជាឯកសារយោង រួមមាន ៖

- ប្រវត្តិរូបរបស់អតីតកម្មាភិបាលខ្មែរក្រហម
- ចម្លើយសារភាពនិងបញ្ជីរាយនាមអ្នកទោសដែលត្រូវបានសម្លាប់នៅមន្ទីរស-២១
- រដ្ឋធម្មនុញ្ញនិងគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ
- សៀវភៅទង់បដិវត្តន៍និងទង់ក្រហម (ទស្សនាវដ្ដីរបស់កម្ពុជាប្រជាធិបតេយ្យ)
- កំណត់ហេតុស្ដីពីកិច្ចប្រជុំគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា
- ពាក្យស្លោកនិងចម្រៀងរបស់កម្ពុជាប្រជាធិបតេយ្យ
- ផែនទីកម្ពុជាប្រជាធិបតេយ្យ និង
- រូបថតដើមរបស់កម្ពុជាប្រជាធិបតេយ្យ។

បន្ថែមពីលើនេះ ព័ត៌មានមួយចំនួនទៀតត្រូវបានដកស្រង់ចេញពីទស្សនាវដ្ដីប្រចាំខែរបស់មជ្ឈមណ្ឌល ឯកសារកម្ពុជា "ទស្សនាវដ្ដីស្វែងរកការពិត" កាលប្រវត្តិកម្ពុជាប្រជាធិបតេយ្យ សារព័ត៌មាន និង អត្ថបទតែងសេចក្ដីដែលបានចូលរួមការប្រកួតប្រជែងក្នុងកម្មវិធី "វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ" ដែលឧបត្ថម្ភដោយមជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយសមាគមអ្នកនិពន្ធខ្មែរ។

# អំពីមជ្ឈមណ្ឌលឯកសារកម្ពុជា

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៥ បន្ទាប់ពីសភាសហរដ្ឋអាមេរិកអនុម័តឲ្យមាន ច្បាប់ស្ដីពីយុត្តិធម៌សម្រាប់អំពើប្រល័យពូជសាសន៍ នៅក្នុងខែមេសា ឆ្នាំ១៩៩៤ ដែលចុះហត្ថលេខាជាធរមានដោយប្រធានាធិបតី ឃ្លីនតុន។ រាជរដ្ឋាភិបាលកម្ពុជា បានគាំទ្រមជ្ឈមណ្ឌលឯកសារកម្ពុជាជាផ្លូវការ។ មជ្ឈមណ្ឌលឯកសារកម្ពុជា ទទួលបានការកោតសរសើរនិងពានរង្វាន់ជាច្រើនចំពោះកិច្ចការរបស់ខ្លួន ក្នុងការគាំទ្រឲ្យមានការចងចាំនិងយុត្តិធម៌សម្រាប់ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា។ នៅក្នុងឆ្នាំ២០១៧ មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានពានរង្វាន់សិទ្ធិមនុស្ស ជូឌិត លី ស្ត្រូណាច់ ពីមជ្ឈមណ្ឌលយុត្តិធម៌និងការទទួលខុសត្រូវ។ នៅក្នុងឆ្នាំដដែល ព្រះបាទសម្ដេច ព្រះបរមនាថ នរោត្តម សីហមុនី ទ្រង់ព្រះរាជទានគ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ធិបឌិន្ទ ដល់លោក ឆាំង យុ ជាការទទួលស្គាល់ស្នាដៃដ៏ល្បីល្បាញរបស់លោកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងឆ្នាំ២០១៨ មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏ជាម្ចាស់ពានរង្វាន់ រ៉ាម៉ុន ម៉ាកសៃសៃ ដែលត្រូវបានចាត់ទុកថាជាពានរង្វាន់ណូបែលអាស៊ី ក្នុងការថែរក្សាការចងចាំជាប្រវត្តិសាស្ត្រដើម្បីការព្យាបាលរបួសផ្លូវចិត្ត និងយុត្តិធម៌។



**រូបថតក្របមុខ៖**
ប្រជាជនកម្ពុជាកំពុងធ្វើការនៅទំនប់ “១ មករា” ស្ទឹងជីនិត ខេត្តកំពង់ធំ ឆ្នាំ១៩៧៦
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។)